សែម_ស៊ូរ

# អត្ថាធិប្បាយ
# មហាវេស្សន្តរជាតក

ស្របតាមកម្មវិធីសិក្សា

CA18

# អត្ថាធិប្បាយ

# មហាវេស្សន្តរជាតក

សម្រាប់

ថ្នាក់ទី ១ ទំនើបជាតិ

ការប្រឡងប្រជែងវិជ្ជាជីវៈផ្សេងៗ

និពន្ធដោយ

**វិសម — សួរ**

សញ្ញាប័ត្រពុទ្ធិកឧត្តមសិក្សាបឋមភូមិ

និស្សិតមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ ភ្នំពេញ

ការផ្សាយរបស់

បណ្ណាគារ ពេជ្រនិល

លេខ ៣៨៣ វិថីកម្ពុជាក្រោម ភ្នំពេញ

## សូមថ្វាយព្រះពរ

- សម្ដេចព្រះមហាក្សត្រិយានីព្រះមាតាជាតិ
- សម្ដេចឪព្រះប្រមុខរដ្ឋជាតិខ្មែរ
- សម្ដេចព្រះសង្ឃរាជថ្នាក់ទី ១ គណៈមហានិកាយ
- សម្ដេចព្រះពោធិវង្ស មហាវិទ្យាធិការនៃពុទ្ធិកសិក្សា
- សម្ដេចព្រះសង្ឃនាយកគណៈធម្មយុត្តិ

សូមសម្ដេចទាំង ៥ ព្រះអង្គ ដែលជាទីគោរពនិងជាទីស្រឡាញ់ស្មើជីវិតនៃពលរដ្ឋខ្មែរ ដែលបានដឹកនាំប្រទេសជាតិនិងសាសនាខ្មែរ ឲ្យមានលក្ខណៈជា សង្គមនិយមព្រះពុទ្ធសាសនា បានប្រកបដោយវិបុលសុខមហាប្រសើរ មានព្រះជន្មវែងដើម្បីពលរដ្ឋ ពុទ្ធសាសនិកជនខ្មែរ បានជ្រកកោនយ៉ាងត្រជាក់ត្រជុំ ។

សេម-សូរ

# យោបល់អ្នកនិពន្ធ

អត្ថាធិប្បាយមហាវេស្សន្តរជាតក ជារឿងប្រធាន និងអត្ថាធិប្បាយ ១ ផ្នែកដែលខ្ញុំបានជ្រើសរើសយកបញ្ហាណាដែលសំខាន់ ៗ ហើយដែលមិត្ត និងប្រុសស្រីជាច្រើនធ្លាប់បានជួបប្រទះ ប្រកបដោយក្ដីលំបាក, អាចបកដោះស្រាយខ្លះ ខ្លះ តាមមតិយោបល់ផ្ទាល់ខ្លួនរបស់ខ្ញុំនេះឯង ។

តាមធម្មតា គោលបំណងការសិក្សាក្នុងមហាវេស្សន្តរជាតក ពុំមានន័យសេចក្ដីដូចគ្នានឹងការសិក្សាក្នុងសៀវភៅកម្រងពីឯទៀត ៗ នោះឡើយ ដោយហេតុថា មហាវេស្សន្តរជាតក មានលក្ខណៈជាអក្សរសិល្ប៍ផ្នែកពុទ្ធនិយមច្បាស់លាស់ជាងគេ ទាំងផ្នែកនៃវត្ថុរូប និងដំណើររឿង ។ ដូច្នេះ ខ្ញុំក៏ត្រូវតែសម្របកិច្ចការនេះទៅតាមចលនារឿងបែបពុទ្ធនិយមដែរ ប៉ុន្តែទោះជាយ៉ាងណា ក៏មិត្តនិងអ្នកប្រុសស្រីទាំងឡាយមិនត្រូវភ្លេចទេថា យើងត្រូវធ្វើការបកស្រាយរឿងនេះទៅតាមបែបអក្សរសិល្ប៍ = មានមតិស្រប មតិផ្ទុយ និងមតិរួម ព្រោះកាលណាយើងរកកំហុស ឬ អ្វីដែលអាក្រក់នៅក្នុងមហាវេស្សន្តរជាតកនេះគ្មានហើយ ពេលនោះយើងនឹងឃើញថា មហាវេស្សន្តរជាតក ឬ តួអង្គព្រះវេស្សន្តរជាដើមនឹងមានលក្ខណៈល្អពិតមែន ។

ជាទីបញ្ចប់ ខ្ញុំសូមឲ្យមិត្តនិងអូនប្រុសស្រី អ្នកសិក្សាទាំងអ
ទុកសៀវភៅនេះជាមតិ, យោបល់ – ការយល់ឃើញមួយប៉ុណ្ណោះជា
ហើយ ប៉ុន្តែកុំគប្បីទុកស្មើនឹងសាស្ត្រាចារ្យមួយរូបដ៏ជំនាញ ឬទុកស្មើនឹ
មេរៀនសម្រាប់យកទៅសូត្រដាក់លើក្រដាស នៅពេលណាមួយនោ
ឲ្យសោះ ។ បើមិត្តនិងប្អូនបានគិតឃើញ និងទុកជាមតិយោបល់មួយនេ
មែន ខ្ញុំយល់ឃើញថា សៀវភៅខ្ញុំនឹងបានជាមិត្តមួយ ដែលអាចជួ
រកល្អ- អាក្រក់ឲ្យមិត្ត និងប្អូនប្រុសស្រីបានយ៉ាងពិតប្រាកដ ។

សូមឲ្យចលនានៃអក្សរសាស្ត្រខ្មែរ មានសកម្មភាពចំរើនទៀ
សម្រាប់កូនខ្មែររៀនសូត្រ ដើម្បីនឹងលើកតម្កើងវប្បធម៌ – អរិយធម៌ខ្មែរ
រិតតែខ្ពង់ខ្ពស់ មានជ័យជំនះលើវប្បធម៌ – អរិយធម៌បរទេស ដែលចូ
បកជ្រៀតជ្រែកវប្បធម៌ - អរិយធម៌យើងយូរហើយនោះ ។

វប្បធម៌ - អរិយធម៌ខ្មែររីកសាយរុងរឿង វប្បធម៌ – អរិយធ
បរទេសត្រូវតែដួលបះពើងជាច់ខ្យល់ស្លាប់ក្សាយ ។

ភ្នំពេញ, ថ្ងៃទី ១៧ ធ្នូ ១៩៦៨

**រស់ម – សូរ**

វិញ្ញាបនប័ត្រឧត្តមសិក្សាអក្សរសិល្ប៍ខ្មែរ និងវប្បធម៌-អរិយធម៌
នៃមហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រ ភ្នំពេញ

អត្ថាធិប្បាយ

# មហាវេស្សន្តរជាតក

កណ្ឌទសពរ

## ប្រធាន

ក្នុងមហាវេស្សន្តរជាតកត្រង់ខាងដើមនៃកណ្ឌទសពរ អ្នកនិពន្ធមិនបានចាប់ផ្ដើមបង្ហាញ នូវដំណើររឿងព្រះវេស្សន្តរតែម្ដងទេ ប៉ុន្តែបែរជាចាប់ផ្ដើមនិទានអំពីដំណើរ ព្រះសម្មាសម្ពុទ្ធ ទ្រង់យាងទៅប្រោសសត្វក្នុងមគធរដ្ឋទៅវិញ ។

ដូច្នេះ សូមធ្វើអត្ថាធិប្បាយ

## បញ្ជាក់អំពីតួអង្គព្រះសម្មាសម្ពុទ្ធព្រមទាំងការត្រាស់ដឹងរបស់ព្រះអង្គ ឱ្យបានល្អមស្តាប់ ។

## អត្ថាធិប្បាយ

តាមធម្មតា រឿងរ៉ាវផ្សេង ៗ ក្នុងគម្ពីរព្រះពុទ្ធសាសនា អ្នកនិពន្ធតែងចាប់ផ្តើមឡើង ដោយបានលើកយកតួអង្គព្រះសម្មាសម្ពុទ្ធដែលជាម្ចាស់, ជាមេដឹកនាំសាសនានេះ មកផ្តើមនិទានធ្វើជាសេចក្តីប្រារព្ធជាកិច្ច ឯក្នុងមហាវេស្សន្តរជាតកវិញក៏ដូច្នោះដែរ ដោយអ្នកនិពន្ធបានលើកឡើងនូវតួអង្គព្រះសម្ពុទ្ធមកផ្តើមជាដំបូង ហាក់ដូចជាឧបកថាប្រយោល ដោយឡែកទៅវិញ បុំន្តែបើពិនិត្យឲ្យច្បាស់ទៅ យើងនឹងបានឃើញថា គឺព្រះសម្មាសម្ពុទ្ធនេះហើយជាអ្នកសំដែងរឿងព្រះមហាវេស្សន្តរ ។

ដូច្នេះ ដើម្បីនឹងចេះដឹងស្គាល់នូវតួអង្គព្រះសម្មាសម្ពុទ្ធ ដែលជាម្ចាស់នៃព្រះពុទ្ធសាសនា ហើយជាអ្នកសំដែងរឿងព្រះវេស្សន្តរនេះ យើងគប្បីធ្វើអត្ថាធិប្បាយបញ្ជាក់នូវលក្ខណៈគុណសម្បត្តិ និងការត្រាស់

ដឹងរបស់ព្រះអង្គដូចតទៅ :

បើយើងនិយាយថា ព្រះពុទ្ធជាមនុស្សអស្ចារ្យ, ជាមហាក្សត្រដែលទ្រង់យាងចេញសាងផ្នួស ហើយមានឫទ្ធានុភាពច្រើនយ៉ាងនេះក៏បាន ប៉ុន្តែយើងមិនត្រូវធ្វើការកត់សំគាល់ថាព្រះពុទ្ធជាមនុស្ស ឬ បុគ្គលអស្ចារ្យ, មានឫទ្ធានុភាពច្រើន ត្រឹមតែអាចហោះហើរទៅតាមអាកាស, ជ្រែកមុជផែនដី ធ្វើការទាក់ទងជាមួយត្រៃភព ឬ អាចកាឡាខ្លួនជាអ្វី ៗ បានដូចបំណង ដូចក្នុងរឿងផ្សេង ៗ ដែលមានតួអង្គយក្ស ឬ មនុស្ស–បិសាច នោះឡើយ ហើយយើងក៏មិនត្រូវសំគាល់ថាព្រះពុទ្ធជាបុគ្គលអស្ចារ្យ មានឫទ្ធានុភាពច្រើន ដោយព្រះអង្គជាមនុស្សកាចសាហាវ ធ្វើការសង្កត់សង្កិន ជិះជាន់កំហែងគំរាមជនណាដោយកម្លាំងកាយ កម្លាំងអំណាចនោះដែរ ។

ព្រះពុទ្ធជាបុរសបុគ្គលអស្ចារ្យ ត្រង់ព្រះអង្គជាអ្នកភ្ញាក់រលឹកនឹកឃើញជានិច្ច ចូវសេចក្តីទុក្ខលំបាកគ្រប់យ៉ាងក្នុងបញ្ហាដំណើរជីវិត ហើយទ្រង់លះអ្វី ៗ ទាំងអស់ដែលព្រះអង្គមាន ដូចជា ទ្រព្យសម្បត្តិយសសក្តិ ប្រពន្ធកូនហើយ យាងចេញទៅសាងផ្នួស ស្វែងរកការត្រាសដឹងចូវចំណេះចេះដឹងដ៏ថ្មីមួយ ដើម្បីយកមកបង្ហាញលាតត្រដាង និងដឹកនាំមនុស្សសត្វដទៃទៀតឲ្យធ្វើតាមព្រះអង្គ ដើម្បីបានគេចផុតពីទុក្ខសោក

ភ័យភ័ន្តក្នុងភពវដ្តសង្សារ ឈានទៅរកស្ថានមួយដ៏ពោរពេញដោយ
សេចក្តីសុខ ហៅថា បរមសុខនេះឯង ។ កាលព្រះអង្គស្វែងរកធម៌
នេះអស់រយៈវេលា ៦ ឆ្នាំ ដោយមានការពិសោធន៍យ៉ាងគ្រប់គ្រាន់ហើយ
ព្រះអង្គក៏បានត្រាស់ដឹងនូវធម៌គ្រប់យ៉ាងដោយព្រះអង្គឯង ។ គឺការ
ត្រាស់ដឹងនេះហើយ ដែលមនុស្សនិងទេពតាបានថ្វាយព្រះនាមដល់ព្រះ
អង្គថា សម្មាសម្ពុទ្ធ ។

ចំពោះន័យនៃពាក្យថាសម្មាសម្ពុទ្ធនេះសោតទៀត ក៏យើងត្រូវ
ធ្វើការកត់សំគាល់ថា ព្រះពុទ្ធជាបុគ្គលឬជាមហាបុរសដែលបានចេះដឹង
នូវចំណេះដ៏វិសេសម៉្យាងដោយព្រះអង្គឯង ឥតមានគ្រូបាអាចារ្យណា
ណែនាំដឹកពន្យល់ព្រះអង្គទាល់តែសោះ ។ ចំណេះចេះដឹងដោយ
ព្រះអង្គឯងនេះ គឺព្រះអង្គបានគិតពិចារណារកឃើញ នៅលើរតន
បល្លង្ក ក្រោមម្លប់ពោធិព្រឹក្សត្រង់គយាសីសប្រទេស ឬពុទ្ធគយានា
ដែនមគធ ( ខេត្តពិហារសព្វថ្ងៃ ) នេះឯង ។ ការដែលព្រះអង្គបាន
ពិចារណារកឃើញនូវចំណេះចេះដឹងជាពុទ្ធិថ្មី ដោយព្រះអង្គឯងនេះ
ហើយ ទើបមនុស្សនិងទេពតាបានថ្វាយព្រះនាមដល់ព្រះអង្គថា " សម្មា
សម្ពុទ្ធ " ។

ព្រះសម្មាសម្ពុទ្ធជាមនុស្សដែរ តែទ្រង់មានញាណ ( ការដឹង

យល់–ស្គាល់ ) មួយពិសេសទៀត លើសពីមនុស្សធម្មតា គឺសម្មា–សម្ពោធិញ្ញាណ ។ ញាណពិសេសនេះ បាននាំឲ្យព្រះអង្គដឹងនូវអ្វី ៗ ទាំងអស់នៅក្នុងលោក បានសេចក្ដីថាព្រះអង្គទ្រង់ជ្រាបនូវបញ្ហាទាំងអស់ ( គ្មានសល់ សូម្បីតែកូនបញ្ហាល្អិតល្អោច កំទេចកំទីណាទាល់តែសោះ ) របស់ពិភពលោក ។ គឺដោយព្រះអង្គទ្រង់ប្រកបដោយសម្មាសម្ពោធិញ្ញាណ ( ការដឹងដោយប្រាជ្ញាត្រាស់ដឹងដោយព្រះអង្គឯងដោយគ្មានអ្នកណាដឹកនាំពន្យល់ ) នេះហើយដែលព្រះអង្គត្រូវបានទាយមួយទៀតថា « លោកវិទូ » ។

ពាក្យថា លោកវិទូ នេះមានន័យថា ព្រះអង្គទ្រង់ជ្រាបច្បាស់នូវបញ្ហាលោក ( មនុស្សលោក, ទេវលោកនិងស្ថាននរកប្រេត ) ។ ការទ្រង់ជ្រាបនេះ មិនមែនជ្រាបតែត្រឹមថា មានលោកទាំងបីនេះនៅកន្លែងណា មានអ្វី ៗ នៅក្នុងទីនោះតែប៉ុណ្ណោះឡើយ ប៉ុន្តែព្រះពុទ្ធអង្គទ្រង់ជ្រាបនូវអតីត, បច្ចុប្បន្ននិងអនាគត ព្រមទាំងហេតុផលដែលទាក់ទងគ្នា, ដែលនាំឲ្យសត្វនិងមនុស្ស – ទេពតាកើតក្នុងលោកនោះផង ជ្រាបទាំងហេតុបច្ច័យដែលនាំឲ្យមានលោកទាំងនោះ និងនាំឲ្យវិនាសលោកទាំងនោះផង ។ គឺការជ្រាបបែបនេះហើយ ដែលហៅលោកវិទូ ។

ព្រះសម្មាសម្ពុទ្ធ ជាអ្នកត្រាស់ដឹងនូវធម៌ទាំងពួងឥតមានសល់។ ពាក្យថាត្រាស់ដឹងនេះ បើនិយាយឲ្យងាយស្តាប់ទៅទៀតថា មនុស្សបច្ចុប្បន្នក៏មានអ្នកត្រាស់ដឹង គឺការរិះរកពិចារណាស្រាវជ្រាវឃើញនូវអ្វីមួយដែរ ដូចជាអ្នកធ្វើគ្រឿងយន្ត អ្នកផ្សំធាតុ អ្នកផ្សំថ្នាំជាដើម ។ អ្នកទាំងនេះក៏ឈ្មោះថាអ្នកត្រាស់ដឹងដែរ ប៉ុន្តែការត្រាស់ដឹងរកឃើញទាំងនេះគ្រាន់តែជាការត្រាស់ដឹងតូចមួយប៉ុណ្ណោះ ឯព្រះសម្មាសម្ពុទ្ធដែលជាអ្នកបានត្រាស់ដឹងនោះ គឺត្រាស់ដឹងនូវអ្វី ៗ ដែលអ្នកផងទាំងពួង ទោះមនុស្ស ឬ ទេពតា មិនអាចត្រាស់ដឹងឲ្យដូចព្រះអង្គឡើយ ។ ព្រះពុទ្ធជាមនុស្សអស្ចារ្យដែលបានត្រាស់ដឹងនូវវិជ្ជា ៣ ប្រការគឺ ៖

**១– បុព្វេនិវាសានុស្សតិវិជ្ជា** – ព្រះអង្គទ្រង់ដឹងស្គាល់នូវជាតិកំណើតកើតស្លាប់របស់ព្រះអង្គ និងរបស់មនុស្សសត្វដទៃដែលធ្លាប់អន្ទោលកើតស្លាប់ចាប់ជាតិជាច្រើនលើកច្រើនសា ដែលហៅថាអនេកជាតិ ។ វិជ្ជានេះគ្មានសាវ័កណា ទោះមានចំណេះចេះដឹងបានសំរេចមគ្គផលថ្នាក់ណាអាចបានដឹងដូចព្រះអង្គឡើយ ។

**២– ចុតូបបាតវិជ្ជា** – គឺជាវិជ្ជាមួយយ៉ាងដែលព្រះសម្ពុទ្ធទ្រង់រកឃើញបន្ទាប់ពីបានវិជ្ជាទីមួយមក ។ វិជ្ជានេះព្រះអង្គទ្រង់ចេះដឹងស្គាល់យល់នូវដំណើរកើតស្លាប់របស់មនុស្សសត្វលោកទាំងអស់ថា អ្នកនោះ

កើតនៅទីនោះ ក្នុងត្រកូលនោះ ។ អ្នកនេះនឹងស្លាប់ទៅកើតនៅទីនោះ បានកំណើត, មានត្រកូលខ្ពង់ខ្ពស់ ឬថោកទាបបែបនេះបែបនោះ ។

៣—អាសវក្ខយវិជ្ជា គឺវិជ្ជាដ៏សំខាន់ក្រៃលែង ដែលព្រះអង្គចេះដឹង ថែមទាំងស្គាល់វិធីដែលនាំឲ្យអស់លើងរីងស្ងួតអាសវៈ គឺគ្រឿងផាប់ជំពាក់របស់សត្វលោក នៅក្នុងវាលវដ្តសង្សារនេះ ។

វិជ្ជាទាំង ៣ យ៉ាងនេះហើយ ដែលជាវិជ្ជាជាន់ខ្ពស់ គ្មានអ្នកណាចេះ ហើយគ្មានអ្នកណាអាចរកឃើញឲ្យដូចព្រះអង្គបានឡើយ ។ ដោយហេតុថាព្រះសម្មាសម្ពុទ្ធទ្រង់មានវិជ្ជានេះហើយ ទើបយើងពោលឲ្យតម្លៃទៅលើការត្រាស់ដឹងរបស់ព្រះអង្គថា ជាការត្រាស់ដឹងដ៏ធំ ។ ការត្រាស់ដឹងនេះនាំឲ្យពួកមនុស្សនិងទេពតាបានថ្វាយព្រះនាម ថែមទាំងលើកតំកល់ព្រះអង្គថាជា សាស្តាចារ្យ ។

ចំពោះពាក្យថាសាស្តាចារ្យនេះទៀត ក៏ព្រះអង្គពុំមែនជាសាស្តាចារ្យ គឺគ្រូអ្នកដឹកនាំបង្ហាត់បង្រៀនធម្មតានោះឡើយ ប៉ុន្តែព្រះសម្មាសម្ពុទ្ធជាសាស្តាចារ្យ អ្នកដឹកនាំប្រាប់ពន្យល់មនុស្សសត្វ ទៅតាមការព្រហ្មឲ្យបានបរមសុខ, ឲ្យមានចិត្តស្ងប់ ឲ្យដើរផុតពីសង្សារវដ្តនេះឯង បានសេចក្តីម្យ៉ាងទៀតថា ព្រះអង្គជាសាស្តាចារ្យលើមនុស្សផង លើពួកទេពផង លើគ្រូឯទៀតៗផង ។ គឺដោយហេតុយ៉ាងនេះហើយ

ទើបយើងហៅព្រះអង្គម្យ៉ាងទៀតថា « បរមសាស្តាចារ្យ » ជាសាស្តាតែមួយ គ្មានសាស្តាចារ្យណាមកផ្ទឹមឲ្យស្មើបាន ។

ព្រះពុទ្ធជាអគ្គមហាទស្សនវិទូដ៏សំខាន់ថែមទាំងជាចិត្តវិទូ,សង្គមវិទូទៀតផង ។ អ្នកប្រាជ្ញនានាជាន់ក្រោយដែលយើងតែងលើកយកគោលគំនិត ឬស្នាដៃមកធ្វើជាគ្រឿងសិក្សាពិចារណាវែកញែក ដូចជាលោកសូក្រាត, អារីស្តុត, ប្លាតុង, ឡាហ្វុងតែន, ដេកាត, លោក ក័ន ជាដើម គ្រាន់តែជាអ្នកមានគោលគំនិតខ្ពស់បន្តិចជាងយើងរាល់គ្នាតែប៉ុណ្ណោះ ប៉ុន្តែមិនមែនជាអ្នកដឹងច្បាស់នូវបញ្ហាលោក, សកលលោក, សង្គមមនុស្ស, ទឹកចិត្តមនុស្ស ឬសត្វឲ្យបានជាក់ច្បាស់ថាយ៉ាងណាៗ នោះឡើយ ចំណែកឯព្រះពុទ្ធវិញទ្រង់ចេះដឹង ថែមទាំងយល់ច្បាស់នូវបញ្ហាអស់នេះដោយគ្មានមើលខុសសោះឡើយ ជាពិសេស ទឹកចិត្តជាធម្មជាតិគ្មានរូបនេះក៏ព្រះអង្គអាចដឹងការពិតតែច្បាស់ណាស់ទៀត អ្នកណាគិតយ៉ាងណា បំរុងនិងធ្វើអ្វី, អ្នកណាមានចិត្តល្អ អាក្រក់យ៉ាងណាៗ ក៏ព្រះអង្គដឹងទាំងអស់ ហើយច្បាស់ហោសផង ។

ព្រះសម្មាសម្ពុទ្ធទ្រង់មានគុណធម៌ពិសេសមួយទៀត គឺព្រះអង្គជាសាស្តាចារ្យនៃមនុស្សសត្វនិងទេវតា ហើយគ្មានកិលេសជាគ្រឿងនាំឲ្យសៅហ្មងជាប់នៅនឹងព្រះអង្គឡើយ ព្រះអង្គជាព្រះអរហន្ត

អ្នកស្លូតគ្មានចំណង់ចង់បានធនអ្វីៗ គ្រប់យ៉ាង, គ្មានលោភៈ ទោសៈ មោហៈទាល់តែសោះ ។ យ៉ាងណាមិញ ការសោយភត្តាហារ ការស្លៀកដណ្ដប់បិទបាំងកាយជាដើម មិនមែនជាការសំខាន់អ្វីប៉ុន្មានឡើយ បានសេចក្ដីថា ព្រះពុទ្ធអង្គមិនសោយអាហារដើម្បីឆ្ងាញ់ពិសា ស្លៀកពាក់ដើម្បីល្អរូបកាយនោះឡើយ ប៉ុន្តែកិច្ចការរស់នៅនេះ គ្រាន់តែជាករណីយកិច្ចរបស់មនុស្សតែប៉ុណ្ណោះ ។

គោលធម៌សំខាន់លើសគេ ហើយដែលគ្មានសាស្ដា, ឬលទ្ធិណាអាចរកឃើញពីអរិយសច្ច ៤ ប្រការ ។ ពាក្យថា អរិយសច្ចនេះបានន័យសេចក្ដីថា « ធម៌ពិតធម៌មែនដ៏ប្រសើរ » ។ អរិយសច្ច ៤ នេះគឺ :

១_ **ទុក្ខសច្ច** – សេចក្ដីទុក្ខលំបាកទាំង ១២ កង បានទុក្ខព្រោះការកើត ( ជាតិ ) ជាដើមជាការពិត ។ អ្វីក៏ដោយឲ្យតែមានរូបតែងមានទុក្ខ ហើយតែងវិនាសអន្តរាយទៅវិញជានិច្ច ។

២ **សមុទយសច្ច** – សេចក្ដីពិតក្នុងហេតុដែលនាំឲ្យមានទុក្ខ ។ ទុក្ខនេះមិនមែនកើតឡើងដោយគ្មានហេតុនោះទេ គឺពិតជាមានហេតុទើបមានបច្ច័យកើតឡើង ។

៣_ **និរោធសច្ច** – សេចក្ដីពិតក្នុងការរំលត់ទុក្ខ ។ សេច

ក្តីទុក្ខទាំងអស់ កាលកើតឡើងតែងរលត់ទៅវិញ ហើយមិនតែប៉ុណ្ណោះ គេអាចរកមធ្យោបាយសំរាប់រំលត់ទុក្ខនោះបានជាផរាប ។

**៤– មគ្គសច្ច**– សេចក្តីពិតក្នុងការរកមធ្យោបាយ សំរាប់រំលត់ទុក្ខ, មធ្យោបាយនេះគឺការដើរតាមផ្លូវមានអង្គ ៨ ប្រការ គឺ :

១– សម្មាទិដ្ឋិ – ការយល់ឃើញត្រូវ

២– សម្មាសង្កប្បៈ – ការត្រិះរិះត្រូវ

៣– សម្មាវាចា – ការនិយាយត្រូវ

៤– សម្មាកម្មន្ត – ការងារត្រូវ

៥– សម្មាអាជីវោ – ការចិញ្ចឹមជីវិតត្រូវ

៦– សម្មាវាយាម – ព្យាយាមត្រូវ

៧– សម្មាសតិ – ការនឹករលឹកត្រូវ

៨– សម្មាសមាធិ – ការតាំងចិត្តត្រូវ ។

សច្ចធម៌ទាំង ៤ ប្រការ ប្រកបដោយមែកធាងដ៏ច្រើននេះហើយ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់ស្វែងពិចារណាហើយបានឃើញ, បានត្រាស់ដឹងដោយការចាក់ធ្លុះយល់យ៉ាងច្បាស់លាស់ ហើយថែមទាំងអាចពន្យល់ប្រាប់ដល់មនុស្សសត្វឲ្យប្រតិបត្តដើរតាមផង

ការធ្វើអត្ថាធិប្បាយបញ្ជាក់បកប៉ុណ្ណេះ បានទាំឲ្យយើងឃើញ

ថា ព្រះពុទ្ធជាមនុស្សធម្មតា ត្រង់ការដែលព្រះអង្គជាអ្នករស់នៅក្នុងសង្គមមនុស្ស ហើយធ្វើការទាក់ទងនឹងមនុស្សលោក ដោយការពន្យល់ណែនាំនូវគោលច្បាប់ ដែលព្រះអង្គបានចេះបានដឹងដោយព្រះអង្គឯងផង, ព្រះពុទ្ធជាមនុស្សអស្ចារ្យត្រង់ព្រះអង្គបានសម្រេចនូវសម្មាសម្ពោធិញ្ញាណ, ជាលោកវិទូ, សង្គមវិទូ, ចិត្តវិទូ, ជាបរមសាស្ដាចារ្យរបស់ទេពតានិងមនុស្សផង ។ ព្រះពុទ្ធអង្គជាមនុស្សមានប្រាជ្ញា ស្គាល់ចេះដឹង–យល់នូវអ្វី ៗ ដោយជាក់ច្បាស់ ដែលផ្ទុយពីពួកអ្នកប្រាជ្ញ,ទស្សនវិទូនានាជំនាន់មុន ឬ ជំនាន់ក្រោយ ដែលគ្រាន់តែមានគំនិតប្លែកតែពុំបានយល់នូវអ្វី ៗ ឲ្យបានច្បាស់លាស់នោះឡើយ ។

## ប្រធាន

ច្បាប់ព្រះពុទ្ធសាសនាថាមាតាបិតា ជាអ្នកមានគុណលើបុត្រធីតាច្រើនណាស់ ហៅថាអនន្តគុណ ប៉ុន្តែកាលព្រះពុទ្ធ ទ្រង់បានត្រាស់ដឹងធម៌ហើយ ទ្រង់ពុំបានយាងទៅប្រោសព្រះមាតា បិតារបស់ព្រះអង្គមុនទេ ទ្រង់បែរជាយាងទៅប្រោសបញ្ចវគ្គិយភិក្ខុ និងព្រះបាទពិម្ពិសារព្រមទាំងបរិស័ទផ្សេងៗទៀត ក្នុងដែនកាសីនិងដែនមគធៈ ទៅវិញ។

ចំពោះពុទ្ធសកម្មភាពនេះ តើអ្នកមានទស្សនៈ និងយោបល់យល់យ៉ាងណា? ចូរធ្វើអត្ថាធិប្បាយពន្យល់

# អត្ថាធិប្បាយ

ព្រាជ្ញាសម្មាសម្ពោធិញ្ញាណ ដែលព្រះពុទ្ធអង្គទើបនឹងបានពិចារណាជញ្ជឹងរកឃើញ នៅក្រោមម្លប់ពោធិព្រឹក្សនាថ្ងៃពេញបូរមី ខែពិសាខ ឆ្នាំរកានោះ ជាវិជ្ជា, ជាពុទ្ធិមួយដ៏ថ្មីមានន័យជាបរមត្ថ ពោលគឺសេចក្ដីល្អិតល្អន់ក្រៃលែង គ្មានអ្នកណាធ្លាប់ដឹងធ្លាប់ឮសោះ ។ ព្រះពុទ្ធទ្រង់ជ្រាបនូវចិត្តមនុស្សសត្វលោកដោយច្បាស់ប្រាកដ ហើយនិងវិជ្ជាថ្មីដែលទ្រង់ទើបនឹងរកឃើញនោះ ទើបព្រះអង្គបានយកវិជ្ជាថ្មីនោះទៅផ្សព្វផ្សាយ ចែករំលែកដោយការដឹកនាំពន្យល់បង្ហាញមនុស្សសត្វតាមលំដាប់លំដោយ, តាមវិស្ស័យចាស់ខ្ចីរបស់ខ្លួន ។

កាលបានត្រាស់ដឹងហើយ, តាមពុទ្ធប្រវត្តិ, ព្រះពុទ្ធជាម្ចាស់ទ្រង់ធ្វើសកម្មភាពចំនួន ៧ បែប ហើយមួយបែប ៗ ចំនួន ៧ ថ្ងៃ មានការគង់នៅលើរតនបល្ល័ង្កក្រោមម្លប់ពោធិព្រឹក្ស ជាទីដែលព្រះអង្គបានត្រាស់ដឹងជាដំបូង រហូតទល់ទ្រង់យាងទៅគង់នៅក្រោមដើមកែសជាទីបំផុត ។ ក្នុងថិរវេលា ៤៩ ថ្ងៃនេះ ព្រះពុទ្ធអង្គពុំសោយអាហារទាល់តែសោះ ហើយពុទ្ធសកម្មជាទីបំផុតនៅក្រោមដើមកែសនោះ តាមសេចក្ដីដំណាលថា មានព្រហ្មមួយឈ្មោះ សហម្បតិ បានចូលទៅសុំយាងព្រះអង្គ

ឲ្យទៅប្រោសសត្វលោក ។

កំពោះការធ្វើពុទ្ធសកម្មបែបនេះ គឺមិនមែនធ្វើអ្វីក្រៅពីការសម្ញ៉ គិតពិចារណាប្រមើលមើលនូវធម៌ដែលព្រះអង្គទ្រង់រកឃើញថ្មី ។ និង និស្ស័យលក្ខណៈរបស់ជនផងទាំងពួង ដែលព្រះអង្គត្រូវយកធម៌នោះទៅ ណែនាំពន្យល់បង្ហាញនោះឡើយ ។ យ៉ាងណាមិញពួកវេជ្ជបណ្ឌិត ទាំងឡាយដែលត្រិះរិះរាវរកផ្សំបង្កើតបានជាថ្នាំមុខណា ៗហើយ ត្រូវ ពិនិត្យពិចារណាថ្លឹងគិតនូវគុណភាពនៃថ្នាំនោះសិន ថាគេត្រូវប្រើដូច ម្តេច ? ប្រើដោយវិធីណា ? ហើយចំពោះបុគ្គលប្រភេទណា ? ព្រះ សម្ពុទ្ធដែលរកឃើញនូវធម៌ជារស្មី. ជាវិជ្ជាដ៏ថ្លៃវិសេសវិសាលនោះហើយ ក៏ត្រូវពិចារណាឲ្យល្អិតល្អន់ជាមុនសិន មុននឹងយកធម៌នោះទៅធ្វើការ អនុវត្តន៍ជាមួយពួកសត្វក្នុងត្រៃភព ។

កាលព្រះអង្គពិចារណាដំបូង ទ្រង់មានព្រះទ័យរួញរានឹងយក ធម៌ដែលព្រះអង្គទើបរកឃើញនោះ ទៅដឹកនាំពន្យល់ពួកសត្វទៅវិញ ព្រោះអីធម៌មានន័យល្អិតល្អន់ក្រៃពេក បើនឹងយកទៅប្រាប់អ្នកផងទាំងពួង ដែលមិនដឹងដូចព្រះអង្គ ក្រែងមិនបានសម្រេចផលយ៉ាងគាប់ព្រះទ័យ ប៉ុន្តែកាលពិចារណាតទៅទៀតនៅចុងសប្តាហ៍ទី ៧ ទ្រង់ក៏សម្រេចព្រះ ទ័យថានឹងយកធម៌នោះទៅបង្ហាញ ពន្យល់ជននានាឲ្យបានដឹងផង ។

គឺការសម្រេចព្រះទ័យថានឹងសំដែងធម៌ប្រោសសត្វលោកនេះហើយដែល យើងហៅថាសហម្បតិព្រហ្ម ចូលទៅអារាធនាអញ្ជើញព្រះអង្គឲ្យសំដែងធម៌ តែតាមពិតគឺទឹកព្រះទ័យករុណារបស់ព្រះអង្គ ដែលលេចចេញមកពីក្នុងសម្មាសម្ពោធិញ្ញាណរបស់ព្រះអង្គផ្ទាល់នោះឯង ជាសហម្បតិព្រហ្ម។ ទឹកព្រះទ័យនេះ កាលដំបូង ពេលទើបនឹងបានត្រាស់ដឹងថ្មីៗ នៅមានលក្ខណៈផ្សេង គឺទ្រង់រួញរា តែនៅទីបំផុតក៏មានលក្ខណៈផ្សេង គឺទ្រង់អាណិតចំពោះសត្វលោក ដែលនៅជាប់ក្នុងអន្ទាក់វដ្តសង្សារ ។

នៅពេលដែលព្រះអង្គមានព្រះទ័យក្រាលពោរពេញទៅដោយមេត្តាករុណានេះ ព្រះអង្គត្រូវប្រមើលមើលនូវឧបនិស្ស័យ ( បុណ្យ, ព្រេង, វាសនា, ការកសាងសន្សំរបស់ជនម្នាក់ៗ ) នៃសត្វលោកតទៅទៀត ។ ទឹកព្រះទ័យនេះត្រូវជួបនឹងបញ្ហា ២ យ៉ាងជាថ្មី :

១-- គួរសងគុណអ្នកមានគុណូបការៈរបស់ព្រះអង្គជាមុន

២-- ឬមួយគួរដឹកនាំជន ដែលមាននិស្ស័យលក្ខណៈចាស់ក្លាជាមុនសិន ។

កាលទ្រង់ពិចារណាតទៅទៀត ទ្រង់ក៏យល់ថា ព្រះធម៌នេះជាឱសថមួយដ៏ពិសេស ដែលព្រះអង្គប្រឹងស្វែងរកឲ្យឃើញដើម្បីព្យាបាលអ្នកជម្ងឺ ។ ដូច្នេះតើជនណាកំពុងឈឺខ្លាំង ជនណាទើបនឹងឈឺបន្តិច

បន្តិច ហើយតើជនណាអាចទទួលថ្នាំនោះរួចនឹងបានជារោគដោយ ក្មតឆាប់មុនគេ ។ ដរែងពីនេះទ្រង់ទតមើលនិស្ស័យលក្ខណៈផ្សេង ៗ ទៀតជាច្រើន ទើបឃើញថា អាឡារតាបសនិងឧទកតាបសជាអ្នកមាន គុណលើព្រះអង្គផង ជាអ្នកមានជម្ងឺខ្វាំងហើយអាចទទួលឱសថទិព្វ គឺ ព្រះធម៌ថ្លៃរបស់ព្រះអង្គផង ប៉ុន្តែជាអកុសល ទ្រង់ជ្រាបថាតាបសទាំង ពីរនេះ បានស្លាប់រំលាយខន្ធទៅហើយក្នុងពេលថ្មី ៗ នេះ ដូច្នេះមាន តែពួកបញ្ចវគ្គិយភិក្ខុទេ ដែលព្រះអង្គត្រូវដឹកនាំហើយនឹងបានសម្រេច ធម៌មុនគេ ។

ការបញ្ជាក់ខាងលើនាំឲ្យយើងយល់បានថា ព្រះពុទ្ធពុំបានបដិសេធគុណូបការៈរបស់មាតាបិតាឡើយ ប៉ុន្តែពេលបានត្រាស់ដឹង ហើយ ព្រះអង្គមានប្រាជ្ញា, មានវិជ្ជា, ទស្សនៈថ្មី ហើយព្រះអង្គក៏ទ្រង់ មានព្រះតម្រិះយោបល់យ៉ាងនេះ ព្រោះមានហេតុភេទដូចតទៅ :

១– ព្រះអង្គត្រូវយាងទៅប្រោសពួកបញ្ចវគ្គិយភិក្ខុ ដែលនៅឯព្រៃ ឥសិបតនមិគទាយ ជិតក្រុងពារាណសី ដែលកាសមុនជនឯទៀតព្រោះ .

ក– ពួកបញ្ចវគ្គិយភិក្ខុ ( ភិក្ខុមានគ្នា ៥ រូបគឺ កោណ្ឌញ្ញ ១, មហានាម ១, វប្បៈ ១, អស្សជិ ១, ភទ្ទិយ ១ ) ជាអ្នកធ្លាប់មានគុណលើ ព្រះអង្គ, ធ្លាប់បំរើព្រះអង្គ កាលព្រះអង្គនៅគង់ឯគយាសីសប្រទេសក្នុង

មគធរដ្ឋ ដើម្បីធ្វើទុក្ករកិរិយាស្វែងរកការត្រាស់ដឹង ប៉ុន្តែពេលនោះ ដោយព្រះអង្គដែលទ្រង់អត់អាហារហើយនៅតែមិនបានត្រាស់ ទ្រង់ក៏ត្រឡប់ភាន់អាហារវិញ ជាហេតុឲ្យពួកភិក្ខុទាំង ៥ រូបនោះ វែងជឿទុកចិត្តថា ព្រះអង្គនឹងមិនអាចស្វែងរកការត្រាស់ដឹងបានឡើយ ម្ល៉ោះហើយក៏រត់ចោលព្រះអង្គ ទៅនៅឯឥសីបតនមិគទាយពននោះទៅ ។

ខ- ពួកបញ្ចវគ្គិយភិក្ខុជាអ្នកមានជំនឿជឿថា ព្រះអង្គនឹងបានត្រាស់ កាលបានត្រាស់ដឹងហើយ ខ្លួននឹងប្រគល់កាយថ្វាយ ជីវិតចំពោះព្រះអង្គ ដោយគ្មានងាករេឡើយ ។ ក្នុងចំណោមបញ្ចវគ្គិយភិក្ខុនោះ ព្រះភិក្ខុកោណ្ឌញ្ញៈ កាលដើមឡើយ ជាព្រាហ្មណ៍ហោរាដែលមានវ័យក្មេងជាងគេ ក្នុងចំណោមព្រាហ្មណ៍ហោរាទាំង ៨ នាក់ ដែលបានទស្សន៍ទាយថ្វាយលក្ខណៈព្រះពុទ្ធកាលទើបនឹងប្រសូតហើយ ។ ព្រាហ្មណ៍កោណ្ឌញ្ញដែលមានវ័យក្មេងជាងគេនេះ បានទាយថ្វាយព្រះសិទ្ធត្ថកុមារដោយពាក្យតែមួយម៉ាត់ថា « ព្រះសិទ្ធត្ថ ពិតជានឹងចេញបួស ហើយនឹងបានត្រាស់ជាព្រះពុទ្ធមិនខាន » ។ កាលព្រះសិទ្ធត្ថចេញបួស កោណ្ឌញ្ញព្រាហ្មណ៍ក៏នាំកូនព្រាហ្មណ៍ ៤ នាក់ទៀតចេញបួសតាមហើយទៅបំរើរង់ចាំការត្រាស់ដឹងនៃព្រះសម្ពុទ្ធ ដើម្បីនឹងបានសម្រេចធម៌តាមព្រះអង្គ ។ មិនតែប៉ុណ្ណោះសោត កោណ្ឌញ្ញ បានធ្វើសេចក្តីប្រាថ្នា

សាងឧបនិស្ស័យមកជាយូហើយថា “ សូមឲ្យខ្ញុំបានត្រាសដឹងធម៌មុ
ក្នុងសំណាក់ព្រះពុទ្ធអង្គណា១កុំខាន ” ។

គ– ពួកបញ្ចវគ្គិយភិក្ខុ ជាអ្នកមានឧបនិស្ស័យចាស់ក្លាណាស់
ទាំងបានសិក្សា ពិចារណារិះគិតរកធម៌សំរាប់រំលត់ទុក្ខបានយ៉ាង
ទៀតផង កាលណាបើបានស្តាប់ធម៌ព្រះអង្គហើយ មុខជានឹងបានត្រ
ដឹងធម៌តាមព្រះអង្គយ៉ាងពិតប្រាកដ ។

អាស្រ័យដោយហេតុទាំងប៉ុន្មាននេះហើយ ទើបព្រះអង្គ
ប្រោសបញ្ចវគ្គិយភិក្ខុនេះជាលើកទី១ ហើយកាលព្រះអង្គបាន
យកធម៌ ធម្មចក្កប្បវត្តនសូត្រ មកសំដែងឲ្យភិក្ខុទាំង ៥ អង្គនោះ
កោណ្ឌញ្ញក៏បានសម្រេចមគ្គផលសមតាមបំណងព្រះអង្គមែន តមក
ថ្ងៃ១រោជ ២រោជ ខែអាសាឍតទៅ ទ្រង់ក៏សំដែងអនត្តលក្ខណ
ឲ្យភិក្ខុ៤អង្គទៀតស្តាប់ ហើយបានសម្រេចមគ្គផលត។គ្នា ។
ជាបំណងដ៏ធំរបស់ព្រះអង្គ ហើយការយកធម្មៈដែលព្រះអង្គបា
ឃើញ ទៅធ្វើការអនុវត្តន៍ជាដំបូងនេះក៏បានសម្រេចមែន ។

២– ទ្រង់យាងត្រឡប់មកកាន់ក្រុងរាជគ្រឹះ ដែនមគធៈវិញ

១– ដែនមគធៈ ទីក្រុងឈ្មោះរាជគ្រឹះ, ស្ថិតនៅខាងកើតដែនកាសី
ពារាណសី ។ ព្រះពុទ្ធបានត្រាសដឹងនៅដែនមគធ ( វេឡុពិហារ សព្វថ្ងៃ

ប្រោសព្រះបាទពិម្ពិសារ ជាព្រះមហាក្សត្រដែនមគធៈ និងដើម្បីដោះពាក្យប្ដេជ្ញាជាមួយព្រះមហាក្សត្រអង្គនេះផង ហើយនៅតាមផ្លូវ ព្រះអង្គបានប្រោសពួកជនដូចតទៅនេះ ព្រោះ :

ក– ទ្រង់បានទេសនាប្រោសយសកុលបុត្ត, មាតាបិតានៃយសកុលបុត្ត និងសំឡាញ់របស់យសកុលបុត្ត ៥០ នាក់ទៀត ឲ្យបានបួសហើយសម្រេចបត្តផល ។ ពមកទ្រង់បានប្រោសភទ្ទិយកុមារ ៣០ នាក់ទៀត ឲ្យបានជាសាវកសម្រេចបត្តផលជាន់ខ្ពស់ ។ ការប្រោសជនទាំងប៉ុន្មាននាក់នេះ ពុំមែនដោយជនទាំងនេះធ្លាប់មានគុណបំណាច់អ្វីលើព្រះអង្គឡើយ ប៉ុន្តែជនទាំងនេះជាមនុស្សមានឧបនិស្ស័យបារមីចាស់ក្លា ហើយនឹងបានជាសាវកដ៏សំខាន់របស់ព្រះអង្គ ក្នុងការប្រកាសផ្សាយពុទ្ធសាសនាក្នុងដែនដីមគធៈនោះផង ។

ខ– ទ្រង់បានប្រោសជដិលជាបងប្អូននឹងគ្នា ៣ នាក់ទៀតគឺ :

ឱរុវេលកស្សប មានបរិវារ ៥០០ នាក់

នទីកស្សប មានបរិវារ ៣០០ នាក់

គយាកស្សប មានបរិវារ ២០០ នាក់

រួមទាំងអស់ មានចំនួន ១០០៣ នាក់ ។

ការដែលព្រះពុទ្ធអង្គទ្រង់ប្រោសពួកជដិលទាំង ៣ នេះ នៅ
នឹងដែនមគធៈនោះ មិនមែនដោយសារពួកទាំងនេះ ធ្លាប់មានគុណ
ការៈអ្វីលើព្រះអង្គឡើយ ហើយថែមទាំងមិនដែលស្គាល់គ្នា ញ៉ែក
ទាក់ទងអ្វីជាមួយទេ ប៉ុន្តែព្រះអង្គប្រោសដោយបានធ្វើបដិហារ្យដល់
១៥០០ បែប ដែលជាកិច្ច ១ យ៉ាងលំបាក ដើម្បីផ្ចាញ់បំបាក់ទិដ្ឋិមា
ពួកជដិល ជាអ្នកបួសស្វែងរកធម៌ ដោយការដុតកំដៅព្រាណ, ដោ
ហាលថ្ងៃហាលខ្យល់ ត្រាំទឹក ដើម្បីបំបាត់កិលេសនោះ ព្រោះមនុ
នៅក្នុងដែនមគធៈ បានប្រគល់ជំនឿ, វាសនារបស់ខ្លួន ទៅលើជដិ
ទាំង ៣ ដែលមានបរិវាររួមគ្នាចំនួន ១០០០ នាក់នោះទាំងស្រុង, ជដិ
ជាមេលទ្ធិ មេសាសនាទាំង ៣ នេះ ជាគ្រូបាធ្យាយ ជាសាស្តាចារ្យ
មនុស្សភាគច្រើន ជាពិសេសគឺពួកព្រាហ្មណ៍ គហបតីនៅក្នុងដែនទេ
អ្នកណាក៏គោរពពួកជដិលទាំងនោះដែរ ។

អាស្រ័យដោយមានមនុស្សគោរពជដិលទាំង ៣ និងបរិ
ទាំងអស់ ដែលប្រព្រឹត្តធម៌ខុសចាកមាគ៌ាកណ្តាល ដែលហៅថាមជ្ឈិ
មាបដិបទានេះហើយ ទើបព្រះសម្ពុទ្ធទ្រង់ប្រោសដឹកនាំជដិលទាំងនេ
ឲ្យចូលមកក្នុងធម្មវិន័យពុទ្ធសាសនាផង ឲ្យបានជាកម្លាំងក្នុងការផ្សា
ព្រះធម្មវិន័យជាពុទ្ធសាសនា ដែលព្រះអង្គទើបនឹងបានរកឃើញនោះ

សាយភាយទៅក្នុងដែនមគធៈនោះផង ។ ព្រះមស្សនៈដ៏ទូលំទូលាយនេះហើយ ដែលយើងត្រូវតែឲ្យតម្លៃទៅលើអង្គព្រះសម្ពុទ្ធថា ជាអ្នកឆ្លាតវាងវៃប៉ិនប្រសប់ក្នុងការប្រកាសផ្សាយពុទ្ធសាសនា ក្នុងដែនមគធៈជាដំបូង ដោយបានយកជដិលទាំង ៣ ធ្វើជាគ្រឿងឧបករណ៍ . . .ទូយរបស់ព្រះអង្គ. បើគ្មានជដិលទាំង ៣ ព្រះអង្គអាចផ្សាយពុទ្ធសាសនាបានដែរ តែមិនស្រួលឆាប់រហ័សទាន់ពេលវេលា ។ ត្រង់នេះសមនឹងពាក្យខ្មែរយើង ដែលធ្លាប់និយាយគ្នាថា « បន្លាមុត ត្រូវយកបន្លាដោះ, សេះបាត់ត្រូវរកសេះតាម » ។

យ៉ាងណាមិញ ពួកមនុស្សរាប់លាននាក់ធ្លាប់គោរពជដិលទាំង ៣ ទៅហើយ បើជដិលចូលមកកាន់ពុទ្ធសាសនា ជាសិស្សរបស់ព្រះពុទ្ធអង្គវិញ ពួកមនុស្សជាសិស្សគណរបស់ជដិល ក៏នឹងគោរពហើយចូលកាន់ព្រះពុទ្ធសាសនា ស្តាប់ពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះអង្គដោយគោរពមិនខាន ។

៣– កាលព្រះសម្ពុទ្ធទ្រង់បានពន្យល់ដឹកនាំពួកជដិលហើយ ឃើញថាព្រះអង្គត្រូវមានកម្លាំងថ្មីមួយយ៉ាងសំខាន់ ក្នុងការប្រកាសផ្សាយពុទ្ធសាសនាឲ្យជ្រួតជ្រាបទៅក្នុងទីផ្សេង ៗ នៃមគធរដ្ឋនោះ ហើយព្រះអង្គក៏ត្រូវឈានជំហានថ្មីមួយទៀតចូលទៅកាន់ក្រុងរាជគ្រឹះ ដើម្បីប្រោស

ព្រះបាទពិម្ពិសារមហារាជជាព្រះចៅមគធរដ្ឋ ។ ការប្រោសព្រះបាទពិម្ពិសារ (១) នេះនាំឲ្យមានបញ្ហាពីរយ៉ាងតទៅទៀត :

ក– មតិខ្លះយល់ថា ព្រះសម្ពុទ្ធទ្រង់យាងទៅប្រោសព្រះបាទពិម្ពិសារនេះ ដោយសារព្រះអង្គទ្រង់កាន់ពាក្យសច្ចៈ ព្រោះកាលព្រះអង្គទើបនឹងសាងព្រះផ្នួសហើយបាន ៧ ថ្ងៃ ព្រះអង្គទ្រង់យាងចូលទៅបិណ្ឌបាត្រក្នុងក្រុងរាជគ្រឹះ បានជួបនឹងព្រះបាទពិម្ពិសារ ។ ទ្រង់សន្ទនាសំណេះសំណាលយូរ ៗ ទៅ ក៏ជាប់ព្រះទ័យព្រះអង្គណាស់ ហើយសូមថ្វាយរាជ្យពាក់កណ្ដាលដល់ព្រះអង្គ ប៉ុន្តែព្រះអង្គមិនព្រមទទួល ហើយទ្រង់ថ្វាយពតិមានចំពោះព្រះបាទពិម្ពិសារ ពីគោលបំណងនៃការស្វែងរកការត្រាស់ដឹងជាព្រះពុទ្ធ ។ ព្រះបាទពិម្ពិសារទ្រង់ត្រេកអរណាស់

១. ព្រះបាទពិម្ពិសារ ជាមហាក្សត្រមគធរដ្ឋ ទ្រង់បានតាំងសេចក្ដីប្រាថ្នា ៥ យ៉ាង តាំងពីទ្រង់នៅជាយុវក្សត្រនៅឡើយគឺ ១– សូមឲ្យជនទាំងឡាយអភិសេកយើងក្នុងរាជសម្បត្តិនៃមគធរដ្ឋ, ២– សូមឲ្យអង្គព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ ស្ដេចមកប្រតិស្ឋានពុទ្ធសាសនាក្នុងរដ្ឋយើង ដែលបានអភិសេកហើយ, ៣– សូមឲ្យខ្លួនយើង បានចូលទៅអង្គុយជិតព្រះដ៏មានព្រះភាគជាម្ចាស់នោះ, ៤– សូមឲ្យព្រះមានព្រះភាគសំដែងធម៌ដល់យើង, ៥– សូមឲ្យយើងបានត្រាស់ដឹងនូវធម៌ដែលព្រះអង្គបានសំដែងហើយ ។

ហើយបាតព្រះឧក្ការថា « បើលោកភ្ជូនបានត្រាសដឹងជាព្រះពុទ្ធកាលណា សូមទ្រង់យាងមកប្រោសខ្ញុំព្រះករុណាជាលើមុនគេ » ។ ព្រះសិទ្ធត្ថទ្រង់ទទួលយល់ព្រមតាមការសុំនេះ ។

ចំពោះមតិខាងលើ ឃើញថា កាលព្រះអង្គបានត្រាសដឹងហើយព្រះសម្ពុទ្ធទ្រង់ពុំភ្លេចពាក្យសន្យានេះឡើយ ព្រះអង្គក៏ទ្រង់យាងទៅប្រោសព្រះបាទពិម្ពិសារមហារាជ មុនព្រះបាទសិរីសុទ្ធោទនៈជាពុទ្ធបិតា ក៏ប៉ុន្តែបើយើងយកពាក្យនេះដដែលមកនិយាយ ក៏នឹងឃើញថា បើព្រះអង្គកាន់ពាក្យសច្ចៈបែបនេះ ឃើញថាមានកំហុសធ្ងន់បេ ប ព្រោះព្រះអង្គមិនបែនប្រោសព្រះបាទពិម្ពិសារនេះមុនគេបង្អស់ទេ គឺទ្រង់ប្រោសក្រោយបញ្ចវគ្គិយភិក្ខុ, យសកុលបុត្ត និងមាតាបិតាយសកុល-បុត្ត ព្រមទាំងសម្លាញ់ ៥៤ នាក់ ហើយតមកក៏ប្រោសភទ្ទិយកុមារ ៣០ នាក់ និងជដិលចំនួន ១០០៣ នាក់ទៀត ទើបយាងមកប្រោសព្រះបាទពិម្ពិសារជាខាងក្រោយ ។ យ៉ាងនេះ ឃើញថា ព្រះពុទ្ធអង្គទ្រង់ប្រោសព្រះបាទពិម្ពិសារក្រោយជនទាំងឡាយចំនួន ១០៩៥ នាក់ មានបញ្ចវគ្គិយភិក្ខុជាដើមទៅវិញ ។ បើព្រះអង្គកាន់ពាក្យសច្ចៈ គួរតែយាងទៅប្រោស

ព្រះបាទពិម្ពិសារជាដំបូងគេ បន្ទាប់ពីពុទ្ធសកម្មភាពចំនួន ៧ កន្លែង ក្នុង
ថិរវេលា ៤៩ ថ្ងៃនោះមកទើបត្រូវ ។

ខ - មតិខ្លះយល់ថាព្រះសម្ពុទ្ធមិនមែនយាងទៅប្រោសព្រះបាទពិម្ពិ-
សារមុនព្រះមាតាបិតា ដោយការគោរពតាមពាក្យសន្យាពីគ្រាមុន ហើយ
ដើម្បីដោះពាក្យប្ដេជ្ញានោះឡើយ ប៉ុន្តែដោយព្រះអង្គទតឃើញឧបនិស្ស័យ
របស់ព្រះបាទពិម្ពិសារ ដែលតាំងសេចក្ដីប្រាថ្នាទាំង ៥ យ៉ាង តាំងពីព្រះ
អង្គនៅជាយុវក្សត្រនៅឡើយតែប៉ុណ្ណោះ ។

ចំពោះមតិទី ២ នេះជាការសមហេតុសមផលដែរ ដ្បិតអីព្រះ
បាទពិម្ពិសារជាមហាក្សត្រមានឫទ្ធិទន់ភ្លន់ ហើយគោរពរាប់អាន – ស្រ-
ឡាញ់ព្រះសិទ្ធត្ថណាស់ តាំងពីបានស្គាល់ជាគ្រាដំបូងម្ល៉េះ ហើយព្រះ
ពុទ្ធអង្គក៏ទ្រង់គង់នៅក្នុងមគធរដ្ឋ ក្នុងការស្វែងរកសព្វញ្ញុតញ្ញាណរហូត
ទល់បានសម្រេច ក៏នៅតែក្នុងមគធរដ្ឋនេះទៀត ។ ចុះបើព្រះអង្គបាន
សម្រេចសេចក្ដីប្រាថ្នាក្នុងដែនទឹកដីនេះហើយ តើឲ្យព្រះអង្គបោះបង់អ្នក
គ្រប់គ្រងប្រទេសនេះម្ដេចកើត ថែមទាំងព្រះចៅមគធរដ្ឋនេះ ព្រះអង្គធ្លាប់
ស្គាល់ទាក់ទងគ្នាផង ត្រូវតែព្រះអង្គទ្រង់ប្រទានធម៌ ពន្យល់ថ្វាយដល់
ព្រះបាទពិម្ពិសារឲ្យហើយស្រេច មុននឹងយាងទៅប្រោសពុទ្ធបិតា និង
ញាតិវង្សរបស់ព្រះអង្គ. ជាពិសេសទៅទៀត ព្រះអង្គបានត្រាសដឹងជា

ព្រះពុទ្ធនេះ ជាហេតុមួយដ៏អស្ចារ្យណាស់ ហើយជាការក្រក្រៃពេក ច្រើនកោដិឆ្នាំ ឬថ្នាក់ដល់អសង្ខេយ្យឆ្នាំផង ទើបមានព្រះពុទ្ធត្រាស់ឡើងមួយព្រះអង្គៗ ។ ព្រះពុទ្ធសមណៈគោតមជាជាតិសាក្យ នៅឯនគរសាក្យក្រុងកបិលពស្តុ ហើយមកតាំងស្មឹងស្មាធិបានត្រាស់ដឹងនៅឯនគរមគធៈឯណោះ រួចក៏យាងត្រឡប់ទៅកបិលពស្តុវិញ ដោយរំលងនគររាជគ្រឹះមគធរដ្ឋ រួចរំលងនគរសាវត្ថី កោសលរដ្ឋ ឃើញថាជាការមិនសមហេតុផលសោះ ។ មុននឹងស្ដេចយាងទៅកបិលពស្តុវិញ គួរតែសំដែងធម៌ប្រោសអ្នកដែនមគធៈ ជាទីដែលព្រះអង្គបានត្រាស់ដឹងនោះជាមុនសិន ។

ការនិយាយមកខាងលើនេះ ក៏នៅតែពុំទាន់អស់ហេតុផលដែលគួរឲ្យឈប់និយាយដែរ ហើយមតិទាំងពីរខាងលើ ក៏ជាការសមរម្យល្មមគួរឲ្យចូលចិត្តណាស់ទៅហើយ ។ បើយើងនឹកគិតទៅដល់ប្រាជ្ញាពោធិញាណរបស់ព្រះពុទ្ធអង្គ ក៏យើងគួរតែជឿថា ពុទ្ធសកម្មនៃការប្រោសសត្វនៅក្នុងដែនកាសីនិងមគធៈ បានបញ្ចវគ្គិយភិក្ខុនិងព្រះបាទពិម្ពិសាររាជជាដើម មុននឹងយាងទៅប្រោសពុទ្ធបិតា ឬញាតិវង្សនោះ ជាការសមរម្យពេកណាស់ទៅហើយ ប៉ុន្តែយើងនៅមានទស្សនៈជាច្រើនទៀតដែលត្រូវលើកយកមកបង្ហាញដូចតទៅ ៖

ក្នុងចំណោមអាណាចក្រឬរដ្ឋនៅប្រទេសឥណ្ឌាផ្នែកខាងជើ
ឬមធ្យមប្រទេសទាំងសម័យមុនពុទ្ធកាលនិងក្នុង សម័យពុទ្ធកាលមគធរដ្ឋ
ដែនវិឬយកំ មានអាណាប្រជានុរាស្ត្រច្រើន, មហាក្សត្រ, ក្សត្រិ
សេនានៃកងទ័ពមានចំណេះចេះដឹង ខាងយុទ្ធសាស្ត្រច្រើន ហើយមា
ពន្ធានុភាពខ្លាំងក្លាពេកណាស់ ។ មគធរដ្ឋជាគូប្រណាំងប្រជែងនឹងកោស
លរដ្ឋ ដែលមានរាជធានី ឈ្មោះក្រុងសាវត្ថី ។ រដ្ឋទាំងពីរនេះ តែ
ច្បាំងតយុទ្ធគ្នាជាញឹកញាប់ ហើយខាងក្រោយមក មគធរដ្ឋមានជ័យ
ជំនះជាស្ថាពរទៅលើកោសលរដ្ឋវិញ, មគធរដ្ឋបានផ្សាយមហាអាណាចក្រ
ចក្រពត្តិទៅលើរដ្ឋនានាផ្នែកខាងជើងនៃមធ្យមប្រទេសទាំងមូលចំនួន ២
រដ្ឋគឺរដ្ឋធំ ១៦ និងជនបទ ( ខេត្ត ) ៥ ទៀត ។ រីឯដែនសក្កៈ ( សាក្យ
ប្រទេស មានទីក្រុងឈ្មោះ កបិលព័ស្តុ ) មិនមែនជារដ្ឋធំដុំប៉ុនមគធរ
ឬកោសលរដ្ឋឡើយ ប៉ុន្តែគ្រាន់តែជាខេត្តតូចមួយប៉ុណ្ណោះ ហើយដែន
សក្កៈនេះត្រូវនៅក្រោមអំណាចកោសលរដ្ឋផង នៅក្រោមអំណាចមគ
រដ្ឋផង តែក្សត្រក្នុងដែនសក្កៈនេះគ្រាន់តែបានពូជឈាមជាវជាសាក្យវង្ស
មិនយកមនុស្សក្នុងវង្សដទៃមកធ្វើជាគូស្រករប៉ុណ្ណោះ ។

គឺដោយហេតុនេះហើយ ទើបព្រះពុទ្ធជាម្ចាស់ដែលបានត្រាស
ដឹងក្នុងដែនមគធរដ្ឋនេះ ត្រូវប្រោសពួកជនទៅក្នុងមគធរដ្ឋនេះឲ្យហើយ

ស្រេច ទោះជានៅមុននេះបន្តិច ព្រះអង្គបានទៅប្រោសពួកជនណា ក៏ទ្រង់ត្រូវតែចៀតមកប្រោសអ្នកនៅក្នុងមគធរដ្ឋជាកិច្ចពិសេសមួយដោយខានមិនបាន ព្រោះ :

ក– មគធរដ្ឋជារដ្ឋធំ មានប្រជាជនច្រើនលានកោដិ មានព្រាហ្មណ៍ និងគហបតីច្រើន ហើយមហាក្សត្រក្នុងដែននេះ ជាមហាចក្រពត្រាធិរាជលើរដ្ឋឯទៀត មានកោសលរដ្ឋជាដើម ។ កាលព្រះអង្គធ្វើការទាក់ទងផ្សាយពុទ្ធសាសនាឲ្យជ្រួតជ្រាបទៅក្នុងមគធរដ្ឋ នឹងមានពុទ្ធបរិស័ទច្រើននៅក្នុងរដ្ឋនេះទៅ នោះល្បី,កិត្តិយស កិត្តិស័ព្ទរបស់ព្រះអង្គ នឹងអាចផ្សាយទៅក្នុងមហាជនបទទាំង ១៦ និងជនបទតូចទាំង ៥ ក្នុងជម្ពូទ្វីបជាមិនខាន ។

ខ– ពួកក្សត្រសាក្យវង្ស មានព្រះបាទសិរីសុទ្ធោទនៈ ជាប្រមុខ ជាក្សត្រមានទិដ្ឋិមានះច្រើនណាស់ មិនសូវគោរពមេសាសនា, មេលទ្ធិណាឡើយ ប៉ុន្តែពួកក្សត្រទាំងនោះ មានការខ្លបខ្លាចអំណាច មគធរដ្ឋណាស់ ព្រោះខ្លួនជាសាមន្តរាជរបស់គេ ។ រឿងនេះអ្នកសិក្សាប្រវត្តិសាស្ត្រនានា សឹងបានដឹងសព្វគ្រប់ហើយអំពីរឿងអ្នកត្រួតត្រា និងអ្នកនៅក្រោមអំណាចគេ ។ កាលបើពួកក្សត្រនៅក្នុងដែនមគធៈទទួលស្គាល់ព្រះពុទ្ធអង្គហើយ ព្រះកិត្តិនាមព្រះអង្គនឹងផ្សាយទៅដល់សាក្យ-

នគរជាបិនខាន ហើយពួកក្សត្រសាក្យវង្សនឹងទទួលស្គាល់ព្រះអង្គថា ជាព្រះពុទ្ធមែន ។

លក្ខណៈត្រង់នេះ យើងអាចឃើញនិងយល់យ៉ាងច្បាស់ថា ព្រះពុទ្ធអង្គជា **សង្គមវិទូ** មួយព្រះអង្គយ៉ាងពិត ស្គាល់សភាពនយោបាយរបស់សង្គមមនុស្ស ស្គាល់ការរស់នៅនិងស្គាល់ការវិវត្តន៍ទៅនៃសង្គមមនុស្ស យ៉ាងច្បាស់ប្រាកដ ។ យ៉ាងណាមិញ បើព្រះអង្គប្រោសពួកជដិលនិងព្រះបាទពិម្ពិសារបានទៅហើយ ពួកជនដទៃទៀតក៏ស្មោះថា នឹងងាយប្រោសណាស់ ពិសេសគឺព្រះញាតិវង្សរបស់ព្រះអង្គដែលនៅក្រោមអំណាចចក្ររបស់មគធរដ្ឋនេះ ។

ផ្ទុយទៅវិញ បើព្រះអង្គចេញពីសាក្យត្រកូលមកស្វែងរកធម៌ ហើយបានត្រាស់ដឹងមានឫទ្ធិអំណាចអស្ចារ្យយ៉ាងនេះ រួចទ្រង់យាងចូលទៅនគរកបិលព័ស្តុវិញ ដើម្បីប្រោសពពួកញាតិ មុខជាមិនបានទទួលផលប្រសើរសោះឡើយ ហើយជាការលំបាកដល់ព្រះអង្គថែមទៀត ព្រោះម្យ៉ាង ពពួកញាតិនៅមានចិត្តមានះរឹងរូសថា “ ព្រះសិទ្ធត្ថជាកូនជាក្មួយ, ជាប្អូនរបស់អញ អញស្តាប់ — គោរព — ប្រតិបត្តតាមធ្វើអ្វី ? ម្យ៉ាងទៀត ពួកញាតិខ្លះនៅមានកំហឹងចំពោះព្រះអង្គ ព្រោះការរត់ចោលរាជសម្បត្តិ, រត់ចោលមហេសីនិងបុត្រ, ខ្លះទៀតមិនជឿទុកចិត្ត

ថាព្រះអង្គបានត្រាស់ដឹងអ្វីទេ ហើយខ្លះទៀតបានទុកព្រះអង្គជាមនុស្ស អបលក្ខណ៍អពមង្គលទៀតផង ព្រោះហេតុព្រះអង្គកោរសក់ កោររោមចិញ្ចើមចេញ ។ គឺដោយមានហេតុយ៉ាងនេះហើយ ទើបព្រះអង្គត្រូវធ្វើយ៉ាងណាឲ្យកិត្តិនាមព្រះអង្គផ្សព្វផ្សាយទៅកាន់ទិសទីផ្សេង ៗ មានក្រុងកបិលព័ស្តុជាជាតិភូមិព្រះអង្គជាមុនសិន ស់បព្រះអង្គយាងទៅជាខាងក្រោយ ជាពិសេស ព្រះកិត្តិនាមដែលផ្សាយចេញពីមជ្ឈដ្ឋាននៃអ្នកមានអំណាចឫទ្ធានុភាព គឺមគធរដ្ឋនេះ ជាការប្រសើរ មានផលថ្លៃថ្លាឧត្តុង្គឧត្តមណាស់ ។

ហេតុទាំងប៉ុន្មានខាងលើនេះ ជាហេតុធំដែលព្រះអង្គត្រូវទៅផ្សាយព្រះពុទ្ធសាសនានៅក្នុងដែនមគធៈនេះ ជាមុន ៗ នឹងយាងទៅប្រោសព្រះពុទ្ធបិតា និងព្រះញាតិវង្ស ។ នៅមានហេតុដទៃច្រើនយ៉ាងទៀតណាស់ដែលព្រះអង្គត្រូវបំពេញនៅក្នុងដែនដីនេះ ដូចជា ៖

— ការប្រតិស្ឋានវត្តឈ្មោះវេឡុវ័ន នៅក្នុងក្រុងរាជគ្រឹះ ទុកជាលំនៅនៃសង្ឃ និងទុកជាគោលចារឹកនៃព្រះពុទ្ធសាសនាក្នុងដែនដីនេះ ។

— ការតាំងអគ្គសាវ័កស្ដាំ ឆ្វេង គឺព្រះសារីបុត្តនិងព្រះមហាមោគ្គល្លាន ឲ្យសមតាមសេចក្ដីប្រាថ្នានៃសាវ័កទាំងពីរនេះពីអតីតជាតិ ។

— ការប្រជុំចតុរង្គមហាសន្និបាតជាគ្រាដំបូង នៅក្នុងវត្តវេឡុ-

វែនផាដើម ។

ដូច្នេះការដែលព្រះពុទ្ធអង្គ បានយាងទៅប្រោសបញ្ចវគ្គិយភិក្ខុក្នុងដែនកាសី និងការយាងទៅប្រតិស្ឋានព្រះពុទ្ធសាសនា ក្នុងមគធរដ្ឋ ដោយបានប្រោសពួកជដិលនិងព្រះបាទពិម្ពិសារជាដើមនោះ មិនមែនដោយព្រះអង្គភ្លេចព្រះគុណូបការនៃពុទ្ធបិតា និងព្រះញាតិវង្សក្រុងកបិលព័ស្តុនោះឡើយ ប៉ុន្តែពុទ្ធសកម្មបែបនេះ នឹងបានសម្រេចផលយ៉ាងវិសេសវិសាលជាងការដែលព្រះអង្គទ្រង់យាង ទៅកាន់ក្រុងកបិលព័ស្តុមុននឹងយាងទៅកាន់ក្រុងរាជគ្រឹះ ។ ដោយការស្គាល់ច្បាស់នូវសង្គមវិវត្តន៍នេះ ទើបយើងអាចថ្វាយតម្លៃថ្មីមួយទៀត ទៅព្រះសម្មាសម្ពុទ្ធជាសង្គមវិទូដ៏អស្ចារ្យ គ្មានអ្នកណាទោសម័យមុនឬសម័យក្រោយ អាចយកទៅប្រៀបប្រដូចបានឡើយ ។ ព្រះពុទ្ធដំណើរយាងទៅកាន់ក្រុងកបិលព័ស្តុ ដោយព្រះបាទសិរីសុទ្ធោទនៈ ចាត់ឲ្យអាមាត្យនិងបរិវារទៅចំនួន ១០ ដងនោះ មិនមែនជាការសំខាន់ឡើយ ប៉ុន្តែសកម្មភាពបែបនេះ គ្រាន់តែជាពិធីសាស្ត្រមួយនៃអ្នកនិពន្ធដែលលើកឡើង ដើម្បីបញ្ជាក់នូវទឹកព្រះទ័យនឹករលឹករបស់ព្រះពុទ្ធបិតាចំពោះកូនយ៉ាងខ្លាំងក្លាតែប៉ុណ្ណោះ ហើយប្រសិនបើព្រះបាទសុទ្ធោទនៈ ពុំបាច់បញ្ជូនទូតឲ្យទៅ

សុំយាងព្រះអង្គ ហើយបើឧទាយិត្ថេរមិនបាច់ពណ៌នា ទូលព្រះសាស្ដាអំពីផ្លូវទៅកបិលព័ស្ដុនោះ ក៏ព្រះពុទ្ធអង្គគង់តែយាងទៅកាន់ជាតិភូមិរបស់ព្រះអង្គ ដើម្បីប្រកាសផ្សាយព្រះពុទ្ធសាសនា និងដើម្បីប្រោសពុទ្ធបិតាព្រមទាំងព្រះញាតិវង្សដែរ ព្រោះផ្លូវទៅកាន់ក្រុងកបិលព័ស្ដុ បើព្រះអង្គមិនធ្លាប់យាងទៅមក ក៏ទ្រង់ជ្រាបតាមពុទ្ធញាណជាមិនខាន ។

### គួរចំណាំ

ព្រះពុទ្ធទ្រង់យាងទៅកាន់ក្រុងកបិលព័ស្ដុនៅថ្ងៃពេញបូរមីខែផល្គុន ឆ្នាំ រកា បន្ទាប់ពីពេលបានត្រាស់ហើយចំនួន ១០ ខែគត់ ។

## ប្រធាន

គេថា ព្រះសម្មាសម្ពុទ្ធទ្រង់ប៉ិន ប្រសប់ក្នុងការដឹកនាំ–ទូន្មាន–អប់រំ មនុស្សណាស់ប៉ុន្តែដើម្បីនឹងប្រោស ពុទ្ធបិតា និងពពួកញាតិក្នុងក្រុង កបិលព័ស្តុជាដំបូង ព្រះអង្គបានធ្វើ បាដិហារ្យ បណ្ដាលឱ្យកើតជាភ្លៀង ធ្លាក់ចុះទៅវិញ ។

តើអ្នកមានយោបល់យ៉ាងណាចំ ពោះពុទ្ធកិច្ចប្រោសសត្វបែបនេះ ?

ចូរពន្យល់ដោយទាញហេតុផល ផ្សេង ៗ មកបញ្ជាក់ ។

# អត្ថាធិប្បាយ

បញ្ចេកទេសនៃការដឹកនាំ — អប់រំរបស់ព្រះពុទ្ធ ចំពោះសត្វលោក មិនមែនស្ថិតនៅក្នុងការមិនយល់ដឹងចិត្ត ដែលជាអរូបធម៌នោះទៀត ក៏ប៉ុន្តែព្រះអង្គតែងស្គាល់ចិត្តអធ្យាស្រ័យ និងគោលបំណងនៃសត្វលោកទូទៅដោយជាក់ច្បាស់ ដោយប្រាជ្ញាសព្វញ្ញុតញ្ញាណនេះឯង ។

ដើម្បីឆ្លើយតបនូវបញ្ហាណាមួយ ចំពោះជនណាម្នាក់ ឬច្រើនរូបក្តី ព្រះពុទ្ធជាម្ចាស់ទ្រង់ជ្រាបច្បាស់នូវរឿង ៗ គ្រប់យ៉ាងរបស់ជននោះ មានលក្ខណៈនៃការរស់នៅ, សង្គម, ទឹកចិត្ត, អធ្យាស្រ័យជាដើម ជាមុន ។ ព្រះអង្គបានចុកនូវឧបមាសេចក្តីនេះ ស្មើនឹងស្រះ ឬបឹងមួយដែលមានព្រលិត, ឈូកផុះពាសពេញនៅក្នុងបឹង-ស្រះនោះដែលជាសេចក្តីប្រៀបធៀបរវាងព្រលិត ឬ ឈូក មកនឹងមនុស្សសត្វដែលមានលក្ខណៈដូចតទៅ :

១– ពួកមនុស្សសត្វខ្លះ នៅក្រាសដោយកាមកិលេសយ៉ាងច្រើន ដូចផ្កាព្រលិតឈូក ដែលទើបនឹងប៉ិចពន្លកចេញពីក្រអៅមើម មិនទាន់

មានលក្ខណៈពិត ថានឹងអាចផុះចេញរួចឲ្យផុតពីទឹក ផុតពីចំណីត្រី
អណ្ដើក ឬ យ៉ាងណាឡើយ ។ មនុស្សសត្វពួកនេះ កាលបើព្រះអង្គ
សំដែងធម៌ សូម្បីច្រើនផងយ៉ាងណា ក៏មិនងាយនឹងបានសម្រេចមគ្គ
ផលអ្វីដែរ ។

២– មនុស្សសត្វពួកខ្លះ ដូចផ្កាឈូកដែលផុះចេញផុតពីទឹកហើយ
អាចគេចផុតពីចំណីត្រីអណ្ដើកបាន ហើយកាលត្រូវកំដៅ ឬ ពន្លឺព្រះអា
ទិត្យ ៣–៤ ផង ក៏នឹងអាចរីកបាន ។ មនុស្សសត្វពួកនេះ កាល
បើបានស្ដាប់ព្រះបរមពុទ្ធោវាទ ម្ដងពីរក៏នឹងអាចយល់–ចេះដឹងបាន
ហើយអាចសម្រេចមគ្គផលបាន ។

៣– មនុស្សសត្វពួកខ្លះ ដូចផ្កាឈូកដែលផុះផុតពីទឹកយូរថ្ងៃហើយ
មានទំហំធំគ្រប់គ្រាន់ បើកាលណាត្រូវពន្លឺព្រះអាទិត្យភ្លាមនឹងអាច
រីកភ្លាម ឥតបង្អង់ចាំយូរថ្ងៃឡើយ ។ មនុស្សសត្វពំពួកនេះ កាល
បានស្ដាប់ឱវាទដឹកនាំរបស់ព្រះសម្ពុទ្ធតែម្ដង ក៏នឹងអាចសម្រេចមគ្គផល
បានតាមសេចក្ដីប្រាថ្នា ។

ដោយការយល់ស្គាល់នូវនិស្ស័យលក្ខណៈ ទឹកចិត្តរបស់
មនុស្សសត្វយ៉ាងនេះហើយ ទើបក្នុងការដឹកនាំពន្យល់ ប្រាប់ធម៌ពិតធម៌
មែន ដែលព្រះអង្គបានរកឃើញនោះ ព្រះអង្គត្រូវប្រើវិធីច្រើនបែប

ច្រើនយ៉ាងណាស់ ដើម្បីត្រូវទៅតាមទឹកចិត្ត និស្ស័យលក្ខណៈរបស់មនុស្សសត្វនោះ ៗ ឧទាហរណ៍ :

ក– កាលព្រះអង្គប្រោសពួកបញ្ចវគ្គិយភិក្ខុ ទ្រង់សំដែងធម្មចក្កប្បវត្តនសូត្រ ពីព្រោះធម៌នេះ មានជម្រៅ, មានខ្លឹមសារក្រៃពេក ហើយជាធម៌ដែលបដិសេធចោលនូវរូបរាងកាយនេះទាំងអស់ថា ជារបស់គ្មានប្រយោជន៍, ការធ្វើខ្លួនឲ្យស្ថិតនៅក្នុងលក្ខណ្ឌស្រួលពេក ឬ លំបាកពេក ក៏ជាមាគ៌ាខុស មិនសម្រេចប្រយោជន៍ឡើយ លុះណាតែដើរតាមមាគ៌ាកណ្ដាល ដែលហៅថា មជ្ឈិមាបដិបទា = ការប្រតិបត្តិតាមផ្លូវកណ្ដាល ទើបអាចរកទីបំផុតទុក្ខឃើញ ។

ការដែលព្រះអង្គសំដែងធម៌នេះប្រោសពួកបញ្ចវគ្គិយភិក្ខុ ក៏ដោយហេតុការតែពួកភិក្ខុទាំងនោះបានជំនឿជឿជាក់ក្នុងចិត្តថា មានតែការប្រតិបត្តិដ៏តឹងតែង មានការរត់អាហារជាដើមទេ ទើបអាចស្វែងរកការត្រាស់ដឹងឃើញ ។ គឺដោយហេតុនេះហើយ បានជាពួកភិក្ខុទាំង ៥ អង្គនោះ បានរត់ចោលព្រះសិទ្ធត្ថនៅពេលដែលព្រះអង្គប្រឹងរត់អាហារហើយមិនបានត្រាស់ដឹង រួចត្រឡប់ឆាន់អាហារវិញ ។ ព្រះអង្គបានបដិសេធការធ្វើកាយឲ្យលំបាក ហើយពន្យល់ប្រាប់ហេតុនិងផលដោយសព្វគ្រប់ ចំពោះពួកភិក្ខុទាំងនោះ ៗ ក៏ស្ដាប់បាន ហើយបានសម្រេច

មគ្គផលគ ៗ គ្មានកជាលំដាប់ ។

ខ– កាលទ្រង់ប្រោសយសកុលបុត្ត ឬមាតាបិតាយសកុលបុត្ត ជាដើម ទ្រង់មិនលើកយកធម្មចក្កប្បវត្តនសូត្រមកសំដែងពន្យល់ទេ គឺទ្រង់លើកយកបញ្ហាទាន, សីល, ឋានសួគ៌ ជាដើម មកសំដែងឲ្យស្តាប់ទៅវិញ ព្រោះអីពួកជនទាំងនេះ មានចំណង់ចំណូលចិត្តក្នុងបញ្ហាទាន, សីល, និងឋានសួគ៌នេះណាស់ ។

គ–កាលព្រះអង្គប្រោសពួកជដិលទាំង១០០៣ នាក់ទ្រង់ប្រើមធ្យោបាយផ្សេង គឺទ្រង់ធ្វើបដិហារ្យផ្ចាញ់ពួកជដិលទាំងនោះ ឲ្យខ្ចបខ្លាចឫទ្ធានុភាពរបស់ព្រះអង្គជាមុនសិន ទើបព្រះអង្គសំដែងធម៌មួយបែបទៀត ហៅថា អាទិត្តបរិយាយសូត្រ ( ធម៌ដែលបញ្ជាក់ថា រូបរាងកាយជារបស់ក្តៅ ) ពន្យល់ប្រាប់ពួកជដិលទាំងនោះ ព្រោះអីពួកជដិលទាំងនោះមានការជឿ និងប្រតិបត្តដុតកិលេសតណ្ហាដោយការអាំងកំដៅខ្លួនលើភ្លើង ។

ឃ– ក្នុងការប្រោសព្រះបាទពិម្ពិសារ ឬសេនាមហាមាត្យ ព្រាហ្មណ៍គហបតីនានាក្នុងក្រុងរាជគ្រឹះ ព្រះអង្គបានសំដែងធម៌ទេសនាពម្មតា ឲ្យជនទាំងនោះដឹងយល់តាមគំនិតប្រាជ្ញារបស់ខ្លួន ហើយបើទោះជាមានហេតុខ្លះ ដូចជាសិស្សរបស់ជដិលមានការសង្ស័យថា ‘ ព្រះពុទ្ធជាសិស្ស

របស់ជដិល ឬ ជដិលជាសិស្សរបស់ព្រះពុទ្ធ » ជាដើម ព្រះអង្គក៏ប្រើឲ្យជដិលសំដែងឫទ្ធិ កាត់ទឹកចិត្តសង្ស័យរបស់ជនទាំងនោះភ្លាម ៗ ។

ង- ក្នុងការសំដែងធម៌ប្រោសពុទ្ធបិតានិងពពួកញាតិ ព្រះអង្គបានធ្វើបាដិហារ្យ បណ្ដាលឲ្យមានភ្លៀងពោក្ខរពស៌ធ្លាក់ចុះលើពពួកញាតិ ហើយទ្រង់សំដែងមហាវេស្សន្តរជាតក ។

ច- ក្នុងការសំដែងធម៌ប្រោសជនផ្សេង ៗ ទៀត ក៏ព្រះអង្គធ្វើទៅតាមនិស្ស័យលក្ខណៈរបស់ជននោះ ៗ ដែរ ដូចជាព្រះអង្គទ្រង់សំដែងធម៌ប្រោសនាងរូបនន្ទាទេវី ដែលត្រូវជាអនុជរួមបិតាជាមួយ កាលព្រះអង្គទ្រង់ជ្រាបទឹកចិត្តនាងរូបនន្ទាថា ជាស្ត្រីស្រឡាញ់រូបរាងកាយណាស់នោះ នៅពេលដែលទ្រង់ជ្រាបថានាងបានចូលទៅក្នុងទីប្រជុំ ហើយបោកខ្លួនពួនចាំមើលព្រះអង្គ ៗ ក៏និម្មិតឲ្យមានស្ត្រីម្នាក់មានរូបយ៉ាងឆើត-ឆាយ លើសពីលំអនៃនាងរូបនន្ទាទៅទៀត ហើយឲ្យឈរបក់ផ្លិតថ្វាយព្រះអង្គ នាងរូបនន្ទាឃើញដូច្នេះ ក៏ស្ងប់ចិត្តបញ្ចេញកាយពីទីពួនមើលស្ទើរមិនដាក់ភ្នែកចំពោះស្ត្រីនិម្មិត ហើយចេះតែឲ្យតម្លៃទៅលើរូប-និម្មិត បង្អាប់ខ្លួនឯងថា អាក្រក់ណាស់ អន់ណាស់ ប៉ុន្តែមិនយូរប៉ុន្មានរូបនិម្មិតក៏ក្លាយខ្លួនទៅជាអាក្រក់ ចាស់ជរា ថ្ពាល់ខូង, សាច់ជ្រីវជ្រួញ, គោងខ្នង សកស្គរ ហើយទីបំផុតរូបនិម្មិតក៏ដួលស្លាប់ហើមស្អោ វ័ក្កត

ឡាតចោមរោមចឹកប្រញាយគ្នា ។ ចំពោះរូបប្រែប្រួលបែបនេះ ធ្វើឲ្យនាងរូបនន្ទាកើតចិត្តធុញទ្រាន់នឹងរូបកាយណាស់ រួចចូលសុំបួសជាភិក្ខុនីក្នុងសំណាក់ព្រះពុទ្ធជាម្ចាស់ ។

ដូច្នេះវិធីសំដែងធម៌ប្រោសដឹកនាំមនុស្សសត្វ ព្រះពុទ្ធពុំមែនធ្វើឡើងដោយបច្ចេកទេសតែមួយ ដោយវិធីដដែលដូចៗគ្នាទេ ។ ជនខ្លះ ព្រះអង្គគ្រាន់តែទេសន៍ពន្យល់ដោយពុទ្ធដីកាធម្មតា ដូចជាបញ្ចវគ្គិយភិក្ខុ, យសកុលបុត្ត, ព្រះបាទពិម្ពិសារជាដើម អ្នកទាំងនោះក៏អាចស្តាប់បាន ចេះដឹងយល់តាមពុទ្ធោវាទទៅហើយ ព្រះអង្គមិនបាច់ធ្វើបាដិហារ្យអ្វីឡើយ ផ្ទុយទៅវិញ ជនខ្លះមិនព្រមស្តាប់, មិនជឿ, មិនគោរពព្រះអង្គឡើយ ហើយដើម្បីនឹងដឹកនាំពន្យល់ធម៌ប្រាប់ដល់ជនទាំងនោះ ព្រះអង្គត្រូវរកវិធីមួយ គឺធ្វើបាដិហារ្យបំបាក់ទិដ្ឋិមានះនៃជនទាំងនោះ ឲ្យខ្ចប់ខ្ចាចជាមុនសិន ទើបព្រះអង្គសំដែងពន្យល់ជាខាងក្រោយដូចការធ្វើបាដិហារ្យមុននឹងសំដែងធម៌ប្រោសពពួកញាតិជាដើម ។

បច្ចេកទេសនៃការដឹកនាំប្រោសសត្វរបស់ព្រះពុទ្ធអង្គ មានសភាពប្រហែលគ្នា នឹងពួកវេជ្ជបណ្ឌិតនានាក្នុងបច្ចុប្បន្នកាលដែរ, ជនណោកើតជម្ងឺណោ ត្រូវយកថ្នាំបែបនេះទៅព្យាបាល, អ្នកកើតជម្ងឺកមរមាស់, ឬក្តៅខ្លួនផ្តាសាយ គ្រាន់តែឲ្យលេបថ្នាំបន្តិចបន្តួច ក៏អាចជា

ស៊ើរយបាន តែផនខ្លះមានជម្ងឺខ្វាំង ត្រូវតែចាក់ថ្នាំមានតម្លៃច្រើនហើយ យូរថ្ងៃ ឬត្រូវវះកាត់, ចាក់ថ្នាំឲ្យសន្លប់ ទើបបានសះស្បើយជម្ងឺនោះ ។

ចំណែកខាង ការធ្វើបដិហារ្យបង្អុរភ្លៀងបោក្ខរពស៌ឲ្យធ្លាក់ចុះ ដើម្បីប្រោសពពួកញាតិនៅក្រុងកបិលពស្តុ គឺជាពិធីម៉្យាង ឬជាបច្ចេកទេសមួយបែប ក្នុងចំណោមពិធី - បច្ចេកទេសដ៏ច្រើនរបស់ព្រះសម្មាសម្ពុទ្ធ ក្នុងការសំដែងពន្យល់ធម៌បង្ហាញដល់សត្វលោកតែប៉ុណ្ណោះ ហើយបាដិហារ្យនេះ មិនមែនជាការបង្ខិតបង្ខំ ឬការធ្វើឲ្យជនណាវិនាសអន្តរាយខូចប្រយោជន៍ឡើយ ក៏ប៉ុន្តែព្រះអង្គធ្វើឡើងដើម្បីឲ្យពពួកញាតិសម្រេចទឹកចិត្តមករកព្រះអង្គ ក្នុងការស្តាប់ធម៌នេះម៉្យាង ម៉្យាងទៀត គឺជាបុព្វហេតុដែលនាំឲ្យព្រះអង្គសំដែងមហាវេស្សន្តរជាតកនេះឯង ។

ដោយព្រះពុទ្ធទ្រង់ជាចិត្តវិទូ១អង្គយ៉ាងសំខាន់ ប្រកបដោយប្រាជ្ញសម្មាសម្ពោធិញ្ញាណនេះហើយ ទើបក្នុងការដឹកនាំ–អប់រំរបស់ព្រះអង្គចំពោះពពួកសត្វ សឹងបានផលប្រសើរគ្រប់អន្លើ ឧទាហរណ៍ដូចការប្រោសពពួកញាតិដែលយើងយល់ថាជាការក្រ តែព្រះអង្គធ្វើបានងាយទៅវិញ ។

កណ្ឌហោមពាន្ត

# ប្រធាន

គេថា កំណើតព្រះវេស្សន្តរ ប្រកបដោយលក្ខណៈអស្ចារ្យប្លែកពីមនុស្សធម្មតា ។

តើលក្ខណៈត្រង់ណាខ្លះដែលបានបង្ហាញថា ព្រះវេស្សន្តរជាតួអង្គអស្ចារ្យហើយអ្នកមានយោបល់យ៉ាងណាចំពោះលក្ខណៈបែបនេះ ។

## អត្ថាធិប្បាយ

ព្រះវេស្សន្តរ ជាតួអង្គមួយដ៏សំខាន់ ប្រកបដោយលក្ខណ
អស្ចារ្យប្លែកចាប់តាំងពីកំណើតមក ។ លក្ខណៈបែបនេះបានធ្វើឲ្យតួអ

ព្រះវេស្សន្តរមានកិត្តិគុណកាន់តែខ្លាំងឡើង ៗ ជាលំដាប់ ។

ចាប់តាំងពីពេលព្រះវេស្សន្តរ ចុះមកទទួលកំណើតក្នុងផ្ទៃព្រះមាតាមក ព្រះនាងសុជាតសុប្បតី តែងមានចំណង់ប្លែកពីធម្មតា គឺព្រះនាងចង់តែធ្វើទានដល់ស្មូមយាចកកំសត់ទុរគត រហូតទល់នាងសុជាតសុប្បតីបានចំណាយព្រះរាជទ្រព្យផ្ទាល់ សាងសាលាសំរាប់ធ្វើទានចំនួន៦កន្លែងទៀត ។ លក្ខណៈនេះគឺជានិមិត្តរូបនៃការចំណាយទ្រព្យដើម្បីជាសាធារណប្រយោជន៍ចំពោះអ្នកក្រីក្រនានា ហើយជានិមិត្តរូបនៃការសង្គ្រោះយ៉ាងល្អទៀតផង ។ បើយើងយករឿងនេះទៅប្រៀបនឹងរឿងព្រះបាទអជាតសត្រូវ ឃើញថាខុសគ្នាឆ្ងាយណាស់ ព្រោះអីអជាតសត្រូវកាលចូលមកចាប់កំណើតក្នុងផ្ទៃមាតា បានបណ្តាលឲ្យមាតាមានចំណង់ប្លែក គឺចង់ហុតឈាមដើមព្រះហស្តរបស់ព្រះបាទពិម្ពិសារជាស្វាមី រហូតទល់ស្គមរីងរៃនៃរាងកាយ ដោយមិនហ៊ានទូលរឿងពិតថ្វាយព្រះស្វាមី តែលុះព្រះស្វាមីជ្រាប ហើយបានចាក់យកឈាមដើមព្រះហស្តថ្វាយព្រះនាងសោយ ព្រះអង្គក៏មានព្រះរូបកាយធាត់ស្រស់ដូចពីដើមវិញ ។ អជាតសត្រូវ កាលមានវ័យពេញកម្លោះ ក៏ចាប់ព្រះបាទពិម្ពិសារជាបិតាយកទៅដាក់គុកបង្អត់អាហាររហូតទល់សុគត ។ ចំណែកខាងព្រះវេស្សន្តរ ពុំដូច្នោះឡើយ គឺបាននាំចិត្តមាតាឲ្យធ្វើតែអំពើ

ល្អទៅវិញ ។

នៅក្នុងពេលដែលព្រះនាងកំពុងយាងទៅតាមថ្នល់ ចន្លោះផ្ទះឈ្មួញទាក្រុងជេតុត្តរដោយមានព្រះគភ៌ផង ព្រះនាងក៏ប្រសូតព្រះរាជបុត្រដ៏អស្ចារ្យនេះនៅកណ្តាលផ្លូវ ដោយគ្មានគ្រោះថ្នាក់អ្វីឡើយ នៅក្នុងពេលប្រសូតមកភ្លាម ព្រះរាជកុមារបានបញ្ចេញនូវលក្ខណៈប្លែកអស្ចារ្យគឺទ្រង់មានព្រះឧង្ការសូសិហនាទបន្លឺឡើងសួរព្រះមាតាថា៖បពិត្រព្រះមេដ៏មានគុណធ្ងន់ប្រសើរអើយ អ្នកមានបាសដឹងហើយ ខ្ញុំនឹងចង់ឲ្យទានបន្តិចហ៎ .. ។ ជាមួយនឹងលក្ខណៈអស្ចារ្យ ដោយការកើតមកហើយភ្លាមចេះនិយាយភ្លាមនេះ ថាមានមេដំរីមួយបានហោះនាំយកកូនឈ្មោលមួយមកថ្វាយព្រះវេស្សន្តរ ។ នេះក៏ជាលក្ខណៈអស្ចារ្យមួយដ៏ប្លែកដែរ ។

សេចក្តីប្លែកអស្ចារ្យទាំងប៉ុន្មានខាងលើនេះ បង្ហាញឲ្យឃើញថាព្រះវេស្សន្តរមិនមែនជាមនុស្សធម្មតាទេ គឺជាមនុស្សមានបុណ្យ-បារមីធ្វើសេចក្តីល្អច្រើន ហើយដែលគ្មានមនុស្សណាយកទៅប្រដូចបាន ។

ឯលក្ខណៈអស្ចារ្យធម្មតាវិញ យើងក៏ឃើញមានត ៗ មកទៀត ក្នុងគ្រាដែលព្រះវេស្សន្តរស្ថិតនៅក្នុងយុវវ័យនៅឡើយ ពោលគឺនៅពេលដែលព្រះអង្គបានដឹងក្តីហើយ ព្រះបិតាទ្រង់ធ្វើគ្រឿងអលង្ការ

ថ្វាយ មានតម្លៃ ១ សែនតម្លឹងបើគិតជាមាស ។ ព្រះកុមារវេស្សន្តរ យកគ្រឿងអលង្ការនោះមកពាក់តែងកាយបានតែបន្តិច ក៏ដោះប្រទានទៅពួកមេនំ ឯព្រះបិតាក៏ឲ្យជាងរចនាធ្វើគ្រឿងអលង្ការបែបនេះ ហើយមានតម្លៃដូចនេះទៀតអស់ ៩ ផង ដើម្បីថ្វាយព្រះវេស្សន្តរ ។

លក្ខណៈនៃទឹកព្រះទ័យដ៏ទូលាយមួយប្លែកទៀត គឺនៅពេលដែលព្រះអង្គមានព្រះជន្មា ៨ វស្សាហើយ ទ្រង់ក៏មានព្រះទ័យចង់ធ្វើរហូតទល់អជ្ឈត្តិកទាន គឺទ្រង់តាំងព្រះទ័យប្រាថ្នាថា បើជនណាម្នាក់ចង់មកសុំសាច់ឈាមពុះទ្រូងរូងយកថ្លើម ប្រមាត់ បេះដូងព្រះអង្គ ៗ ក៏ឲ្យគេធ្វើតាមចិត្តចុះ ។ នេះបង្ហាញឲ្យឃើញថា ព្រះវេស្សន្តរជាអ្នកស្រឡាញ់សេចក្តីល្អ មានព្រះទ័យទូលំទូលាយណាស់ ព្រះអង្គឥតចេះតំណាញ់អ្វីឡើយ ។

លក្ខណៈរបស់ព្រះវេស្សន្តរ ជាលក្ខណៈអស្ចារ្យប្លែកពីមនុស្សធម្មតា ។ លក្ខណៈប្លែកនេះ បាននាំឲ្យយើងធ្វើសេចក្តីសន្និដ្ឋាន និងពន្យល់បានថា ព្រះវេស្សន្តរមិនត្រឹមតែជាអ្នកមានបុណ្យបារមីប៉ុណ្ណោះទេ ប៉ុន្តែព្រះអង្គជាតួអង្គព្រះពោធិសត្វ អ្នកសាងសេចក្តីល្អពទោពេលមុខ ហើយព្រះអង្គនឹងសាបព្រួសសេចក្តីល្អ គឺការឲ្យទាននូវគ្រឿងស៊ីចុកស្លៀកពាក់នេះដល់ពួកស្មូមយាចកកំសត់ទុរគតថែមទៀតផង ។

## ប្រធាន

ចូរធ្វើការពិភាក្សាអំពីសកម្មភាពនៃទានរបស់ព្រះវេស្សន្តរក្នុងការប្រទានដំរីបច្ច័យនាគេន្ទ្រ ឲ្យទៅព្រាហ្មណ៍អ្នកស្រុកកលិង្គរាស្ត្រ ។

## អត្ថាធិប្បាយ

ទឹកព្រះទ័យរបស់ព្រះវេស្សន្តរដែលបានលេចចេញតាំងពីពេល
ប្រសូតមក បានបង្ហាញឲ្យអ្នកផងទាំងពួងឃើញច្បាស់ថា ព្រះអង្គជា
បុរសម្នាក់ដែលមានព្រះទ័យទូលាយក្នុងការឲ្យទានណាស់ ប៉ុន្តែជាមួយ
នឹងសកម្មភាពទាននេះ, ការប្រទានដំរីរតនមង្គលឈ្មោះបច្ច័យនាគេន្ទ្រ បា
បង្កើតជាបញ្ហា ១ យ៉ាងស្មុគ្រស្មាញ ជាហេតុនាំឲ្យព្រះអង្គត្រូវគេបំបរប
ចេញពីព្រះនគរ ។ តើសកម្មភាពនៃទាននេះមានលក្ខណៈយ៉ាងណា

តាមមតិខ្លះយល់ឃើញថា ការប្រទានដំរីបច្ច័យនាគេន្ទ្រ

នេះ គឺជាសកម្មភាពនៃទានមួយដ៏ល្អប្រសើររបស់ព្រះវេស្សន្តរ ព្រោះម្យ៉ាងដំរីនេះជាព្រះរាជទ្រព្យផ្ទាល់របស់ព្រះអង្គ ដែលមេដំរីបានយកមកថ្វាយនៅពេលដែលព្រះអង្គទើបនឹងប្រសូត បានសេចក្ដីថា ដំរីនោះមិនមែនជារាជទ្រព្យជាប់កេរ្តិ៍ដំណែលតាំងពីរាជមុន ៗ ឡើយ ហើយក៏មិនមែនជាសម្បត្តិសំរាប់រាជបល្ល័ង្កដែរ ម្យ៉ាងទៀត ដំរីបច្ច័យនាគេន្ទ្រគឺជាប្រដាប់សំរាប់សាងបារមីរបស់ព្រះវេស្សន្តរ ក្នុងការស្វែងរកការត្រាស់ដឹងជាព្រះពុទ្ធអង្គនេះឯង ។

ព្រះវេស្សន្តរជាតួអង្គពោធិសត្វអ្នកសាងបារមី កាលបើបានជួបប្រទះនឹងការកសាងព្រះបារមីនេះហើយព្រះអង្គត្រូវតែសាងភ្លាម ព្រោះពេលវេលាបានហុចឲ្យហើយ ។ ការប្រទានដំរីនេះទុកជាការសង្គ្រោះចំពោះមនុស្សជាតិមួយប្រទេសយ៉ាងធំ ព្រោះអីនៅស្រុកកលិង្គរាស្ត្រក្នុងសម័យនោះត្រូវអន្តរាយមួយចូលមកយាយីយ៉ាងខ្លាំង ដោយគ្មានភ្លៀងធ្លាក់ទាល់តែសោះ ទោះបីព្រះមហាក្សត្រក្នុងប្រទេសនោះទ្រង់តាំងធម៌កាន់ឧបោសថសីលយ៉ាងណាក៏នៅតែគ្មានភ្លៀងធ្លាក់ដែរ ។ គឺដោយហេតុនេះហើយ ទើបព្រះចៅកលិង្គរាស្ត្របានចាត់អាមាត្យឲ្យក្លែងខ្លួនជាព្រាហ្មណ៍ ៨ នាក់ទៅសុំដំរីបច្ច័យនាគេន្ទ្រពីព្រះវេស្សន្តរដើម្បីយកចូលទៅក្នុងប្រទេសរបស់ព្រះអង្គ នឹងមានភ្លៀងធ្លាក់សំរាប់ប្រកបមុខរបររ

ទាំងពួង ។

បញ្ហាគ្មានភ្លៀងធ្លាក់នេះ ជាបញ្ហាមួយធំបំផុតនៅគ្រប់ប្រទេ
ទាំងអស់ក្នុងលោកនេះ ។ ទីណាគ្មានភ្លៀងធ្លាក់ ផលដំណាំក៏ត្រ
ខូចអន្តរាយផង ដីបណ្ដុះមិនបានផង ហើយមានបញ្ហាផ្សេង ៗទៀ
ត្រូវលេចចេញមកជាច្រើនទៀតផង ដូចជាការអត់ឃ្លាន, ពម្ងឺផ្សេង
កើតឡើង បំបាត់ជីវិតមនុស្ស សត្វ ជាដើម ។ នៅប្រទេសខ្មែ
យើង បុព្វបុរសបានជីកប្រឡាយបង្ហូរទឹកបារាយណ៍សំរាប់ផ្ទុកទឹកទុក
ប្រាស រហូតទល់ពួកសិល្បករបានរចនារូបចម្លាក់ទុកនៅត្រង់ខ្លោងទ្វ
ចូលទៅឋានសួរ ដោយឆ្លាក់រូបពួកអសុរ និងទេវៈទាញនាគដើម្បីក
សមុទ្រទឹកដោះយកទឹកអម្រឹតថែមទៀត ។ រូបចម្លាក់នេះ តាមគោលជ
ណរខ្មែរ មិនមែនបានន័យថា កូរសមុទ្រទឹកដោះដើម្បីយកទឹកអម្រ
ដោយសុទ្ធសាធនោះឡើយ ក៏ប៉ុន្តែគេធ្វើឡើងជានិមិត្តរូបនៃការបង្កើ
រក្សាទុកនូវទឹកសម្រាប់ប្រើប្រាសធម្មតានេះឯង ។ ដូច្នេះទឹកជារបស
មានតម្លៃណាស់ ខ្មែរក្នុងបច្ចុប្បន្នកាលប្រឹងប្រែងរោយណាយទឹកយ៉ាងខ្ល
ដោយបាននាំគ្នាទាំងប្រទេសជីក ស្រះ, អណ្ដូង, ប្រឡាយ រហូតទល
ធ្វើទំនប់ធំ ៗ សម្រាប់ទុកទឹកប្រើប្រាសផង ។ នៅប្រទេសឥណ្ឌ
បញ្ហាខ្វះទឹកនេះបានបង្កើតជាវិបត្តិមួយយ៉ាងធំ រហូតទល់មានមនុស្សស្លា

ព្រោះគ្មានទឹក គ្មានអាហារបរិភោគជាច្រើនម៉ឺនសែននាក់ ។ ព្រះវេស្សន្តរដែលទ្រង់មានកំណើតជាជនជាតិឥណ្ឌា នៅក្នុងសម័យបុរាណដែរនោះ ព្រះអង្គក៏បានជួបប្រទះនឹងបញ្ហានេះដែរ ។ យ៉ាងនេះហើយបានជាព្រះអង្គប្រឹងដោះស្រាយបញ្ហាអាយុជីវិតនៃមនុស្សជាតិ ដោយបានប្រទានដំរីរត្នមង្គលឲ្យទៅពួកអ្នកស្រុកកលិង្គរាស្ត្រ ដើម្បីឲ្យមានទឹកសម្រាប់ប្រើប្រាស់គ្រប់វិស័យការងារ ។

ផ្ទុយទៅវិញ បានមតិខ្លះយល់ថា ការប្រទានដំរីបច្ច័យនាគេន្ទ្ររបស់ព្រះវេស្សន្តរនេះ ជាកំហុស ១ យ៉ាងធំទោះជាដំរីនោះជាព្រះរាជទ្រព្យផ្ទាល់របស់ព្រះអង្គក៏ដោយ ព្រះអង្គក៏មិនត្រូវប្រទានឲ្យទៅប្រទេសណាដទៃទៀតឡើយ ព្រះអង្គត្រូវតែទុកដំរីនេះឲ្យនៅក្នុងប្រទេសជានិច្ច ព្រោះដំរីនេះជាគ្រឿងមង្គល ជាអាយុជីវិតរបស់ប្រទេសមួយទាំងមូល បើដំរីនេះនៅទីណា ភ្លៀងតែងធ្លាក់ចុះក្នុងទីនោះ ចុះព្រះវេស្សន្តរបានប្រទានដំរីនេះឲ្យទៅបរទេសទៅហើយ តើអ្នក ប្រទេសនឹងបានទឹកពីណាសម្រាប់ប្រើប្រាស់, ហើយអាយុជីវិតរប ប្រទេសនឹងទៅជាយ៉ាងណាទៅវិញ ? តើព្រះវេស្សន្តរអាចចិញ្ចឹមមនុស្ស ១ នគរបានដែរឬទេ ?

**បញ្ហានេះហើយ ដែលនាំឲ្យពួកអ្នកនគរមានកំហឹងយ៉ាងខ្លាំងក្លា**

វេហ្គតចលសុំឲ្យព្រះបាទស្រីសញ្ជ័យ បំបរបង់ព្រះវេស្សន្តរចេញពីព្រ
នគរ ។ កំហឹងនេះ មិនមែនត្រឹមតែរឿងដំរី ប៉ុណ្ណោះទេ ប៉ុន្តែលើស
ពីនេះទៀត គឺការដែលព្រះវេស្សន្តរបានប្រទានទាំងស្វេតច្ឆត្រ គ្រឿ
ប្រដាប់ពេទ្យហ្ម និងទ្រមាក់ ៥០០ នាក់ទៅជាមួយផង ។ លក្ខណៈត្រ
នេះហើយ ដែលនាំឲ្យពួកអ្នកនគរខឹងនឹងព្រះវេស្សន្តរយ៉ាងខ្លាំង ព្រោ
ទ្រមាក់ហ្មទាំងនោះ ត្រូវព្រាត់ប្រាសពីកូន ប្រពន្ធ ទៅនៅឯប្រទេស
កលិង្គរាស្ត្រ ជាមួយដំរីបច្ច័យនាគេន្ទ្រ ។

ព្រឹត្តិការណ៍ក្នុងរឿងប្រទានដំរីនេះ មានរឿងតូច ។ ហើយជាចំណុ
ខ្សោយ នាំឲ្យពួកអ្នកនគរកើតកំហឹងចំពោះព្រះវេស្សន្តរ ព្រោះអ៊ីសក
ភាពបែបនេះ ហាក់ដូចជាព្រះវេស្សន្តរហ៊ានយក បានកាត់ដៃជើង កា
ព្រះរាជ្យប្រទេសឲ្យអន្តរាយទៅតែម្ដង ។

ព្រឹត្តិការណ៍ខាងលើ នាំឲ្យអ្នកជាតិនិយមនិងអ្នកមនុស្សនិយ
មានការដែកបកស្រាយទៅវិញទៅមកមិនចប់ ។ ពួកជាតិនិយមបានឲ្
កំហុសទៅលើព្រះវេស្សន្តរយ៉ាងខ្លាំង ត្រង់ព្រះអង្គពុំយល់នយោបាយ
ស្រុកទេស. រីពួកមនុស្សនិយម មិនបានចោទប្រកាន់ព្រះវេស្សន្តរទេ
ព្រោះគេយល់ឃើញថា អំពើទានរបស់ព្រះវេស្សន្តរ គឺជាការសង្គ្រោ
ចំពោះមនុស្សជាតិ — ដោះស្រាយបញ្ហាការរស់នៅរបស់មនុស្ស ដែល

ត្រូវកម្លាំងធម្មជាតិសង្កត់មកលើជីវិតយ៉ាងធ្ងន់ណាស់ទៅហើយ ឲ្យបានរួចផុតពីគ្រោះថ្នាក់នេះដោយស្រួល ប៉ុន្តែទោះយ៉ាងនេះក៏ដោយ ក៏យើងឃើញនៅក្នុងទំព័រ ៨៤ នៃមហាវេស្សន្តរជាតកនេះថា « រីអស់អ្នកនគរផងទាំងឡាយ ហេតុតែទេវតាមកអា-គៀសចិត្តនោះមិញណា ក៏សឹងតែខឹងនឹងព្រះពោធិសត្វនោះក្រៃពេក ហើយបបួលគ្នាទៅជំនុំនៅមុខព្រះលាន ស្រដីនូវពាក្យនោះកងរំពងពុះនៅនាកណ្ដាលអាកាស » ទៅវិញ ។ ដូច្នេះ បើតាមពាក្យនេះ ឃើញថា ការដែលព្រះវេស្សន្តរបានប្រទានដំរីបច្ច័យនាគេន្ទ្រឲ្យទៅពួកព្រាហ្មណ៍នៅនគរកលិង្គរាស្ត្រនោះ ពួកអ្នកនគរស្រីពិរាស្ត្រឥតមានតូចចិត្ត នឹកទោមនស្សខឹងសំបារចំពោះព្រះវេស្សន្តរអ្វីបន្តិចដោយខ្លួនឯងឡើយ ប៉ុន្តែដោយហេតុតែបានទេវតាមកអាគៀសបញ្ចូលចិត្តក៏បណ្ដាលឲ្យពួកអ្នកនគរដែលធ្លាប់រស់ដោយសារដំរី និងដោយសារព្រះវេស្សន្តរនោះ ខឹងនឹងព្រះវេស្សន្តរឡើង ។ បើតាមផ្ទៃនៃអត្ថរូបនេះ គេយល់ថា ពួកអ្នកនគរនិងព្រះវេស្សន្តរ គ្មានហេតុវិបត្តិទំនាស់ប្រឆាំងទាស់នឹងគ្នាឡើយ ប៉ុន្តែគឺទេវតាឯណោះវិញទេ ដែលបានការមនពេញ

ចិត្តនឹងសកម្មភាពនៃការបំពេញទានរបស់ព្រះវេស្សន្តរ ។

ចំពោះរឿងទេវតាដែលចេះមានចិត្តឈឺឆ្អាលបែបនេះ នាំឲ្យមានបញ្ហាចោទនិងដោះស្រាយជាច្រើនតទៅទៀត ថា :

– ហេតុអ្វីបានជាទេពតាមិនពេញចិត្តនឹងព្រះវេស្សន្តរ ក្នុងការសង្គ្រោះចំពោះមនុស្សម្នាគ្រូវភ័យ ដែលកើតពីកង្វះធម្មជាតិ ( គ្មានភ្លៀងធ្លាក់ ) គ្របសង្កត់ ?

– ឬមួយទេពតាកាន់ជើងស្រឡាញ់តែពួកអ្នកនគរស្រីពិរាស្ត្រ-ស្អប់អ្នកនគរកលិង្គរាស្ត្រ ?

– ឬមួយទេពតាទាំងនោះជាអ្នកកាន់ចិត្តអាក្រក់ ស្អប់ព្រះវេ–ស្សន្តរ, កាន់ចិត្តមិច្ឆាទិដ្ឋិចំពោះទានរបស់ព្រះអង្គ ដែលធ្វើសង្គ្រោះដល់ពួកមនុស្សនៅកលិង្គរាស្ត្រ ?

– បើទេពតាទាំងនោះ មិនចង់ឲ្យដំរីបច្ច័យទាគេន្ទ្រយ្យាតចេញពីនគរ ម្ដេចក៏ទេពតាទាំងនោះមិនជួយធ្វើអន្តរាគមន៍ឲ្យភ្លៀងធ្លាក់ចុះក្នុងនគរកលិង្គរាស្ត្រផង ឬមួយទេពតាទាំងនោះគ្មានសមត្ថភាព ?

បុព្វហេតុដែលនាំឲ្យទេពតាបណ្ដាលចិត្តពួកអ្នកនគរស្រីពិរាស្ត្រឲ្យខឹងនឹងព្រះវេស្សន្តរនេះ គឺដោយហេតុពួកទេពតាទាំងនោះ មានចិត្តគុំគួនរឿងអ្វីមួយចំពោះព្រះវេស្សន្តរហ្នឹងឯង បើពុំដូច្នោះទេ ប្រហែល

ជាទេពតាពួកនេះ មិនធ្វើផ្លូវថ្នោះឡើយ ប៉ុន្តែបែរជាជួយថ្វាយពរព្រះអង្គទៅវិញមិនខាន ហើយថែមទាំងជួយធ្វើយ៉ាងណាឲ្យព្រះវេស្សន្តរនិងអ្នកនគរស្រីពិរាស្ត្រ បានសុខសាន្តនឹងគ្នាផង ។

ផ្ទុយទៅវិញ មានមតិខ្លះយល់ថា បុព្វហេតុដែលនាំឲ្យទេពតាបញ្ចូល ឬ អាគៀសចិត្តពួកអ្នកនគរនោះ គឺមកពីទេពតាទាំងនោះជួយជ្រោមជ្រែងព្រះវេស្សន្តរ ក្នុងការបំពេញទានបារមីឲ្យរឹតតែខ្ពង់ខ្ពស់ឡើងទៅទៀត ព្រោះថា បើធ្វើយ៉ាងនេះទៅ នឹងនាំឲ្យព្រះវេស្សន្តរធ្វើសត្តសតកមហាទាន, ធ្វើទានឯទៀត ។ ហើយកាលបើព្រះអង្គត្រូវគេបំបរបង់ឲ្យទៅនៅក្នុងភ្នំគិរីវង្កតនោះ ព្រះអង្គនឹងបានលើកបុត្រធីតា មហេសីធ្វើជាទានទៀត ។ បើយើងយកមតិនេះធ្វើការពិចារណា យើងនឹងបានឃើញនៅក្នុងផ្ទៃអត្ថរូបទាំងមូលនៃមហាវេស្សន្តរជាតក ថា ព្រះវេស្សន្តរបានធ្វើសកម្មភាពយ៉ាងនេះមែន ជាពិសេសទៅទៀតក្នុងផ្ទៃរឿងទាំងមូល យើងក៏ឥតបានឃើញថា នគរជេតុត្តរ ឬ ស្រុកស្រីពិរាស្ត្រកើតទុរ្ភិក្សគ្មានភ្លៀងធ្លាក់ ព្រោះតែគ្មានដំរីបច្ច័យនាគេន្ទ្រនោះឡើយ បានសេចក្តីថា អ្នកស្រុកបានសុខសប្បាយទាំងអស់តែគ្នា ហើយក្នុងចំណោមនោះ មានតែព្រះវេស្សន្តរនិងមហេសី បុត្រធីតាប៉ុណ្ណោះដែលទទួលទុក្ខវេទនា១ខណៈ ។

រួមមតិទស្សនៈទាំងអស់ខាងលើនេះមក បាននាំឲ្យយើងមានយោបល់ថា ការដែលព្រះវេស្សន្តរទ្រង់ប្រទានដំរីបច្ច័យនាគេន្ទ្រ ឲ្យទៅពួកអ្នកស្រុកកលិង្គរាស្ត្រនោះ គឺដើម្បីបំពេញទានបារមីនេះម៉្យាង និងម៉្យាងទៀត គឺដើម្បីជួយស្រោចស្រង់ជីវិតមនុស្ស ឲ្យរួចពីគ្រោះថ្នាក់នេះឯង ប៉ុន្តែបើគិតទៅតាមគំនិតអ្នកជាតិនិយមវិញ អំណោយទាននេះមានលក្ខណៈផ្ទុយពីផលប្រយោជន៍ នៃនយោបាយរបស់ប្រទេសជាតិទៅវិញ ព្រោះដំរីនេះ ជាអាយុជីវិតរបស់អ្នកនគរស្រីពិរាស្ត្រនេះឯង ។

ការគិតប្រយោជន៍ផ្ទាល់ខ្លួន, ជាធម្មតារបស់អ្នកលោភលន់, ការគិតប្រយោជន៍ជាតិ ជាធម្មតារបស់មហាបុរសស្នេហាជាតិមាតុភូមិ, ឯការគិតប្រយោជន៍ទូទៅចំពោះមនុស្សជាតិ ជាធម្មតារបស់ព្រះវេស្សន្តរពោធិសត្វ ។

ថែម-ស៊ូ

## ទានកណ្ឌ

# ប្រធាន

តើទានរបស់ព្រះវេស្សន្តរ ជាទានដើម្បីសង្គ្រោះ ឬ ជាទានដើម្បីមាន ?

ចូរធ្វើអត្ថាធិប្បាយ បញ្ជាក់ហេតុផល ។

## អត្ថាធិប្បាយ

ការឲ្យគ្រឿងប្រើប្រាស និងគ្រឿងបរិភោគហៅថាទាន ។ ព្រះវេស្សន្តរបានប្រព្រឹត្តធ្វើទាននេះយ៉ាងខ្លាំងក្លា រហូតដល់មានព្រះកិត្តិនាមល្បីល្បាញពេញទាំងប្រទេស ហើយនៅសល់ព្រះកិត្តិនាមនេះរហូតទល់សព្វថ្ងៃនេះថែមទៀត ។

ន័យទី ១ របស់អំណោយទានព្រះវេស្សន្តរ មានសេចក្ដីថា

ព្រះវេស្សន្តរជាមនុស្សម្នាក់មានចិត្តល្អ មិនចេះកំណាញ់សោះ ... ដូ
នៅក្នុងមហាវេស្សន្តរជាតក ( ទំព័រ ១៦ ) បានដំណាល ... លុ
ព្រះពោធិសត្វធំចំរើនឡើង ទើបព្រះមហាក្សត្រធិរាជស្តេចឲ្យប្រដាប់ថ្វា
គ្រឿងអលង្ការ មានតម្លៃមួយសែនដំឡឹងឲ្យព្រះបរមពោធិសត្វ ។ ទ្រង់
បន្តិចហើយ ស្តេចដោះឲ្យទៅជាទានអស់មេនំផងទាំងឡាយ ហើយ
ព្រះមហាក្សត្រធិរាជ ទ្រង់ឲ្យប្រដាប់ថ្វាយព្រះបរមពោធិសត្វវិញទៀត
ព្រះអង្គទ្រង់បន្តិច ហើយស្តេចដោះប្រទានទៅមេនំផងវិញទៀត ។
នាកាលព្រះអង្គនៅក្មេងនៅឡើយ នោះតែងនឹងដោះគ្រឿងប្រដាប់ឲ្យ
ទៅជាទានមេនំផងទាំងឡាយរៀង ៗ ទៅជាគំរាប់ ៩ ដងហោង ,, ។

ក្នុងផ្ទៃនៃអត្ថរូបនេះបញ្ជាក់ឲ្យយើងឃើញថា ព្រះវេស្សន្តរ
ជាអ្នកមានចិត្តល្អណាស់ ប៉ុន្តែព្រះទ័យល្អនោះ ពុំទាន់មានគោលដៅ
ចាក់ចំទៅលើអ្វីមួយនោះឡើយ បានសេចក្តីថា ព្រះកុមារវេស្សន្តរ
ទ្រង់ដោះគ្រឿងអលង្ការប្រទានទៅពួកមេនំទាំងនោះ មិនមែនដើម្បី
តបស្នងសងគុណ ឬ ព្រោះឃើញមេនំទាំងនោះ ជាមនុស្សក្រីក្រគោក
យ៉ាកលំបាកវេទនានោះឡើយ ។ ការឲ្យបែបនេះគ្រាន់តែមានន័យ
ថា ឲ្យព្រោះខ្លួនមានចិត្តល្អឥតចេះកំណាញ់ស្វិតែប៉ុណ្ណោះ ។

**ន័យទី ២ របស់អំណោយទានព្រះវេស្សន្តរនេះ** មានសេចក្តី

ទូលំទូលាយជាងមុន ពោលគឺព្រះវេស្សន្តរធ្វើទានចំពោះស្មូមយាចក ជាអ្នកកំសត់ទុគ៌តឥតទីពឹងពំនាក់ ដោយព្រះអង្គបានប្រទានតាំងពីគ្រឿងបរិភោគចំរែតពោះ បានស្រួលខ្លួន រហូតទល់គ្រឿងសំលៀកបំពាក់ បិទបាំងកាយ– ការពារកំដៅថ្ងៃ– ខ្យល់ និងសត្វធាតុផ្សេង ៗ ថែមទៀត ។

មនុស្សដែលចូលមកទទួលយកអំណោយទានរបស់ព្រះវេស្សន្តរ មិនមែនជាអ្នកមានដីធ្លីសម្រាប់ធ្វើដំណាំយកផល ឬ មានកេរ្តិ៍ដំណែលសម្រាប់រកទទួលទានធ្វើរបរយកផលឡើយ ប៉ុន្តែសុទ្ធតែជាអ្នកក្រគ្មានទីពឹង គ្មានមុខរបរ ហើយអ្នកខ្លះគ្មានទាំងលំនៅស្ថានសម្រាប់នៅឲ្យបានសមរម្យផង ។ បញ្ហាទាំងអស់នេះ មានចោទឡើងយ៉ាងជាក់ស្តែង ហើយញឹកញាប់បំផុតនៅប្រទេសឥណ្ឌា ។

ទឹកដីឥណ្ឌា បើតាមគម្ពីរផ្សេង ៗ និយាយថាជាប្រទេសដ៏សមគួរ ឬ ជាទឹកឆ្អែងល្អ ( បដិរូបទេស ) ប៉ុន្តែតាមភូមិសាស្ត្រ និងប្រវត្តិសាស្ត្រវិញ ទឹកដីនេះ ជាទីអាក្រក់– លំបាកទៅវិញ ព្រោះមនុស្សនៅក្នុងប្រទេសនេះត្រូវរងទុក្ខលំបាកអត់ឃ្លាន ព្រោះឥទ្ធិពលនៃធម្មជាតិគ្របសង្កត់ជាញឹកញាប់ ដូចជា :

១– ជាទីគ្មានទឹកសម្រាប់ធ្វើផលដំណាំ ព្រោះត្រូវរីងរាំងគ្មាន

ភ្លៀងធ្លាក់រហូតរាប់ឆ្នាំក៏មាន ។

២– ជាទីដែលត្រូវទឹកជំនន់ជន់លិចផលដំណាំ បំផ្លាញជីវិតមនុស្សអស់ជាច្រើនក្នុងមួយគ្រា មួយសម័យ ព្រោះទឹកដីនេះមានភ្នំហេម-ពាននៅខាងជើង ហើយទឹកដីខាងជើងមានកំពស់ខ្ពស់ជាងខាងត្បូងរាប់គីឡូម៉ែត្រ កាលណាទឹកកករលាយខ្លាំង ក៏បណ្ដាលឲ្យទឹកហូរធ្លាក់មកខាងត្បូងខ្លាំងដែរ រកទីបញ្ចេញទឹកឲ្យឆាប់រហ័សមិនបាន ។

៣– ជាទីដែលត្រូវជម្ងឺរាតត្បាតជាញឹកញយ ព្រោះខ្វះអនាម័យ ឬ នៅពេលក្រោយមានការរាំងរែងស្ងួត និងក្រោយមានទឹកជំនន់ ។

៤– ជាទីដែលត្រូវធាតុត្រជាក់ពេក បណ្ដាលឡើងនាំឲ្យមនុស្សក្រីក្ររងារឹងពោះរហូតស្លាប់ ។

៥– ជាទីដែលត្រូវធាតុក្ដៅហួសកំរិត គ្របសង្កត់ម្ដងម្កាលទោះមានភ្លៀងធ្លាក់ក៏ដោយ ។ ធាតុអាកាសក្ដៅនេះក៏បណ្ដាលឲ្យដំណាំនិងជីវិតមនុស្សអន្តរាយដែរ ។

៦– ជាទីដែលត្រូវមហន្តរាយនៃសង្គម បណ្ដាលឡើង ព្រោះ**ចម្បាំងសាសនា–ចម្បាំងជាតិសាសន៍** ។ សាសនានៅប្រទេសឥណ្ឌាមានច្រើនណាស់ តាំងពីបុរាណកាលរហូតមកទល់បច្ចុប្បន្នកាល

ហើយសាសនាដែលធំជាងគេគឺ ពុទ្ធសាសនា, សាសនាព្រាហ្មណ៍, ាសនាជេន, សាសនាហិណ្ឌូ, សាសនាមហាម៉ាត់ ឯទៃពីនេះមាន ាសនាតូច ៗ ជាច្រើនទៀត ហើយបរិស័ទនៃសាសនាទាំងនោះ លើក លែងតែពុទ្ធសាសនិកចេញ តែងតែច្បាំងកាប់សម្លាប់គ្នាជាញឹកញយ ណាស់ ដូចជាសាសនាគោរពគោនិងសាសនាគោរពជ្រូកជាដើម ។ ទៃពីសាសនាគឺបញ្ហាភាសា ។

បច្ចុប្បន្នកាល ប្រជាជននៅឥណ្ឌាមានប្រមាណ ៥២០ លាន នាក់ ។ ក្នុងបណ្តាជនទាំងនេះ មានភាសាដល់ទៅ ៨៣៥ ភាសា ផ្សេង ៗ គ្នា ហើយភាសាដែលសំខាន់ ៗ ជាងគេ មានប្រជាជននិ-យាយច្រើន គឺ :

១– ប្រជាជនឥណ្ឌាចំនួន ១៤០ លាននាក់និយាយភាសាហិណ្ឌី ។

២– ប្រជាជន ៣៣ លាននាក់និយាយភាសាទេលុគូ ។

៣– ប្រជាជន ២៧ លាននាក់និយាយភាសាម៉ារ៉ាធី ។

៤– ប្រជាជន ២៥ លានកន្លះនិយាយភាសាទមិឡ ។

៥– ប្រជាជន ១៦ លានកន្លះនិយាយភាសាគុជ្ជរាទី ។

៦– ប្រជាជន ១៤ លានកន្លះនិយាយភាសាគន់ណាតា ។

៧– ប្រជាជនចំនួន១៣លានកន្លះនិយាយនិងប្រើភាសាម៉ាលេយ្យា-

ឡើង ។

៨– ប្រជាជនចំនួន ១៣ លាននាក់ប្រើភាសាឱរិយា ។

៩– ប្រជាជនចំនួន ១២ លានកន្លះប្រើភាសារជ្ជស្ថានី ។

១០– ប្រជាជនចំនួន ១២ លាននាក់និយាយនិងប្រើភាសាបញ្ចាពិ ។

១១– ប្រជាជនចំនួន ៥ លាននាក់ប្រើភាសាអស្សាមេសៈ ។

១២– ប្រជាជនចំនួន ១៧,៥ កន្លះប្រើភាសាផ្សេង ៗ ទៀត ។

ក្នុងចំណោមអ្នកប្រើភាសាផ្សេង ៗ គ្នានេះ ខ្លះកាន់សាសនា, ទំនៀមទម្លាប់ប្រពៃណីដូចគ្នាក៏មាន ផ្សេងគ្នាក៏មាន ជួនអីអ្នកប្រើភាសាតែមួយ តែប្រកាន់លទ្ធិសាសនា ជំនឿប្រពៃណីផ្សេងគ្នាក៏មាន ។ សព្វថ្ងៃនៅប្រទេសឥណ្ឌាទាំងមូល ដោយធ្លាប់នៅក្រោមអំណាចអង់គ្លេសជាច្រើនឆ្នាំ ក៏ប្រើភាសាអង់គ្លេសជំនួសភាសាជាតិវិញ ព្រោះប្រជាជនភាគច្រើន ៗ ចេះភាសានេះ ។

៧– ជាទីដែលមានជាតិប្រកាន់វណ្ណៈដាច់ ៗ ពីគ្នាដោយច្រើន ។ វណ្ណៈទាំង ៤ គឺវណ្ណៈព្រាហ្មណ៍, ក្សត្រ, វេស្ស និងសូទ្រ នៅមានពាសពេញទាំងប្រទេស ។ ពួកវណ្ណៈសូទ្រ ត្រូវគេមើលងាយប្រើប្រាស់ដូចសត្វធាតុ ។

៨– ជាទីដែលមានវណ្ណៈនាយទុនជិះជាន់ច្រើន ។ ពួកអ្នកមាន

ទ្រព្យច្រើននៅស្រុកឥណ្ឌា បានប្រើអំណាចរបស់ខ្លួនផ្ដាច់ការ ទៅលើប្រជាជនក្រីក្រយ៉ាងខ្លាំង ឯប្រជាជនក្រីក្រក៏ច្រើនណាស់ទៅទៀត ។ ដូច្នេះបានជាមានរឿងគេដំណាលថា នៅឥណ្ឌាជាទីពោរពេញដោយអ្នកសុំទានច្រើនជាអនេក នៅស្ថានីយរថភ្លើង, ចំណតរថយន្ត ឬទីប្រជុំជនទេសចរនានា មិនចេះខ្វះអ្នកសុំលុយកាក់ឡើយ ។

គឺដោយមានបញ្ហាទាំងប៉ុន្មានខាងលើនេះហើយ ទើបមានបញ្ហាវិបត្តិអន្តរាយជាច្រើនកើតឡើង ដែលយើងតែងជួបប្រទះជាញឹកញាប់នៅក្នុងមហាវេស្សន្តរជាតក ជាពិសេស គឺមានអ្នកក្រច្រើន ថែមទាំងមិនសូវមានការយោគយល់គ្នាផង ។ អំណោយទានរបស់ព្រះវេស្សន្តរក្នុងពេលនោះ មានន័យច្រើនយ៉ាងទៅទៀត :

ក– ចែករំលែកសេចក្ដីសុខដល់មនុស្ស ដែលគ្មានសេចក្ដីសុខដូចគេឯទៀត ៗ ដែលរស់នៅក្នុងសង្គមជាមួយគ្នា ។

ខ– ជួយសង្គ្រោះមនុស្សដែលគ្មានទីពំនឹង គ្មានជម្រកឲ្យបានរស់នៅដោយស្រួល មួយខណៈមួយពេលផង ។

គ– ចងមនុស្សដែលរស់នៅក្នុងសង្គម ជាតិសាសន៍ជាមួយគ្នា ឲ្យស្គាល់-ស្រឡាញ់រាប់អានគ្នា ទុកគ្នាជាមិត្តសំឡាញ់ ជាសហជីវិនី-សហជីវិន ក្រវរស់នៅក្នុងសង្គមពូជពង្សជាមួយគ្នា កុំឲ្យមានវិបត្តិទំនាស់នឹង

គ្នា ស្ងួម្បីមនុស្សទាំងនោះមានសាសនា ទំនៀមទម្លាប់ប្រពៃណី លទ្ធិ
ជំនឿផ្សេង គ្នាយ៉ាងណាក៏ដោយ ។ អំណោយបែបនេះហើយ
ដែលយើងអាចសន្និដ្ឋានបានថា ព្រះវេស្សន្តរជាអ្នកសង្គមវិទូមួយដ៏សំខាន់
ហើយអំណោយទានរបស់ព្រះអង្គ គឺដើម្បីសង្គ្រោះចំពោះមនុស្សជាតិដូច
ព្រះអង្គឲ្យបានសុខសប្បាយដោយសារព្រះរាជទ្រព្យនោះឯង ។

ន័យទី ៣ មានសេចក្ដីទូលំទូលាជាងន័យទាំងពីរខាងដើមទៅ
ទៀត ពោលគឺព្រះអង្គធ្វើដើម្បីសង្គ្រោះប្រជាពលរដ្ឋដែលក្រីក្រឲ្យផុតពី
ទុក្ខភ័យផង និងដើម្បីយកកំប្រៃផលប្រយោជន៍ដែលកើតចេញពីទាន
នោះធ្វើជាស្ពានបន្ទំបារមីឲ្យបានចាស់ក្លា ប្រយោជន៍នឹងបានត្រាស់ជា
ព្រះពុទ្ធ ១ ព្រះអង្គក្នុងពេលណា ១ ដើម្បីចម្លងសត្វលោកដែលជោគជាំ
ដោយសេចក្ដីទុក្ខសោកភិតភ័យគ្រប់ប្រការនេះ ឲ្យផុតចាកវដ្ដសំសារឆ្លង
ទៅកាន់ត្រើយនៃបរមសុខ ពោលគឺព្រះនិព្វាននេះឯង ។

គោលដៅទី៣ នេះ មានតម្លៃលើសគោលដៅនានាទាំងអស់
ប៉ុន្តែកម្រនឹងមានជនណាបានស្រាវយល់ច្បាស់ប្រាកដឡើយ ព្រោះ
ជាគោលដៅ ១ ដែលស្ថិតនៅទីស្ងាត់កំបាំងណាស់ ។

ផ្ទុយទៅវិញ មានអ្នកខ្លះយល់ថាព្រះវេស្សន្តរបានធ្វើទានដើម្បី
ទានទៅវិញ បានសេចក្ដីថា ព្រះវេស្សន្តរឲ្យរបស់របរផ្សេង ៗ ដល់
អ្នកផងទាំងពួង ចាប់តាំងពីការធ្វើទានធម្មតារហូតទលធ្វើសត្តសតកមហា

ទាន ក៏ដើម្បីនឹងឲ្យគេស្រឡាញ់រាប់អានចូលចិត្តព្រះអង្គ ឬ ដើម្បីឲ្យគេធ្វើកិច្ចការណា ១ ជាប្រយោជន៍ដ៏ធំចំពោះព្រះអង្គ ប្រៀបដូចអ្នកស្ទូចប្របក់ដែលចំណាយសាច់ធ្វើជានុយបន្តិច ដើម្បីស្ទូចយកត្រី កន្ត្របដ៏ធំជាងនុយនោះឡើយ ។ ព្រះវេស្សន្តរឥតមានគោលបំណងយ៉ាងនេះទាល់តែសោះ គឺព្រះអង្គឲ្យអ្វីទៅអ្នកឯទៀត គឺឲ្យដោយស្មោះ មិនមែនឲ្យដើម្បីឲ្យគេថ្វាយអ្វីមកព្រះអង្គវិញនោះទេ ព្រោះបើព្រះអង្គចង់បានយ៉ាងនេះដដែល ព្រះអង្គមិនបាច់ចាំធ្វើទានឡើយ រាជសម្បត្តិកិត្តិយស និងអ្វី ។ ផ្សេងទៀត ត្រូវតែធ្លាក់មកលើព្រះអង្គដោយមិនបាច់ចាំខំឡើយ ព្រះអង្គនៅផ្ងុំតែស្ងៀម របស់ទាំងនេះក៏នឹងត្រូវតែបានមកព្រះអង្គជាការចាំបាច់ ។

ព្រះវេស្សន្តរធ្វើទានមិនមែនដើម្បីទានឡើយ ប៉ុន្តែអំណោយទានទាំងប៉ុន្មាន គឺព្រះអង្គធ្វើក្នុងគោលដៅ ២ យ៉ាង, ម្យ៉ាងធ្វើស្របទៅតាមកាលសម័យនៃសង្គម ដែលត្រូវសង្គមដូចគ្នាជិះជាន់ ឬ ត្រូវកំលាំងធម្មជាតិគ្របសង្កត់ ហើយព្រះអង្គត្រូវដោះស្រាយបញ្ហាសង្គមកិច្ចនេះឲ្យបានធូរស្រាលបន្តិច, ម្យ៉ាងទៀត ធ្វើដើម្បីបានផលប្រយោជន៍ដ៏ធំក្នុងការស្វែងរកការត្រាស់ដឹង ដើម្បីរកសេចក្តីសុខដល់មនុស្សលោកនេះឯង ដូចពុទ្ធភាសិត ១ សំដែងថា ‹‹ សុខោ ពុទ្ធានមុប្បាទោ ការបានត្រាស់ជាព្រះពុទ្ធ តែងបានសុខ ( ដល់សង្គមមនុស្សលោក ) ។

# ប្រស្នា

គេថាព្រះវេស្សន្តរ ធ្វើសត្តសតកមហាទាន គឺដើម្បីនឹងបំផ្លាញព្រះរាជទ្រព្យឲ្យអស់ មុននឹងយាងចេញទៅគង់នៅក្នុងព្រៃភ្នំគិរីវង្កត។

តើអ្នកមានយោបល់យ៉ាងណាចំពោះមតិខាងលើនេះ ?

## អត្ថាធិប្បាយ

ក្រោយពេលដែលត្រូវគេសុំបំបរបង់ ឲ្យយាងទៅគង់នៅ
ព្រះនគរ, ព្រះវេស្សន្តរបានចាប់ធ្វើសត្តសតកមហាទាន ជាទាន
បែបយ៉ាងសម្បើមអស្ចារ្យនៅក្នុងព្រះនគរ រួចទើបព្រះអង្គយាងចេ
ព្រះនគរទៅគង់នៅគិរីវង្កត ។ ចំពោះទានបែបនេះ នាំឲ្យមានប

ចោទឡើងថា ព្រះវេស្សន្តរធ្វើទានដើម្បីបំផ្លាញរាជទ្រព្យ ក្នុងពេលដែលព្រះអង្គលែងសង្ឃឹមថានឹងបានសោយរាជ្យហើយ ។

សត្តសតកមហាទាន ជាអំណោយមួយដ៏ប្លែកអស្ចារ្យ មិនដែលកើតមានឲ្យញឹកញាប់ សូម្បីតែលើកទី ២ នៅក្នុងសង្គមមនុស្សនេះឡើយ ។ ទាននេះ មានតែក្នុងសម័យព្រះវេស្សន្តរមួយពេលប៉ុណ្ណោះពោលគឺព្រះអង្គបានធ្វើអំណោយ ជារបស់ចំនួន ៧ រយមុខ ហើយក្នុងមួយមុខ ។ មាន ៧ រយទៀត ដូចជាដំរី ៧ រយ, គោ ៧ រយ, សេះ ៧ រយ, ខ្ញុំប្រុស ៧ រយ, ខ្ញុំស្រី ៧ រយ ជាដើម បើបូករួមរបស់ទាំងអស់ទៅ ឃើញថា របស់ទាំងនោះមានចំនួនដល់ទៅ ៤៩០.០០០ របស់ ។ គឺដោយការធ្វើអំណោយបែបនេះហើយ ទើបមានមតិខ្លះយល់ថា ព្រះវេស្សន្តរ នៅពេលដែលមានមហាបាតុកម្មប្រឆាំងនឹងព្រះអង្គហើយ ទ្រង់តូចព្រះទ័យចំពោះរាជវង្សនិងអ្នកស្រុកស្រីពិរាស្ត្រយ៉ាងខ្លាំង ហើយដោយទ្រង់មានព្រះតម្រិះយល់វែងឆ្ងាយថា អំណើះតទៅ ព្រះអង្គលែងបានគ្រប់គ្រងរាជសម្បត្តិនេះទៀត ម្ល៉ោះហើយព្រះអង្គក៏ចាប់ធ្វើសកម្មភាពមួយដ៏ធំទៀត គឺការធ្វើសត្តសតកមហាទាននេះឯង ។

ចំពោះមតិនេះ នាំឲ្យយើងយល់បានថា ប្រហែលជាព្រះអង្គធ្វើឡើងក្នុងបំណងយ៉ាងនោះមែន ព្រោះអីការឲ្យទានរបស់ចំនួន ៧

**រយមុខ** ហើយក្នុងមួយមុខៗ ៧ រយថែមទៅទៀតនោះ ឃើញថាច្រើ
ពន់ពេកណាស់ ព្រះរាជទ្រព្យពិតជាគ្មានដល់ទៅប៉ុណ្ណោះឡើយ ដូច្នេ
ត្រូវតែយកប្រាក់ដែលត្រូវយកពីទីណាមួយមកទិញដូរ យករបស់ទាំងនោ
មកឲ្យទានទើបគ្រាន់ ។ មិនតែប៉ុណ្ណោះ អ្នកទទួលអំណោយ
ទានរបស់ព្រះវេស្សន្តរក្នុងពេលនោះ មិនមែនសុទ្ធតែអ្នកក្រីក្រកំសត់ទុ
គតឡើយ ប៉ុន្តែមានទាំងពួកក្សត្រ, សេដ្ឋី, គហបតី, ឈ្មួញ នៅ
ក្នុងនគរ និងនគរដទៃទៀតក្នុងជម្ពូទ្វីបមកទទួលយករបស់ទាំងនោះ ហើយ
ពួកស្រីក្រមុំល្អ ៗ ត្រូវបានទៅពួកមនុស្សមានវណ្ណៈធំ ៗ ទាំងអស់ ដោយ
មានទេពតាបានទៅឃោសនាប្រាប់ឲ្យមកទទួល ដូចមានសេចក្តីក្នុងមហា
វេស្សន្តរជាតកទំព័រ ១៣៣ ថា “ . . . ហេតុតែអានុភាព
នៃការឃោសនានោះក្តី អស់ស្ដេចនិងនាំ
ឡាយ ក៏មកទទួលយកស្រីកញ្ញាអំពីព្រះមហា
ក្សត្រឲ្យទាននោះ នាំទៅកាន់ឋានលំនៅអាត្ម
នីនៃ ៗ នោះហោង ។ បពិត្រអើយ វីអស
អ្នកផងទាំងពួងអម្បាលម៉ាន នៅនាជេតុត្តរនគ
នោះ នោះស្ដេចក្តី ព្រាហ្មណ៍ក្តី ឈ្មួញក្តី អស

អ្នកទាំងអម្បាលនោះ សឹងមកទទួលយកទាន នោះ . . .» ។

បើយោលតាមសេចក្តីនៃអត្ថរូបខាងលើនេះក៏រឹតតែឃើញច្បាស់ទៅទៀតថាព្រះវេស្សន្តរទ្រង់ឲ្យទាន គឺឲ្យដោយគ្មានទីដៅឡើយ ហើយតាមច្បាប់ថា ការឲ្យរបស់ ៥ យ៉ាងនឹងមិនបានផលប្រយោជន៍ទេគឺ:

១- ឥត្ថីទានំ ការឲ្យស្ត្រីទៅបុរស

២- ឧសភទានំ ការឲ្យគោញីទៅគោឈ្មោល

៣- មជ្ជទានំ ការឲ្យគ្រឿងស្រវឹង

៤- សមជ្ជទានំ ការឲ្យល្បែងរបាំ

៥- ចិត្តកទានំ ការឲ្យរូបគំនូរដែលនាំឲ្យកើតចិត្តរីករាយ ។

ព្រះវេស្សន្តរបានឲ្យស្រីក្រមុំល្អ ៗ ទៅពួកក្សត្រ, គហបតី ព្រាហ្មណ៍, ឲ្យគ្រឿងស្រវឹងទៅជាទានបែបនេះ តើនឹងមានផលប្រយោជន៍យ៉ាងណាចំពោះព្រះអង្គក្នុងការស្វែងរកសម្មាសម្ពោធិញ្ញាណទៅអនាគតកាល ។ អាស្រ័យហេតុនេះហើយ ទើបមានអ្នកខ្លះមានយោបល់យល់ថា ព្រះវេស្សន្តរធ្វើសត្តសតកមហាទាន ដើម្បីចំផ្លាញទ្រព្យឲ្យអស់ក្នុងពេល ដែលព្រះអង្គត្រូវពលរដ្ឋធ្វើបាតុកម្មប្រឆាំង ទាស់នឹង

ព្រះអង្គ ហើយសុំឲ្យបំបរបង់ព្រះអង្គទៅនៅក្នុងព្រៃភ្នំ ។

ផ្ទុយទៅវិញ សត្តសតកមហាទាន ពុំមែនជាអំពើកើតឡើ
ដោយគំនិតចង់ព្យាបាទដូច្នោះឡើយ ប៉ុន្តែទាននេះ ព្រះវេស្សន្តរបា
ផ្ដើមធ្វើឡើង ដើម្បីទុកជាអនុស្សាវរីយ៍មួយដ៏ធំជាចុងក្រោយបង្អស់ មុ
នឹងព្រះអង្គត្រូវឃ្លាតចេញពីព្រះនគរ និងប្រជាពលរដ្ឋជាទីស្រឡាញ់របស
ព្រះអង្គ ដែលព្រះអង្គធ្លាប់នៅរួមសុខទុក្ខ ធ្លាប់ឲ្យទានជារបស់ផ្សេង
ចំពោះជនរួមជាតិព្រះអង្គដែលក្រីក្រកំសត់ទុរគតនេះឯង ។

ទានជាអនុស្សាវរីយ៍នេះ ព្រះអង្គត្រូវធ្វើឲ្យបានធំដុំជាងពេល
ណា ៗ ទាំងអស់ ដើម្បីទុកជាទីរលឹកប្រចាំជីវិតរបស់ព្រះអង្គផង ដើម្បី
ឲ្យជនរួមជាតិរបស់ព្រះអង្គបានសប្បាយផុតកម្រិតពុតលេខ មុននឹងព្រះ
អង្គបែកចេញទៅផង ។ ព្រះវេស្សន្តរធ្វើនេះ គឺក្នុងគោលបំណង
ហ្នឹងឯង មិនមែនដោយមានកំហឹងចំពោះជនណា ហើយធ្វើដើម្បីបំ
ផ្លាញរាជទ្រព្យឲ្យអស់ហិនហោចនោះឡើយ ។

ទោះបីព្រះវេស្សន្តរធ្វើសត្តសតកមហាទាន ដែលនៅក្នុង
ចំណោមនោះ មានលាយឡំដោយរបស់មិនស្អាតខ្លះ ដូចជាស្ត្រី
សម្រាប់បុរស, ស្រាជាគ្រឿងស្រវឹងក៏ដោយ ក៏មានរបស់ឯទៀត ។

ច្រើនមុខណាស់ ដែលមានផលប្រយោជន៍ដល់សាធារណជន ហើយអំពើនេះសោតទៀត ក៏ព្រះវេស្សន្តរធ្វើឡើងក្នុងក្របខណ្ឌទានតែប៉ុណ្ណោះ មិនមែនធ្វើដើម្បីបំផ្លាញរាជទ្រព្យនោះឡើយ ។ ទានជាទីរលឹកចុងក្រោយនេះ ជាតឹកតាងនៃទឹកព្រះទ័យដ៏ល្អ ហើយទូលំទូលាយរបស់ព្រះវេស្សន្តរហ្នឹងឯង ៖

## ហឫទ័យព្រះវេស្សន្តរ

មានលក្ខណៈទូលំទូលាយជាងជនឯទៀត ត្រង់ព្រះអង្គគិតឃើញដល់សេចក្ដីសុខទុក្ខរបស់ជនដទៃទៀត ដែលកើតមកក្នុងត្រកូលក្រខ្សត់ ទទួលតែទុក្ខលំបាកក្នុងឆាកជីវិត ។ ព្រះវេស្សន្តរចង់ជួយចែកសុខឲ្យអ្នកក្រខ្សត់ យកទុក្ខចេញពីស្មា បានជាទ្រង់ធ្វើតែទាននេះឯង ។

កណ្ឌនៃបរិច្ឆេទ

# ប្រធាន

រាជសម្បត្តិ ជាទីត្រូវការរបស់មនុស្សទូទៅណាស់ ប៉ុន្តែព្រះវេស្សន្តរ បែរជាមិនព្រមទទួលរាជសម្បត្តិនេះពីពួកក្សត្រចេតរាស្ត្រនៅមាតុលនគរឡើយ ។

ចូរធ្វើការពិភាក្សាមើល តើព្រះវេស្សន្តរមានគោលគំនិតយ៉ាងណាក្នុងរឿងនេះ

## អត្ថាធិប្បាយ

រាជបល្ល័ង្កជាទីស្ថាន១ដ៏ខ្ពស់ផុត ពោរពេញទៅដោយសុខមាល

ាព ហើយដែលមនុស្សតែងត្រូវការណាស់ ប៉ុន្តែព្រះវេស្សន្តរសូម្បី
កក្សត្រចេតរាស្ត្របានសុំយាងឲ្យសោយរាជ្យក៏ដោយ ព្រះអង្គក៏មិន
ាមទទួលតាមសេចក្ដីអញ្ជើញនោះដែរ ។ ចំពោះព្រះកាយវិការ
របនេះ នាំឲ្យយើងមានចិត្តសង្ស័យ ហើយត្រូវតែធ្វើការពិចារណា
ទៅទៀត ។

គាបមតិខ្លះយល់ថា ពួកក្សត្រចេតរាស្ត្រជាក្សត្រចំណុះរបស់
ព្រះវេស្សន្តរ គឺព្រះវេស្សន្តរជាអធិរាជលើពួកចេតរាស្ត្រនេះឯង ។
ាស្រ័យហេតុនេះហើយ បានជាពួកចេតរាស្ត្របានសុំអញ្ជើញព្រះ
វេស្សន្តរឲ្យសោយរាជ្យ ប៉ុន្តែការអញ្ជើញនេះគ្រាន់តែជាកិច្ចគួរសមចំ-
ពោះអធិរាជ ក្នុងឋានៈនៃខ្លួនជាសាមន្តរាជប៉ុណ្ណោះ ។ តាមធម្មតា
ក្សត្រសាមន្តរាជ ឬ បទេសរាជ តែងមានការកោតខ្លាចចំពោះអធិរាជ
ណាស់ ដូចប្រទេសខ្មែរក្នុងសម័យនគរភ្នំ, ចេនឡា និងមហានគរ
ដែរ ក្សត្រសាមន្តរាជនានា ដូចជាចាមជាដើម តែងនាំសួយសារអាករ
មកថ្វាយអធិរាជខ្មែររៀងរាល់ឆ្នាំ ។

គឺដោយការអញ្ជើញជាកិច្ចគួរសមនេះហើយ បានជាព្រះ
វេស្សន្តរមិនព្រមទទួល ។

មានមតិខ្លះយល់ថា ព្រះវេស្សន្តរមានព្រះទ័យធុញទ្រាន់នឹង

**កាមសម្បត្តិ**នោះខ្លាំងណាស់ទៅហើយ ដូចអ្នកដែលបរិភោគចំ
ហារឆ្អែតមិនអាចនឹងចង់បរិភោគចំណីដដែល ឬចំណីផ្សេងនោះទៀ
ចំពោះបតិបែបនេះ ឃើញថាសមហេតុផលដែរ ប៉ុន្តែបើយើ
ទឹកចិត្តមនុស្សមកថ្លឹងមើល ឃើញថាមានលក្ខណៈផ្ទុយគ្នា ដ្បិត
បរិភោគចំណីអាហារឆ្អែត និងការចង់ធំខ្ពស់ ចង់សុខសប្បាយ 
លក្ខណៈផ្ទុយគ្នា ។ ចំណង់ក្នុងការចង់បានទ្រព្យ បុណ្
នេះមិនមានទីបំផុត, មិនចេះឆ្អែតឆ្អល់សោះឡើយ ។

ចំពោះរឿងនេះ បើយើងបែរមកពិនិត្យផ្ទៃអត្ថរូបក្នុងកណ្ឌ
វេសន៍វិញ យើងនឹងឃើញដូចតទៅនេះ គឺ :

១-- ពួកចេតរាស្ត្រ កាលបានឃើញ បានជួបព្រះវេស្សន្តរហើ
ក្រោយពេលដែលព្រះវេស្សន្តរ បានថ្លែងប្រាប់រឿងរ៉ាវដោយសព្វ
ទាំងរស់អង្គក៏កើតព្រះទ័យសង្វេគ ពិករអាណិតព្រះវេស្សន្តរណា
ហើយបានស្រុះស្រួលគ្នាសុំអញ្ជើញព្រះអង្គថា « . . . . . ស្
អញ្ជើញព្រះអង្គសោយរាជ្យ ស្ថិតនៅជាឥ
កំពូលនៃយើងខ្ញុំនៅនានគរនេះហោង ។ .
បពិត្រព្រះសម្មតិទេព មហាក្សត្របរសើរអ

សូមធានអម្ចាស់សោយរាជ្យនៅនគរយើងខ្ញុំនេះ ក៏យើងខ្ញុំទាំង ៦ ម៉ឺននេះ នឹងទៅទូលព្រះបាទស្រីសញ្ជ័យ ប្រាប់អ្នកស្រីពិរាស្ត្រផងទាំងឡាយឲ្យគេអត់ទោសព្រះអង្គ ។ បពិត្រមហារាជអើយ រីអស់អ្នកស្រីពិរាស្ត្រនោះ កាលបើគេដឹងថា ព្រះបាទស្រីសញ្ជ័យអត់ទោសព្រះអង្គហើយ អ្នកស្រីពិរាស្ត្រ ក៏នឹងមកចោមរោមបំរើជាបរិវារព្រះអង្គនោះច្រើនក្តាត់ហោង ។

ព្រះវេស្សន្តរពុំបានយល់ស្របនឹងពាក្យទាំងនោះឡើយ ហើយព្រះអង្គក៏មានបន្ទូលតបទៅវិញថា "... យើងនឹងសំដែងថ្លែងប្រាប់ថា បើយើងបានទទួលសោយរាជសម្បត្តិនៅនានគរនេះហើយ រីដំនៀល ២ ប្រការនឹងកើតមានប្រាកដ គឺអ្នកស្រីពិរាស្ត្រគេនឹងត្មះតិះដៀលយើងថា ឱព្រះវេស្សន្តរអើយ សោយរាជសម្បត្តិមិនឋិតនៅដោយគន្លងធម៌ ... ហើយប្រការមួយទៀត ឥឡូវនេះមកយល់តែគេឃាត់ឲ្យសោយរាជ្យផ្ទៀងក្ញុំ ក៏សោយរាជ្យព្រងើយ .... រីព្រះបាទស្រីសញ្ជ័យ ព្រះ

អង្គជាស្តេចធំ ឧត្តមប្រសើរកន្លងរំលងអស់រាស្ត្រប្រជាផងទាំងឡា
ពិត. គឺមោះអស់អ្នកស្រីពិរាស្ត្រផងទាំងឡាយ គេខឹងហើយគេ
នូវអស់នាយដំរី. នាយសេះ, នាយរថៈ នាយពលក្រោលំនោ
ផងទាំងឡាយ គេនឹងសម្លាប់ព្រះអង្គត្បិតតែយើងនេះឯង . . .
ព័រ ១៨៣ – ១៨៤ ។

ផ្តែអត្ថរូបខាងលើនេះ បានបញ្ជាក់ឲ្យឃើញច្បាស់ថា
ក្សត្រចេតរាស្ត្របានសុំអញ្ជើញឲ្យសោយរាជ្យ ដោយពេញព្រះទ័យ
ថែមទាំងសុំធានាថា នឹងជួយធ្វើអន្តរាគមន៍ កុំឲ្យពួកស្រីពិរាស្ត្រខឹ
ប៉ុន្តែព្រះវេស្សន្តរប្រកែកពុំព្រម ព្រោះខ្លាចមានពាក្យជំនៀលនេះ
ម្យ៉ាងទៀតខ្លាចពួកស្រីពិរាស្ត្រធ្វើទុក្ខទោសដល់ព្រះបាទស្រីសញ្ជ័យ
តាឯព្រះឆត ។

២– ពួកចេតរាស្ត្របានអង្វរទៅទៀតដោយពាក្យថា ‘ បពិត្រ
អង្គតែងព្រងើយធ្វើនូវសេចក្តីចំរើនដល់អ្នកស្រីពិរាស្ត្រអើយ បើមានហេតុ
ឡើងក្នុងដែននោះក្តី សូមឲ្យព្រះអង្គគ្រងរាជ្យក្នុងនគរនៃយើងខ្ញុំនេះ
មានស្តេចចេតរាស្ត្រទាំងឡាយ ចោមរោមជារាជបរិវារ . ។
ព្រះវេស្សន្តរក៏នៅតែមិនព្រម ហើយមានព្រះឱង្ការតប

វិញថា « ហៃមហាមិត្រអើយ បើយើងសោយរាជ្យនៅនគរនេះហើយ សមអ្នកស្រីពិរាស្ត្រផងទាំងឡាយ គេនឹងបរពលសកលយោធាសេនា-មាត្យ បើកទ័ពចីរដេរដាសពាសពេញទាំងក្រឡាមហាប្រឹថពី ខ្មីឃ្មាត សង្គ្រាគបកចោមរោម មាតុលនគរនេះប្រាកដមិនទេឡើយ ។ ហៃសម្លាញ់អើយ ម្លោះហើយ ក៏វានឹងកើតជាកោលាហលអំពល់នូវចម្បាំងរាំងជល ប្រកាប់ប្រចាក់គ្នា រីអស់មនុស្សម្នា មហាជនផងទាំងឡាយនោះ សឹងស្លាប់ច្រើនពុំខានឡើយ . . . . » ទំព័រ ១៨៦ ។

សេចក្ដីបញ្ជាក់ខាងលើនេះ បានចង្អុលប្រាប់យើងថា ពួកក្សត្រចេតរាស្ត្រ មានភក្ដីភាពចំពោះព្រះវេស្សន្តរមែន ប៉ុន្តែព្រះវេស្សន្តរមិនព្រមទទួលនេះ ព្រោះទ្រង់យល់ឃើញថា នឹងកើតហេតុផុលរមាស់រាងអ្នកមាតុលនគរ និងពួកស្រីពិរាស្ត្រ ព្រោះតែរឿងព្រះអង្គទម្លូលរាជសម្បត្តិនៅទីនោះ ។

រូបសេចក្ដីទាំងអស់មក រាជសម្បត្តិនៅមាតុលនគរ ដែលពួកក្សត្រចេតរាស្ត្រចំនួន ៦ ម៉ឺនបានអញ្ជើញនោះ ពុំមែនជាគោលដៅ ជាចំណុចធំរបស់ព្រះអង្គឡើយ ឯគោលដៅដ៏ធំរបស់ព្រះអង្គ គឺការយាងទៅគង់នៅភ្នំ គិរីវង្កត ដើម្បីសាងបារមីមួយទៀត គឺទេក្ខម្មបារមីនោះ

ឯង ។ គោលដៅនេះមិនអាចបានរឿមួយមកការាំងបានទៀយ ហើយ
ដើម្បីឲ្យបានស្គាល់ច្បាស់ថា គេពីរិតនៅក្នុងព្រៃភ្នំគិរីវង្កតនោះ មា
សភាពយ៉ាងណា នោះព្រះអង្គត្រូវលះបង់នូវសុខុមាលភាព ដែលព្រះអ
ធ្លាប់ជួបប្រទះរួចហើយពីមុននោះឲ្យស្រឡះចេញ ដើម្បីធ្វើការពិសោធ
ដោយព្រះអង្គឯង ឲ្យពិតតែច្បាស់ទៅទៀត ។

រាជសម្បត្តិ និងប្រាថ្នាសម្មាសម្ពោធិញ្ញាណ មានផលនិងមាន
សេចក្ដីសុខផ្សេងគ្នា ។

មនុស្សទូទៅ ប្រាថ្នារាជសម្បត្តិយ៉ាងណា. ព្រះវេស្សន្តរ
ព្រាថ្នាកប្រាថ្នាសម្ពោធិញ្ញាណលើសនោះ រាប់លានកោដិផងទៅ
ទៀត ។

# កណ្ឌជូជក

## ប្រធាន

តាជូជក ជាតួអង្គមួយដ៏សំខាន់ ក្នុងមហាវេស្សន្តរជាតក ។ ចូរលើកនូវតួអង្គនេះ មកធ្វើការសិក្សា បញ្ជាក់តាម លក្ខណៈអក្សរសិល្ប៍។

## អត្ថាធិប្បាយ

ក្រោយពេលដែលព្រះវេស្សន្តរច្រង់យាង ចេញទៅគង់នៅគិរិវង្កតដើម្បីសាងផ្នួសជាតាបសឬសីបាត់ទៅ អ្នកនិពន្ធបានលើកយកតួអង្គមួយថ្មីទៀត មកធ្វើការពណ៌នាជាឧបកថាក្នុងកណ្ឌទី ៥ ហៅថា ជូជកកណ្ឌ ។ រឿងតាជូជកនេះហាក់ដូចជារឿងកំប្លែងមួយដាច់ដោយឡែកពីសាច់រឿងធំ ប៉ុន្តែកាលយើងធ្វើការពិនិត្យ ពិចារណាឲ្យហ្មត់ចត់ទៅ រឿងនេះមានសារសំខាន់ណាស់ ដែលយើងនឹងធ្វើការសិក្សា

ដូចតទៅ :

រឿងតាជូជក មិនមែនជារឿងដាច់ចេញពីរឿងព្រះវេស្សន្តរនិងរឿងក្នុងសង្គមមនុស្សនេះឡើយ ហើយតាជូជកជាតួអង្គមួយដ៏សំខាន់សម្រាប់សិក្សាពិចារណាទៅក្នុងមហាវេស្សន្តរជាតកនេះ ។ ជាដំបូងអ្នកនិពន្ធបានពណ៌នាអំពីតួអង្គ និងជីវភាពតាជូជកដោយច្បាស់លាស់ថា តាជូជកជាមនុស្សមានរូបអាក្រក់ . . . " ឯកោ ព្រាហ្មណោ មានព្រាហ្មណ៍ម្នាក់ឈ្មោះ ជូជកព្រឹទ្ធាចារ្យ រូបអន្ធការ . . . ធ្មេញស ក្បាលវែងតូចម្ខាងដូចផ្លែព្នៅ " ហើយតាជូជកមានជីវភាពជាអ្នកសុំទាន . . . គាត់តែងនឹងដើរសូមទានគេ ថាបើពុំបានឯស្រុក គាត់ទៅឯវត្តអ្នកយើង . . . ក្រែងជួបប្រទះនឹងសត្រូវវាប្លន់យក " ។

លក្ខណៈនៃការពណ៌នានេះបាននាំឲ្យយើងឃើញនូវលក្ខណៈ ២ យ៉ាងគឺ ម៉្យាងតាជូជកជាតួអង្គកំប្លែង មានរូបរាងកាយប្លែក គឺធម្មជាតិបានតាក់តែងមកឲ្យប្លែកពីមនុស្សឯទៀត ។ ម៉្យាងទៀតរូបរាងតាជូជក ជារូបគួរឲ្យសង្វេគអាណិត ។

តាជូជក ជាមនុស្ស ឯកោអនាថា គ្មានទីពឹងពំនាក់ ព្រោះគ្មានសាច់ញាតិបងប្អូនឡើយ ហើយគាត់ដើរសុំទានគេបានមកក៏លក់

បានជាមាសប្រាក់ ហើយយកទៅផ្ញើនឹងព្រាហ្មណ៍ប្ដីប្រពន្ធជាសំ–
ឡាញ់នឹងគាត់ ។ ក្នុងការទាក់ទងនឹងសំឡាញ់នេះ តាផ្លូជកក៏
ននាំងអមិត្តតាបឆាជាកូនក្រមុំព្រាហ្មណ៍ មកធ្វើជាភរិយាសំឡាញ់ចិត្ត ។
លដែលតាផ្លូជកជាមនុស្សមានវ័យចាស់ជរា ហើយមានទាំងរូបអា
ក់ប្លែក គ្មានអ្វីមួយដែលមានរសជាតិសោះនោះ ហើយបានភរិយា
លមានរូបល្អ នៅកំពុងពេញវ័យក្រមុំយកមកធ្វើជាភរិយានេះ បាននាំ
អ្នកអានមានចិត្តប្លែកខ្លាំងណាស់ទៅទៀត ខ្លះនឹកស្ញើចនឹងគាត់ថា
ចាស់ពូកែ បានបង្សោបាយចេះរកប្រពន្ធបានវ័យក្មេង ប៉ុន្តែខ្លះនឹក
ប់ខឹង ហើយថែមទាំងនឹកសង្វេគចំពោះតាផ្លូជកទៅវិញ ដោយខ្លួន
ស់ជរាណាស់ទៅហើយ ៗ បានប្រពន្ធក្មេង ដែលជាវ័យផ្ទុយគ្នាស្រ
ះដូចមេឃនិងដី ។

ផ្ទុយទៅវិញ ទោះជារូបគាត់ចាស់ជរាប៉ុណ្ណោះក៏ដោយ ក៏តា
ជកជាមនុស្សមានប្រាជ្ញាឆ្លាតវាងវៃ ប៉ិនប្រសប់ក្នុងការនិយាយបញ្ចុះ
ញ្ចូលដោះសាដែរ ដូចជា :

– ពេលព្រាហ្មណ៍ប្ដីប្រពន្ធ ជាសំឡាញ់បានចាយវាយទ្រព្យរបស់
ត់អស់ តាផ្លូជកចេះរកចំណុចខ្សោយមកនិយាយសំឡុតគំរាមព្រាហ្មណ៍
ប្រពន្ធថា ៈ« គាត់នឹងប្ដឹងទៅក្រុមតុលាការ ហើយគាត់មានស្គាល់

ទៅក្រុមសាលាជាបក្សពួករបស់គាត់ ។ នឹងឲ្យគេចាប់ដាក់គុកខ្នោះឃ្នា
ឲ្យភ្នាក់ងារទាហានចាប់ចងវាយដំបែកឈាម . . ។

–ពេលដែលចេតបុត្របានសំឡុតគំរាមបំរុងនឹងបាញ់សម្លាប់គាត់ត
ជូជកបានកុហកចេតបុត្រថា ខ្ញុំជារាជគ្រូក្នុងព្រះរាជវាំងជេតុត្តរ ហើយ
ត្រូវព្រះបាទស្រីសញ្ជ័យបញ្ជូនបកក្នុងឋានៈជារាជទូត ដើម្បីសួរសុខទុ
ព្រមទាំងសុំអញ្ជើញព្រះវេស្សន្តរឲ្យទៅសោយរាជសម្បត្តិផង ។

– កាលបានជួបព្រះវេស្សន្តរហើយ តាជូជក, មុនក៏អង្វសុំយ
ជាលីក្រស្នាពីព្រះវេស្សន្តរ, ក៏និយាយសួរសុខទុក្ខ ថែមទាំងនិយា
សរសើរលើកជើងព្រះវេស្សន្តរយ៉ាងច្រើន ដើម្បីជាគ្រៀងបន្ទន់ចិត្តព្រ
វេស្សន្តរ ហើយទើបសុំជាលីក្រស្នាជាខាងក្រោយ ។

ដូច្នេះ តួអង្គជូជកនៅក្នុងកណ្ឌនេះមានលក្ខណៈសំខាន់ច្រើ
បែបយ៉ាងពកាស់ គឺ :

១– តួអង្គតាជូជកដែលលេចចេញឡើងនៅក្នុងកណ្ឌនេះ ជាកិច្ច
ដ៏សំខាន់ ដើម្បីជួយបន្ធូរបរិយាកាសដែលកំពុងតុកពេញក្នុងដើមទ្រូង
អ្នកអានទស្សនារឿងព្រះវេស្សន្តរ ក្នុងខណៈដែលព្រះវេស្សន្តរចេញទ
គង់នៅក្នុងព្រៃស្ងាត់បាត់ស្ងាត់ស្ងៀមទៅ ។ កណ្ឌទាំងប៉ុន្មានខាងដើម គ្មា
រឿងណាគួរឲ្យអ្នកអានទស្សនារីករាយចិត្ត–សើច–សប្បាយ គឺមា

តែរឿងដែលនាំឲ្យអស្ចារ្យក្នុងចិត្ត និងរឿងនៃការទុក្ខព្រួយ ដ៏ផ្ទុយបដិបក្ខ រវាងព្រះវេស្សន្តរនិងពួកស្រីពិរាស្ត្រឥតមានធូរស្រាលសោះ ប៉ុន្តែចេះតែមានសភាពតឹងឡើង ។ រហូតទល់ព្រះវេស្សន្តរឃ្លាតចេញទៅគង់ក្នុងព្រៃភ្នំបាត់ ។ ការព្រាត់ប្រាស មានទុក្ខវេទនានេះហើយ ដែលនាំឲ្យអ្នកដឹងរឿងព្រះវេស្សន្តរ កើតការចង្អៀតចង្អល់ចិត្តខ្លាំងណាស់ ប៉ុន្តែកាលបានឃើញដឹង ឮរឿងជូជកនេះឡើង ក៏ភ្លេចរឿងចាស់ចោលអស់ មកចាប់ចិត្ត ចាប់អារម្មណ៍តែលើរឿងថ្មីនេះទៅវិញ ។

២– តាជូជកជាស្ពានចម្លងអ្នកអាន ទស្សនា ឲ្យបានឃើញព្រះវេស្សន្តរដែលគង់នៅក្នុងព្រៃស្ងាត់ ជាមួយមហេសីនិងបុត្រីបុត្រាថា តើព្រះអង្គមានជីវភាពយ៉ាងណានៅក្នុងទីនោះ ព្រោះអីកាលណាតាជូជកចូលទៅរកសុំជាលីក្រស្នាពីព្រះវេស្សន្តរ យើងក៏នឹងបានឃើញព្រះវេ–ស្សន្តរក្នុងពេលនោះឯង ។

៣– អ្នកនិពន្ធបានលើកយកអង្គតាជូជក មកឲ្យធ្វើការទាក់ទងជាមួយព្រះវេស្សន្តរ ក៏ដើម្បីនឹងបង្ហាញឲ្យរឹតតែឃើញយ៉ាងជាក់ច្បាស់ ថាព្រះវេស្សន្តរជាមហាបុរស ដែលមានទឹកព្រះទ័យទូលាយណាស់ក្នុងការឲ្យទានកុំថាតែរាជទ្រព្យក្រៅខ្លួន សូម្បីតែព្រះរាជបុត្រាបុត្រីដែលកើតចេញពីសាច់ ក៏ព្រះអង្គហ៊ានលើកឲ្យជាទានដែរ ។

៤– តាជូជក ជាតួអង្គមួយដ៏សំខាន់ណាស់ទៅទៀតក្នុងការជួយបំ-

ពេញទានបារមីរបស់ព្រះវេស្សន្តរឲ្យរិតតែពេញលេញឡើង បានសេច
ថា បើគ្មានតួអង្គតាជូជក ក៏គ្មានអ្នកណាទៅសុំជាលីក្រស្នាពីព្រះវេស្ស
ដែរ ហើយព្រះវេស្សន្តរ ក៏មិនបានធ្វើបុត្តបរិច្ចាគតាមព្រះបំណងឡើយ

រឿងទាំងប៉ុន្មានខាងលើនេះហើយ បានជាអ្នកនិពន្ធបានលើ
យកតួអង្គតាជូជក មកដាក់ក្នុងកណ្ឌ ១ តែឯង ហើយក្នុងកណ្ឌត
ទៅទៀត យើងក៏ឃើញតាជូជក បានធ្វើសកម្មភាពទាក់ទងនឹងព្រះវេស្ស
កាន់តែជិតដិតឡើង ៗ ។

ដូច្នេះ រឿងតាជូជក ជារឿង ១ ដ៏សំខាន់ ជាតួអង្គ ១ដែល
មានសកម្មសកម្មរស់រវើក ថែមទាំងមានលក្ខណៈ ជាលោកិយសច្ចៈថែ
ទៀត ព្រោះអ្នកនិពន្ធចេះពណ៌នាតួអង្គនេះឲ្យបានក្បោះក្បាយច្បាស់
ណាស់ ទាំងរូបរាង, ជីវភាព, ទឹកចិត្ត និងសកម្មភាពនានា ពោ
គឺអ្នកនិពន្ធបានលើកយកតួអង្គ ១ ដែលអាក្រក់អន់ថយ មកពណ៌នា
បានល្អពីរោះស្តាប់ នាំឲ្យមានសំណើច និងកំសត់បាត ។ ផ្ទុយរឿ
ព្រះវេស្សន្តរ បើគ្មានតាជូជកនេះទេ រឿងនេះនឹងទៅជាមានលក្ខណ
សោះកក្រោះឥតរសជាតិ, ឥតខ្លឹមសារ ហើយថែមទាំងធ្វើឲ្យអ្នកអា
លែងចូលចិត្តចង់មើល ចង់ស្តាប់តទៅទៀតឡើយ ។ តាជូជ
នេះជាកត្តានៃទានបារមីរបស់ព្រះវេស្សន្តរផង, ជាបុព្វហេតុដែលនាំ
ព្រះវេស្សន្តរបានយាងចូលមកកាន់ព្រះនគរជួបជុំព្រះញាតិវង្សផង ។

# ប្រធាន

មរណភាពនៃតាជូជកក្នុងមហាវេស្សន្តរជាតក មិនគ្រាន់តែបង្ហាញនូវទ្រឹស្តីកម្មផលប៉ុណ្ណោះទេ តែជាការបញ្ជាក់នូវតថភាពក្នុងសង្គមមនុស្សឲ្យកាន់តែច្បាស់ទៀតផង ។

តើអ្នកមានយោបល់យ៉ាងណាចំពោះបញ្ហានេះ ។

## អត្ថាធិប្បាយ

តួអង្គតាជូជក បានជួយរចនាមហាវេស្សន្តរជាតកឲ្យរិតតែល្អឡើង
មួយកំរិតយ៉ាងធំ ហើយនៅក្នុងមហារាជបព្វ តាជូជកក៏បានធ្វើមរណ-
ភាពព្រោះអាហារទៅ ។ មរណភាពនៃតាជូជកនេះ រិតតែធ្វើឲ្យ
មហាវេស្សន្តរជាតកមានលំអ, មានតម្លៃខ្លាំងណាស់ទៅទៀត ។

**នៅក្នុងកណ្ឌទី ៥ យើងបានឃើញហើយថា តាជូជកជ**
**តួអង្គមានរូបរាងអាក្រក់** មានគំនិតវាងវៃ ឆ្លាតដោះខ្លួនឲ្យបានរួចម្ដង
ផងមួយគ្រាដែរ តែយើងពុំទាន់ស្គាល់ចិត្តគំនិតរបស់គាត់ថាល្អ ឬ អា
ក្រក់នៅឡើយ លុះដល់កាន់ទី ៨ គឺកុមារបព្វ ទើបយើងឃើញហើយ
ដឹងថា តាជូជក មិនមែនត្រឹមតែមានរូបអាក្រក់ប៉ុណ្ណោះទេ ប៉ុន្តែថែ
ទាំងមានចិត្តអាក្រក់ កាចព្រហើនទៀតផង ។ ពេលដែលតា
ព្រាហ្មណ៍ព្រឹទ្ធនេះបានជួបនឹងព្រះវេស្សន្តរ ហើយបាននិយាយបន្ទន់ព្រ
ទ័យព្រះវេស្សន្តរដើម្បីសុំបុត្រាបុត្រីរួច ព្រះវេស្សន្តរគ្រាន់តែមានព្រ
បន្ទូលថា សុំឲ្យរង់ចាំនាងមទ្រីត្រឡប់មកពីបេះផ្លែឈើវិញ ក៏តាជូជ
មិនព្រមដែរ តែត្រង់នេះគឺជាការឆ្លាតវាងវៃរបស់គាត់ទេ ។ លុ
ដល់ព្រះវេស្សន្តរព្រមប្រទានហើយ តាជូជក ក៏ចាប់ដាលិក្រស្នាចងដៃ
ទាំងពីរនឹងវល្លិ រួចវាយដំនៅចំពោះព្រះភក្ត្រព្រះវេស្សន្តរ រហូតទល់ហូ
ឈាមពោរពងពេញព្រះកាយ ហើយកាលកុមារទាំងពីររត់គេចខ្លួនរួច តា
ជូជកត្រឡប់មករកឯសំណាក់ព្រះវេស្សន្តរវិញ លុះព្រះវេស្សន្តរមាន
ព្រះបន្ទូលថា មិនបានឃើញទេ តាជូជកក៏ពោលត្មះតិះដៀលព្រះអង្គថា
ចេះកុហកភូតភរ ។

នៅតាមផ្លូវក្នុងព្រៃ តាព្រាហ្មណ៍នាំបណ្ដើរកុមារទាំងពីរដើ

គាត់កំដៅថ្ងៃ គ្រួសខ្សាច់ រហូតទល់ឡើងខ្ទុះពោរពងព្រះបាទទាំងពីរហើយ ក៏នៅតែបណ្ដើរឥតឈប់ឈរ រហូតទល់ពេលឈប់សំរាក តាជូជក ក៏យកកុមារទាំងពីរទៅចងក្រៀកនឹងដើមឈើ ហើយគាត់ឡើងដេកបរិ-ភោគអាហារលើចុងឈើធ្វើព្រងើយ ។ លក្ខណៈទាំងប៉ុន្មាននេះហើយ ដែលបង្ហាញថា តាជូជកជាមនុស្សចាស់ចិត្តអាក្រក់ គ្មានមេត្តាករុណា ចំពោះក្មេងតូច ៗ បន្តិចសោះ ឬមួយដោយគាត់ជាមនុស្សទោល ពុំធ្លាប់ដែលមានកូនមានចៅ ?

តួអង្គតាជូជកនៅក្នុងកណ្ឌនេះ បានប្រែលក្ខណៈពីសភាពកំ-ប្លុកកំប្លែងដែលគួរឲ្យចង់សើច មកជាសភាពអាក្រក់ ដំណាងសភាវៈអាក្រក់ថោកជាតិ គួរឲ្យស្អប់ខ្ពើម ហើយធ្វើឲ្យអ្នកអានទស្សនា កើតចិត្តធុញទ្រាញ់ តឹងទ្រូងចង្អៀតចង្អល់ចិត្តទៅវិញ ។

ប៉ុន្តែលុះដល់មហារាជបព្វ គឺកណ្ឌ ទី ១០ យើងបានឃើញថា តាជូជកត្រូវបានរង្វាន់មួយយ៉ាងធំ អំពីព្រះបាទស្រីសញ្ជ័យ ជារាជអយ្យ-កោជាលីក្រស្នា ក្នុងការលោះយករាជនត្តាទាំងពីរនេះ ។ បន្ទាប់ពីបាន ទទួលរាជរង្វាន់មក តាជូជកអរសប្បាយណាស់ ហើយដោយសេចក្ដី ស្រេកឃ្លានគ្របសង្កត់ខ្លាំងពេក តាជូជកក៏បរិភោគអាហារទាល់តែបែក ពោះស្លាប់ ។ ត្រង់ចំណុចនេះហើយ ដែលនាំឲ្យអ្នកអានទស្សនាបាន

ធ្វើក្នុងដើមទ្រូងមួយខណៈយ៉ាងធំ ដោយបានឃើញថា ផាលីក្រស្នាបាន
រួចពីទុក្ខទោស ហើយតាផូជកជាចាស់កំណាចត្រូវស្លាប់អន្តរាយជីវិត ។

មរណភាពនៃតាផូជកនេះ គឺជាការសងចិត្តនៃអ្នកអានមួយ
ខណៈយ៉ាងធំ ព្រោះអីម្នាក់ ៗ សុទ្ធតែផ្តោតចិត្តអាណិតផាលីក្រស្នាដែល
ត្រូវតាផូជកធ្វើបាបនោះខ្លាំងណាស់ ពរុះអ្នកធ្វើបាបគេបានទទួលរងទុក្ខ
រហូតទល់ស្លាប់នេះ អ្នកអាណិតក៏ធូរសប្បាយជាអនេក ។ រីឯតាផូជក
ដែលស្លាប់នេះសោតទៀត បើតាមទ្រឹស្តីកម្មផលថា គាត់ត្រូវតែស្លាប់
ដោយអធម្មកម្ម ឲ្យសមហើយស្របទៅតាមអំពើដែលខ្លួនបានធ្វើអាក្រក់
ដោយការប្រទូស្តសាហាវយចំពោះអ្នកដែលមិនប្រទូស្តតប មានព្រះវេស្សន្តរ
ផាលីក្រស្នាជាដើម ។

ផ្ទុយទៅវិញ អ្នកខ្លះយល់ថា មរណភាពនេះ មិនគ្រាន់តែ
បញ្ជាក់ឲ្យឃើញច្បាស់នូវបញ្ហាកម្មផលដែលថែងថា អ្នកធ្វើអាក្រក់ ត្រូវ
ទទួលផលអាក្រក់ អ្នកប្រទូស្តធ្វើបាបចំពោះអ្នកមិនប្រទូស្ត ត្រូវបានផល
អាក្រក់មកវិញ ដូចការបាចអង្កាមប្រាសខ្យល់តែប៉ុណ្ណោះទេ ប៉ុន្តែជា
លក្ខណៈពិសេសម្យ៉ាងដែលបញ្ជាក់នូវតថភាព គឺសភាពពិតជាក់ស្តែង
នៅក្នុងសង្គមមនុស្ស ឲ្យរិតតែច្បាស់ឡើងថែមទៀត ។ តើតថភាព
នេះគឺអ្វី ?

តាមទ្រឹស្តីកម្មផល ដែលយើងធ្លាប់ជឿ ធ្លាប់ឲ្យតម្លៃនោះ មរណភាពរបស់ តាជូជកនេះ ជាការសមហេតុផលណាស់ហើយ ប៉ុន្តែលក្ខណៈម៉្យាងទៀតដែលយើងរិតតែឃើញជាក់ស្តែង គឺការបរិភោគចំ-ណីអាហារនេះ ។ អាហារជាថ្នាំសម្រាប់តែរោគឃ្លានឲ្យបានស្រាកស្រាន្តឬយពេលមួយខណៈប៉ុណ្ណោះ ប៉ុន្តែអាហារនេះ ក៏ជាថ្នាំពិសពុលមួយដ៏អាក្រក់ណាស់ អាចសម្លាប់អ្នកបរិភោគខុសពេលវេលា ឬហួសកំរិត ហួសចំណុះពោះបានដែរ ។ តាជូជកដែលអត់អាហារយូរហើយ ( ១៥ ថ្ងៃ ) នោះ កាលបានចំណីអាហារឆ្ងាញ់ត្រូវមាត់ត្រូវនឹងតំលានក្រពះនោះ ក៏ចេះតែបរិភោគរហូតទល់ហួសចំណុះពោះគាត់ ហើយក៏ត្រូវបែកពោះស្លាប់ភ្លាម ។ នេះក៏ចាត់ថាជាផលម៉្យាងដែរ គឺផលអាក្រក់ដោយការបរិភោគហួសកំរិត ហួសចំណុះពោះនេះឯង ។ តថភាពម៉្យាងទៀត គឺមានលក្ខណៈទៅក្នុងអក្សរសិល្ប៍ ព្រោះបើតាជូជកមិនស្លាប់ក្នុងពេលនេះ ឬពេលណាមួយនោះទេ អ្នកអានទស្សនាក៏រិតតែតឹងចិត្តឡើង ៗ , រាជទ្រព្យដែលព្រះបាទស្រីសញ្ជ័យត្រូវចំណាយ ដែលគិតជាមាសមានប្រមាណ ២ ពាន់តម្លឹងក្នុងការលោះយកជាលីក្រស្នានោះ នឹងត្រូវខូចប្រយោជន៍ជាច្រើន ព្រោះ

ត្រូវបានទៅតាជូជកយកទៅប្រើប្រាស់ជាទ្រព្យផ្ទាល់ខ្លួនតែម្នាក់ឯង ។

ដូច្នេះ មរណភាពរបស់តាជូជក គឺជាតម្លៃមួយដ៏សំខាន់ក្នុ-
មហាវេស្សន្តរជាតក បើតាជូជក មិនស្លាប់ទេ មហាវេស្សន្តរជាត
នឹងទៅជារឿងសោកស្រោះឥតតម្លៃ ឥតខ្លឹមសារសោះឡើយ ហើ
តួអង្គអាក្រក់ចេះតែមានឥទ្ធិពលខ្លាំងឡើង នៅគ្រប់ចលនារឿងខ្មែរទា
ជាពិសេស គឺរឿងជាបែបពុទ្ធនិយមនេះឯង ។

## មរណភាពនៅក្នុងអក្សរសិល្ប៍ខ្មែរ

១– ស្លាប់ដោយផលកម្ម = បែបពុទ្ធនិយម

២– ស្លាប់ដោយសង្គ្រាម = រាមកេរ្តិ៍, ជិនវង្ស

៣– ស្លាប់ដោយបច្ចុប្បន្នកម្ម ឬ សង្គមបរិយាកាស =
កាកី, ទុំទាវ ។

## កណ្ឌច្ចទ្បពន–មហាពន

# ប្រធាន

ចូរលើកនូវការពណ៌នាអំពីធម្មជាតិក្នុងកណ្ឌច្ចទ្បពន និងកណ្ឌមហាពនមកធ្វើការសិក្សាបញ្ជាក់ ។

## អត្ថាធិប្បាយ

នៅតាមផ្លូវក្នុងព្រៃដែលតាជូជកធ្វើដំណើរទៅរកព្រះវេស្សន្តរ នៅគិរីវង្កត យើងបានឃើញធម្មជាតិជាច្រើនអនេក នៅត្រៀបត្រាដែលពណ៌នាដោយចេតបុត្រនិងអច្ចុតមហាឫសី ដើម្បីប្រាប់ដល់តាជូជក ។

ក្នុងអក្សរសិល្ប៍ខ្មែរ ភាគច្រើនគឺរឿងប្រលោមបុរាណ ឬរឿងពុទ្ធនិយមបែបខ្មែរ កវីនិពន្ធពុំដែលបោះបង់ចោលនូវការពណ៌នាធម្ម-

ជាតិនេះឡើយ ឯក្នុងមហាវេស្សន្តរជាតក នៅស្ទើរតែគ្រប់កណ្ឌទាំងអស់
អ្នកនិពន្ធបានលើកយកបញ្ហាធម្មជាតិនេះមកពណ៌នាយ៉ាងច្រើន ជាពិ–
សេសនៅក្នុងកណ្ឌចូឡពន ( ព្រៃតូច ) និងកណ្ឌមហាពន ( ព្រៃធំ ) កា
ពិពណ៌នាអំពីធម្មជាតិនេះ បានលេចចេញឡើងដោយច្បាស់លាស
ហើយសព្វគ្រប់ផង ព្រោះធម្មជាតិណាក៏យើងឃើញមាននៅក្នុងកណ្ឌ
ទាំងពីរនេះដែរ ចាប់តាំងពីសត្វតូចព្រៃរបោះរបោយរហូតទល់សត្វធំព្រៃ
ស្រោងស្រងាត់ ។ ធម្មជាតិក្នុងកណ្ឌទាំងពីរ ចាប់ពីទំព័រ ២៦០ រហូ
ទៅមានច្រើនណាស់ ហើយបើសង្ខេបមក យើងអាចចែកជាផ្នែកនៃ
ធម្មជាតិទាំងនោះដូចតទៅនេះ

**ក) ផ្នែករុក្ខជាតិ** — កវីបានពណ៌នាអំពីឈើក្នុងព្រៃមាន
ច្រើនពួក ច្រើនផ្នែក ដូចជា ‥ ត្របែក ត្រសេក ស្ដី ស្ដង់ ...
គគីរ ឆាំឆា គុយ គ ឧទុម្ពរ ... ក្ដាំងងា ចំបា ចំប៉ុ ...
មង្ឃុត ល្មុត សេដា ពុទ្រា ធ្នា ធ្នុង ដងអង្កាល់ អំពិល ទ្រមូង ក្រ
ញូង ក្រឡាញ់ ព្រហូត ស្ដី ស្ដោ តាត្រាវ ពេបីទាល ព–
ពាលខែ ។ ល ។

**អ្នកនិពន្ធ បានពណ៌នាអំពីរុក្ខជាតិនេះដោយមានបច្ចេកទេស**

ដ៏សំខាន់ម៉្យាងទៀត គឺធម្មជាតិទាំងអស់សុទ្ធតែមានលក្ខណៈជាខ្មែរ ហើយដែលខ្មែរយើងធ្លាប់ជួបប្រទះ ធ្លាប់ស្គាល់នៅនឹងស្រុកខ្មែរ ព្រមទាំងការពណ៌នានោះរៀបរាប់ទៅតាមគួអក្សររៀង ៗ គ្នា ហើយឈើនេះមានពួក បានក្រុមផ្សេងទៀត ដូចជា :

– ឈើមានផ្កាក្រអូប : ក្រវាន់, ចំប៉ី ចំប៉ា ក្តាំងភា, ក្រស្នា ។ ល ។

– ឈើមានខ្លឹម ឬ ស្លឹកដូចជាចន្ទន៍ ទ្ធនស្រី, មាលតី, ដីប្លិ, លំពាន់, កាំញាក់ កាំញា, មនង្គសិលា ។ ល ។

– ឈើមានផ្លែជាអាហារ ដូចជា ក្រសាំង, ពង្រ, គូលែន, សិរមាន់, គុយ, ស្រគុំ, ពិល, ព្នៅ, ស្វាយ ។ ល ។

– ឈើមានខ្លឹមសម្រាប់ប្រើការផាប់ ។ ដូចជា កកោះ, គគីរ, សុក្រំ, ថ្លឹក, ឈើទាល, ខ្ទង, ត្បែង, នាងនួន, បេង, ស្រឡៅ ។ ល ។

ផងទៃពីនេះ មានឈើ និងវល្លិជាបរិវារឯទៀត ដែលមានប្រយោជន៍សម្រាប់ធ្វើថ្នាំផ្សេងយ៉ាងច្រើនអនេក ។

**ខ) ផ្នែកខារីជាតិ** – ធម្មជាតិផ្នែកនេះ បានដល់ស្មៅ ឬវត្ថុដែលដុះនៅក្នុងទឹក ដូចជា ឈូកស ឈូកច្រាល, ឈូកក្រហម,

កុបុទ, ឧប្បល, លំចង់, ស្បង្កីជ, ព្រលិត, ស្លន់, កំពីងពួយ

**គ) ផ្នែកមច្ឆាជាតិ** – ធម្មជាតិផ្នែកនេះ បានដល់ពួ ធំជាច្រើនអនេក មានទាំងត្រីទឹកសាប និង ត្រីទឹកប្រៃនៅក្នុងស្រ ពពោះផង ដូចជា ត្រីឆ្តោក.ឆ្ពិន, ច្រកែង, អណ្តែង, ប្រា, ឆ្តោរាហ៊ូ, ក្រពើ, ប្ពាម្ញ, ប្ពាម៉ា. គុជ្រា. អណ្តែងងាំង, ត ផ្ទក់, ក្អុកក្អិ. ក្រាយ, ខ្ទាំងហាយ, ក្ទាំងហាត, ស្លាត, ជ ថ្កិន, ក្ពាន់, បង្កា, បង្កង. កំពិស, ចង្វា, ឆ្លាម, បករ, ផ្សោត

**ឃ) ផ្នែកសត្តជាតិ** – ធម្មជាតិពួកនេះ មានច្រើន គ្នា ដូចជា រាជសីហ៍, ដំរីព្រៃ, សិង្ហ,ខ្លា, រមាស, រមាំង, ប្រើស, គោព្រៃ, ខ្ទីង, ចចក, ស្វាន, ស្វា, ឆ្មាបា, ចាបរិ, ស ឱម្ស. ព្រាកព្រៃ ។ល។

**ង) ផ្នែកបក្សាជាតិ** – ធម្មជាតិពួកនេះ បានដ មានស្លាបហើរ ដូចជា ឥន្ទ្រី. ឆ្មាត, ខ្ញែងស្រាក. ក្ងោក, ចោល មិតុបេ, តាវ៉ៅ, ស្វិតចៅ, ហង្ស, អានិជ្ជ, មាន់ទោ, មាន់ទឹក, មាន់ព្រៃ, ចាប, លលក, ព្រាប ជាដើម ។

**ច) ផ្នែកនិពិជ្ជន្តិកសត្វ** – ធម្មជាតិពួកសត្វឥតឆ្អឹង

ជា សុច, ម្ទូសស្រួយ, មមង់, មមាច, កន្ទេចអាល, ខ្លែប, ខ្ទួយ, ខ្យាដំរី, ជាដើម ។

**ឆ) ពួកឧរគ្គសត្វ** — បានដល់ពួកសត្វលូនដោយទ្រូង ដូចជា ពស់វែកដំបូក, វែកស្រវែង, វែកក្របី, ថ្លាន់, កន្តែន, ក្រពើ, រទាយ ទន្សង ជាដើម ។

ធម្មជាតិទាំងអស់នេះ មានស្ថិតនៅក្នុងកណ្ឌចូឡពន និងមហាពន ដែលស្ថិតនៅក្នុងជួរភ្នំហេមពាននោះឯង ។ ភ្នំហេមពាននេះ មានកំពូលធំ ៗ ដល់ទៅ ៨៤០០០ កំពូល ហើយកំពូលដែលខ្ពស់ជាងគេ គឺកំពូលភ្នំ អេវ៉េរេសត៍ ( Everest ) មានកំពស់ដល់ទៅ ៨៨៨៣ ម និងកំពូលភ្នំ អណ្ណាបូរណា ( Annapurna ) កំពស់ ៨.០៧៥ ប ។ ភ្នំនេះសម្បូណ៌ដោយទឹកកកគ្រប់ពេលវេលា ហើយដែលស្ថិតនៅក្នុងប្រទេសនេប៉ាល ( Népal ) ផ្នែកខាងជើង ។

ឬយវិញទៀត ធម្មជាតិទាំងប៉ុន្មានផ្នែកនេះ សុទ្ធតែកំពុងបញ្ចេញ ត្រួយ, ស្លឹក ផ្កាផ្លែ, ខ្ចីទុំ, មានកូន, មានគូ រត់ប្រវៀងគ្នាយ៉ាងល្អមើលបំផុត ។

ការពណ៌នា ធម្មជាតិក្នុងកណ្ឌទាំងពីរនោះ មានតម្លៃសំខាន់ត្រង់ការធ្វើឲ្យដំណើរតាជូជក មានសភាពបរិតយូរបន្តិចមុននឹងនាំអ្នកអាន

ឲ្យចូលទៅឃើញជីវភាពព្រះវេស្សន្តរនៅក្នុងព្រៃ ហើយអាចនាំចិត្តឲ
ធូរស្រាលជាមួយនឹងធម្មជាតិទាំងនោះសិន សឹមបានជួបការឃើញព្រ
វេស្សន្តរ. រាជបុត្រាបុត្រី និងនាង មទ្រី ដែលគង់តាំងធម៌ក្នុងព្រៃ
នោះ ។ មិនតែប៉ុណ្ណោះសោត ការពណ៌នាធម្មជាតិក្នុងចូឡពន និ
មហាពននេះ បានធ្វើឲ្យបរិយាកាសបានធូរស្រាល ព្រមទាំងធ្វើឲ្យអ្ន
អានបានឃើញថា ព្រះវេស្សន្តរគង់នៅក្នុងព្រៃជ្រៅឆ្ងាយ ជាទីរហោ
ស្ថាន គ្មានអ្នកណាបានទៅជួបប្រទះក្រៅពីតាជូជកនេះឡើយ ។

សូមអានសៀវភៅ

ល្បើកមហាជាតក៍ -- កណ្ឌមទ្រីជាតិ និងកណ្ឌជូជក មាន
សាច់កំណាព្យរស់រវើក ចាប់ចុងជូនយ៉ាងរណ្តំ ស្របតាម
បុរាណកនិងសម័យនិយម របស់អ្នកនិពន្ធ សែម - សួរ

## ប្រធាន

ធម្មជាតិជាតួអង្គមួយដ៏សំខាន់ក្នុងអក្សរសិល្ប៍ខ្មែរ ។

ចូរបង្ហាញនូវការពិពណ៌នា អំពីលក្ខណៈធម្មជាតិ ក្នុងអក្សរសិល្ប៍ខ្មែរ និងបញ្ហាធម្មជាតិក្នុងមហាវេស្សន្តរជាតក ។

## អត្ថាធិប្បាយ

ធម្មជាតិក្នុងអក្សរសិល្ប៍ខ្មែរ ជាវត្ថុមានតម្លៃដ៏សំខាន់ប៉ុន្មាន ទុកស្មើនឹងតួអង្គមួយយ៉ាងវិសេសវិសាល ។ ក្នុងរឿងរ៉ាវខ្មែរជាបែបប្រលោមលោក ឬរឿងល្បើក កវីខ្មែរពុំដែលបោះបង់ចោលនូវបញ្ហាធម្មជាតិនេះម្តងណាឡើយ ។

ទំនោរទោរទន់ទឹកចិត្តចំពោះធម្មជាតិរបស់កវីនិពន្ធខ្មែរ តែង

ៈលេចចេញឡើងនៅស្ទើរតែគ្រប់ចលនាអក្សរសិល្ប៍ខ្មែរ និងស្ទើរតែគ្រប់
រឿងប្រលោមនិយម បែបសាស្ត្រាល្បើកក្នុងបុរាណសម័យ ។ ធ
ជាតិដែលកវីនិពន្ធ បានពោលពណ៌នាក្នុងកិច្ចការរបស់ខ្លួននោះ ។ ជា
គ្រឿងឧបករណ៍ដ៏សំខាន់ម្យ៉ាង អាចផ្តល់នូវបញ្ហាផ្សេង ។ ជាច្រើន
បញ្ហាសប្បាយរីករាយ, បញ្ហាកំសត់, បញ្ហាអស្ចារ្យ ។ ល ។ ការពណ៌
នាធម្មជាតិនេះ មានលក្ខណៈច្រើនបែបយ៉ាងណាស់ ប៉ុន្តែបើសង្ខេ
មក យើងនឹងបានឃើញថា មានលក្ខណៈ ៣ យ៉ាងប្លែកពីគ្នា ៖

## ១- ការពណ៌នាធម្មជាតិ ជាបែបទេសភាព ដែលមានពិតនៅក្នុងធម្មជាតិ.—

ដើម្បីធ្វើឲ្យចលនាដែ
ធម្មជាតិក្នុងផ្នែកនេះ លេចចេញជារូបរាងឡើងក្នុងអក្សរសិល្ប៍ខ្មែរ កវីបា
ធ្វើការពណ៌នាដោយខ្លួនឯង ឬក៏ឲ្យតួអង្គណាមួយធ្វើដំណើរជាមួយធម្ម
ជាតិ ហើយពោលរៀបរាប់ធម្មជាតិទាំងនោះ តាមលក្ខណៈរៀងរាយជ
ផ្លូវ ជារបៀប ជាលំដាប់លំដោយគ្នា គឺធម្មជាតិដែលមាននៅក្នុងព្រៃយ៉ា
ណា ក៏ពោលរៀបរាប់ ធ្វើឲ្យធម្មជាតិទាំងនោះមានលក្ខណៈទេសភា
ហាក់ដូចជាយើងបានឃើញ ធ្លាប់ជួបប្រទះនៅទីណាមួយរួចមកហើយឧ
ទាហរណ៍ក្នុងរឿងសព្វសិទ្ធិរបស់ម៉ឺនភក្តីអក្សរតាំងឆ្នំថា សព្វសិទ្ធិបានចូ

ទៅប្រពាតព្រៃព្រឹក្សា ហើយពោលរៀបរាប់ធម្មជាតិថា « លំពាន់លំ–ពស់លាស់លំពង់ ត្រៀងត្រង់រាក់រាគរោករកា សុក្រំសុក្រាចក្រាច ត្រៀលស្វា ក្រឹស្នាចន្ទន៍ខ្នុរសប្បុរល្វែង » ។ ឬក៏ « ឈ្លូសក្តាន់រមាស រមាំងទ្រាយ ស៊ីដោយខ្សែកឡាយកូនគូរ៉ា ទន្សាយទន្សោងរត់រោរា នាំគ្នាទៅឈប់ឈ្មប់ទន្សេង » ។ ឬមួយថា « កញ្ចុះស្ទុះចឹកកញ្ចាក់ស្វា ត្រីឆ្វាំងពេលឆ្វារារត់ឆ្វាយ អណ្តើងអណ្តើកខ្ញើកកកាយ ក្ងាំងហាយបោល លាយនឹងក្ងោកហោត ។ ល ។

## ២– ការពណ៌នាធម្មជាតិជាសញ្ញាភាព ឬជា ឧបមាន –

ផ្ទុយពីការពណ៌នាផ្នែកទី ១, នៅក្នុងផ្នែកនេះ កវីបានលើកយកធម្មជាតិមកប្រៀបប្រដូចនឹងតួអង្គទៅវិញ ពោលគឺជួនអីតួអង្គដែលបែកព្រាត់ប្រាសគ្នា ក៏ពោលរៀបរាប់ធម្មជាតិនៅក្នុងព្រៃដែលខ្លួនជួបប្រទះ បានឃើញនៅជិតខ្លួន ដោយទុកវត្ថុនេះជាខ្លួនឯង ហើយទុកឈើ ឬ សត្វនោះជាគូរសង្សារ ឬជនណាម្នាក់ដែលខ្លួនស្រឡាញ់ពេញចិត្តហើយព្រាត់ចោល ឧទាហរណ៍ ក្នុងរឿងសព្វសិទ្ធិនេះដដែល កាលសព្វសិទ្ធិយាងទៅប្រពាតព្រៃ ដោយបានឃ្លាតចេញពីនាងសុវណ្ណ-កេសរ ហើយបានឃើញព្រៃព្រឹក្សា មច្ឆាជាតិ សត្វបក្សាបក្សី និង

ហ្វូងសត្វដែលនៅក្នុងព្រៃនោះ ទ្រង់នឹកស្រណោះដល់ត្វជីវិតដែលទ្រង់
ឃ្លាតមកឆ្ងាយ ទ្រង់ក៏ពោលពណ៌នាធម្មជាតិថា “ដើមព្រីងសព្វព្រា
ទន្ទាបទុំ ចាប់ជាទ្រនំយំហើរធ្លាក់ ដូចគលអង្រាត់កាត់ទូនល្អង ព្រា
ដៀតបំពរងប៉ងមើលព្រៃ ។ . . . រនាំងព្រៃស៊ុំខាងខាត់ត្រពាំង
ខ្ទះខ្ទុតរគេខ្ទាំងក្រោយជើងខ្នង ដូចបងឃ្លាតពិត្តបិត្តព្រលឹង ប៉ើះប៉ើយ
សបនឹងប្អូនទីងខ្ទី ។ . . . ខ្ទែងស្រោកស្រពិសំបុកពង រ
ដើមលើទងមែកខ្ទែងពពក ខ្វះយំស្រៀវស្រែកសប្រែកញ័រ ខ្ទះទុំពេ
វល្លិខ្ទុតញាតប្លែ ។ ដូចខ្លួនបងបានប្រាណផ្តេកផ្តិត និងប្អូនខ្វំបចិត្ត
ឥតមោះមៃ គ្រានេះឃ្លាឃ្លាតរវាតវៃ ព្រាត់ឆ្ងាយបកព្រៃព្រះហិមវា ,, ។

ឬមួយកាលទុំបែកឃ្លាតចេញពីនាងទាវ ហើយក៏ច្រៀងរៀប
រាប់ធម្មជាតិថា “ ពិដោរផលាផ្កាកំភ្លឹងដូចបងនែបនឹងទាវពិសិ ពិដោរបុ
ផ្កាចំប៉ី ដូចបងនែបស្រីទាវឥតភ្លេង ។ ចំប៉ីចំពើបទើបជួបគ្នា ឥឡូ
ឃ្លាតឃ្លាទាវទ្ធនល្អង រំដួលអន់រួយពេកក់ន្ទង ចិត្តបងអាល័យថ្ងៃកន្និដ្ឋា
ឆ្នះឆ្នពិដោរផ្កាក្រវាន់ ដូចក្លិនទាវស្បាន់ដិតកាយា ពិដោរថ្មី ។ ដូចក្លិនផ្កា
ជាប់នៅកាយផាហ៊ុំប្រាវាត់ ,, ។

ការពណ៌នាធម្មជាតិក្នុងផ្នែកនេះ បានធ្វើឲ្យធម្មជាតិដែលគ្មា
**វិញ្ញាណ** ( ឈើព្រៃ ) ឬ **គ្មានចេតនាសញ្ញា** ដូចជា កន្ទង់, មាន់,បក្សី

ាដើប ឲ្យមានវិញ្ញាណក មានធម្មសញ្ញាជាសិល្បៈឡើង ហើយមិន
ណ្ហាៈ ការពណ៌នានេះទុកជាគ្រឿងបំពេរមនោសញ្ចេតនាអ្នកអាន
ទ្ធង់លន្ទោចអណ្តែតអណ្តូងស្រងេះស្រងោចថែមទៀតផង គឺអ្នក
ចេះយកចិត្ត នឹកស្រណោះអាលោះអាល័យ ទៅប្រៀបប្រដូចនឹង
ាតិដែលរស់នៅក្នុងសង្គមនៃធម្មជាតិទៅវិញ ។

## ៣) ការពណ៌នាធម្មជាតិដើម្បីសូរស័ព្ទពីរោះ

ផុតពីផ្នែកទាំងពីរខាងដើម ការពណ៌នាធម្មជាតិក្នុងផ្នែកទី
៖ បានធ្វើឡើងក្នុងលក្ខខ័ណ្ឌ ១ ដែលធម្មជាតិនោះមានឈ្មោះ
ពិអក្សរជាមួយគ្នា ឬអក្សរដែលមានសូរស័ព្ទឡើងភ្លើយឆ្លងគ្នា
ញសម្លេងរណ្តំគ្នាយ៉ាងពីរោះ ឧទាហរណ៍ក្នុងរឿងសព្វសិទ្ធិ ។
ណ៌នាអំពីធម្មជាតិថា “ ឪដើមពពេលសត្វពពូល ទុំមូលលើ
បកសាខា ពពូលពាពាំនាបុប្ផា ហើរឆ្លាទៅទុំពពេលផង ។
ពងទៅពពាលខែ ហើយហិចហើរហែគ្នាត្រសង ពាំផ្កាពពាយ
ៈល្អង ពពូលយំពងប៉ប៉ុកអី „ ។ ឬក៏ “ មានដើមទទឹមទទាទុំ
រងាវយំឮច្រៀវច្រៃ ខ្វះហើរទទះចុះទុំឮ ទៀបឆ្នេរផលស័យ
ស្វាប „ ។ ឬក៏ “ពញ្ញាក់ចុះទុំចុងពញ្ញា ហើយហើររេរាទៅពញ្ញើ
ពញ្ញាក់បក្ខងេងើ ខ្វះហើរពញ្ញាមទៅតាមវាល „ ។ ឬ “ ត្រ

ផ្កាងហែលផ្ទឹមនឹងត្រីផ្ទក់ ត្រីស្លាញស្ទើតស្ទក់ដេញត្រីស្លាត ពរស្វៃបែ
ស្ទឹងប្រឹងសង្វាត ត្រីឈ្វាតហែលឆ្វៀររៀលឆ្វាត់ ។ ល ។

ការពណ៌នាធម្មជាតិផ្នែកនេះ ទោះរៀបរាប់អំពីដើមឈើ, វល្លិ
ផ្កា, សត្វ, បក្សាបក្សី ឬ ពួកត្រីនៅក្នុងទឹកក៏ដោយ កវីពុំបានគិតថ
ដើមពេលឈើ ឬ ត្រីនោះ ៗ មានកំណើតនៅទីខុសគ្នា ខ្លះនៅក្នុងព្រៃ ខ្ល
ដុះក្នុងស្រុក ត្រីខ្លះនៅទឹកប្រៃ ហើយត្រីខ្លះទៀតនៅទឹកសាបនោ
ឡើយ ឲ្យតែធម្មជាតិទាំងនោះមានអក្សរដូចគ្នា ឬ អាចបញ្ចេញសំឡេង
រណ្ដំគ្នា កវីក៏លើកយកទៅដាក់ឲ្យនៅជិតគ្នា ហើយជួនកាលសត្វខ្ល
ជាសត្រូវនឹងគ្នា ក៏គេដាក់ឲ្យប្រឡែងគ្នាលេងដែរ ។ សំឡេងរណ្ដំ
នេះហើយដែលអាចលេចចេញជាសិល្បៈម៉្យាងនៅក្នុងអក្សរសិល្ប៍ គឺ
សិល្បៈធម្មជាតិនេះឯង ដូចជាពាក្យថា “ ពពួល, ពពាលខែ, ពពេ
ទុំចុងពពេល; ទទារគស៊ីលើទីទួល, ទទះស្វាច, ទទឹកជោគ ឬ ត្រ
ផ្កាង . . . ផ្ទឹមត្រីផ្ទក់ ជាដើម ។

ការពណ៌នាធម្មជាតិផ្នែកទី ៣ នេះ ជួនវាមានលក្ខណៈជា
សញ្ញាភាព ឬ ជាឧបមានផងក៏មាន ឧទាហរណ៍ “ នដើមកំពីង
ពួយដុះព័ន្ធ វារវល្លិវិលវង់កំពុងផ្កា ដូចរៀមកំពុងរួមស្នេហា នឹងកែ
កល្យាណ៍អនុជន្ទន ។ ព្រលិតដូចបងប្រឡែងលោម ព្រលឹមលា

គោបព្រលឹងស្ងួន ព្រលាប់បងរិលទៅឲ្យជួន ឲ្យជួបនឹងនួនព្រលឹងបង . . . ។ល។

ឯការពណ៌នាធម្មជាតិនៅក្នុងមហាវេស្សន្តរជាតក ក៏មានលក្ខណៈស្របចូលទៅក្នុងការពណ៌នាទាំង ៣ ផ្នែកខាងលើនេះដែរ ប៉ុន្តែធម្មជាតិនៅក្នុងមហាវេស្សន្តរជាតក បានក្លាយទៅជាតួអង្គមួយដែលមានចលនាច្រើនបែបយ៉ាងណាស់ ហើយចលនាមានសភាពខ្ពស់ទាបស្របទៅតាមទឹកចិត្ត សកម្មភាពនៃតួអង្គថែមទៀត ។ យើងអាចសង្ខេបចលនានៃធម្មជាតិនៅក្នុងមហាវេស្សន្តរជាតកបានជា ៥ ផ្នែកសំខាន់ ៗ ដូចតទៅ

១– ធម្មជាតិមួយផ្នែក បានផ្តល់នូវសភាពសប្បាយរីករាយចំពោះអ្នកដែលមានចិត្តចង់ទៅនៅជាមួយនឹងធម្មជាតិនោះ ឧទាហរណ៍ នាងមទ្រី បានពណ៌នាអំពីធម្មជាតិក្នុងព្រៃហេមពាន្តពីចម្ងាយដើម្បីទូលថ្វាយព្រះវេស្សន្តរជាស្វាមីថា « បពិត្រមហារាជក្សត្រថ្លៃប្រសើរអើយ រីព្រៃហេមពាន្តនោះសប្បាយក្តាត់ហោង . . . បីដូចនូវស្រះមានឲ្យដ៏នគរជេតុត្តរនេះឯងហោង ។ ទំព័រ ១០២–១០៥ ។ ការពណ៌នានេះ នាងមទ្រី ពុំបានដឹងថា ព្រៃនោះយ៉ាងណាឡើយ ប៉ុន្តែដើម្បីធ្វើព្រះទ័យព្រះវេស្សន្តរឲ្យសប្បាយរីករាយនឹងទីនោះ ហើយអាចបំ**ភ្លេចចោល**ព្រះនគរ

និងរាជសម្បត្តិបាន • ។

២– ផ្ទុយទៅវិញ ធម្មជាតិក្នុងហេមពាន្តផងដែលនោះ មានសភា
.គួរឲ្យខ្លាចណាស់ ឧទាហរណ៍ ព្រះវេស្សន្តរនិងព្រះបាទស្រីសញ្ជ័
បានពណ៌នាប្រាប់នាងមទ្រី ដើម្បីកុំឲ្យនាងចង់ទៅតាមព្រះអង្គនៅក្នុង
នោះ ‘ . . . . ហៃនាងមទ្រីអើយ អាពុកនឹងស្រដីប្រាប់មេ . . .
នោះមុខគួរស្បើមពេកហោង ។ ទំព័រ ១៤០–១៤១–១៤២ ។

៣– ធម្មជាតិមួយផ្នែកធំ បានផ្តល់សភាពសប្បាយខ្លះ ទុក្ខ
ដែលជាហេតុនាំឲ្យតួអង្គនានាដែលធ្វើដំណើរកាត់ធម្មជាតិទាំងនោះ ត្រូ
តែមានការប្រុងប្រយ័ត្នជានិច្ច ប៉ុន្តែក្នុងទីខ្លះក៏ធ្វើឲ្យតួអង្គបានសប្បា
មួយខណៈៗ ។ ធម្មជាតិជំពូកនេះ យើងបានឃើញស្ទើរតែទាំងអ
នៅក្នុងកណ្ឌចូឡពន និងមហាពនព្រមទាំងក្នុងកណ្ឌនាងមទ្រីខ្លះៗ ។

៤– ធម្មជាតិមួយផ្នែកទៀត បានផ្តល់នូវសភាពទុក្ខព្រួយ លំបា
វេទនា ក្នុងពេលដែលតួអង្គជួបនឹងហេតុកាចចំឡែក ឬទទួលទុក្ខព្រួ
ក្នុងពេលណាមួយ ឧទាហរណ៍ ជាលីពណ៌នាធម្មជាតិដែលខ្លួនទៅជិ
ប្រាប់នាងក្រស្នា នៅពេលដែលខ្លួនត្រូវព្រាត់ប្រាសពីបិតា ‘ ឱក្រស្

មាសបងអើយ ស្រពោះដើមជប្ពព្រឹក្សរងិតនូវមែកសាខា . . . . . សឹងប្រាសចាកសរសើហើយ ’ ។ ឬមួយពេលនាងមទ្រីយាងទៅបេះផលោក្នុងព្រៃ ក៏បានជួបនឹងពពើខ្លះដែលធ្លាប់មានផ្លែទុំក៏ឥតផ្លែទុំ, មេឃបិទបាំងរលោកខុសធម្មតាជាដើម ។ ធម្មជាតិបែបនេះ យើងឃើញមាននៅក្នុងកណ្ដាលមទ្រីស្ទើរតែទាំងអស់ ហើយផ្ទៃពីនេះ ឃើញមាននៅក្នុងមហារាជបព្វ ដែលជាលីក្រស្នាបានពណ៌នាទូលព្រះរាជអយ្យកោ អយ្យិកា ឲ្យបានជ្រាបនូវទុក្ខវេទនារបស់ព្រះមាតាបិតា ។

៥— មានធម្មជាតិមួយពួកទៀត បានផ្ដល់នូវសេចក្ដីត្រេកអរសាទរក្នុងពេលដែលព្រះវេស្សន្តរធ្វើមហាទាន គឺបុត្តបរិច្ចាគ, ទារបរិច្ចាគជាដើម ។ ពេលនោះ ធម្មជាតិមានព្រៃព្រឹក្សា ភ្នំតូច ធំទឹកសមុទ្រជាដើម ក៏កក្រើករំពើកពុះពោរ បោកបក់ ហាក់ដូចមានវិញ្ញាណចេះជួយសំដែងសេចក្ដីអបអរសាទរចំពោះអំពើល្អអស្ចារ្យរបស់ព្រះវេស្សន្តរ ប៉ុន្តែពេលខ្លះធម្មជាតិបែរជាប្រែលក្ខណៈស្រពោន ក្រៀមក្រោះ ស្វាត់ស្វៀមទៅវិញដូចជានៅពេលដែលតាជូជកវាយបណ្ដើរជាលីក្រស្នានៅក្នុងព្រៃជាដើម។

ដូច្នេះធម្មជាតិ គឺជាតួអង្គមួយដ៏សំខាន់ណាស់ ហើយថែមទាំងចេះប្រែលក្ខណៈរបស់ខ្លួនទៅតាមសកម្មភាពនៃតួអង្គ និងចលនានៃ

រឿងនានាផង ។ ធម្មជាតិក្នុងមហាវេស្សន្តរជាតក មិនត្រឹមតែនាំ
អ្នកអាន ឬធ្វើឲ្យតួអង្គមានសេចក្ដីសប្បាយ ឬលន្ធង់លទ្រោចប៉ុណ្ណ
ឡើយ ថែមទាំងចេះបង្កើតសភាពអស្ចារ្យ. ចេះកក្រើកញាប់ញ័រចេះថ្ល
ទុក្ខព្រួយជាមួយតួអង្គនិងចេះសប្បាយរីករាយ អបអរសាទរជាមួយតួរ
នានាទៀតផង ។

## លក្ខណៈនៃការពណ៌នាធម្មជាតិ

ក្នុងអក្សរសិល្ប៍ខ្មែរ កវីខ្មែរតែងធ្វើការពណ៌នាធម្មជាតិ ដែលមាននៅក្នុងស្រុកខ្មែរ ស្របតាមចំណង់ចំណូលចិត្តនៃខ្មែរ នេះឯង ។ នេះជាលក្ខណៈពិសេសមួយរបស់ខ្មែរក្នុងអក្សរសិល្ប៍ខ្មែរ ។

## កណ្ឌទី ៨ — កុមារបាពិ

**ប្រធាន**

ព្រះវេស្សន្តរ នៅក្នុងកុមារបាពិ
មានលក្ខណៈ ជាមនុស្សសាមញ្ញ
ផង ជាពោធិសត្វដ៏សំខាន់ផង ។
ចូរធ្វើវិភាគ នូវលក្ខណៈទាំង
ពីរក្នុងកុមារបាពិនេះ ដោយមាន
គោលបញ្ជាក់ឲ្យច្បាស់លាស់ ។

### អត្ថាធិប្បាយ

សកម្មភាពនៃទានបារមីរបស់ព្រះវេស្សន្តរ ពុំមែនស្ថិតនៅដាច់ពីសង្គមមនុស្ស ឬជនជាសាច់ឈាមរបស់ព្រះពុទ្ធឡើយ ក៏ប៉ុន្តែមានការ

ទាក់ទងទៅនឹងសង្គមមនុស្សព្រមទាំងមហេសីនិងបុត្រផង ។

ដើម្បីនឹងធ្វើនូវទាន ១ ដ៏សំខាន់ក្នុងក្របខណ្ឌនៃព្រះអង្គ ជាព្រ ពោធិសត្វ ហើយទ្រង់បំពេញទានបារមីនេះ ព្រះវេស្សន្តរត្រូវបំពេញទ្ បុត្តបរិច្ចាគថែមទៀត ។ ការលើកជាលីក្រស្នាឲ្យទៅតាជូជកនៅក្នុ កុមារបាពិ បាននាំឲ្យអ្នកអានសំគាល់ឃើញនូវលក្ខណៈរបស់ព្រះវេស្សន្ត ២ យ៉ាង គឺ :

១-- ព្រះវេស្សន្តរជាមនុស្សសាមញ្ញ នៅមានទឹកព្រះទ័យដូចបិតា ឯទៀត ៗ ដែរ ។

២-- ព្រះវេស្សន្តរមានលក្ខណៈជាពោធិសត្វ ស្រឡាញ់ទានបារមី លើសពីបុត្តធីតាទៅទៀត ។

ចំពោះលក្ខណៈទាំងពីរខាងលើនេះ យើងនឹងធ្វើវិភាគចែក ឲ្យដាច់ចេញពីគ្នា ដើម្បីធ្វើការសិក្សាដូចតទៅ :

លក្ខណៈទីមួយ ព្រះវេស្សន្តរជាតួអង្គដែលមានទឹកព្រះទ័យដូច មនុស្សសាមញ្ញទូទៅ ហើយដូចបិតាឯទៀត ៗ ដែលចេះស្រឡាញ់ អា-ណិតអាសូរចំពោះបុត្រធីតាដែរ ។ លក្ខណៈនេះ យើងឃើញលេច ចេញឡើងនៅពេលតាជូជកចូលទៅសុំរាជបុត្រាបុត្រីអំពីព្រះអង្គ ។ ក៏ព្រម ប្រទានឲ្យតាមបំណង ប៉ុន្តែទ្រង់ឃាត់ឲ្យតាជូជកនៅបង្អង់រង់ចាំមួយរាត្រី

សិន ដើម្បីចាំឲ្យជួបនឹងនាងមទ្រី . . . . « ព្រាហ្មណ៍អើយ . . . . ព្រហាមឡើងសឹមចៅនាំយកកូនអញទៅហោង » ( ទំព័រ ៣២៤ - ៣២៥ ) ។ កាលតាជូជកមិនព្រម ព្រះវេស្សន្តរក៏ទ្រង់ផ្តាំផ្ញើនឹងតាជូជកថា « ហែចៅព្រាហ្មណ៍អើយទោះបើយោបីព្រះស្តេចមិនចង់ខានសម្រាន្តនៅរាយ ឲ្យកូនទាំងពីរបានលាទៅនាងមទ្រី . . . ឲ្យចៅព្រាហ្មណ៍ឯងច្រើនជាពន្ទិកមិនខាន ( ទំព័រ ៣២៦ - ៣២៧ ) ។

ព្រះរាជឱង្ការផ្តាំផ្ញើនេះ បញ្ជាក់ថា បើតាជូជកនាំយកកុមារទាំងពីរចូលទៅនគរជេតុត្តរហើយ មុខជាជាលីក្រស្នា បានជួបនឹងព្រះជាទស្រីសញ្ជ័យជាអយ្យកោអយ្យិកាមិនខាន ។ កាលជួបហើយពិតជានឹងបានរួចពីក្រញាំដៃតាជូជកមិនលែងឡើយ ។

កាលព្រះអង្គបានប្រទានជាលីក្រស្នា ទៅតាជូជករួចស្រេចហើយ ទ្រង់បានកាត់ថ្លៃជាលីជាមាសមួយពាន់តម្លឹង ឯនាងក្រស្នាក៏ទ្រង់កាត់ថ្លៃជាមាសមួយរយពាន់តម្លឹង និងខ្ញុំប្រុសខ្ញុំស្រី ដំរី ពាជី គោឧសភរាជ អស់គ្រឿងប្រភេទមួយ ៗ សឹងជារយ មួយមុខ ៗ ឧទាហរណ៍ ទំព័រ ៣៣៨ - ៣៣៩ - ៣៤០ ។ មិនតែប៉ុណ្ណោះសោត ព្រះវេស្សន្តរបានមានព្រះឱង្ការថា « . នាងក្រស្នាជាប្អូនស្រីតំងាតូចនេះគប់នូវលក្ខណាគាយពាល្អ មកកើតទាត្រកូលអំបូរថ្លៃ កូនអើយអាពុកក្រែងអ្នក

ឥតអំបូរពូជពង្សទូរជន មានតែទ្រព្យយកមកចាក់ផាក់ឲ្យព្រាហ្មណ៍ យក
ទៅតាមចិត្តប្រាថ្នាធ្វើជាភរិយា សេពសម្ពន្ធនឹងត្រកូលជាន់ទាប សន្តាន
ផាមហាក្សត្រ នឹងបាត់បង់ច្រឡំទៅជារាស្ត្រ .... ទើបនាងក្រស្នាប្អូន
ស្រីបារូចចេញជាអ្នកផាហោង ។ ក្នុងឃ្លានេះ រិតតែបញ្ជាក់ឲ្យឃើញ
ច្បាស់ថា ព្រះវេស្សន្តរជាមនុស្សដែលប្រកាន់ជាតិ ប្រកាន់ត្រកូល មើល
ងាយមនុស្សក្នុងវណ្ណៈឯទៀតក្រៅពីវណ្ណៈត្រកូលរបស់ព្រះអង្គយ៉ាងខ្លាំង។

ល៎ះប្រទាន ជាលីក្រស្នា ព្រមទាំងបានកាត់តម្លៃយ៉ាងនេះរួច
ហើយ ព្រាហ្មណ៍ជូជកចាប់ចងជាលីក្រស្នាបណ្តើរចេញទៅជាលីក្រស្នា
បានយំសោកទួញរៀបរាប់ទូលព្រះវេស្សន្តរជាបិតាដោយសព្វគ្រប់ ព្រះ
វេស្សន្តរទ្រង់អាណិតរាជបុត្រាបុត្រីណាស់ ទ្រង់សោកសៅអាក់អួល
ក្នុងព្រះទ័យ ហាក់ដូចជាចង់ស្លាប់ ញ័ររន្ធត់ប្រប់អស់រាងកាយ ចូលទៅក្នុងសាលាហើយទ្រង់
សោយសោករៀបរាប់រំលឹកនូវមនុស្សារិយ៍សំខាន់ ៗ យ៉ាងច្រើន ឧ
ទាហរណ៍ .. . . . កាលនោះព្រះបាទស្រីវេស្សន្តរបរមហាសត្វ
ស្តេចស្តាប់ពាក្យព្រះរាជកុមារទ្រង់ព្រះកន្សែងពិលាបជាពន្លឹកដូច្នោះ ព្រ
អង្គក៏បានព្រះហឫទ័យសៅសោក អាណិតអាសូរព្រះរាជបុត្រទាំងពី
លើសលន់ពន់ប្រមាណ . . . យកកូនអញត្រឡប់មកវិញក្នុងពេល
ឥឡូវនេះឯង ។ ទំព័រ ៣៥៥–៣៥៦–៣៥៧–៣៥៨ ។

មិនតែប៉ុណ្ណោះសោត ព្រះវេស្សន្តរបានប្រែក្លាយលក្ខណៈទៅជាមនុស្សកាចសាហាវយង់ឃ្នង ហើយវង្វេងភាន់ជាត់ស្មារតីទៀតផង គឺទ្រង់ឃើញតាជូជកវាយដំជាក្រស្នាទៅចំពោះព្រះភក្ត្រព្រះអង្គ ហើយទ្រង់គ្រោធខ្លាំងណាស់ ទ្រង់គិតនឹងតាមកាត់កព្រាហ្មណ៍កញ្ចាស់យកជាលីក្រស្នាមកវិញ ឧទាហរណ៍ . . . . ឧប៉ូចរញ្ញគិតនេះហើយ . . . យកកូនអញត្រឡប់មកវិញក្នុងកាលឥឡូវនេះឯង ។ ទំព័រ ៣៥៧–៣៥៨ ។

គឺលក្ខណៈទាំងអស់នេះហើយ ដែលបានបញ្ជាក់ថា ព្រះវេស្សន្តរជាមនុស្សសាមញ្ញ, ជាបិតាដែលមានព្រះទ័យស្រឡាញ់បុត្រធីតាដូចបិតាឯទៀត ៗ ដែរ ហើយមិនតែប៉ុន្តែប៉ុណ្ណោះ ព្រះវេស្សន្តរថែមទាំងបានលក្ខណៈជាមនុស្សធុនអន់ទន់ខ្សោយម្នាក់ទៀតផង ពោលគឺជាអ្នកមានកំហឹងរហូតដល់ទៅចង់ទាញអាវុធប្រហារតាជូជកព្រាហ្មណ៍ចាស់បំបាត់ជីវិតចោល ។

ផ្ទុយទៅ លក្ខណៈទី ២ ព្រះវេស្សន្តរ គឺជាតួអង្គព្រះពោធិសត្វអ្នកស្វែងរកសព្វញ្ញុតញ្ញាណ ដោយព្រះទ័យយ៉ាងមុតមាំលើសអ្វី ៗ ទាំងអស់ ។ យ៉ាងណាមិញ ចាប់តាំងពីព្រះនាងទូលអំពីសុបិននិមិត្តភ្លាមព្រះអង្គក៏យល់ភ្លាមថា នឹងមានអ្នកមកសុំទានបុត្រីបុត្រាក្នុងថ្ងៃ

ស្អែក ហើយព្រះអង្គក៏មានព្រះបន្ទូលបង្វែងដានព្រះនាងមទ្រី ដើម្បីឲ្យ
នាងចេញផុតដោយសុខចិត្តសុខថ្លើម ក៏ង កាលព្រះអង្គបានធ្វើបុត្តបរិ–
ច្ចាគ ។ មិនតែប៉ុណ្ណោះ ដល់វេលាព្រឹកព្រហាមឡើងព្រះអង្គទ្រង់គ
ចាំអ្នកសូមទានយ៉ាងទន្ទឹងផ្ទះ ដូចអ្នកប្រមឹកស្រាអង្គុយរង់ចាំប្រពន្ធមកពី
ផ្សារនឹងអាលបានស្រាធំកផ្លូវឆ្ពោះឯង ។ ទំព័រ ៣១៤ ។

កាលតាជូជកបានទូលសុំព្រះរាជបុត្រាបុត្រី ព្រះអង្គទ្រង់មាន
ព្រះទ័យត្រេកអរក្នុងការឲ្យទានបុត្រពីតាចេះ ស្មើនឹងអ្នកក្រខ្សត់ម្នាក់ដែល
បានមាស ១ ពាន់តម្លឹងភ្លោះឯង ។ ទំព័រ ៣២៣–៣២៤ ។ កាល
ព្រះអង្គបានប្រទានកាលីក្រស្នាទៅតាជូជកហើយ ទ្រង់បានតាំងព្រះទ័យ
អធិដ្ឋានថា « សូមឲ្យបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាលកុំខាន ,
លុះទ្រង់មានព្រះទ័យក្រោធនឹងព្រាហ្មណ៍ ដែលវាយធ្វើបាបរាជបុត្រាបុត្រី
រួចទ្រង់ពិចារណាដោយក្ដីស្រឡាញ់ចំពោះសម្មាសម្ពោធិញ្ញាណវិញ ទ្រង់
ក៏ស្រាយក្រោធវិញភ្លាម ហើយថែមទាំងត្មះតិះដៀលព្រះអង្គឯងវិញថា
ព្រះអង្គបានធ្វើខុសធ្ងន់ណាស់ ហើយព្រះពុទ្ធរាល់ព្រះអង្គពីអតីតកាល
តែងតែធ្វើបុត្តបរិច្ចាគយ៉ាងនេះជានិច្ច ទើបបានត្រាស់ដឹង ។

លក្ខណៈទាំងប៉ុន្មាននេះ បានបញ្ជាក់ឲ្យឃើញថា ព្រះវេ–
ស្សន្តរជាព្រះពោធិសត្វ ដែលមានព្រះទ័យស្នេហាចំពោះសម្មាសម្ពោ–

ពិញ្ញាណគ្មានអ្វីប្រៀបបាន ។

ការចេះផ្សំនូវលោកិយសច្ចៈ នៃតួអង្គព្រះវេស្សន្តរដែលមានលក្ខណៈជាបិតាចេះស្រឡាញ់បុត្រីបុត្រាបែបធម្មតា ភ្ជាប់ទៅនឹងអច្ឆរិយនៃព្រះវេស្សន្តរ ដែលមានលក្ខណៈជាតួអង្គព្រះពោធិសត្វ អ្នកស្រឡាញ់សម្មាសម្ពោធិញ្ញាណដ៏លើសលុបនេះ បានធ្វើឲ្យអ្នកអានមានចិត្តស្រឡាញ់ជឿចំពោះព្រះវេស្សន្តរកាន់តែខ្លាំងឡើងៗ ដោយហេតុថាលក្ខណៈទាំងពីរ មានស្ថិតនៅក្នុងតួអង្គតែមួយ ដែលជាមនុស្សជាតិស្ថិតនៅក្នុងសង្គមមនុស្សនេះឯង ។ លក្ខណៈទាំងពីរនេះ អាចជួយធ្វើឲ្យតួអង្គព្រះវេស្សន្តរមានតម្លៃមួយកំរិតទៀតយ៉ាងខ្ពង់ខ្ពស់បំផុត គឺជាព្រះពោធិសត្វដែលសាងបារមីនៅក្នុងមនុស្សលោក តាំងពីក្នុងសង្គមមនុស្សច្រើនគ្នារហូតទល់ក្នុងសង្គមតូចមួយដែលមានតែព្រះអង្គនិងរាជបុត្រាបុត្រី ព្រមទាំងអគ្គទេពីនៅក្នុងរហោស្ថាន ។

# ប្រធាន

ព្រះវេស្សន្តរខំបំពេញទានបារ-មី ហេតុធល់ហ៊ានលះ មហេសីនិងបុត្រធីតាធ្វើជាទាន ប្រកបដោយលក្ខណៈជាវីរជនក្នុងលោក ប៉ុន្តែមានមតិខ្លះយល់ថា ព្រះវេស្សន្តរធ្វើបាបមហេសីនិងបុត្រធីតា ហើយធ្វើទានដើម្បីទានទៅវិញ ។

ចំពោះមតិបែបនេះ តើអ្នកមានយោបល់យ៉ាងណា ?

## អត្ថាធិប្បាយ

ការកសាងបារមីដើម្បីបានប្រាជ្ញាសម្មាសម្ពោធិញ្ញាណ មិ

មែនជាការងាយស្រួលដូចការធ្វើកិច្ចការណាមួយនោះឡើយ  ក៏ប៉ុន្តែ
ជាការលំបាក  ហើយកម្រនឹងបានជនណាម្នាក់ដែលមិនមែនជាពោធិ
សត្វធ្វើបាននោះឡើយ  ។

ព្រះវេស្សន្តរបានបំពេញទានបារមីក្នុងឋានៈព្រះអង្គជាពោធិ–
សត្វប្រកបដោយលក្ខណៈប្លែកពីជន  និងទានឯទៀត ។ ត្រង់ការលះបង់
មហេសី និងបុត្រឲ្យទៅជាទាននេះឯង  ។  ការធ្វើទានបែបនេះ
ជាអំពើ ១ ដ៏កម្រមានណាស់  ព្រោះអីមនុស្សយើងតែងស្រឡាញ់
កូនប្រពន្ធនេះស្មើនឹងការស្រឡាញ់ជីវិតដែរ  ប៉ុន្តែបើមានកំហឹងខ្វែង
ហួសប្រមាណ ក៏តែងបោះបង់កាត់កាល់ចោលតែប៉ុណ្ណោះ  ផុយទៅ
វិញ  គ្មានអ្នកណាម្នាក់កំពុងស្រឡាញ់កូនប្រពន្ធដ៏ខ្វែងក្វាហើយ ។ លះ
បង់កូនប្រពន្ធនោះឲ្យទៅជាទានដល់ជនណាម្នាក់នោះឡើយ។  ចំណែក
ព្រះវេស្សន្តរវិញ  ទ្រង់លើកទ្រព្យសម្បត្តិផ្សេង ។ ដែលសំខាន់ ។ ធ្វើ
ជាអំណោយទាន ហើយ  ក៏ត្រូវពួកអ្នកនគរសុំឲ្យបំបរបង់ចេញទៅនៅ
ក្នុងព្រៃ  ហើយនៅទីនោះ ព្រះអង្គគ្មានអ្វីធ្វើទាន ក៏លើកជាលិក្រស្នា
ជាបុត្រាបុត្រីប្រសូតចេញពីដើមនរា –គ្មានទោសកំហុសអ្វីសោះប្រទាន
ទៅតាជូជកព្រាហ្មណ៍ដែលមានចិត្ត និងកាយវិការកាចសាហាវ ហ៊ាន
វាយតប់ចាប់ចងនៅទីចំពោះព្រះនេត្រព្រះអង្គយ៉ាងជាក់ស្ដែង។ អំណោយ

មានបែបនេះហើយដែលនាំឲ្យគេចោទប្រកាន់ព្រះវេស្សន្តរថា ជាអ្នកបានធ្វើបាបបុត្របុត្រាក្នុងប្រយោជន៍ផ្ទាល់របស់ព្រះអង្គ បើព្រះអង្គចង់បានត្រាស់ជាព្រះពុទ្ធ ម្តេចក៏ទ្រង់មិនយកខ្លួនព្រះអង្គឲ្យទៅនៅបំរើតាជូជកដោយព្រះអង្គឯងទៅ ។ ព្រះវេស្សន្តរដែលបានធ្វើយ៉ាងនេះគឺដើម្បីនឹងបានត្រាស់ជាព្រះពុទ្ធដោយព្រះអង្គឯងតែប៉ុណ្ណោះ ។

ចំពោះការចោទប្រកាន់ខាងលើនេះ ជាការសមហេតុផលណាស់ ព្រោះអី បើព្រះវេស្សន្តរធ្វើត្រឹមតែទានធម្មតា មានការប្រទានព្រះរាជទ្រព្យ ឬ ជីវបច្ច័យនានាគេន្ទ្រនោះ មិនជាអ្វីទេ គឺសូមឲ្យព្រះវេ–ស្សន្តរធ្វើទៅចុះ ប៉ុន្តែចំពោះការលើកបុត្របុត្រា និងមហេសីឲ្យជាទាននេះ ជាការហួសហេតុពេកណាស់ បើមហេសីមានទោសកំហុសចំពោះព្រះអង្គ ឬបុត្របុត្រាធំពេញវ័យហើយ ក៏គួរព្រះអង្គធ្វើយ៉ាងនេះ ប៉ុន្តែនាងមទ្រីក្តី ជាលីក្រស្នាក្តី ជាអ្នកគ្មានកំហុស ហើយស្ថិតនៅក្នុងវ័យតូចខ្ចីថែមទៀត ។ ត្រង់នេះហើយ ដែលធ្វើឲ្យអ្នកផងទាំងពួងយល់ថា ព្រះវេស្សន្តរជាស្វាមី- បិតា គ្មានសង្គហធម៌ចំពោះមហេសីនិងបុត្របុត្រាសោះ ។

ផ្ទុយទៅវិញ មតិខ្លះបានឲ្យតម្លៃទៅលើព្រះសកម្មភាពរបស់

ះវេស្សន្តរយ៉ាងថ្លៃថ្លាសក៏រិតទៅវិញថា ព្រះសកម្មភាពបែបនេះ ជា
ន្ទរកម្មកិច្ចការរបស់បុរសដ៏មានតម្លៃយ៉ាងកម្រមានណាស់ ព្រោះការដែល
ះអង្គ ព្រមលះបងបោះបង់ និងបុត្រីបុត្រាឲ្យជាទាន ដែលគ្មានអ្នកណាអាច
ដូចនេះហើយ ដែលព្រះអង្គមានតម្លៃនិងលក្ខណៈជាវីរជននេះឯង ។
រពោលថា បើព្រះវេស្សន្តរចង់បានគ្រាស ម្តេចក៏មិនយកខ្លួនព្រះអង្គ
ទៅនៅបំរើតាជូជកនោះ ជាការមិនសមហេតុផលសោះឡើយ ព្រោះ :

– តាជូជកមិនត្រូវការព្រះអង្គឲ្យទៅនៅឲ្យបំរើគាត់ឡើយ គឺ
វការតែជាលី-ក្រស្នាតែប៉ុណ្ណោះ ។

– ហេតុដែលតាជូជកមិនត្រូវការនេះ ដោយសារព្រះវេស្សន្តរ
មនុស្សមានវណ្ណៈខ្ពស់ មានវ័យនៅក្មេង, មានរូបឆោមលោមពណ៌
ជាងតាជូជកយ៉ាងឆ្ងាយ ប្រសិនណាបើព្រះវេស្សន្តរទៅនៅបំរើតា
ជកមែន ដោយតាជូជកយល់ព្រមដែរនោះ ថ្ងៃណាមួយ តាជូជកនឹងរក
ងប្រច័ណ្ឌព្រះវេស្សន្តរហើយកើតហេតុទាស់ទែងគ្នានឹងព្រះវេស្សន្តរមិន
ន ព្រោះហេតុតែព្រះវេស្សន្តរមានសម្រស់ជាងតាត់ ហើយក្រែងនាង
ចិត្តតាបទាចាប់ចិត្តស្រឡាញ់ព្រះវេស្សន្តរជាងតាជូជក ។

– មិនតែប៉ុណ្ណោះ បើទោះជាព្រះវេស្សន្តរបានយកខ្លួនព្រះអង្គ

ឯងទៅធ្វើផ្លូវឆ្មោះកើត ក៏ទានបារមីនៅតែពុំពេញលេញដែរ ព្រោះហេ
តែខ្វះបុត្តបរិច្ចាគ, ទារបរិច្ចាគនេះឯង ។

ដោយរួមខ្លីមក ការធ្វើទានរបស់ព្រះវេស្សន្តរ មិនមែនដើម្បី
ប្រយោជន៍ផ្ទាល់ព្រះអង្គតែមួយព្រះអង្គឯងនោះឡើយ ប៉ុន្តែដើម្បីនឹងបា
សម្រេចនូវសម្មាសម្ពោធិញ្ញាណចំពោះព្រះអង្គផង ហើយព្រះអង្គនឹងយ
ប្រាថ្នាសម្មាសម្ពោធិញ្ញាណ ដែលទ្រង់បានប្តូរទ្រព្យសម្បត្តិ, បុត្របុត្រ
និងមហេសី ព្រមទាំងអជ្ឈត្តិកទាននោះ ទៅបំភ្លឺដឹកនាំផ្លូវសត្វលោកទាំ
សាកល ឲ្យបានឆ្លងផុតពីសមុទ្រទុក្ខគឺវដ្តសំសារនេះឯង ។

សូមមិត្រទាំងឡាយចាំអានសៀវភៅ
„ ស្រណោះឋានបដ្ឋសឡុរ ”
របស់អ្នកនិពន្ធ ខៀវ ឆម – ស្ទុរ មិត្រនឹងបានឃើញច្បាស់
នូវទស្សនៈសំខាន់ ៗ បែបមនុស្សសាស្ត្រ, ទ្រឹស្តីពុទ្ធសាសនា
ទាក់ទងនឹងទឹកចិត្ត, ចំណង់ចំណូលចិត្ត និងទំនោរទំនន់ចិត្ត
នៃខ្មែរ ចំពោះព្រះពុទ្ធសាសនាយ៉ាងច្បាស់មិនខាន ។

## កណ្ឌទី ៩ – មទ្រីបាព៌

# ប្រធាន

នាងមទ្រី ជាស្ត្រីកន្សែងសារពេជ្រ របស់ព្រះពោធិសត្វ ។

ចូរបង្ហាញថា តើលក្ខណៈត្រង់ណាខ្លះដែលបានបញ្ជាក់ថា នាងមទ្រីជាស្ត្រីកន្សែងសារពេជ្រមែន ។

## អត្ថាធិប្បាយ

នាងមទ្រីមិនមែនមានឋានៈត្រឹមតែអគ្គមហេសី នៃព្រះមហាក្សត្រមួយព្រះអង្គប៉ុណ្ណោះទេ ប៉ុន្តែនាងគឺជាស្ត្រីកន្សែងសារពេជ្រព្រះពោធិសត្វថែមទៀតផង ។ ក្នុងមហាវេស្សន្តរជាតក អ្នកនិពន្ធបាន

ពណ៌នាពីទឹកព្រះទ័យនាងមទ្រីនេះ ច្រើនជាងពណ៌នាខាងរូបសម្ប
ហើយជាពិសេស អ្នកនិពន្ធបានទុកកណ្ឌ ១ តែឯង សម្រាប់ពណ៌ន
ពីទឹកព្រះទ័យដ៏សប្បុរសប្រកបដោយស្វាមីភក្តិ និងសកម្មភាពគ្រប់យ៉ា
ក្នុងការជួយបំពេញទានរបស់ព្រះវេស្សន្តរជាព្រះស្វាមី ។

ដែលហៅថាពោធិសត្វ គឺតួអង្គបុរសណាដែលបានសាង
កំពុងសាងបារមី ដើម្បីបានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គក្នុងលោក ។
តួអង្គពោធិសត្វ គឺជាមនុស្ស ឬ សត្វដែលមានសន្តានចិត្ត និងសកម្ម
ភាពល្អជានិច្ច ទោះក្នុងកំណើតជាមហាក្សត្រ ក៏ដូចជាសេដ្ឋី គហបតី
ឬរាស្ត្រប្រជាតូចតាចក្រីក្រ ឬ ក្នុងកំណើតនៃសត្វធំមានឫទ្ធានុភាពច្រើន
ក៏ដូចជាសត្វតូចតាចល្អិតល្អោចដែរ ។ ស្ត្រីភេទទោះជាមនុស្ស ឬ
សត្វដែលបានជាគូគ្រងតាមប្រពៃណីនៃមនុស្សសត្វហើយ ស្ត្រីភេទ
នោះហៅថាស្ត្រីជាកន្សៀសារពេជ្ញ គឺជាគូរបស់ព្រះពោធិសត្វនេះឯង ។

តាមធម្មតា ស្ត្រីកន្សៀសារពេជ្ញនេះតែងមានការទាក់ទងជា
មួយព្រះពោធិសត្វជាដរាប, បើពោធិសត្វកើតជាមនុស្ស ស្ត្រីកន្សៀ
សារពេជ្ញ ក៏កើតជាមនុស្សដែរ ហើយទោះស្ថិតនៅក្នុងវណ្ណៈត្រកូល
ណា ប្រទេសជាតិណាក៏ដោយ ក៏តែងបានជួបគ្នាជាគូគ្រង មិនដែល
ខានឡើយ បើពោធិសត្វយកកំណើតជាសត្វណាមួយ ស្ត្រីកន្សៀ

សារពេជ្ជ ក៏យកកំណើតជាសត្វនោះដែរ ថែមទាំងបានជួបគ្នាជាគូគ្រង ដូចក្នុងកំណើតជាមនុស្សដែរ ។ មួយវិញទៀត ព្រះពោធិសត្វនិង ស្ត្រីកន្ទៃសារពេជ្ជនេះ បើទោះជាព្រាត់គ្នាទៅដល់ទីណា ក៏មិនដែល ព្រាត់រហូតទេ តែងនឹងមានជំនួយគ្រោះខ្ទួនណា ១ នាំឲ្យជួបវិញជានិច្ច ហើយប្រសិនបើព្រះពោធិសត្វ ឬ ស្ត្រីកន្ទៃសារពេជ្ជនេះត្រូវស្លាប់បាត់ បង់ជីវិតដោយហេតុណា ១ គូអង្គដែលរស់នៅ តែងនៅម្នាក់ឯងរហូត ឥតយកគូគ្រងទៀតឡើយ ។ គូអង្គបែបនេះហើយដែលហៅថាកន្ទៃ សារពេជ្ជ ។

ព្រះនាងមទ្រីជាកន្ទៃសារពេជ្ជនៃព្រះវេស្សន្តរពោធិសត្វ ។ ហេតុដែលផ្ដុំលបង្ហាញឲ្យឃើញថា នាងមទ្រីមានលក្ខណៈជាកន្ទៃ សារពេជ្ជនេះ មានច្រើនកន្លែង ច្រើនបំណុចណាស់ ។ នៅក្នុង គណ្ឌហេមពាន្ត យើងបានឃើញថាអ្នកនិពន្ធបានលាតត្រដាងនូវភក្ដីភាព របស់នាងមទ្រីចំពោះព្រះស្វាមីយ៉ាងវែង. ពេលដែលព្រះវេស្សន្តរមិនព្រម ឲ្យនាងទៅតាម នាងមទ្រីសោយសោករៀបរាប់ថា បើព្រះស្វាមីមិន ឲ្យនាងទៅតាមទេ នាងនឹងយកអុសមកគប្រមាណប៉ុនភ្នំ ហើយដុត អុសនោះឲ្យឆេះ រួចនាងនឹងលោតចូលភ្លើងឲ្យក្ស័យសង្ខារទៅ ប្រសើរ ជាងនាងរស់នៅ ។ នាងប្រៀបព្រះវេស្សន្តរដូចបាដំរី ដើរត្រាច់ក្នុង

ព្រៃសព្វព្រោះព្រលងដងភ្នំផងទាំងពួង ឯរូបព្រះនាងដូចដំរីបណ្ដើរកូនទាំងពីរតាមដោយតន្ទងដងព្រៃភ្នំទាំងពួងនោះដែរ » ។ ទំព័រ ១០១។ពេលដែលព្រះវេស្សន្តរ បានពោលពណ៌នាអំពីព្រៃហេមពាន្តជាទីគួរឲ្យខ្លាច ដើម្បីបន្ទាចនាងមទ្រីកុំឲ្យនាងចង់តាមទៅ ប៉ុន្តែនាងមទ្រីបែរជាពណ៌នាអំពីព្រៃហេមពាន្តយ៉ាងច្បាស់ ថាជាទីសប្បាយគួរឲ្យចង់នៅទៅវិញ ។

នៅឯភ្នំ គិរីវង្កតឯណោះ នាងមទ្រីពុំធុញទ្រាន់នឹងធ្វើការបំរើព្រះស្វាមីដែលត្រូវគេបំបរបង់ ហើយបកតាំងពីមិនោះឡើយ ។ ព្រឹកឡើងនាងដងទឹក បោសសំអាតអាស្រម លួងលោមព្រះរាជបុត្រីបុត្រា ហើយទើបលីទំពក់រែកកញ្ជែចេញទៅក្នុងព្រៃស្ងាត់តែម្នាក់ឯង ដើម្បីស្វែងរកបេះផលានុផលមកថ្វាយព្រះស្វាមីនិងបុត្រីបុត្រា ។ ព្រះនាងបានធ្វើការសព្វគ្រប់ទាំងអស់ ឥតឲ្យព្រះស្វាមីឃើញសព្រះទ័យឡើយ ។

ចំណុចដែលរិតតែបញ្ជាក់ឲ្យឃើញច្បាស់ថា ព្រះនាងមទ្រីជាស្ត្រីកន្សែសារពេជ្ជគឺត្រង់ពេលដែលនាងសន្លប់បាត់ស្មារតី ក្រោយពីពេលនាងត្រឡប់ពីព្រៃមកវិញ ហើយរកបុត្រីបុត្រាមិនឃើញ លុះព្រះវេស្សន្តរប្រាប់រឿងពិត ហើយឲ្យអនុមោទនាទាន នាងក៏លើកព្រះហស្តទទួលអនុមោទនាដោយព្រះទ័យយ៉ាងរីករាយ ថែមទាំងសុំឲ្យព្រះស្វាមីបានត្រាសជាព្រះពុទ្ធទៅអនាគតកាលទៀតផង ។ លើសពីនេះទៅទៀតកាលឥន្ទព្រាហ្មណ៍មកសុំនាងពីព្រះស្វាមីនាងបានទូលព្រះសវាមីថា ទោះ

ាព្រះស្វាមីពុះទ្រូងយកប្រមាត់បេះដូងឲ្យទាន ក៏ព្រះនាងនៅតែសុខព្រះ
ទ័យដោយក្តីរីករាយជានិច្ច ។

អំពើទាំងប៉ុន្មាននេះ មិនមែនបង្ហាញថា នាងធ្វើដើម្បីចំអកគក
អង្រងង់ឲ្យព្រះស្វាមីឡើយ ប៉ុន្តែនាងធ្វើដោយព្រះទ័យស្មោះណាស់ ព្រោះ
ព្រះនាងបានដឹងព្រះទ័យព្រះស្វាមីយ៉ាងច្បាស់តាំងពីដើមរហូតមក ព្រះស្វា
មីព្រមលើកជាលីក្រស្នានិងរូបព្រះនាងឲ្យជាទានមិនមែនដោយអស់មធ្យោ
បាយឬដោយខ្ជិលចិញ្ចឹមនោះឡើយ ប៉ុន្តែពិតជាមានគោលបំណងមួយ
ដើម្បីបានត្រាសជាព្រះពុទ្ធទៅអនាគតកាលយ៉ាងច្បាស់លាស់ ។ ស្ត្រី
ដូចនាងមទ្រីនេះ រកគ្មានទេក្នុងលោកនេះ ហើយប្រពន្ធបែបនេះ បើ
ព្រាត់ប្រាសដោយហេតុណាមួយ តើនរណានឹងអត់ទ្រាំមិនសម្រក់ទឹក
ភ្នែក សំដែងសេចក្តីស្តាយស្រណោះកើត ?

ទឹកចិត្តដ៏មោះមុត ស្របតាមគោលបំណងព្រះស្វាមីនេះហើយ
ដែលបញ្ជាក់ឲ្យឃើញថា នាងមទ្រីជាស្ត្រីកន្សែសារពេជ្ជ ជាគូគ្រងពី
អតីតរបស់ព្រះពោធិសត្វ ។ នាងមទ្រីតែងធ្វើសកម្មភាពគ្រប់យ៉ាងទាំងអស់
តាមបំណងព្រះស្វាមី មិនឲ្យឃ្លើសព្រះទ័យព្រះស្វាមីទាល់តែសោះ ។

សក្កបាត៌

# ប្រធាន

ព្រះឥន្ទ ជាតួអង្គមួយដ៏សំខាន់ក្នុងមហាវេស្សន្តរជាតក ។ តើអន្តរាគមន៍របស់ព្រះឥន្ទ្រាធិរាជ ក្នុងកណ្ឌនេះនឹងមានទំហំ នៃតម្លៃយ៉ាងណាចំពោះព្រះវេស្សន្តរ និងនាងមទ្រី ។

## អត្ថាធិប្បាយ

ព្រះឥន្ទ្រាធិរាជនិងសកម្មភាពរបស់តួអង្គនេះ ក៏ជាកត្តានៃទាន
បារមីមួយរបស់ព្រះវេស្សន្តរដែរ ហើយមិនតែប៉ុណ្ណោះសោត អន្តរាគមន៍

របស់ព្រះឥន្ទ្រាធិរាជក្នុងកណ្ឌទី ១០ អាចមានលក្ខណៈ មានន័យដ៏ជ្រៅឆ្ងាយទៀតណាស់ ។

ព្រះឥន្ទគឺជាស្តេចទេវតាដែលតែងជួយយកអាសា, ជួយផ្តល់សុខសប្បាយ ឬជួយដាក់ទណ្ឌកម្មដល់មនុស្សលោកទាំងឡាយណាដែលបានធ្វើអំពើល្អ - អាក្រក់ជានិច្ច ។ តួអង្គព្រះឥន្ទក្នុងពុទ្ធនិយម គឺជានិមិត្តរូបនៃយុត្តិធម៌, ជាអ្នកស្អាតស្អំ ហើយជាអ្នកមានអ្វី ៗ សុទ្ធតែមិព្វទាំងអស់ ។ ក្នុងសក្កបាពិ ព្រះឥន្ទត្រូវមានបេសកកម្មដ៏ពិសេសក្នុងការជួយបំពេញទានបារមីព្រះវេស្សន្តរផង ជួយសម្រាលទុក្ខលំបាកមួយដ៏ខ្លាំងក្លារបស់ព្រះអង្គផង ។ ដូច្នេះយើងចង់ដឹងថា បើគ្មានអន្តរាគមន៍របស់ព្រះឥន្ទទេ តើរឿងព្រះវេស្សន្តរនឹងក្លាយទៅជាយ៉ាងណាទៅវិញ ?

តាមពិត ការដែលព្រះវេស្សន្តរបានធ្វើបុត្តបរិច្ចាគរួចហើយនេះ ក៏មិនមែនមានន័យថា ព្រះអង្គបានបញ្ចប់នូវសុកម្មភាពនៃទានដែរ គឺព្រះអង្គត្រូវតែបំពេញទារបុត្តបរិច្ចាគទៀត ។ តាមរយៈអ្នកនិពន្ធ បានបញ្ជាក់ថា កាលពន្លកនៃទឹកព្រះទ័យរបស់ព្រះមហាវេស្សន្តរ បានពកលេចចេញជារូបរាងយ៉ាងនេះហើយ ៗ មានស្មូមយាចកណាម្នាក់មកសូមយកនាងមទ្រីជាមហេសី ដែលនៅគាល់បំរើធ្វើវត្តប្រតិបត្តិព្រះអង្គរៀង

រាលថ្ងៃនៅក្នុងទីរហោស្ថាននោះ ព្រះវេស្សន្តរមុខជានឹងលើកប្រទានទៀតជាមិនខាន ។ ការប្រទានបែបនេះ នឹងបានផលដ៏ប្រសើរ គឺទានបារមីត្រូវតែបានពេញលេញចំពោះព្រះអង្គ ប៉ុន្តែព្រះវេស្សន្តរក៏ត្រូវតែបានទទួលផលអាក្រក់ដ៏ខ្លាំងក្លាណាស់ដែរ គឺត្រូវលំបាកព្រះកាយនៅក្នុងព្រៃហោត់ព្រៃហោងតែមួយព្រះអង្គឯង ដោយគ្មានអ្នកបំរើធ្វើកិច្ចវត្តគ្រប់យ៉ាងដូចនាងមទ្រីជាមិនខាន ។ ការលំបាកដែលជាផលវិបាកដ៏អាក្រក់នេះហើយ ដែលអាចធ្វើឲ្យការប្រព្រឹត្តិធម៌បំពេញផ្នួសជាឥសីភេទរបស់ព្រះអង្គត្រូវខូចអន្តរាយ ព្រោះគ្មានអ្នកដងទឹក, រកបេះផលានុផលមកថ្វាយ ដូចកាលនាងមទ្រីគង់នៅ ។

គឺដោយមានការយល់ឃើញបែបនេះហើយ ទើបព្រះឥន្ទ្រាធិរាជបានកាឡាខ្លួនជាព្រាហ្មណ៍ព្រឹទ្ធាចារ្យ ចុះមកសុំនាងមទ្រីពីព្រះវេស្សន្តរភ្នាម ។ ក្នុងបេសកកម្មនេះ យើងបានឃើញទៀតថា ព្រះវេស្សន្តរក៏ព្រមប្រទាន, នាងមទ្រីក៏សុខព្រះទ័យ ហើយឥន្ទព្រាហ្មណ៍ក៏បានទទួលនាងមទ្រី ។ ចំណុចនេះហើយ ដែលនាំឲ្យអ្នកអានទូទៅមានការពេញចិត្តនឹងព្រះវេស្សន្តរណាស់ ហើយមិនតែប៉ុណ្ណោះ គេថែមទាំងនៅមានជំនឿនិងមានភក្តីភាពចំពោះព្រះអង្គទៀតផង ។ ព្រះឥន្ទ្រាធិរាជ គាល់សូមនាងមទ្រីបានដូចបំណងហើយ ក៏បានប្រគល់នាងថ្វាយ

ព្រះវេស្សន្តរវិញ ដើម្បីឲ្យទៅបំរើព្រះអង្គក្នុងកិច្ចការគ្រប់យ៉ាងដូចសព្វផង រួចក៏បានជំណែងខ្លួនជាព្រះឥន្ទ្រាធិរាជដូចដើមវិញ ដើម្បីទូលរៀងហេតុគ្រប់ប្រការចំពោះព្រះអង្គ ។

សកម្មភាពរបស់ព្រះឥន្ទក្នុងពេលនេះ ជាលក្ខណៈប៉ូយចង្អុលឲ្យឃើញថា គេចេះធ្វើឲ្យលក្ខណៈដ៏ពិឃ្លួយ បានក្លាយជាលក្ខណៈដ៏ធូរស្រាលទៅវិញ ។ របៀបចេះបន្ធូរបរិយាកាសបែបនេះ អាចធ្វើឲ្យដំណើររឿងនៅតែមានតម្លៃជានិច្ច ។ ប៉ុន្តែទោះយ៉ាងនេះក៏ដោយ ក៏នៅតែមានបញ្ហាចោទសួរថា បើព្រះឥន្ទចេះបន្ធូរបរិយាកាសនៃរឿងឲ្យធូរស្រាល, ចេះជួយបំពេញទានបារមីឲ្យបានពេញលេញ ហើយចេះជួយធ្វើអន្តរាគមន៍ក្នុងកិច្ចការដែលតឹងលំបាកយ៉ាងនេះ ម្ដេចក៏មិនក្លែងធ្វើជាតាព្រាហ្មណ៍ជូជក មកសុំជាលីក្រស្នាពីព្រះវេស្សន្តរទៅ ? ម្ដេចក៏បណ្ដោយឲ្យតាជូជកមែន ៗ ដែលមានប្រពន្ធនៅក្មេងខ្ចីឈ្មោះ នាងអមិត្តតាបនា នៅស្រុកកុន្នវិដ្ឋគ្រាម ហើយដែលមានចិត្តកាចសាហាវនោះ មកសុំជាលីក្រស្នាធ្វើអី ?

ចំពោះបញ្ហាបែបនេះ យើងឃើញថាព្រះឥន្ទជាតួអង្គសំខាន់ក៏ដូចជាមិនសំខាន់ ប៉ុន្តែបើយើងគិតតែបន្តិចយ៉ាងនេះទៅវិញថា "ដើម្បីនិងរចនារឿង ១ ឲ្យមានតម្លៃ មានសម្រស់គ្រប់

**យកគ្រឿងរចនានោះ ពីគម្ពីរមជ្ឈដ្ឋានមកដាក់បញ្ចូលគ្នា** ,, នោះយើងនឹងបានឃើញ បានយល់ភ្លាមថា ,, តាជូជកមែនទែន ដែលចូលទៅសុំជាលិក្រស្នាពីព្រះវេស្សន្តរនោះ ក៏ជាតួអង្គមានតម្លៃស្មើ នឹងតាជូជកឥន្ទព្រាហ្មណ៍ដែលចូលទៅសុំនាង មទ្រីដែរ ព្រោះអីការសុំជាលិក្រស្នារបស់តាជូជក អាចធ្វើដំណើររឿងឲ្យមានកំរិតទារុណភាពខ្ពស់ឡើងមួយថ្នាក់យ៉ាងធំ ថែមទាំងបង្ហាញឲ្យឃើញនូវសភាពកំសត់ស្រងេះស្រងោចផង នូវទឹកព្រះទ័យព្រះវេស្សន្តរជាពោធិសត្វផង ជាបិតាសាមញ្ញ ដូចអ្នកផងទាំងពួងផង ។ ដូចយើងបានឃើញរួចហើយថា រឿងព្រះវេស្សន្តរ បើគ្មានតាជូជកចូលមកធ្វើអន្តរាគមន៍ទេ នឹងក្លាយទៅជារឿងសោះកក្រោះ ហើយបើតាជូជកមិនស្លាប់ ក៏រឿងនេះរិតតែគ្មានតម្លៃ គ្មានរសជាតិខ្លាំងពេកាស់ទៅទៀត ។ ដោយហេតុនេះហើយទើបអ្នកនិពន្ធបានបង្កើតតួអង្គតាជូជក ប្ដីនាងអមិត្តតាបនាផង និងឥន្ទព្រាហ្មណ៍ផង ដើម្បីរឿងនេះស្ថិតនៅក្នុងសភាពជាលោកិយសច្ចៈ លាយគ្នានឹងអច្ឆរិយៈ ក្នុងការបំពេញទានបារមីរបស់ព្រះវេស្សន្តរ ។ តាជូជកដូចជាគ្រឿងផ្សំ, ឥន្ទព្រាហ្មណ៍ដូចគ្រឿងទឹក ឯព្រះវេស្សន្តរ និងរាជបុត្រាបុត្រី ព្រមទាំងមហេសីជាសាច់ ជាបន្លែ ។ **របស់ទាំងអស់នេះ** កាលផ្សំចូលគ្នាហើយ នឹងបង្កើត

ជាចម្ងាញ់ ( រសជាតិ ) មួយយ៉ាងពិសេសឡើង ។

បើរឿងព្រះវេស្សន្តរ នៅតែនិយាយពីអន្តរាគមន៍របស់ព្រះឥន្ទ ឬ ទេពតាជដែល ។ តាជូជកក៏ទេពតា, អ្នកស្រីពិរាស្ត្រខឹង ក៏ព្រោះទេពតាបញ្ចូលចិត្ត, នាងមទ្រីទៅព្រៃ ក៏ទេពតាចុះមកឃាត់ផ្លូវកុំឲ្យមកពីថ្ងៃ ហើយអ្នកមកសុំនាងមទ្រី ក៏ព្រះឥន្ទកាឡាខ្លួន ជូជកនាំជាលីក្រស្នាចូលទៅជេតុត្តរ ក៏ព្រោះទេវតាបង្វែងផ្លូវ . . . យ៉ាងនេះ រឿងព្រះវេស្សន្តរ នឹងត្រូវអស់តម្លៃរលីងធេងដូចសម្លគ្មានគ្រឿងគ្រាអ្វីសោះ នឹងគ្មានរសជាតិ ( ចម្ងាញ់ ) សោះឡើយ ។

ដូច្នេះ សកម្មភាពរបស់ព្រះឥន្ទដែលកាឡាខ្លួនមកធ្វើជាជូជកព្រាហ្មណ៍សុំនាងមទ្រីពីព្រះវេស្សន្តរ ក្នុងពេលនេះអាចចាត់បានថាជាតម្លៃ ១ ដ៏ពិសេស ស្មើនឹងតួអង្គឯទៀត ។ មានតួអង្គតាជូជកមែនទែនដែរ ហើយក្នុងពេលនេះ បើគ្មានព្រះឥន្ទចុះមកធ្វើអន្តរាគមន៍ផងទេ រឿងព្រះវេស្សន្តរ នឹងក្លាយទៅជារឿងទារុណភាពយ៉ាងសុទ្ធសាធទៅវិញ ព្រោះអី វិបត្តិទំនាស់ដែលលេចចេញពីទានបារមីនេះចេះតែមានសកម្មភាពតឹងឡើងធ្វើឲ្យអ្នកអាន ឬ ពុទ្ធសាសនិកជន លែងពេញចិត្តនឹងព្រះវេស្សន្តរឡើយ ។

## ប្រធាន..................

គោលបំណងធំបំផុត របស់ព្រះ
ព្រះវេស្សន្តរស្ថិតនៅត្រង់ការប្រាថ្នា
សម្មាសម្ពោធិញ្ញាណ ឯណោះទេ
សូម្បីពួកក្សត្រនៅមាតុលនគរ បាន
អញ្ជើញព្រះអង្គឲ្យសោយរាជ្យ នៅ
ចេតរាស្ត្រ ក៏ព្រះអង្គមិនព្រមទទួល
ដែរ ប៉ុន្តែក្នុងសក្កបព្វ ព្រះវេស្សន្តរ
បែរជាសុំពរ អំពីព្រះឥន្ទ្រាធិរាជដើម្បី
បានត្រឡប់ទៅ សោយរាជសម្បត្តិ
ព្រមទាំងប្រាថ្នាភាពជាធំ ដូចមនុស្ស
ធម្មតាទៅវិញ ។

ចូរធ្វើការពិភាក្សាដោះស្រាយនៅ

# មើលតើព្រះវេស្សន្តរជាអត្តទត្តបុគ្គល ឬយ៉ាងណា ?

## អត្ថាធិប្បាយ

វីរកម្មរបស់ព្រះវេស្សន្តរ បានមានកំរិតខ្ពស់ធុតនៅពេលដែលព្រះអង្គបានប្រទាន ជាលីក្រស្នា ទៅតាជូជក ព្រមទាំងការប្រទាននាងមទ្រីទៅឥន្ទព្រាហ្មណ៍ ។ លក្ខណៈទាំងអស់នេះបញ្ជាក់ឲ្យឃើញថាព្រះវេស្សន្តរជាអ្នកប្រាថ្នាតិចណាស់ ប៉ុន្តែ បន្ទាប់ពីទ្រង់បានធ្វើទាននេះរួច ព្រះអង្គបានប្រែលក្ខណៈទៅជាមនុស្សធម្មតា ប្រាថ្នារាជ្យ និងភាពជាធំផ្សេងទៀតជាច្រើន តាមរយៈពរ ៨ ប្រការ ចំពោះព្រះឥន្ទ្រាធិរាជ ។ បើដូច្នោះ តើព្រះវេស្សន្តរ នឹងទៅជាអ្នកប្រាថ្នាធំ, ជាអត្តទត្តបុគ្គលវិញ ឬ យ៉ាងណា ?

តាមរយៈ ៨ ប្រការ យើងបានឃើញថា ព្រះវេស្សន្តរមានចំណង់យ៉ាងធំលើសលុបផ្ទុយពីលក្ខណៈខាងដើមស្រឡះ ។

ពរទីមួយថា សូមឲ្យព្រះវររាជបិតាស្ដេចមកអញ្ជើញយើងខ្ញុំ

ត្រឡប់ទៅគ្រងរាជ្យវិញ ។ ចំពោះចំណង់ព្រះទ័យបែបនេះឃើញថា ផ្ទុយពីក្នុងកណ្ឌខាងដើមស្រឡះ ព្រោះនៅក្នុងកណ្ឌហេមពាន្ត យើងបានដឹងថា ព្រះវេស្សន្តរមានព្រះទ័យលះរាជសម្បត្តិយ៉ាងដាច់អាល័យ ហើយទោះជាពួកក្សត្រចេតរាស្ត្រ បានសុំយាងព្រះអង្គឲ្យសោយរាជ្យ ដោយមានការធានាអះអាងយ៉ាងណា ក៏ព្រះអង្គនៅតែមិនព្រមជាដាច់ខាត ដល់មកឥឡូវព្រះវេស្សន្តរហាក់ដូចជាមានការធុញទ្រាន់នឹងគង់នៅក្នុងព្រៃនោះណាស់ ព្រោះជាទីស្ងាត់រហោស្ថាន ក្រោយពេលព្រះអង្គបានធ្វើការពិសោធន៍អស់រយៈពេលជិតមួយឆ្នាំនោះមក ។ តើការចង់យាងវិលត្រឡប់មកកាន់រាជសម្បត្តិវិញនេះ ដោយទ្រង់មានគោលបំណងយ៉ាងណា ? ចុះបើពួកអ្នកនគរមិនត្រូវការព្រះអង្គទេ តើព្រះអង្គនឹងយាងមកដូចម្ដេចកើត ? ឬទ្រង់ចង់យាងចូលមកក្នុងព្រះនគរ ដោយចង់សងសឹកចំពោះអ្នកនគរស្រីពិរាស្ត្រវិញ ?

ចំពោះមតិខាងលើនេះ បើគិតទៅតាមលក្ខណៈព្រះវេស្សន្តរជាមនុស្សបថុជ្ជន ឃើញថាព្រះអង្គពិតជាមានគោលបំណងណាមួយមិនខាន ប៉ុន្តែបើគិតទៅតាមនិស្ស័យទឹកព្រះទ័យរបស់ព្រះអង្គ ដែលយើងធ្លាប់ស្គាល់រួចមកហើយ ឃើញថាព្រះវេស្សន្តរមិនមានបំណងអាក្រក់ណាមួយ ដើម្បីសងសឹកចំពោះអ្នកនគរស្រីពិរាស្ត្រទេ ព្រោះថាបើព្រះ

ចង់ធ្វើយ៉ាងនេះ ព្រះអង្គមិនបានយាងចេញទៅណាឲ្យលំបាកព្រះអង្គ ព្រះអង្គនៅតែក្នុងព្រះនគរហើយអាចធ្វើយ៉ាងណាក៏បានដែរ ព្រោះង់មានកូនអាមាត្យជារាជបរិពារដល់ទៅ ៦ ម៉ឺននាក់ ហើយមិនតែណ្ណោះព្រះអង្គចង់ធ្វើយ៉ាងនេះ តែបែរជាទ្រង់យាងចេញទៅគង់នៅឆ្ងាយាច់ពីរាជ្យក្រុងផ្ទះ បើទោះចង់ធ្វើអ្វី ក៏គ្មានកម្លាំងឲ្យបានមាំមួនឡើយ ។ះបើព្រះអង្គគ្មានកម្លាំងចិត្តទៅហើយ តើនឹងអាចទៅធ្វើអ្វីកើតចំពោះអ្នកនគរ ។

តាមពិត ការដែលព្រះវេស្សន្តរចង់យាងត្រឡប់មកកាន់ព្រះនគរវិញនេះ គឺដោយមានបំណងចង់ធ្វើសកម្មភាពនៃទានណាមួយពិសេស ចំពោះប្រជាជនក្នុងព្រះនគរតទៅទៀតតែប៉ុណ្ណោះ ព្រោះពីពេលនេះ :

– ពួកអ្នកនគរប្រកែលរស់កំហឹងចំពោះព្រះអង្គហើយ ។ ថែមទាំងពាល់ក្ដួរចិត្តព្រះទ័យដែលប្រកបដោយសប្បុរសធម៌យ៉ាងនេះ ដោយច្បាស់លាស់ទៀតផង ។

ព្រះអង្គបានធ្វើបុត្តបរិច្ចាគ, ទារបរិច្ចាគ បានចប់សព្វគ្រប់ហើយ ។ នៅពេលចប់ដំណាក់ការដ៏មានតម្លៃចំពោះការស្វែងរកប្រាជ្ញា

ក្រាសដឹងនេះ ព្រះអង្គត្រូវរកបច្ចេកទេសមួយទៀត ដើម្បីបំពេញទា
បារមីឲ្យរិតតែមានកំរិតខ្ពស់ឡើង ។

ចំណុចទាំងអស់នេះ បាននាំឲ្យឃើញថា ការចង់យាងរិ
ត្រឡប់នៃព្រះវេស្សន្តរចូលមកក្នុងព្រះនគរវិញ ពិតជាគ្មានបំណងអាត្រ
ណាមួយក្រៅពីចង់ធ្វើប្រយោជន៍ដ៏ខ្ពង់ខ្ពស់ឲ្យមនុស្សជាតិ នៅក្នុងព្រះន
នោះឡើយ ។ អាស្រ័យហេតុនេះហើយ បានជាយើងឃើញនៅក្នុង

ពរទី ២ ថា សូមឲ្យមានអំណាចដោះទុក្ខទោសរបស់សត្វទាំ
ឡាយឲ្យផុតពីក្ដីស្លាប់ ។

ពរទី ៣ ថា សូមឲ្យបានជួយសង្គ្រោះដល់ជនកំសត់ទុរគត
ទៅ ឲ្យផុតពីក្ដីក្រលំបាកតោកយ៉ាក ។

ពរទី ៤ ថា សូមកុំឲ្យយើងខ្ញុំមានចិត្តត្រេកត្រអាលខាងផ្លូវកាម
គុណជាអកុសល ។

ពរទី ៥ ថា សូមឲ្យចៅជាបើនិងនាងព្រះស្នា បានគ្រប់គ្រងព
រីពិជ័យជេតុត្តរ ។

ពរទី ៦ ថា កាលបើយើងខ្ញុំ បានទៅដល់បុរីរាជធានីហើយ
សូមឲ្យមានអាហារទិព្វកើតឡើងរៀងរាល់ថ្ងៃ ។

ពរទី ៧ ថា សូមឲ្យការបរិច្ចាគទានរបស់យើងខ្ញុំ កុំបីមានខ្វះខាតអ្វីឡើយ ។

ពរទី ៨ ថា សូមឲ្យយើងខ្ញុំក្រោយរំលាងបញ្ចក្ខន្ធហើយ សូមឲ្យបានទៅកើតនាឋានតុសិតទេវលោកកុំបីខានឡើយ ។

ពរទាំងនេះ សុទ្ធតែបានបញ្ជាក់បង្ហាញនូវគោលបំណងដ៏ល្អរបស់ព្រះវេស្សន្តរចំពោះអ្នកនគរទាំងអស់ ។ យ៉ាងណាមិញ គ្រង់ពរខ្លះ ដូចជាពរទី ៥ ថា សូមឲ្យជាលីនិងនាងក្រស្នា បានគ្រប់គ្រងរាជ្យនៅនគរជេតុត្តរ ក៏ហាក់ដូចជាព្រះអង្គនៅតែជាប់ព្រះទ័យ អាល័យចំពោះបុត្រាបុត្រី ដែលទ្រង់បានលះឲ្យទៅតាជូជកទៅហើយនោះដានិច្ច ប៉ុន្តែទោះជាយ៉ាងណាក៏ព្រះអង្គ ក្នុងឋានៈជាបិតា ទ្រង់តែងតែមានព្រះទ័យនឹកគិតទៅដល់អនាគតរបស់បុត្រាបុត្រីជាការធម្មតា ព្រោះបំណងធំលើសនេះទៅទៀតនោះ មិនមែនត្រឹមតែការចង់ឲ្យបុត្រីបុត្រានេះ បានរាជសម្បត្តិប្រកបដោយសេចក្តីសុខយ៉ាងហូរហៀរប៉ុណ្ណោះទេ តែលើសពីនេះទៅទៀត គឺព្រះអង្គចង់ឲ្យជាលីក្រស្នា ជាសាច់ឈាមរបស់ព្រះអង្គនេះ បានទៅជាតំណាងព្រះហស្ត តំណាងព្រះអង្គទៅអនាគតក្នុងការជួយសង្គ្រោះប្រជាជនក្រីក្រក្នុងនគរឲ្យដូចក្នុងរាជ្យព្រះអង្គអញ្ចឹងដែរ

ចំពោះពរទី ៤ ថា សូមកុំឲ្យយើងខ្ញុំបានចិត្តត្រេកត្រអាលខា
ផ្លូវកាមគុណជាអកុសល និងពរទី ៨ ថា « សូមឲ្យយើងខ្ញុំក្រោយរំលា
បញ្ចក្ខន្ធហើយ សូមឲ្យបានទៅកើតនាឋានៈ តទេវលោកកុំបីខា
ឡើយ » ក៏បានបញ្ជាក់នូវព្រះទ័យសង្គោសប្រាថ្នា មិនចង់ឲ្យខ្លួនព្រះអ
ទៅជាមនុស្សខិលខូចក្នុងចំណង់អាក្រក់ ឬរៀងប្រពន្ធកូនអ្នកដទៃ ឬប
ជាមួយស្រីញីអាក្រក់ថ្លៃជាតិណាមួយនោះឡើយ ហើយការប្រាថ្នាឲ្
បានកើតក្នុងឋានតុសិតនោះសោតទៀត ក៏ដោយសារទីនោះជាទីដែល
មានតែមនុស្សល្អកើត ស្ដើងដោយកិលេសតណ្ហា អាចសន្សំតែកុសល
កម្មផ្សេង ៗ ទៀតបានដោយស្រួលទៀតផង ។

ដូច្នេះព្រះវេស្សន្តរមិនមែនជាអត្តទត្ថបុគ្គល ដូចអ្នកខ្លះបានយល
ឃើញនោះឡើយ ព្រោះអី ការសុំពរទាំង ៨ ប្រការនេះ សុទ្ធតែមាន
លក្ខណៈប្រកបដោយទស្សនៈល្អៗ ជាផលប្រយោជន៍, ជាសេចក្ដីល្អចំ-
ពោះមនុស្សក្រីក្រ, អ្នកមានទុក្ខទោសទាំងអស់ហើយសំណូមពរនេះបាន
ធ្វើឡើងនៅពេលក្រោយដែល ព្រះអង្គបានបញ្ចប់នូវបុត្តបរិច្ចាគនិងទារ-
បរិច្ចាគនេះឯង ។

## ប្រធាន

អន្តរាគមន៍របស់ពួកទេវៈ ជាចលនាមួយដ៏សំខាន់ ក្នុងអត្ថបទអក្សរសិល្ប៍ខ្មែរផ្នែកពុទ្ធនិយម ។

តើអន្តរាគមន៍របស់ពួកទេវៈក្នុងមហាវេស្សន្តរជាតក បានផ្ដល់នូវអ្វីខ្លះដល់តួអង្គ និងចលនាក្នុងជាតកនេះ ។

## អត្ថាធិប្បាយ

មេវន្តរាគមន៍នៅក្នុងអក្សរសិល្ប៍ខ្មែរ ពិសេសក្នុងចលនាពុទ្ធនិយមបែបខ្មែរនេះ មិនមែនគ្រាន់តែបង្ហាញនូវសភាពអស្ចារ្យប្លែកប៉ុណ្ណោះ

ទេ ប៉ុន្តែជាកត្តាមួយអាចនាំដំណើររឿងឲ្យប្រែប្រួលផ្លាស់ប្ដូរដំណើរ
ចលនាមួយ ទៅចលនាមួយទៀត តាមគោលបំណងនៃអ្នកនិពន្ធ
ក៏មាន ។

អន្តរាគមន៍របស់ពួកទេវៈក្នុងអក្សរសិល្ប៍ផ្នែកពុទ្ធនិយម មាន
ចលនាច្រើនបែបយ៉ាងណាស់ ហើយចលនានេះអាចប្ដូរដំណើររឿ
ឲ្យផ្លាស់ពីសភាពមួយទៅកាន់សភាពមួយទៀតបាន ។ អន្តរាគមន៍ទេ
មានលក្ខណៈពិសេស គឺជាជំនួយក្រៅខ្លួនមួយរបស់តួអង្គណាម្នាក់
ច្រើនគ្នា ដែលទទួលទុក្ខលំបាកវេទនាខ្លាំងហួសគំរិត ទាល់ច្រកទាល់
ផ្លូវគ្មានមធ្យោបាយណានឹងដោះស្រាយកើតក្រៅពីការចាំទទួលការព្រាត់
ប្រាស ឬ ស្លាប់បាត់បង់ជីវិតអសារបង់ដោយអំពើអយុត្តិធម៌ណា ១ មក
គ្របសង្កត់ ហើយរកផ្លូវដោះស្រាយគ្មាន ។ ពួកទេវៈចុះមកជួយភោគ
កុលកុមារក្នុងដំណើរទៅតាមរកនាងសុខមាលន្ធា ដោយក្លែងខ្លួនជាត្មាត
ក្អែក ឬ ជារុយ ឬមួយពួកទេវៈជួយដាក់ថ្នាំបន្សាបពិស គិន្នរពោធិសត្វ
ដែលត្រូវព្រះបាទព្រហ្មទត្តបាញ់សម្លាប់នៅក្នុងព្រៃ ( គិន្នរីជាតក ) ឲ្យ
សាបរលាបបានរស់រានមានជីវិតឡើងវិញជាដើម ។ តួអង្គដែល
ត្រូវទទួលទុក្ខទារុណកម្មបែបខាងលើនេះ បើគ្មានទេវន្តរាគមន៍ទេ និង
មិនអាចសម្រេចបំណងណាមួយបានឡើយ ហើយមិនតែប៉ុណ្ណោះ

សាត ដំណើររឿងដែលទាល់ច្រកបែបនេះហើយ បើគ្មានទេវន្តរាគមន៍ទ ក៏អាចក្លាយទៅជារឿងសោះកក្រោះ គ្មានចម្ងាញ់ គ្មានខ្លឹមសារសារៈ ។

ផ្ទុយពីទេវន្តរាគមន៍បែបខាងលើនេះបន្តិចនៅក្នុងមហាវេស្សន្តរជាតក ទេវន្តរាគមន៍បានផ្ដល់នូវចលនាប្លែក ៗ គ្នាគឺ:

- បង្កើតឲ្យមានវិបត្តិទំនាស់រវាងតួអង្គនីមួយ ៗ ដើម្បីចោទជាបញ្ហាបង្កើតរឿងតទៅមុខទៀត ឧ– ពួកទេពតាបកអាភៀសបញ្ចូលចិត្តពួកអ្នកស្រីពិរាស្ត្រឲ្យខឹងនឹងព្រះវេស្សន្តរ ថែមទាំងបានសុំឲ្យបំបរ-បង់ព្រះវេស្សន្តរឲ្យទៅគង់នៅក្នុងព្រៃភ្នំទៀតផង ។ ឬមួយពួកទេវៈបានក្លែងកាឡាខ្លួនជាខ្លាធំ រាជសីហ៍ ខ្លាដំបងទៅស្កាត់រាំងដំណើរនាងមទ្រីកុំឲ្យយាងមកសាលាវិញទាន់ក្នុងវេលាថ្ងៃ ដែលជាបុព្វហេតុនាំឲ្យនាងមទ្រីមានវិបត្តិទំនាស់នឹងព្រះស្វាមី ហើយត្រូវឃ្លាតពីបុត្រីបុត្រា ។

ផ្ទុយពីការបង្កើតវិបត្តិទំនាស់ ធ្វើឲ្យចលនារឿងមានសកម្ម-ភាព និងមានដំណើរតឹងតែង ទេវន្តរាគមន៍បានជួយតួអង្គឲ្យបានស្រួល ធ្វើដំណើររឿងឲ្យធូរស្រាលវិញ ឧទាហរណ៍ ទេវតាជួយបង្រួមផ្លូវពីមាតុគុលនគរ ទៅគិរីវង្កត, ជួយនិម្មិតសាលាថ្វាយព្រះវេស្សន្តរ,

ចុះមកធ្វើជាព្រះវេស្សន្តរ និងព្រះនាងមទ្រី ហើយចូលទៅបំពៅបំពេរថ្នា
ថ្នម ជាលីក្រស្នា, ជួយបង្វែងផានតាជូជកឲ្យភ័ន្តច្រឡំផ្លូវដើរចូលទៅ
នគរជេតុត្តរ ដើម្បីនឹងឲ្យជាលីក្រស្នាបានជួបនឹង រាជអយ្យកោអយ្យិកា
ព្រះឥន្ទ្រកាឡាខ្លួនចុះមកសុំនាងមទ្រីពីព្រះវេស្សន្តរ ហើយថ្វាយទៅព្រះ
វេស្សន្តរវិញជាដើម ។

— មិនតែប៉ុណ្ណោះ អន្តរាគមន៍មួយផ្នែកទៀតបានជួយបំពេញ
ទានបារមីព្រះវេស្សន្តរថែមទៀត ដូចជាទេពតាដែលកាឡាខ្លួនជាសត្វ
សាហាវទាំង ៣ ចាំស្កាក់ផ្លូវព្រះនាងមទ្រីកុំឲ្យយាងមកទាន់ពេលតាជូជក
ដែលមកសុំជាលីក្រស្នា ឬព្រះឥន្ទ្រកាឡាខ្លួនជាព្រាហ្មណ៍មកសុំព្រះនាង
មទ្រី ។ កិច្ចការទាំងនេះ គឺជាលក្ខណៈបង្អាក់ដំណើរ ឬ ជាអ្វីមួយ
ក៏ដោយ ក៏មានសភាពស្ថិតនៅក្នុងការជួយបំពេញទានបារមីរបស់ព្រះ
វេស្សន្តរដែរ ។

ដូច្នេះ ទេវន្តរាគមន៍ក្នុងអក្សរសិល្ប៍ខ្មែរផ្នែកពុទ្ធនិយមនេះ ជា
ជំនួយដ៏សំខាន់ម៉្យាងដល់តួអង្គ ឬដំណើររឿងដែលជួបនឹងវិបត្តិទំទាស់
ខ្វាំងក្លា, ទាល់ច្រកមែនទែន ឲ្យបានធូរស្បើយវិញនេះឯង ។ ទេ-
វន្តរាគមន៍ក្នុងមហាវេស្សន្តរជាតក មិនត្រឹមតែបានលក្ខណៈដូចខាងលើ

នេះប៉ុណ្ណោះទេ ប៉ុន្តែផាចលនាមួយបង្កើតនូវបញ្ហាចោទ និងជួយដោះស្រាយទានបារមីរបស់ព្រះវេស្សន្តរមួយកំរិតយ៉ាងធំ ថែមទាំងធ្វើបំណើររឿងដែលស្ថិតនៅក្នុងបរិយាកាសតឹងតែងស្ទើរដាច់ទៅហើយនោះឲ្យបានធូរស្រាលវិញ ជាពិសេសគឺជួយបញ្ចប់ដំណើររឿងឲ្យស្ថិតនៅក្នុងក្របខ័ណ្ឌនៃចលនាអក្សរសិល្ប៍ពុទ្ធនិយមទៀតផង ។ ចលនានៃទេវន្តរាគមន៍មានតម្លៃស្មើនឹងតួអង្គឯទៀត ៗ ក្នុងផ្នែករឿងដែរ ។

## បញ្ហាទេវន្តរាគមន៍

១– ជួយមនុស្សខូចឲ្យប្រព្រឹត្តអាក្រក់ខ្លាំងឡើងៗ — ទេវតាជួយព្រះពិទវង្សឲ្យទៅដល់កន្លែង ទាតសុវណ្ណខេមានិងនាងបទុមសុរិយា ។

– ២ ជួយផ្តល់បុត្តិធម៌ដល់តួអង្គ ដែលទទួលអកុសលទោសដូចក្នុងរឿងមរណមាតា, និងទសជាតក៏ជាដើម ។

– ៣ ជួយដោះស្រាយវិបត្តិធំនាស់ ដែលតឹងតែងឲ្យបានធូរស្រាលឬជួយបំពេញទានបារមីដូចក្នុងមហាវេស្សន្តរជាតក ។

# ប្រធាន

ក្នុងកុមារជាតិ ព្រះវេស្សន្តរទ្រង់ មានព្រះបន្ទូល នឹងរាជបុត្រាបុត្រីថា « កូនអើយ អាពុកទុកបាសពូវថ្ងៃ ស្មើសំពៅភេគ្រាធំចិញ្ចែងសំរាប់ ចំ-ឡងឆ្លងកាត់សមុទ្រសង្សារ ដាក់ដល់ត្រើយ គឺព្រះនិព្វាន អា-ពុកនឹងចម្លងអស់ពពួកសត្វនិករអមរ នូចឥន្ទព្រហ្ម មនុស្សសត្វផងទៅ ដាក់ព្ធដ៏ស្ថាននិព្វាន ទាំងអស់ ហោង » ។

យោលតាមព្រះបន្ទូល ខាងលើនេះ តើជាលីក្រស្លាជាតួអង្គយ៉ាង

ណាក្នុងមហាវេស្សន្តរជាតក ។ ចូរធ្វើអត្ថាធិប្បាយបញ្ជាក់ ដោយមានគោលអាង ។

## អត្ថាធិប្បាយ

ក្នុងការសាងបារមីរបស់ព្រះវេស្សន្តរ, ក្រៅពីទ្រព្យសម្បត្តិផ្សេងៗ ដែលព្រះអង្គត្រូវលើកប្រទានទៅអ្នកផងទាំងពួង, ជាលីក្រស្នាក៏ជាកត្តានៃទានបារមីដ៏សំខាន់របស់ព្រះវេស្សន្តរដែរ ដោយព្រះអង្គបានទុកនូវរាជបុត្រាបុត្រីទាំងពីរអង្គនេះ ស្មើនឹងសំពៅមាសមួយដ៏ធំ សម្រាប់ចម្លងព្រះអង្គឲ្យដល់ត្រើយនៃសេចក្ដីប្រាថ្នា ។

យើងរស់នៅ, យើងមានកូនប្រុសស្រីជាទីពឹង, ជាអ្នកតពូជពង្ស ។ កូនជាទីពឹងរបស់ឪពុកម្ដាយ មិនមែនបានន័យថា ឪពុកម្ដាយសុទ្ធតែត្រូវរស់ ចង់មានបានទ្រព្យសម្បត្តិដោយសារកូនប្រុសស្រីនោះឡើយ គឺប៉ុន្តែឪពុកម្ដាយតែងចង់យកកូនធ្វើជាទីពឹងដ៏សំខាន់មួយ ក្នុងការជួយលើកតម្កើងកិត្តិយសនៃគ្រួសារពង្សរបស់ខ្លួន, ចង់ឲ្យកូនធ្វើសេច-

ក្ដីព្យ ដើម្បីឪពុកម្ដាយបានខ្ពស់មុខមាត់ មិនខ្មាសគេៀនអ្នកជងទាំងពួង
មិនតែប៉ុណ្ណោះ ឪពុកម្ដាយសប្បាយចិត្តយ៉ាងខ្លាំងបំផុត ចំពោះកូនដែល
ស្ដាប់ដំបូន្មាន ធ្វើតាមបំណងណាដែលខ្លួនបង្គាប់បញ្ជាឬ ចង់ឲ្យធ្វើ ។
ក្នុងច្បាប់ពុទ្ធសាសនា, ច្បាប់ស្រីមិគោបទេស, ច្បាប់ផ្សេង ។ របស់ខ្មែរ
យើងជាដើម តែងប្រើងចោទនិងដោះស្រាយបញ្ហាកូនប្រុសស្រីនេះណាស់
ដើម្បីធ្វើការបញ្ជាក់ហើយបញ្ជាក់ទៀតថា កូនជាទីពឹងរបស់ម្ដាយឪ—
ពុក ។ សុភាសិតខ្មែរមួយ បានបញ្ជាក់រិតតែច្បាស់ណាស់ថា

**« ទំពាំងស្នងឫស្សី »** ។

ក្នុងមហាវេស្សន្តរជាតក, ជាលីក្រស្នាជាកូនដ៏សំខាន់ណាស់
គឺពិតជាទីពឹងនៃឪពុកម្ដាយមែន ដោយព្រះវេស្សន្តរបានទុកដាក់ថា មាន
តម្លៃស្មើនឹងសំពៅមួយដ៏ធំ សម្រាប់ចម្លងព្រះអង្គឲ្យធ្វើដំណើរទៅកាន់
ត្រើយនៃគោលបំណងក្នុងការធ្វើទានបារមី ។ តាមព្រះបន្ទូលនេ
យើងអាចសន្និដ្ឋានបានថា ជាលីក្រស្នាជាទីពឹងពំនាក់របស់ព្រះអង្គក្នុង
ការកសាងប្រាជ្ញាសម្មាសម្ពោធិញាណ ។ ក្នុងការបំពេញទានបារ
នៅក្នុងព្រៃភ្នំ បើកុំមានជាលីក្រស្នា ព្រះវេស្សន្តរមិនដឹងបានអីធ្វើបុត្ត—
បរិច្ចាគ ហើយក៏មិនដឹងបានអ្វីនឹងសម្រេចគោលបំណងបានដែរ ហើយ
ប្រសិនបើជាលីក្រស្នាមិនព្រមធ្វើតាមបំណង ក៏ព្រះវេស្សន្តរជាបិតាមិ

អាចធ្វើទានបារមីផ្នែកនេះបានសម្រេចផលឡើយ ។

ផ្ទុយទៅវិញ ជាលីក្រស្នាទោះជាស្ថិតនៅក្នុងវ័យក្មេងតូច ទើបនឹងបានព្រះជន្ម ៤ វស្សានិង ៣ វស្សាប៉ុណ្ណេះក៏ដោយ ក៏ក្សត្រាក្សត្រី ទាំងពីរអង្គនេះមានព្រះទ័យថ្លៃថ្នូរបីក្មាលក្នុងការបំពេញគោលបំណងព្រះ បិតាណាស់ សុខចិត្តឲ្យបិតាដាក់ទានព្រះអង្គទៅតាជូជកកំណាចដោយ ឥតរួញរាសោះឡើយ ។ នាងក្រស្នាសូម្បីមានវ័យនៅតូចក្តីក៏នាងស្ទើ តាមដំណាងបិតាជានិច្ច ឧទាហរណ៍ ទំព័រ ៣៣៧ ថា "...ទោះយោ បីព្រាហ្មណ៍នេះវាសម្លាប់អញក្តី ក៏តាមចំនើងចិត្តវាចុះ អញនឹងឡើងទៅ ថ្វាយបង្គំព្រះជនកអញឥឡូវនេះ" ។ ជាលីជាកុមារបានស្គាល់ជាក់នូវ លក្ខណៈតាជូជកថា ជាមនុស្សចាស់កាចសាហាវ ព្រោះប្រកបដោយ ប្រុសទោស ១៨ ប្រការ មានជាទជើងនោះធំស្គក់ ដំបារកោងកូកជា ដើម ។ ទំព័រ ៣៤៥-៣៤៧ ។

លក្ខណៈទាំងប៉ុន្មានខាងលើនេះ បានធ្វើឲ្យយើងយល់ស្រប ទៅតាមព្រះបន្ទូលនៃព្រះវេស្សន្តរខាងដើមនោះដែរ គឺជាលីក្រស្នាជា ស្ពានចម្លងទានបារមីឲ្យបានសម្រេចមែន ។

បិនតែប៉ុណ្ណោះសោត ជាលីក្រស្នាជាអ្នកការពារសកម្មភាព ព្រះវេស្សន្តរជាបិតានៅចំពោះការចោទប្រកាន់ របស់ពួកសេនាមាត្យទៀត

ផង ឧទាហរណ៍ « បពិត្រសម្តេចព្រះរាជអយ្យកោអើយ ម្តេចឡើ
ក៏ពួកអាមាត្យនាំគ្នាពិន្ទាសម្តេចព្រះវរបិតាខ្ញុំ ហេតុអ្វីតរឿករទាវនៅក្នុង
ព្រឹក្សានាកាលសម្តេចព្រះវររាជបិតាចេញចាកបុរី ពុំបានអ្វីជាទ្រព្យសម្ប
សព្វពិតពេក ខ្ញុំប្រុសស្រីដំរីសេះ រទេះគោក្របី នឹងធ្វើទានដូចរស់
កូលេក្យត្រវិរំពីរាជ្យរៀងមកឡើយ បពិត្រសម្តេចព្រះអយ្យកោអើយ រ
ព្រះរាជហឫទ័យសម្តេចព្រះវររាជបិតាតែងនឹងកាត់វិលាសទ្ធាធ្វើទាន ជា
យល់តែមុខបុត្រាបុត្រី ពាពាហ៊ិរទានក្រៃលែងនឹងរស់ទានផងបាន ១០
កំលាំងតាំងព្រះរាជហឫទ័យ នឹងផ្សាយកព្រះសព្វញ្ញុតញ្ញាណ ឲ្យបា
ព្រោសជាព្រះពុទ្ធតាមប្រវេណីព្រះពុទ្ធរំពីបុរាណ ស្អាងព្រះបារមីទា
តាមព្រះរាជហឫទ័យព្រាថ្នាឲ្យបានមគ្គផល ម្តេចឡើយក៏ពួកមនុស្សអ
សេលបពត្ថុះពិះដៀលផល់ព្រះវររាជពិតា ពិនដឹងទេឬ ថាប្រទីបផ្កាលាត
ជាពន្លឺរស់សព្វសត្វ ម្តេចឡើយក៏បកស្កាត់ សំដីការអ៊ុមកស្រដិតោទ្បេ
អឹងករ រាសម្តេចព្រះអយ្យកោតើយល់ព្រមដូចពាក្យរស់មុខមន្ត្រីហើយ
ឬអញ្ញាស់ ។ ទំព័រ ៤៣៨ - ៤៣៩ ។

រាជកុមារជាលី ជាអ្នកស្គាល់ឋានៈព្រះអង្គណាស់ ព្រោ
ពេលដែលព្រះរាជអយ្យកោពុំទាន់លោះខ្លួនព្រះអង្គពីតាជូជកទេ ទ្រង់
តាំងខ្លួនថាជាមនុស្សដូចទាសាទាសីគេធម្មតា ។ លុះព្រះបាទព្រ
សញ្ជ័យសួរសាក ព្រះអង្គក៏ទូលពពិមានសព្វគ្រប់រំពីតម្លៃខ្លួនព្រះអង្គ និ

នាងក្រស្នា ដែលព្រះបិតាបានកាត់តម្លៃរួចមកហើយ ឥតមានភ្លេចកន្លែងណាសោះ ។

ជាលីជាស្ពានចម្លងព្រះបិតាឲ្យបានវិលមកក្នុងព្រះនគរវិញ ដូចសំណូមពរដែលព្រះវេស្សន្តរបានសុំចំពោះព្រះឥន្ទ្រមែន ។ ពេលព្រះរាជអយ្យកោបានសាកសួរជាលី ៗ ក៏បានទូលពត៌មានអំពីការលំបាករបស់ព្រះមាតាបិតា ដែលគង់នៅក្នុងព្រៃភ្នំនោះសព្វគ្រប់ ដែលជាបុព្វហេតុនាំឲ្យព្រះបាទស្រីសញ្ជ័យទ្រង់លើកកងទ័ពទៅអញ្ជើញព្រះវេស្សន្តរ ឲ្យយាងចូលមកក្នុងនគរវិញ ។ ពេលកងទ័ពលើកចូលទៅកាន់គិរីវង្កត ជាលីជាបគ្គុទ្ទេសក៍ដ៏សំខាន់ក្នុងការនាំផ្លូវ ព្រះបាទស្រីសញ្ជ័យ និងរាជបរិពារចូលទៅកាន់ គិរីវង្កត ពោលគឺ កាលតាជូជកនាំរាជកុមារទាំងពីរបណ្តើរកាត់ព្រៃមក ទោះបីព្រៃពិតស្និទ្ធក្រាស់ ហើយជាលីក្រស្នាមានទុក្ខទោសទារុណកម្មបែបណាក៏ដោយ ក៏រាជកុមារនៅតែកត់សំគាល់ចាំផ្លូវបានទាំងអស់ឥតភ្លេចភ្លាំង ឬ ភាន់ច្រឡំសោះឡើយ ។

ដូច្នេះ ជាលីក្រស្នា ជាកត្តានៃទានបារមីរបស់ព្រះវេស្សន្តរផង ជាតួអង្គដែលជួយដោះស្រាយវិបត្តិទំនាស់ក្នុងទានបារមី ឲ្យបានផុតរលត់ផង ហើយជាស្ពានចម្លងព្រះវេស្សន្តរដែលគង់នៅក្នុងព្រៃឲ្យបានវិលត្រឡប់ចូលមកកាន់ព្រះនគរវិញផង ។

# ប្រធាន

ភ្លៀងបោក្ខរពស្សក្នុងកណ្ដាលស-
ពារនិងក្នុងនគរកណ្ដាលតើមានន័យនិង
តម្លៃដូចគ្នាឬផ្សេងគ្នា ។

## អត្ថាធិប្បាយ

តាមផ្នែកនៃអដ្ឋកថាក្នុងមហាវេស្សន្តរជាតក ភ្លៀងបោក្ខរពស្សិ
បានធ្លាក់ចុះពីរលើក ។ ភ្លៀងពិសេសនេះ មិនគ្រាន់តែបញ្ចេញ
នូវសភាពអស្ចារ្យ ធ្វើឲ្យមនុស្សដែលបានជួបប្រទះក្នុងពេលនោះ មានការ
កោតស្ញប់ស្ញែងប៉ុណ្ណោះទេ ប៉ុន្តែបានចោទជាបញ្ហា ព្រមទាំងមានធម៌
និងតម្លៃយ៉ាងប្លែកទៀតផង ។

ក្នុងកណ្ដាលសពារផ្នែកខាងដើមភ្លៀងបោក្ខរពស្សិបានបង្អុរចុះនៅ
ពេលដែលព្រះពុទ្ធអង្គយាងចូលទៅក្រុងកបិលពស្តុជាលើកទី ១ បន្ទាប់
ពេលបានត្រាស់ដឹងមក ១០ ខែ ( ថ្ងៃពេញបូរមីខែផល្គុន ) ។ ពេ

ព្រះអង្គយាងចូលទៅនោះ ពួកញាតិវង្សមានព្រះបាទ **សិរីសុទ្ធោទន.** ពុទ្ធបិតាជាប្រធាន បាននិមន្តព្រះអង្គទៅគង់នៅឧទ្យានឈ្មោះនិគ្រោធ ( ឧទ្យានដែលមានដើមជ្រៃធំ ៗ ផុះ ) ។ ពួកញាតិវង្សដែលមានទិដ្ឋិមានះរឹងត្អឹងតាំងពីយូរហើយនោះ ក៏គិតគ្នាទុកជាស្រេចថានឹងមិនថ្វាយបង្គំព្រះពុទ្ធទេព្រោះព្រះអង្គត្រូវជាកូន, ជាក្មួយ,ជាបង, ជាប្អូនរបស់គេគ្រប់គ្នា ។ ព្រះពុទ្ធទ្រង់ជ្រាបអធ្យាស្រ័យនេះហើយក៏ទ្រង់ចូលចតុត្ថជ្ឈានអភិញ្ញាសមាបត្តិ ហើយហោះផ្ទោះឡើងទៅក្នុងផ្ទៃអាកាស បញ្ចេញពន្លឺរស្មីភ្លឺព្រោងព្រាយហាក់ដូចធូលីហុយ ចុះមកលើព្រះកេសពួកសាក្យ-រាជទាំងអស់ ។ ទំព័រ ២០-២១ ។ ពួកសាក្យរាជកាលឃើញដូច្នោះក៏នាំគ្នាលើកព្រះហស្តសំពះប្រណម្យថ្វាយបង្គំព្រះពុទ្ធជាម្ចាស់ ថែមទាំងសរសើរគុណបារមីព្រះអង្គដោយព្រះទ័យត្រេកអរសាទរទៀតផង ។ គឺក្នុងខណៈនោះហើយដែលភ្លៀងបោក្ខរពស៌ បានបង្អុរធ្លាក់ចុះលើពួកសាក្យរាជទាំងនោះនៅកណ្តាលជំនុំជន ។ ភ្លៀងបោក្ខរពស៌ដែលធ្លាក់ចុះនេះគឺធ្លាក់ក្រោយភ្លៀងបោក្ខរពស៌ ដែលបង្អុរនៅពេលដែលព្រះពុទ្ធអង្គទ្រង់យោនយកកំណើតជាព្រះវេស្សន្តរនៅ ឯភ្នំ គិរីវង្កត ។

ភ្លៀងបោក្ខរពស៌ ដែលបង្អុរចុះនៅកណ្តាលជំនុំពួកញាតិឯក្រុងកបិលព័ស្តុនេះ មានន័យសេចក្តីដ៏សំខាន់ត្រង់បណ្តាលឲ្យព្រះពុទ្ធជា

ម្ចាស់អាចរកមធ្យោបាយមួយថ្មី ក្នុងការសំដែងមហាវេស្សន្តរជាតកនេះ ឡើងបានដោយស្រួល ហើយមានតម្លៃដ៏សំខាន់ត្រង់ការដែលធ្វើឲ្យពួក ញាតិដែលបាត់ទិដ្ឋិមានះហើយនេះ នាំគ្នាចុះចូលដោយការយកចិត្តទុក ដាក់នឹងស្តាប់មហារឿងនេះផង និងធម៌ដទៃរបស់ព្រះពុទ្ធផ្សេងទៀតផង ។

ផ្ទុយទៅវិញ បើភ្លៀងបោក្ខរពស៌មិនបង្អុរចុះទេ ពួកញាតិ នឹងខ្វះការគោរព ហើយជាពិសេសខ្វះការកើតសរសើរស្ញប់ស្ញែងចំពោះ ព្រះអង្គ នៅតែទុកព្រះអង្គថា ជាកូន, ជាក្មួយ ឬជាញាតិមិត្តមួយធម្មតា គ្មានការអ្វីប្លែកសោះឡើយ ព្រោះពួកញាតិទាំងនោះ ឬអ្នកក្រុងកបិល– ពស្តុទាំងមូល ក្រៅតែពីពួកភិក្ខុជាអតីតរាជទូតព្រះបាទសិរីសុទ្ធោទនៈ ចំនួន ១០១០ អង្គ គ្មានជនណាម្នាក់ដឹងថា ព្រះសិទ្ធត្ថទ្រង់ត្រាស់ដឹងធម៌ នោះយ៉ាងណាៗសោះឡើយ ដូចកង្កែបនៅក្នុងអណ្តូង មើលឃើញ តែត្រីអណ្តូងនៅជុំវិញខ្លួនថាធំធេងណាស់ គ្មានទីណាធំជាងនេះទៀត ទេ ។ កាលបើដូច្នេះ ព្រះពុទ្ធត្រូវមានការលំបាកយ៉ាងខ្លាំងជាងនេះ ក្នុងការសំដែងធម៌ពន្យល់ប្រាប់ផ្លូវល្អ-អាក្រក់ ។ បើមានភ្លៀងបោក្ខរ- ពស៌នេះបង្អុរចុះហើយ ពួកញាតិនិងជនដទៃទៀត បានផ្តោតចិត្តផ្ចិត អារម្មណ៍មកតែលើព្រះអង្គមួយគត់ទៅហើយ ព្រះអង្គអាចសំដែងធម៌ ណាក៏បាន ប៉ុន្តែព្រះអង្គត្រូវតែលើកយកមហាវេស្សន្តរជាតកនេះមក

ទេសនា ព្រោះជាខ្សែរឿងមួយដ៏សំខាន់មានទំហំនិងប្រវែងល្មម មានធាតុអស្ចារ្យ, កំសត់, ទារុណកម្មលាយឡំជាមួយ, មានការចុះអន់ថយពីភាពជាមហាក្សត្រ ទៅជាអ្នកបួសនៅក្នុងព្រៃ ហើយការគង់នៅក្នុងព្រៃនោះក៏ដោយសារពួកប្រជាជនក្នុងនគរបំបរបង់ចេញ, មានទារុណកម្មប្រកបដោយទាសភាពពោលគឺជាលីក្រស្នាជាដើមហើយ នៅភាគខាងចុងរឿងនេះមានភ្លៀងបោក្ខរពស់បែបនេះបានបង្អុរចុះដូចក្នុងពេលហ្នឹងដែរ ។

ចំណែកខាងភ្លៀងបោក្ខរពស់ ដែលបង្អុរចុះនៅឯភ្នំគិរីវង្កតវិញ គឺបានប្រព្រឹត្តទៅនៅពេលដែលក្សត្រទាំង ៦ អង្គ . បានជួបជុំគ្នានៅក្នុងទីមួយ ក្រោយពេលមានហេតុវិបត្តិ ព្រោះទានបារមីរបស់ព្រះវេស្សន្តរ ។ ភ្លៀងនេះធ្លាក់ចុះនៅពេលដែលក្សត្រទាំង ៦ អង្គបានជួបគ្នាហើយសោយសោកសន្លប់បាត់ស្មារតីជាមួយគ្នា, ពួកបរិពារឃើញដូច្នោះក៏សោកទាល់តែសន្លប់ដែរ លុះតែភ្លៀងបោក្ខរពស់ធ្លាក់មកលើ ទើបបានដឹងព្រះអង្គ ដឹងខ្លួនឡើងវិញ ។

ភ្លៀងបោក្ខរពស់ក្នុងពេលនេះ ធ្លាក់ចុះតាំងពីកាលព្រះវេស្សន្តរនៅជាពោធិសត្វឯណោះ ហើយភ្លៀងនេះ ក៏មានន័យនិងតម្លៃផ្សេងពីភ្លៀងនៅឯក្រុងកបិលព័ស្តុដែរ ផ្សេងគ្នាត្រង់ភ្លៀងនៅគីរីវង្កត ជាហេតុ ១ ដែលផុសឡើងដើម្បីបញ្ចប់នូវវិបត្តិទំនាស់ផ្សេង ៗ ក្នុងសកម្មភាពនៃទាន-

ភរិយានោះឯង ។

ពួករាជវង្ស, ពួកអាមាត្យ ឬជនដទៃទៀត កាលបើមានទ្រព្យសម្បត្តិ ហើយមានទាំងភ្លៀងបោក្ខរពស៌ធ្លាក់ចុះមកបែបនេះទៅហើយ តើនឹងនៅប្រកាន់ទោសអួសដំណើរព្រះវេស្សន្តរបែបម៉េចទៀត ពេលនេះត្រូវតែសុំអញ្ជើញព្រះវេស្សន្តរ ឲ្យចូលទៅកាន់រាជបល្ល័ង្កវិញជាការចាំបាច់ ។

ដូច្នេះភ្លៀងបោក្ខរពស៌ ដែលធ្លាក់ចុះក្នុងពេលទាំងពីរនេះ មិនមានន័យនិងតម្លៃដូចគ្នាឡើយ ។ កាលភ្លៀងនេះធ្លាក់ចុះនៅឯកបិលពស្ដុ គឺដើម្បីផល់ការងាយស្រួល ក្នុងការសំដែងធម៌របស់ព្រះពុទ្ធអង្គ ព្រោះភ្លៀងនេះជាគ្រឿងទាញទឹកចិត្តពួកសាក្យរាជ ឲ្យយោគអារម្មណ៍ចាប់ភ្ជាប់មូលមកលើព្រះអង្គតែមួយ ហើយម្យ៉ាងទៀត គឺដើម្បីព្រះពុទ្ធទ្រង់បានទេសនាមហាវេស្សន្តរជាតក៏ ដែលមានភ្លៀងបែបនេះបង្អុរចុះដែរ ។ ចំណែកខាងបោក្ខរពស៌ដែលបង្អុរចុះ នៅពេលព្រះវេស្សន្តរបានជួបជុំព្រះញាតិវង្សនៅឯគិរីវង្កតនោះ ជាភេទ ១ សម្រាប់បញ្ចប់វិបត្តិទំនាស់ ដែលលេចចេញឡើងពីការធ្វើទានបារមីនៃព្រះពោធិសត្វផង និងដើម្បីផល់ការងាយស្រួលផល់ការយាងត្រឡប់ចូលមកព្រះនគរ តាមរយៈពរ ៨ ប្រការរបស់ព្រះឥន្ទផង ។

# ប្រធាន

ចូរលើកឆ្លងការសរជាតិក្នុងទីបំផុតនៃមហាវេស្សន្តរជាតក មកធ្វើការសិក្សាបញ្ជាក់ ។

## អត្ថាធិប្បាយ

រឿងរ៉ាវផ្សេង ៗ ក្នុងជាតកពុទ្ធនិយម ឬ រឿងដែលមានលក្ខណៈបែបពុទ្ធនិយមក្លែងក្លាយខ្លះ ដូចជារឿងគាកិជាដើម កវីនិពន្ធតែងលើកនូវការសរជាតិមកចង្អុលបង្ហាញនៅចុងចប់នៃរឿងជាដរាប។ការសរជាតិនេះជាលក្ខណៈសំខាន់ ១ ក្នុងចំណោមលក្ខណៈសំខាន់ ៗ នៃរឿងរ៉ាវបែបពុទ្ធនិយម ។

ការសរជាតិជាកត្តាដ៏សំខាន់ ១ សម្រាប់បញ្ជាក់នូវផលនៃកម្មដែលតួអង្គនីមួយ ៗ បានធ្វើហើយ, អ្នកធ្វើល្អ បានមកជាតួអង្គមាន

លក្ខណៈនិងសកម្មភាពល្អ ដូចជាព្រះពុទ្ធ, ព្រះសារីបុត្ត, មោគ្គល្លាន នាងឧប្បលវណ្ណាថេរី. នាងវិសាខាជាដើម ចំណែកខាងអ្នកធ្វើអាក្រក់ ក៏បានជាតួអង្គអាក្រក់ ដូចជា ទេវទត្ត, នាងចិញ្ចាជាដើម ។

ចំពោះការសរជាតិក្នុងមហាវេស្សន្តរជាតកវិញ ឃើញថា មិនមានការសមហេតុផលទាំងអស់ទេ តួអង្គខ្លះក៏បានលក្ខណៈសម ទៅតាមសកម្មភាពរបស់ខ្លួនពិតមែន ក៏ប៉ុន្តែ មានតួអង្គខ្លះពុំសមហេតុ ផលឡើយ ដែលយើងត្រូវលើកយកមកធ្វើការសិក្សា– ពិភាក្សាដូច តទៅ :

## ១) អំពីតួអច្ចតាជូជក បានសរជាតិទៅកើត

**ជាភិក្ខុទេវទត្ត** — ការសរជាតិនៃតួអង្គនេះ ពុំមានលក្ខណៈសម ហេតុផលឡើយ ព្រោះតាជូជកគ្មានធ្វើកំហុសអ្វីចំពោះព្រះវេស្សន្តរ សោះ ។ ហេតុដែលនាំឲ្យគាត់ទៅ សុំ ជាលីក្រស្នាពីព្រះវេស្សន្តរ ក៏ដោយសារឮល្បីល្បាញថា ព្រះវេស្សន្តរ ជាក្សត្រមានព្រះទ័យទូលាយ ចង់តែធ្វើទាននេះណាស់ ហើយពេលជួបព្រះវេស្សន្តរ ក៏តាជូជកបាន ទូលសុំជាលីក្រស្នាដោយត្រង់តាមដំណើរហេតុ ។ ក្នុងករណីនេះប្រ សិនបើព្រះវេស្សន្តរមិនព្រមប្រទានជាលីក្រស្នា កំតាជូជកមិនហ៊ានទៅ ដណ្ដើម ឬ ប្រទូស្តរ៉ាយដោយប្រការណា១ដែរ ប៉ុន្តែដោយព្រះវេស្សន្តរ

សុខព្រះទ័យលើកប្រទានឲ្យ តាជូជកក៏ទទួលយកតាមការគួរ លុះតាជូជកបានជាលីក្រស្នាហើយ ព្រះកុមារទាំងពីរពិតជាសម្បត្តិកម្មសិទ្ធិរបស់គាត់ផ្តាច់មុខ បើជនណាចង់បាន ជននោះត្រូវតែយកមាសមួយពាន់តម្លឹងទៅលោះទើបបាន ព្រោះអី តម្លៃប៉ុណ្ណោះ គឺលេចចេញពីព្រះឱស្ឋព្រះវេស្សន្តរនោះឯងដែលបានកាត់ដោយព្រះអង្គឯង ។ ដូច្នេះសូម្បីព្រះវេស្សន្តរក្តី បើចង់បានជាលីក្រស្នាមកវិញ ត្រូវតែយកទ្រព្យអ្វីដែលមានតម្លៃស្មើនឹងមាស ១ ពាន់តម្លឹងទៅលោះជាលីក្រស្នាមកទើបបាន ។ តាជូជករាយបណ្តើរជាលីក្រស្នា យើងពុំអាចចោទប្រកាន់គាត់បានទេ ព្រោះជាលិក្រស្នាជាកម្មសិទ្ធិរបស់គាត់ទៅហើយ ព្រះវេស្សន្តរបានប្រទានជាលីក្រស្នានេះ មានទាំងស្រោចទឹកកុណ្ឌីលើដៃគាត់ ហើយសុំប្រាថ្នាប្រាជ្ញាសព្វញ្ញុតញ្ញាណទៀតផង ។

ដូច្នេះ តាជូជកនេះជាតួអង្គមួយដ៏សំខាន់ក្នុងការជួយបំពេញទាន គឺជាកត្តានៃទានបារមីរបស់ព្រះវេស្សន្តរយ៉ាងពេញលក្ខណៈ បើគ្មានតាជូជក, បើតាជូជកមិនទៅសុំជាលីក្រស្នាពីព្រះវេស្សន្តរទេ ទានបារមីរបស់ព្រះវេស្សន្តរនឹងមិនបានពេញលេញឡើយ ។ មិនតែប៉ុណ្ណោះ តាជូជកនេះជាស្ពាននាំចម្លងព្រះវេស្សន្តរឲ្យចូលមកកាន់ព្រះនគរវិញផង ។ ដូច្នេះហើយបានជាយើងអាចសន្និដ្ឋានបានថា

តាជូជកជាតួអង្គគ្មានបានធ្វើកំហុសអីចំពោះព្រះវេស្សន្តរទេ តាជូជក
តិះដៀលព្រះវេស្សន្តរ ក៏មិនមែនជាការប្រទូស្តអ្វីអាក្រក់ធ្វើឲ្យព្រះវេស្សន្ត
ខូចប្រយោជន៍ដែរ ។

ចំណែកខាងទេវទត្តវិញ ជាតួអង្គមួយដែលបានប្រទូស្តរ៉ាយ
ចំពោះព្រះអង្គ និងព្រះពុទ្ធសាសនាយ៉ាងចេញមុខ ។ កាលទេវទ
គ្មានគេរាប់អាន ក៏ទៅសេពគប់ជាមួយនឹងរាជកុមារឈ្មោះអជាតសត្រូ
បង្គាប់រាជកុមារនេះ ឲ្យសម្លាប់ព្រះបាទពិម្ពិសារជាបិតា ដើម្បីបានរាជ
សោយនៅក្នុងមគធរដ្ឋ ឯទេវទត្តគិតនឹងសម្លាប់ព្រះពុទ្ធអង្គ ដើម្បីបា
កាន់ដំណែងជាព្រះពុទ្ធ ហើយគ្រប់គ្រងពុទ្ធបរិស័ទជំនួសព្រះអង្គ ។ បំ
ណងនេះចេះតែរីកធំឡើង ។ នៅក្រោយពេលដែលខ្លួនបានចូលទៅ
គ្រប់គ្រងពុទ្ធបរិស័ទអំពីសំណាក់ព្រះពុទ្ធអង្គ ហើយមិនបានសម្រេចបំ-
ណង ។ បន្ទាប់នេះទេវទត្តបានចេញមុខប្រទូស្តរ៉ាយព្រះពុទ្ធអង្គពេញទី
បានបំបែកសង្ឃឲ្យបាក់បែកគ្នា ហើយតមកក៏ឲ្យហ្មដំរីលែងដំរីឲ្យព្រៀ
ព្រះពុទ្ធ លុះបំណងនេះមិនបានសម្រេច ក៏ឡើងលើភ្នំគិជ្ឈកូដប្រមៀ
ថ្មមកលើព្រះពុទ្ធអង្គ ដើម្បីធ្វើឃាតព្រះអង្គចោល តែមិនបានសម្រេ
ដូចបំណងទៀត គ្រាន់តែត្រូវព្រះបាទ បណ្តាលឲ្យចេញព្រះលោហិ
បន្តិចប៉ុណ្ណោះ ។ ទេវទត្តនេះបានប្រឆាំងប្រទូស្តតយុទ្ធជាមួយព្រះពុ

អង្គដោយចេតនាក្លាហាន និងដោយបទឧក្រិដ្ឋយ៉ាងធ្ងន់ផុតកំរិត ។ អាស្រ័យហេតុនេះហើយ ទើបព្រះធរណីស្រូបទេវទត្តនេះ ទម្លាក់ឲ្យទៅរងទុក្ខក្នុងមហានរកឈ្មោះអវិចីនេះឯង ។

ដូច្នេះការយកតួអង្គតាជូជកនេះទៅប្រៀបប្រដូចនឹងតួអង្គទេវទត្ត ជាការពុំត្រឹមត្រូវសមហេតុផលសោះឡើយ ព្រោះតាជូជកឥតបានប្រទូស្ត ចំពោះព្រះវេស្សន្តរសោះ ប៉ុន្តែគ្រាន់តែជាតួអង្គមួយដែលមានលក្ខណៈ អាក្រក់នៅក្នុងផ្ទៃរឿងខាងចុងប៉ុណ្ណោះ ហើយជាតួអង្គដែលជួយបំពេញ ទានបារមី ជួយធ្វើជាស្ពានចំឡងព្រះវេស្សន្តរ ឲ្យបានយាងចូលមកកាន់ ព្រះនគរវិញ និងជាតួអង្គមួយដែលជួយរចនាផ្ទៃរឿង – ដំណើររឿងឲ្យ មានសម្រស់តែប៉ុណ្ណោះ ។ ព្រះវេស្សន្តរនិងមហាវេស្សន្តរជាតក បើ គ្មានតួអង្គតាជូជកទេ នឹងទៅជាសោះកក្រោះ គ្មានតម្លៃសោះឡើយ ឯព្រះពុទ្ធសាសនាវិញ បើគ្មានភិក្ខុទេវទត្តទេនោះ ជាការប្រសើរណាស់ ព្រះសម្ពុទ្ធឥតរវល់ខ្វល់នឹងរឿងកករល្អក់នេះឡើយ ព្រោះទេវទត្តជាតួ អង្គធ្វើឲ្យព្រះពុទ្ធសាសនាជួបនឹងវិបត្តិមួយដ៏ធំ នាំឲ្យព្រះពុទ្ធជាម្ចាស់រវល់ ខ្វល់ព្រះទ័យរំខានដល់ការបំពេញពុទ្ធកិច្ចឯទៀតៗ ហើយនាំឲ្យព្រះពុទ្ធ-សាសនារាប់ឱនផង ។

## ២) អំពីតួអង្គនាងអមិត្តតាបនា បានជានា

ចិញ្ចា.— ការយកតួអង្គទាំងពីរ ទៅធ្វើការសរជាតិផ្ទុយគ្នា ក៏
តែមិនសមហេតុផលខ្លាំងណាស់ទៅទៀត ព្រោះអី

— នាងអមិត្តតាបនា គ្រាន់តែជាប្រពន្ធរបស់តាជូជកប៉ុណ្ណោ
ប៉ុន្តែ នាងនេះឥតបានធ្វើការទាក់ទងជាមួយព្រះវេស្សន្តរ ឬ ធ្លាប់ស្គា
ព្រះអង្គដល់ម្តងសោះ ។ នាងបានឲ្យតាជូជកជាស្វាមីទៅសុំជា
ក្រស្នាពីព្រះវេស្សន្តរ ក៏ដោយសារនាងបានឮលឺខ្លួរខ្លាយថា ព្រ
វេស្សន្តរមានព្រះទ័យសប្បុរសណាស់ ហ៊ានលះបង់ទ្រព្យដីមានត
រហូតទល់ហ៊ានលះបង់ជីវិតឲ្យជាទានទៀត ។ ដូច្នេះ នាងអមិត្ត-
តាបនាឥតបានប្រមាថមាក់ងាយ ឬ ធ្វើការប្រទូស្តរ៉ាយដោយចេញមុខ
ដោយលបលាក់ចំពោះព្រះវេស្សន្តរសោះឡើយ ។

— រីឯនាងចិញ្ចាវិញ នាងជាស្ត្រីខាងបក្សពួកនិគ្រន្ថអន្យតិរ្ថិ
ដែលជាសត្រូវប្រឆាំងនឹងព្រះពុទ្ធសាសនា ។ នាងចិញ្ចា ( ចិណ្ចា
មាណវិកា ) ដែលស្ថិតនៅក្នុងបក្សពួកនិគ្រន្ថនេះ ក៏ចេញមុខបំរើបក្ស
ពួករបស់ខ្លួន ប្រទូស្តរ៉ាយប្រឆាំងមួលបង្កាច់ព្រះពុទ្ធ ដើម្បីបង្អាប់ព្រះពុទ្ធ
សាសនាដោយក្បាហាន ។ ពេល ១ នាងចិញ្ចាបានយកឈើចង

ភ្លាប់នឹងពោះធ្វើដូចខ្លួនមានផ្ទៃពោះគ្រប់ខែទៅហើយ ។ បានចូលទៅជេរ ផ្ទះតិះដៀលព្រះពុទ្ធជាម្ចាស់នៅកណ្តាលបរិស័ទក្នុងវត្តជេតពន ដោយ បានចោទថា ព្រះពុទ្ធជាម្ចាស់បានទៅលេងសាហាយស្មន់ជាមួយនាងរហូត ទល់មានផ្ទៃពោះប៉ុណ្ណេះ ព្រះពុទ្ធបែរជាធ្វើព្រងើយកន្តើយទៅវិញ ។ ពេលនោះព្រះឥន្ទ ក៏ក្លែងខ្លួនធ្វើជាសត្វកណ្តុរតូច ១ ចូលទៅកាត់ខ្សែ ចំណងពោះទម្រាក់ឈើ ដែលនាងយកទៅចងធ្វើជាកូននោះធ្លាក់បកភ្លាម, ពួកពុទ្ធបរិស័ទឃើញដូច្នោះ ក៏នាំគ្នាវាយបណ្តេញចេញពីទីប្រជុំ ហើយ ព្រះធរណីក៏ស្រូបនាងចិញ្ចានេះ នៅចំពោះព្រះចក្ខុនៃព្រះពុទ្ធ និងភ្នែក នៃពុទ្ធបរិស័ទក្នុងគ្រានោះ ។

នាងចិញ្ចា ជាស្ត្រីម្នាក់ដែលបានធ្វើកំហុសយ៉ាងធំចំពោះ ព្រះពុទ្ធអង្គ ដោយបានចេញមុខប្រទូស្ត និងព្រះអង្គយ៉ាងជាក់ស្តែង ហើយក៏ត្រូវទទួលទោសយ៉ាងទាន់ហាន់ដែរ ប៉ុន្តែ នាងក៏បាននាមថា ជាវីរនារីនៅក្នុងបក្សពួករបស់នាងទៅវិញ ។ ចំណែកនាងអមិត្ត- តាបនា ឥតបានបំរើនត្តបតិជនណាម្នាក់ ឬ បានប្រទូស្តរាយព្រះវេ- ស្សន្តរដោយចេញមុខក៏ទេដែរ ។

សេចក្តីបញ្ជាក់មកខាងលើនេះបាននាំឲ្យយើងឃើញថា ការ សរជាតិនៅក្នុងមហាវេស្សន្តរជាតក ពុំមានលក្ខណៈត្រឹមត្រូវ សមហេតុ

ហើយពុំមានគុណភាពរវាងតួអង្គនិងតួអង្គឡើយ ។ មិនតែប៉ុណ្ណោះ សោត កវីនិពន្ធធ្វើការសរជាតិក្នុងមហាវេស្សន្តរជាតកនេះ ក៏មានលក្ខណៈខុសពីការពិតខ្លះទៀតផង ដូចជា :

| | | |
|---|---|---|
| តាជូជក | បានជា | ទេវទត្ត |
| នាងអមិត្តតាបនា | ‖ | នាងចិញ្ចា |
| ទេវបុត្រដែលនិម្មិតជារាជសីហ៍ | ជា | ឧបាលិ |

មហាមាត្យអ្នកចាត់ចែងទាន បានជា អានន្ទ ជាដើម ក៏រិតតែគ្មានតុល្យភាពមិនត្រឹមត្រូវខ្លាំងណាស់ទៅទៀត ព្រោះទេវទត្ត, នាងចិញ្ចា, ឧបាលិ និងព្រះអានន្ទ សុទ្ធតែតួអង្គដែលមានព្រឹត្តិការណ៍មានសកម្មភាព ហើយចូលមកជួបនិងព្រះពុទ្ធជាម្ចាស់ នៅពេលជាខាងក្រោយយ៉ាងឆ្ងាយ ពីពេលដែលព្រះអង្គទេសនាមហាវេស្សន្តរជាតកនេះ នៅឯក្រុងកបិលព័ស្តុជាគ្រាដំបូងនោះទៅទៀត ។

## ប្រធាន

គេថាផ្លែអត្ថរូប នៃមហាវេស្សន្តរជាតក មានលក្ខណៈនៃបញ្ហាចោទនិងដោះស្រាយសំខាន់ ៗ ប្រកបដោយពិធីសាស្ត្រដ៏ប៉ិនប្រសប់ ។

ចូរលើកនូវបញ្ហាចោទ និងដោះស្រាយបញ្ហាផ្សេង ៗ ក្នុងមហាវេស្សន្តរនេះមកធ្វើការសិក្សា ដោយផ្អែកលើគោលមតិសំខាន់ ៗ ។

## អត្ថាធិប្បាយ

មហាវេស្សន្តរជាតក មានផ្លែនៃអត្ថរូបពោរពេញទៅដោយ-

ការចោទ និងដោះស្រាយបញ្ហាប្រកបដោយលោកិយសច្ចៈ និងអត្ថរ៉ិប

ជាបែបសំយោគនិយម ។ យើងនឹងលើកនូវលក្ខណៈទាំងនេះម

ធ្វើការសិក្សាដូចតទៅ :

**បញ្ហាចោទទី១** – គរីនិពន្ធបានលើកនូវបញ្ហាចោទនេះប

ធ្វើជាពិធីសម្រាប់ផ្ដើមរឿង គឺចោទតាមរយៈពួកក្សត្រសាក្យរាជ ដែ

ប្រកបដោយទិដ្ឋិមានះ មានគំនិតប្រកាន់មាំថា “ អញ, ឯង ” ព

បែប “ អាត្មានិយម ឬ អញនិយម ” យ៉ាងខ្លាំង មិនអាចនរណ

កាច់បំបាក់បានដោយងាយឡើយ ។ ទិដ្ឋិមានះបែបអាត្មានិយ

នេះហើយដែលនាំឲ្យយើងឆ្ងល់ថា តើព្រះពុទ្ធដែលត្រូវជាកូន,

ក្មួយ, ជាបង ឬ ប្អូនពួរបស់កសាក្យរាជទាំងនោះ ទ្រង់នឹងរកវិធីណាយ

ដោះស្រាយបាន ហើយតើព្រះសម្ពុទ្ធទ្រង់ធ្វើយ៉ាងណានឹងងាយទូន្

ពួកសាក្យរាជទាំងនោះ ?

**បញ្ហាដោះស្រាយ** – អ្នកនិពន្ធពុំបានដោះស្រាយដោ

ខ្លួនឯងឡើយ ប៉ុន្តែគេដោះស្រាយតាមរយៈព្រះពុទ្ធជាម្ចាស់ គឺព្រះពុទ្ធ

ជ្រាបនូវទឹកចិត្តអាត្មាស្រ័យនៃពួកញាតិទាំងនោះហើយ ក៏ទ្រង់

ទៅក្នុងអាកាសសំដែងបាដិហារ្យ បញ្ចេញរស្មីភ្លឺព្រោងព្រាយ ឆើតឆា

ធ្លាក់មកលើព្រះកេសពពួកញាតិទាំងនោះ រួចភ្លៀងបោក្ខរពស៌ក៏បង្អុរចុះ
មកបន្ទាប់នោះដែរ ។ នៅតាមរយៈភ្លៀងបោក្ខរពស៌នេះ មានបញ្ហា
ចោទមួយទៀត គឺ :

**បញ្ហាចោទទី ២** – តាមដំណក់ទឹកភ្លៀងបោក្ខរពស៌នេះ
គឺមានសេចក្ដីអស្ចារ្យយ៉ាងណាខ្លះ ?

**បញ្ហាដោះស្រាយ** – ភ្លៀងបោក្ខរពស៌នេះ មិនមែនធ្លាក់
តែក្នុងពេលនេះទេ សូម្បីពីក្នុងកាលកន្លងយូរយារណាស់មកហើយ
នោះ ក៏ធ្លាក់ចុះយ៉ាងនេះដែរ ។ ដូច្នេះ តាមរយៈភ្លៀងបោក្ខរពស៌
នេះ មានបញ្ហាចោទផង បញ្ហាដោះស្រាយផង គឺដោះស្រាយតាម
រយៈមហាវេស្សន្តរជាតកនេះឯង ។

**បញ្ហាចោទទី ៣** – អ្នកនិពន្ធបានលើកបញ្ហាមកចោទ តាម
រយៈជីវិតប្ច័យនាគេន្ទ្រ តាមទានបារមី និងតាមរយៈអ្នកនគរស្រីពិរាស្ត្រ
ដែលបង្កើតជាវិបត្តិចំនាស់ ធ្វើដំណើររឿងឲ្យមានលក្ខណៈតឹងតែងឡើងៗ
ហើយកាលព្រះវេស្សន្តរគង់នៅក្នុងព្រៃ បញ្ហាចោទបានលេចឡើងតាម
ទានបារមីនេះថែមទៀត ពោលគឺការប្រទានជាលីក្រស្នាទៅតាជូជក, ប្រ-
ទាននាងមទ្រីទៅឥន្ទ្រព្រាហ្មណ៍ ដែលហាក់ដូចជាធ្វើបរិកាសយានៃដំណើរ

រឿងឲ្យរិតតែតឹងឡើង ៗ ។

**បញ្ហាដោះស្រាយ**– ដើម្បីនឹងដោះស្រាយវិបត្តិទំនាស់ បញ្ហាចោទទាំងប៉ុន្មានខាងលើនេះ អ្នកនិពន្ធក្តី ព្រះវេស្សន្តរក្តីហាក់ដូច គ្មានសមត្ថភាពនឹងដោះស្រាយដោយខ្លួនឯងទេ ។ ដូច្នេះដើម្បីនឹង ស្រាយបញ្ហាអស់នេះរួច ធ្វើដំណើររឿងឲ្យធូរស្រាលវិញ អ្នកនិ ត្រូវលើកទេវជំនួយក្រៅខ្លួនរបស់តួអង្គ គឺអន្តរាគមន៍របស់ពួកទេវៈ ធ្វើជាគ្រឿងឧបករណ៍ ។ អ្នកនិពន្ធបានដោះស្រាយបញ្ហាទាំងអស់ខ លើនេះ តាមខណៈ តាមលំដាប់ដូចតទៅនេះ :

**ខណៈទី ១**– ប្រជុំបញ្ហាទាំងអស់ក្នុងវគ្គរឿង ស្ថិតនៅ ដំណើរតាជូជកសុំជាលីក្រស្នាបានពីព្រះវេស្សន្តរ ហើយត្រឡប់យក ស្រុកទេសគាត់វិញ ។ តាមដំណើរនេះ យើងឃើញថា ព្រះវេ ស្សន្តរបានកាត់ថ្លៃរាជបុត្រានិងបុត្រីថែមទៀត ។ ផ្ទុអត្ថរូបបែប ហើយ ដែលអាចបង្កើតជាការសង្ស័យមួយចំពោះអ្នកអានថា តើតា ជកនាំយកជាលីក្រស្នាទៅផ្ទះសម្បែងរបស់គាត់ ដើម្បីឲ្យនាងអមិត្តតា នាប្រើប្រាស ឬមួយក៏តាជូជកនាំចូលទៅនគរជេតុត្តរ តាមសំណូម របស់ព្រះវេស្សន្តរចំពោះតាជូជក និងចំពោះព្រះឥន្ទ្រាធិរាជ ? ដូ

ដើម្បីនឹងឲ្យបញ្ហានេះចេញរួច កវីនិពន្ធបានលើកយកអន្តរាគមន៍របស់ពួកទេវៈ មកធ្វើជាមធ្យោបាយសម្រាប់ដោះស្រាយ ដោយក្នុងខណៈនោះ មានទេវៈមកបញ្ចូលចិត្តតាជូជក ឲ្យវង្វេងផ្លូវដឹកជាលីក្រស្នាចូលទៅនគរជេតុត្តរ ហើយបានជួបនឹងព្រះបាទស្រីសញ្ជ័យ ។ ក្នុងខណៈនេះ ការដោះស្រាយនៅតែពុំទាន់រួចបានធូរស្រាលនៅឡើយ ព្រោះមានកួនបញ្ហា ១ ទៀតចោទថា ‘ ពួករាជអាមាត្យបានចោទប្រកាន់ព្រះវេស្សន្តរថា ទ្រង់ធ្វើទានមិនសមហេតុផល ខុសប្រវេណីមហាក្សត្រពីបុរាណ ’ ។ ដូច្នេះ ការដោះស្រាយដោះទេវៈ គ្រាន់តែនាំឲ្យព្រះកុមារទាំងពីរបានជួបនឹងព្រះអយ្យកោអយ្យិកាតែប៉ុណ្ណោះ តែពុំទាន់បានដោះស្រាយបញ្ហាព្រះវេស្សន្តរ ដែលត្រូវជាប់ចោទទាំងអស់នោះឲ្យរួចឡើយ ។ ដូច្នេះ ដើម្បីនឹងដោះស្រាយបញ្ហានេះតទៅ អ្នកនិពន្ធត្រូវរកមធ្យោបាយថ្មីមួយទៀតមកធ្វើជាវិធីដោះស្រាយ ។

**ខណៈទី ២**– ក្នុងនេះ អ្នកនិពន្ធធ្វើការដោះស្រាយតាមរយៈជាលី ដែលមានភារៈជាអ្នកការពារបិតាផង លើកកិត្តិយសបិតាផង ហើយអាចធ្វើជាស្ពានចម្លងបិតាឲ្យចូលមកកាន់ព្រះនគរផង ។

– ជាលីជាអ្នកការពារបិតា និងជាអ្នកលើកកិត្តិយសបិតាដោយព្រះកុមារបានទូលព្រះបាទស្រីសញ្ជ័យថា ‘ មិនគួរឡើយនឹងមានពាក្យ

តិះដៀលរបស់ពួកអាមាត្យទាំងនោះទេ ព្រះបិតារបស់ទូលបង្គំជាអ្នកមានព្រះហឫទ័យល្អណាស់ . . . . . ទ្រង់ធ្វើទានដើម្បីផ្សាយកព្រះសព្វញ្ញុតញ្ញាណ ឲ្យបានត្រាស់ជាព្រះពុទ្ធតាមប្រវេណីព្រះពុទ្ធអំពីបុរាណ . . . . ។ ទំព័រ ៤៧៨-៤៧៩ ។

– ជាលីជាស្ពានចំឡងព្រះវេស្សន្តរ ឲ្យបានចូលមកកាន់ព្រះនគរ ដោយជាលីបានទូលព្រះអយ្យកោ អំពីទុក្ខវេទនារបស់ព្រះជនកជននីដែលគង់នៅក្នុងព្រៃឆ្ងាយ ដោយសព្វគ្រប់ ហើយទូលអង្វរឲ្យព្រះរាជអយ្យកោ ទៅអញ្ជើញព្រះបិតាឲ្យចូលមកក្នុងព្រះនគរវិញ ។ ទំព័រ ២៩០ . . . . ។

ការដោះស្រាយក្នុងខណៈទី ២ នេះ ក៏ពុំទាន់បានរួចស្រឡះនៅឡើយដែរ ពោលគឺព្រះវេស្សន្តរបានគង់នៅតែក្នុងព្រៃដដែល ដូច្នោះអ្នកនិពន្ធត្រូវធ្វើការដោះស្រាយតាមរយៈព្រះបាទស្រីសញ្ជ័យតទៅទៀត។

**ខណៈទី ៣** – ឬងនេះ អ្នកនិពន្ធបានលើកយកតួអង្គព្រះបាទស្រីសញ្ជ័យធ្វើជាតំ ជាប្រធានក្នុងការដោះស្រាយនេះ ពោលគឺព្រះបាទស្រីសញ្ជ័យ ទៅជាតួអង្គមួយលែងគោរពលទ្ធិប្រជាធិបតេយ្យ ដូចនៅក្នុងកណ្ឌហេមពាន្តនិងទានកណ្ឌទៀតហើយ តែព្រះអង្គបានប្រកាន់យកអត្តាធិបតេយ្យ ឬរាជាធិបតេយ្យ មកធ្វើការដោះស្រាយទៅវិញ ។

ដូច្នេះនៅក្នុងខណៈទី ៣ នេះ យើងបានឃើញថាព្រះបាទស្រីសញ្ជ័យទ្រង់លើកកងទ័ពចូលទៅកាន់គិរីវង្កត ដើម្បីសុំយាងព្រះវេស្សន្តរមកកាន់រាជសម្បត្តិវិញ ។ នៅទីនោះ ការដោះស្រាយហាក់ដូចជាមានការធូរស្រាលបន្តិច ដោយព្រះវេស្សន្តរបានពោលរំលឹកអំពីរឿង ដែលពួកអ្នកស្រីពិរាស្ត្របានមានកំហឹងចំពោះព្រះអង្គ ព្រះបាទស្រីសញ្ជ័យទ្រង់លួងលោមដោយហេតុផ្សេង ។ ទាល់តែព្រះវេស្សន្តរបានយល់ព្រម ។

ការដោះស្រាយក្នុងខណៈទី ៣ នេះ ក៏នៅតែពុំទាន់រួចស្រឡះនៅឡើយ ព្រោះអី យើងឃើញថា ព្រះបាទស្រីសញ្ជ័យទ្រង់យល់ព្រមហើយអះអាងក៏ពិតមែន ប៉ុន្តែចុះពួកអ្នកស្រីពិរាស្ត្រដែលមានកំហឹងចំពោះព្រះអង្គរួចហើយនោះ តើនឹងទៅជាយ៉ាងណាទៅវិញ ? ដូច្នេះយើងត្រូវតែត្រិះរិះរាវរកមើល តើនៅមានការដោះស្រាយទៀតដែរ ?

ខណៈទី ៤– ជាបញ្ចប់ អ្នកនិពន្ធត្រូវធ្វើការដោះស្រាយតាមរយៈនៃដំណើរយាងចូលមកកាន់ព្រះនគរវិញ, តាមរយៈអន្តរាគមន៍នៃទេវៈទៅទៀត ។ អាស្រ័យហេតុនេះហើយ បានជានៅទីបញ្ចប់ យើងឃើញថា គ្រាន់តែព្រះវេស្សន្តរទ្រង់ព្រះចិន្តាថា « ឱថ្ងៃព្រឹកនេះ សមស្នមផងទាំងឡាយរាឮពតិមានថា អញមកដល់ព្រះនគរហើយ សមព្រហាមស្អែកនេះឯង វានឹងមកចោមរោមសុំអញពុំខាន..... » ខណៈនោះ

ក៏ក្ដៅដល់អាសនៈសម្ដេចអមរិន្ទ្រាធិរាជ . . . . ព្រះអង្គបណ្ដាលនូវមហា
មេឃឯងឲ្យបោរជននូវទឹកបង្អុរនូវភ្លៀងរត្នទាំង ៧ ប្រការ ឲ្យធ្លាក់ចុះមក
ឯលិច ឯកើត ឯជើង ឯត្បូងព្រះរាជមន្ទីរនោះប្រមាណស្មើចង្កេះ ទី
ក្រៅអំពីនោះប្រមាណស្មើជង្គង់ ។ . . . . . ទ្រព្យធ្លាក់ចុះត្រង់ផ្ទះ
សម្រាសរបងរបស់បុគ្គលឯណា ក៏ឲ្យបុគ្គលនោះជញ្ជូនយកទុកជាទ្រព្យ
របស់ខ្លួនចុះ . . . . ។ ទំព័រ ៥៣៦-៥៣៧ ។

ការដោះស្រាយតាមរយៈអន្តរាគមន៍នៃទេវៈក្នុងខណៈទី ៤ នេះ
យើងអាចសន្និដ្ឋានបានថានឹងមានផ្លូវចេញទៀតយ៉ាងស្រួលបំផុត ព្រោះ
ទោះបើយើងមិនបានឃើញនៅក្នុងផ្ទៃអត្ថរូបបានបង្ហាញថាពួកស្រីពិរាស្ត្
លែងខឹងក៏ដោយ ក៏យើងអាចយល់ថា បើប្រជាជនបានទ្រព្យសម្បត្តិ
ច្រើន បានសុខក្សេមក្សាន្តទៅហើយ តើនឹងមានផលមាស់យ៉ាងណា
ទៀតកើត ? ជាពិសេសភ្លៀងរត្ន ៧ ប្រការនេះ បានធ្លាក់ចុះបន្ទាប់ពី
ពេលព្រះវេស្សន្តរយាងចូលព្រះនគរថ្មី ៗ រិតតែបញ្ជាក់ថាទានបារមីដោយ
ទឹកព្រះទ័យយ៉ាងសប្បុរសរបស់ព្រះវេស្សន្តរ ពិតជាមានឥទ្ធិពល មាន
តម្លៃណាស់ មិនអាចសាបសូន្យទៅជាអ្វីឡើយ ហើយទឹកព្រះទ័យ
សប្បុរសនិងសកម្មភាពនៃទានបារមីនេះ មានឥទ្ធិពលលើសពីជំរឿបច្ច័យ
នាគេន្ទ្រទៅទៀត ។ កាលដើមអ្នកស្រីពិរាស្ត្រយល់ថា មានតែជំ

បច្ច័យនាគេន្ទ្រទេ ដែលមានតម្លៃអាចបណ្ដាលឲ្យមានទឹកភ្លៀង សំរាប់ធ្វើស្រែចំការ ប្រើប្រាស ចុះបើឥឡូវ ក្រោយពីព្រះវេស្សន្តរបានធ្វើបុញ្ញបរិច្ចាគនិងទានបរិច្ចាគមក ហើយបានយាងចូលមកក្នុងព្រះនគរភ្លាម ក៏ស្រាប់តែមានទឹកភ្លៀងធ្លាក់ចុះដល់ទៅភ្លៀងរត្ន ៧ ប្រការទៀត តើជាការគួរឲ្យស្ដាយស្រណោះចំពោះដំរីបច្ច័យនាគេន្ទ្រដែរឬយ៉ាងណា ? បើទោះជាមានចិត្តស្ដាយខ្លាំងយ៉ាងណា ក៏គេរសាយចិត្តពីរឿងនោះដែរ ព្រោះឥឡូវគេមានសម្បត្តិធ្លាក់ដល់ទៅរត្ន ៧ ប្រការ សម្រាប់ជីវភាពគេទៅហើយ ។

ការចោទនិងដោះស្រាយបែបខាងលើនេះហើយ ដែលជាលក្ខណៈសំខាន់នៅក្នុងមហាវេស្សន្តរជាតក ជាពិសេសបញ្ហាចោទនិងដោះស្រាយទាំងអស់ សុទ្ធតែធ្វើទៅតាមសកម្មភាពនៃទានបារមីរបស់ព្រះវេស្សន្តរដោយសុទ្ធសាធ ហើយនៅទីបំផុត អ្នកនិពន្ធបានធ្វើការការពារតួអង្គព្រះវេស្សន្តរ តាមរយៈទានបារមីនេះដដែល ឥតចេញផុតពីព្រំដែននេះឡើយ ។

# ប្រធាន

ស្ត្រីជាតួអង្គមួយដែលតែងមានឡើងនៅក្នុងអក្សរសិល្ប៍ខ្មែរ ។
ចូរលើកឆ្លងតួអង្គស្ត្រីក្នុង មហាវេស្សន្តរជាតក មកធ្វើការសិក្សាដោយ ការប្រៀបធៀបទៅនឹងតួអង្គស្ត្រីឯទៀត ៗ ក្នុងរឿងរាមកេរ្តិ៍,កាកីនិងរឿងទុំទាវ ហើយបញ្ជាក់តម្លៃនៃតួអង្គផង ។

## អត្ថាធិប្បាយ

អក្សរសិល្ប៍ខ្មែរបែបសាស្ត្រាល្បែង—ប្រលោមលោក មិនដែលបោះបង់នូវតួអង្គស្រីនេះចោលម្តងណាឡើយ ។

ល្អ–អាក្រក់ ដោយរូបរាង, ដោយចិត្តគំនិត, ទាំងអស់នេះទុកជាអលង្ការមួយអាចជួយរចនារៀងឲ្យមានសប្រស់ មានតម្លៃបាន ។

ស្ត្រីភាពក្នុងអក្សរសិល្ប៍ខ្មែរ មិនមែនគ្រាន់តែមាននាទីសំរាប់ទុកជាល្បែងនៃបុរសភាគខ្លះ, មិនមែនគ្រាន់តែជាគ្រឿងលំអនៃគ្រួសារ ហើយមិនមែនជាអ្នកបង្កើតគ្រួសារប៉ុណ្ណោះទេ ប៉ុន្តែ មាននាទីជាអ្នកបំរើឧត្តមគតិនៃសង្គម, យុត្តិធម៌ទៀតផង ។ យ៉ាងណាមិញ តួអង្គស្ត្រីក្នុងមហាវេស្សន្តរជាតក ជាអ្នកមានលក្ខណៈនិងគុណសម្ប័ទដ៏ល្អប្លែក ហើយជានិមិត្តរូបនៃសេចក្តីល្អរបស់សង្គមមនុស្សផង ។ ព្រះនាងសុជាតសុប្បតី ជាព្រះមាតានៃព្រះពោធិសត្វផង, ជាកំពូលនៃស្ត្រីក្នុងព្រះនគរផង ហើយជាអ្នកមាននាទីជាតំណាងនៃសេចក្តីល្អថែមទៀត ។ តាំងពីនៅក្នុងអត្តភាពនាស្ថានផ្សេងៗណោះ ដែលព្រះនាងបានសុំពរអំពីព្រះឥន្ទ្រាធិរាជដើម្បីឲ្យបានកើតជាមនុស្ស ហើយក្នុងចំណោមពរទាំង ១០ ប្រការនោះ ពរទី ៤ ថា “ សូមឲ្យមានកូនប្រុស ១ មានកិត្តិនាមល្បីល្បាញ ” និងពរទី ៩ ថា « សូមឲ្យមានអំណាចអាចដោះមុក្ខទោសរបស់មនុស្សសត្វផងទាំងឡាយ » ។

មួយជីវិតព្រះនាងសុជាតសុប្បតី ព្រះនាងធ្វើសុទ្ធតែអំពើល្អទាំងអស់ ហើយឃើញបុត្ររបស់ព្រះនាងធ្វើល្អដែលត្រូវចំចំណុចព្រះ

ទ័យនាងហើយ នាងមិនមានព្រះទ័យកំណាញ់ ហើយហាមឃាត់ព្រះរាជបុត្រសោះឡើយ ។ ពេលព្រះវេស្សន្តរមានទុក្ខទោសព្រោះអំពើល្អ ដោយត្រូវពួកស្រីពិរាស្ត្រសុំឲ្យបំបរបង់ចេញពីព្រះនគរ ព្រះនាងសុបារសុប្បតី មិនខ្វាចអ្វីនឹងចេញព្រះភ័ក្ត្រការពារព្រះរាជបុត្រាដែលគ្មានទោសកំហុសសោះនោះឡើយ ។ព្រះនាងបញ្ចេញមតិយោបល់ការពារព្រះរាជបុត្រដោយការពន្យល់បញ្ជាក់ហេតុផលដោយសព្វគ្រប់ ប៉ុន្តែពេលដែលមតិនាងត្រូវបរាជ័យមតិភាគច្រើន នាងស៊ូទាំព្រះទ័យនៅស្ងៀមដោយមិនបានបញ្ចេញស្នៀតកលកិច្ចល្បិចអាក្រក់ណាធ្វើឲ្យសង្គមមនុស្សនិងមនុស្សភាគច្រើនឲ្យវិនាសខូចដោយសារព្រះនាងឡើយ ។ ព្រះនាងស្រឡាញ់រាជបុត្រដែលព្រះអង្គ បានប្រាថ្នាថាឲ្យមានល្បីល្បាញនោះណាស់ ប៉ុន្តែ នាងគោរពច្បាប់ គោរពមតិភាគច្រើន តាមលទ្ធិប្រជាធិបតេយ្យជាងការស្រឡាញ់ព្រះរាជបុត្រនោះទៅទៀត ។

ប៉ុណ្ណេះ យើងអាចឃើញបានថា តួអង្គស្ត្រីដែលមានកិត្តិយសអំណាចច្រើនដូចនាងសុបារសុប្បតី គឺពិតជាតំណាងយុត្តិធម៌ និងសេចក្តីល្អក្នុងអក្សរសិល្ប៍ខ្មែរយ៉ាងច្បាស់លាស់ ។

ដទៃពីនេះ តួអង្គនាងមទ្រី ជាស្ត្រីដែលមានគុណសម្បត្តិល្អឥតពីរ នាងជាស្ត្រីដែលមានព្រះទ័យស្មោះស្ម័គ្រចំពោះព្រះវេស្សន្តរ

ស្វាមីមិនអាចរកស្ត្រីណាមកប្រៀបស្មើគ្មានឡើយ ។ ពេលព្រះស្វាមីមានទុក្ខទោស នាងសុំយកខ្លួនទៅតាមនៅបំរើព្រះស្វាមី ហើយនាងមទ្រី ទោះជាមិនដែលយាងទៅព្រៃហេមពាន្តក៏ដោយ ក៏នាងប្រឹងរកមធ្យោបាយមកនិយាយពណ៌នា ដោយល្អិតល្អន់អំពីព្រៃហេមពាន្តថាជាទីគួរឲ្យសប្បាយរីករាយចង់ទៅអាស្រ័យនិត្យនៅណាស់ ។ ការធ្វើយ៉ាងនេះ គឺដើម្បីឲ្យស្វាមីបានក្សាន្តព្រះទ័យនឹងទីនោះផង ដើម្បីឲ្យព្រះស្វាមីពេញព្រះទ័យនឹងឲ្យនាងតាមទៅនៅជាមួយផង ហើយទោះជាព្រះវេស្សន្តរហាមឃាត់យ៉ាងណា ក៏នាងនៅតែសូមអង្វរដោយការប្រៀបធៀបយ៉ាងល្អិតល្អាញ ។ នាងមិនខ្លាចព្រះស្វាមីមានស្ត្រីដទៃទៀតយកទៅនៅក្នុងព្រៃនោះឡើយ ព្រោះនាងដឹងយល់ស្គាល់ច្បាស់ណាស់អំពីចិត្តព្រះទ័យព្រះស្វាមីនាង. ក្នុងចំណោមជនទាំងអស់ដែលធ្លាប់ស្គាល់ព្រះវេស្សន្តរមានតែនាងមទ្រីមួយគត់ប៉ុណ្ណោះ ដែលស្គាល់ព្រះវេស្សន្តរជាងគេហើយនាងក៏មិនខ្លាចនឹងទៅនៅបំរើព្រះស្វាមីនេះដែរ ។

នៅក្នុងព្រៃស្ងាត់ នាងមទ្រី រ៉ាប់រងកិច្ចការគ្រប់យ៉ាងទាំងអស់តែមួយព្រះអង្គឯង ។ ព្រះនាងដងទឹក, យាងទៅបេះ, ជីកកកាយផ្លែឈើ, មើមឈើ, ធ្វើការគោរពព្រះស្វាមីដោយក្រយាហារផ្សេង ៗ មើលថែព្រះរាជបុត្រីបុត្រាដែលនៅតូច ៗ ជាដើម ។ ការ

សារទាំងអស់នេះ នាងធ្វើដោយមិនខ្ជិលច្រអូស ហើយដោយពេញព្រះទ័យជានិច្ច ។ ព្រះនាងស៊ូលះបង់សេចក្ដីសុខគ្រប់យ៉ាងដែលព្រះនាងធ្លាប់ជួបប្រទះក្នុងកាលពីមុនទាំងអស់ ។ ពេលនេះព្រះនាងបានទុកខ្លួនស្មើនឹងខ្ញុំបំរើស្រីម្នាក់ប៉ុណ្ណោះ ។

នៅចំពោះមុខនៃការបំពេញទានរបស់ព្រះស្វាមី ព្រះនាងមទ្រីបានសុខព្រះទ័យ សុខកាយធ្វើជាមួយដោយប្ដូរផ្ដាច់, ពេលយាងទៅព្រៃដើម្បីស្វែងរកផលានុផល មកថ្វាយព្រះស្វាមីនិងបុត្រីបុត្រា បានជួបនឹងសត្វសាហាវមកឃាំងព្រះនាង ធ្វើឲ្យដំណើរព្រះនាងយឺតយូរខុសធម្មតា លុះយាងមកដល់អាស្រមបទ ត្រូវព្រះស្វាមីចោទប្រកាន់ ក៏ព្រះនាងឥតឈ្លោះជជែកបែកជាអូរហូរជាស្ទឹងដែរ ព្រះនាងស៊ូខាំព្រះទន្តទាល់តែសន្លប់បាត់ស្មារតី លុះដឹងព្រះអង្គឡើង ឮថាព្រះស្វាមីបានលើកបុត្រីបុត្រាប្រទានទៅតាជូជកព្រាហ្មណ៍ទៅហើយ ព្រះនាងបង្ក្រាប់ចិត្តព្រះទ័យទាល់តែសោះ ផ្ទុយទៅវិញ ព្រះនាងបែរជាទទួលអបអរសាទរ អនុមោទនាទាន តាំងព្រះទ័យអធិដ្ឋានសំបូងសប្រុង សុំឲ្យព្រះស្វាមីបានសម្រេចនូវត្រៃយរតនៈ ពោលគឺព្រះនិព្វានថែមទៀត ។

មិនតែប៉ុណ្ណោះសោត ពេលឥន្ទព្រាហ្មណ៍បានមកសុំព្រះនាងអំពីព្រះវេស្សន្តរ ព្រះនាងសុខព្រះទ័យតាមបំណងព្រះស្វាមីជានិច្ច ហើយ

កុំថាឡើយត្រឹមលើកព្រះនាងឲ្យជាទាន សូម្បីព្រះស្វាមីឲ្យសាច់ឈាមបេះដូងថ្លើមថ្លែង ក៏ព្រះនាងសុខព្រះទ័យដែរ ។

នេះហើយស្ត្រីភេទម្នាក់ដែលជាតំណាងឧត្តមគតិ, តំណាងសេចក្តីស្មោះត្រង់នៅក្នុងមហាវេស្សន្តរជាតក គឺនាងមទ្រីជាកត្តានៃទានបារមីរបស់ព្រះវេស្សន្តរ ហើយការលើកយកសកម្មភាពនិងតួអង្គទាំងពីរនេះមកលាតត្រដាង ក៏ដើម្បីបង្ហាញឲ្យឃើញថា ស្ត្រីភេទក្នុងមហាវេស្សន្តរជាតក ជាតួអង្គមានឧត្តមគតិខ្ពង់ខ្ពស់, មានវិចារណញ្ញាណស្មើនឹងបុរសដែរ ។

ផ្ទុយទៅវិញ, ស្ត្រីក្នុងរឿងរាមកេរ្តិ៍ ពុំមានលក្ខណៈបែបនេះឡើយ ។ ស្ត្រីមួយពួកត្រូវគេប្រមាថមើលងាយ ឧទាហរណ៍ នាងកែកេសី ត្រូវព្រះលក្ស្មណ៍ជារាជបុត្រចង់សម្លាប់ចោល នៅពេលព្រះនាងបានយករឿងពិតមួយមកទូលព្រះបាទទសរថ ដើម្បីឲ្យព្រះអង្គផ្ទេររាជ្យថ្វាយទៅភិរុទ, នាងសូរបនខា ត្រូវព្រះលក្ស្មណ៍ចាប់កាត់ច្រមុះ, សក់ និងត្រចៀកចោល ។

ស្ត្រីមួយពួកទៀតត្រូវគេបំបិទសិទ្ធិ, បំបិទមាត់មិនឲ្យនិយាយ ឬធ្វើអ្វីបាន ឧទាហរណ៍ នាងតារាទេពីត្រូវពាលីហាមមិនឲ្យពោលពាក្យអ្វីឲ្យសោះ នៅពេលដែលនាងបានយល់ការណ៍ ក្នុងគ្រាដែលសុគ្រីព

មកបញ្ឆោតបោកចេញទៅឲ្យរឹងគ្នានៅទីវាលហួយ ។ នាងតារា
នេះជាស្ត្រីស្មោះត្រង់នឹងព្រះស្វាមីណាស់ នាងមានប្រាជ្ញាយល់ឃើ
ហេតុអាក្រក់ហើយ ទើបនាងលួងអង្វរព្រះស្វាមី ប៉ុន្តែព្រះស្វាមីបាន
នាងជាភេទខ្សោយ ឥតបានការអ្វីទាល់តែសោះ ។ ពេលព្រះស្វ
នេះត្រូវសររបស់ព្រះរាមដួលលើដី នាងទួញរៀបរាប់អំពីយោបល់រ
របស់នាងដែលបានទូលព្រះស្វាមី ប៉ុន្តែជាការគ្មានប្រយោជន៍អ្វីទៀ
ព្រោះរាហួសការអស់ទៅហើយ ។

នាងមណ្ឌោគិរី កាលឃើញហេតុការណ៍មិនស្រួល នឹងអា
ធ្លាក់ដល់រាពណ៍ជាព្រះស្វាមីបាន នាងក៏ទូលព្រះស្វាមីថា ពង្សក្អែកមិ
អាចនឹងនៅរួបរស់ជាមួយកែវមណីបានទៀយ គួរតែព្រះស្វាមីយកនា
សីតាទៅថ្វាយព្រះរាមវិញ ។ មតិនេះសមហេតុផលណាស់ ប៉ុ
ព្រះស្វាមីមិនព្រមស្តាប់ ហើយថែមទាំងធ្វើបន្ទាប់កិត្តិយសនាងថែម
ក្នុងរឿងនេះ ពិតមែនតែនាងមិនព្រមចូលដៃ រួមស៊ូស្លាប់រស់ជាមួយព្រ
ស្វាមីក៏ដោយ ក៏នាងបានយល់ឃើញហេតុភេទអាក្រក់ហួសវិស័យ មិ
អាចគស៊ូទៅកើត ។

នាងសីតា ទោះណានាងនៅតែតាំងព្រះទ័យស្មោះត្រង់ចំពោ
ព្រះរាមផង, សំដែងកាយវិការឲ្យព្រះរាមបានទតឃើញឲ្យច្បាស់ រហូ

ទល់ហ៊ានដើរលុយភ្លើង បង្ហាញព្រះទ័យស្មោះត្រង់ចំពោះព្រះស្វាមីផងក៏ដោយ ក៏ត្រូវព្រះរាមធ្វើទោសដល់ប្រាថ្នាបំផ្លាញជីវិតព្រះនាងចោល នៅពេលដែលព្រះនាងគ្រាន់តែគូររូបយក្សក្រុងរាពណ៍ប៉ុណ្ណោះ ។ ទណ្ឌកម្មមួយដែលព្រះនាងបានទទួលពីព្រះរាម ជាអំពើខុសហួសមាត្រាខ្លាំងណាស់ ដែលមិនអាចឲ្យព្រះនាងវិលត្រឡប់មកកាន់ប្រទេសជាតិ, កាន់ព្រះរាជវាំងបានវិញឡើយ ។ ព្រះនាងសីតាដែលត្រូវព្រះរាមចាត់ព្រះលក្ស្មណ៍ឲ្យយកទៅប្រហារជីវិតនោះ នាងពុំតូចព្រះទ័យ ឬក្បត់ព្រះស្វាមីសោះទេ សេចក្ដីស្មោះត្រង់យ៉ាងណាដែលព្រះនាងធ្លាប់មានពីដើម នាងនៅតែស្មោះត្រង់ដដែល ហើយនាងពុំមានគំនុំគុំគួនអ្វីចំពោះព្រះស្វាមីដែរ ។ ពេលក្រោយមកព្រះស្វាមីបានសុំជានាជាមួយព្រះនាងវិញ រហូតទល់បានចូលកោដ្ឋបញ្ឆោតយកនាងឲ្យចូលទៅក្នុងព្រះនគរ ក៏នាងមិនព្រមចូលឡើយ ព្រោះព្រះនាងខ្លាចព្រះស្វាមីធ្វើបាបរុកគួន បំបិទសិទ្ធិក្នុងការនិយាយស្ដី មិនឲ្យបង្ហាញការពិតដូចមុនទៀត ។ ព្រះនាងធ្វើយ៉ាងនេះ មិនមែនដោយស្អប់ព្រះស្វាមីឡើយ ប៉ុន្តែតើឲ្យព្រះនាងធ្វើតាមយ៉ាងម៉េចកើត ? អ្នកណាដែលបានស្គាល់ព្រះទ័យព្រះរាមជាងនាងសីតាទៅទៀត ? នាងសីតាដែលមានព្រះគភ៌ពេលផ្ទៃ ព្រះរាមហ៊ានឲ្យគេយកទៅសម្លាប់ចោលដោយគ្មានជំនុំជំរះទៅហើយ ផ្ទៃក្រោយ

បើព្រះនាងនៅតែឈ្នួលក្បាលមករស់នៅជាមួយ មុខតែត្រូវព្រះ
ចាប់អារកេរ្តិ៍យផ្ទាល់ព្រះហស្តមិនខាន នាងចេញទៅរស់នៅក្នុង
សប្បាយជាងការរស់នៅជាមួយព្រះរាម ព្រោះនាងស្គាល់ព្រះរាមច្បា
ណាស់ ស្គាល់នូវចិត្តព្រះទ័យដែលគ្មានអ្នកណាស្គាល់ឲ្យដូចព្រះ
ឡើយ ។

នៅក្នុងរឿងកាកី អ្នកនិពន្ធបានទុកតួស្រីជាល្បែងសម្រា
យកទៅលេងសើច តាមសម្រេចតណ្ហា. ម្តងនាងកាកីត្រូវបានទៅ
បាទព្រហ្មទត្តយកទៅធ្វើជាព្រះស្នំឯក, ម្តងទៀតត្រូវបានទៅស្តេច
នៅស្ថានសិម្ពលី យកទៅកំសាន្តសប្បាយ ដោយការលួចឆក់ពី
បាទព្រហ្មទត្ត, ហើយម្តងទៀតត្រូវបានគន្ធនលេងសើចសប្បាយ
ទីងឈ្នួបយកការពីនាង មកថ្វាយព្រះបាទព្រហ្មទត្តជាម្ចាស់ដើម
នៅទីបំផុតនាងកាកីត្រូវស្លាប់ខ្លួន ព្រោះគេចោទថានាងជាស្ត្រីចិត្ត
សាវ៉ា មួយហើយមិនឆ្អែតថែមមួយទៀត ។

ចំពោះយើងដែលគ្រាន់តែស្គាល់នាងកាកីវិញ តើយើង
កំហុសទៅលើនាង ដូចព្រះបាទព្រហ្មទត្តដែរ ឬ យ៉ាងណា ? រឿង
នេះហើយដែលនាំឲ្យស្ត្រីភេទខ្លះនឹកតូចចិត្តនឹងវាសនាខ្លួន ក្តុក់ក្តួ
ចំពោះស្វាមីណាស់ មិនតែប៉ុណ្ណោះ ការពោលថាគេយកតួអង្គព្

រឿងកាកីទុកជាល្បែងនោះ ព្រោះមួយជីវិតស្ត្រីក្នុងរឿងនេះ យើងពុំបានឃើញនាងកាកីធ្វើល្អផង សំដីដែលនាងពោលថ្លែងដោះសា បានត្រូវអ្នកមានអំណាចផងបដិសេធចោលដោយគ្មានមេត្តា អាណិតអាសូរបន្តិចបន្តួចទាល់តែសោះ ។ គ្រុឌក្តី ព្រះបាទព្រហ្មទត្តក្តី គន្ធនក្តី សុទ្ធតែពាក់មុខអាក្រក់ដាក់នាង រកមធ្យោបាយសម្លាប់នាងចោលដោយគ្មានប្រណីឡើយ ។

ស្ត្រីក្នុងរឿងទុំទាវ មានលក្ខណៈ ២ យ៉ាងផ្សេងគ្នាគឺ ស្ត្រីម្យ៉ាងគេទុកជាគ្រឿងសប្បាយដែរ ដូចជាការដែលពួកអាមាត្យស្វែងរកស្ត្រីរូបល្អទៅថ្វាយព្រះរាជា, ស្ត្រីម្យ៉ាងទៀតគេទុកជាគ្រឿងម៉ាស៊ីនគ្រឿងយន្ត ដែលបានចលនាឡើងដោយការបង្គាប់បញ្ជារបស់មនុស្ស, គេទុកថានាំមិនអាចធំជាងនាឡិបានឡើយ, ជាតិស្ត្រីក្រមុំមិនអាចរើសគូគ្រងតាមសេចក្តីប្រាថ្នា ចំណង់ចំណូលចិត្តខ្លួនឯងទេ ដូចជានាងទាវ ត្រូវម្តាយបង្ខំមួយលើកជាពីរបីលើកចង់ឲ្យយក ម៉ឺនងួន, ចង់ឲ្យធ្វើព្រះស្នំឯក ហើយត្រឡប់ឲ្យមកយកម៉ឺនងួនដដែលនេះវិញ តាមចំណង់ចិត្តរបស់អ្នកអាណាព្យាបាល ។

អ្នកនិពន្ធរឿងរាមកេរ្តិ៍, កាកី និងរឿងទុំទាវពុំបានចាត់លើកតម្កើងស្ត្រីភេទឲ្យមានគំនិតខ្ពង់ខ្ពស់, មានប្រាជ្ញា និងទុកជាតំណាងបុគ្គ-

ធម៌, មានសិទ្ធិសេរីភាពដូចក្នុងរឿងព្រះវេស្សន្តរឡើយ ។

ដូច្នេះ ក្នុងចំណោមអ្នកនិពន្ធរឿងទាំងបួននេះ យើងឃើ
ថាមានតែអ្នកនិពន្ធរឿងព្រះវេស្សន្តរមួយប៉ុណ្ណោះ ដែលមានគោល
និត យោបល់ល្អចំពោះតួអង្គស្រ្តី ដោយបានចាត់ទុកស្រ្តីភេទ
មានតម្លៃស្មើនឹងបុរស. ឲ្យមានឧត្តមគតិ យុត្តិធម៌ និងប្រាជ្ញាយល់
ជ្រៅរាក់ដូចបុរសដែរ ។ មិនតែប៉ុណ្ណោះ អ្នកនិពន្ធនេះប
សិទ្ធិ និងសេរីភាពចំពោះស្រ្តី ដោយមិនបានប្រកាន់បាន:, 
ស្របទៅតាមលទ្ធិសង្គមនិយមព្រះពុទ្ធសាសនា ។ ត្រង់នេះហើ
ដែលយើងបានឃើញមួយចំណុចទៀតថា រឿងព្រះវេស្សន្តរមានលក្ខណ
ប្លែក, មានលំអប្លែកពីរឿងឯទៀត ។ ដោយការចេះលើកតម្កើងតួអង្គ
នេះឯង ។

# ប្រធាន

គេពោលថា « មហាវេស្សន្តរជាតក គឺអ្នកនិពន្ធបានតាក់តែងឡើងស្របទៅតាមសង្គម និងមនោសាស្ត្រខ្មែរ » ។

ចំពោះមតិបែបនេះ តើអ្នកមានយោបល់យ៉ាងណាដែរ ។

## អត្ថាធិប្បាយ

ពិតមែនតែមហាវេស្សន្តរជាតក ជាអត្ថបទអក្សរសិល្ប៍បែបពុទ្ធនិយមដោយពាក្យសម្រាស់ក៏ដោយ ក៏អ្នកនិពន្ធពុំបានចោលនូវលក្ខណៈជាបែបខ្មែរនិយម ស្របទៅតាមគំរោងចំណូលចិត្តរបស់ខ្មែរដែរ ។ នៅក្នុងផ្ទៃរឿងទាំងមូលមានចំណុចជាច្រើនណាស់ ដែលលាតត្រដាងនូវលក្ខណៈខ្មែរ ។

អរិយធម៌ខ្មែរផ្នែកណាក៏ដោយ ដែលខ្មែរបានទទួលពីបរទេស ដូចក្បាច់រចនា ភាសា និងអក្សរជាដើម ក៏ខ្មែរមិនដែលទុកឲ្យនៅមាន លក្ខណៈជាតិបរទេសទាំងស្រុងទេ ខ្មែរតែងយកមកច្នៃរចនាធ្វើឲ្យមាន លក្ខណៈជាខ្មែរ តាមមនោគមន៍. តាមសង្គម និងចិត្តចិត្តនៃខ្លួនជាខ្មែរ ជាដរាប សូម្បីព្រះពុទ្ធសាសនា ក៏ខ្មែរយកមកគោរពប្រតិបត្តិធ្វើឲ្យបាន បែបផែនឲ្យទៅជាខ្មែរដែរ ឧទាហរណ៍ ពិធីបុណ្យទាន, បុណ្យផ្កា, កឋិន, បញ្ចុះសីមា. អភិសេក ជាដើម ក៏ខ្មែរពុំធ្វើដូចជនជាតិឥណ្ឌា ដែលជាជាតិដើមនៃព្រះពុទ្ធសាសនានេះឡើយ ។

ការបញ្ជាក់ដោយសង្ខេបនេះ បាននាំឲ្យយើងយល់បានដល់ ចលនានៃអក្សរសិល្ប៍ ដែលជាចលនាពុទ្ធនិយម ដោយអ្នកនិពន្ធបាន លើកយកបញ្ហានៃការសាងបារមីរបស់ព្រះពោធិសត្វមកចោទ និងដោះ ស្រាយតាមរបៀបខ្មែរដោយច្បាស់លាស់ ។ ចាប់តាំងពីចាប់ផ្ដើម រឿងរហូតដល់ចប់ ចលនាពុទ្ធនិយមបែបខ្មែរបានលេចឡើងជាហូរហែ ជាប់រហូត ឧទាហរណ៍ ការធ្វើទានរបស់ព្រះវេស្សន្តរ គឺមិនមែនទាន ដើម្បីទានឡើយ ប៉ុន្តែជាទានដើម្បីចែកសុខសប្បាយ សុភមង្គលដល់ មនុស្សទូទៅនេះឯង ។ ការធ្វើទានថ្នាក់ដល់ទៅបុត្តបរិច្ចាគ, ទារ- បរិច្ចាគរបស់ព្រះវេស្សន្តរ មិនមែនគ្រាន់តែប្រាថ្នាប្រាថ្នាសម្មាសម្ពោធិ-

ញាណទៅអនាគតកាលប៉ុណ្ណោះទេ ប៉ុន្តែ ពេលធ្វើទាននេះហើយព្រះវេស្សន្តរក៏ប្រាថ្នាឲ្យបានត្រឡប់ចូលមកព្រះនគរវិញ ហើយបានព្រះបាទៈជាមហាក្សត្រដូចពេលមុន ថែមទាំងឲ្យមានអំណាច មានសម្បត្តិសម្បូរហូរហៀរលើសពីពេលមុនទៅទៀត ។ សេចក្តីប្រាថ្នានិងសំណូមពរនេះ មិនមែនជាការដែលនិយាយឲ្យតែឮនោះឡើយ ក៏ប៉ុន្តែបានសម្រេចផលចេញឲ្យអ្នកផងឃើញច្បាស់នឹងភ្នែកមែន ។

ត្រង់នេះហើយដែលបានបញ្ជាក់ថាព្រះវេស្សន្តរ មិនមែនមានលក្ខណៈតែបែបឥណ្ឌានោះឡើយ គឺព្រះវេស្សន្តរជាខ្មែរនេះឯង ។ ព្រះវេស្សន្តរបែបឥណ្ឌា ( ក្នុងគម្ពីរជាតកដ្ឋៈ ) មិនមានការប្រាថ្នា និងបានរាជសម្បត្តិនេះឡើយ ឯក្នុងមហាវេស្សន្តរបែបខ្មែរ គឺប្រាថ្នាទាំងសម្មាសម្ពោធិញ្ញាណ ប្រាថ្នាទាំងសម្បត្តិនិងអត្តភាពលោកិយ ហើយសេចក្តីប្រាថ្នាទាំងពីរនេះបានសម្រេចដូចគ្នា ។ ក្នុងអត្តភាពជាព្រះវេស្សន្តរដែលបានបំពេញទានបារមីនោះ ព្រះវេស្សន្តរបានរស់នៅក្នុងឋានៈជាអ្នកបំពេញទាន អស់ច្រើនឆ្នាំដូចអាយុពោធិសត្វធម្មតា លុះដល់រំលាងខន្ធទៅក៏ទៅកើតក្នុងស្ថានសួគ៌ទៀត ។ ចំណុចទាំងនេះហើយ ដែលខ្មែរយើងតែងមានការចូលចិត្ត ហើយចង់ធ្វើ ចង់បានណាស់ ព្រោះអំពើណាដែលគេធ្វើទៅហើយដោយការមើលមិនឃើញ ស្ថិតនៅជាអរូបី

ខ្វាំងពេក ខ្មែរមិនចូលចិត្តធ្វើឡើយ ឧទាហរណ៍ច្បាស់លាស់ប្រជា
ខ្មែរធ្វើបុណ្យកឋិន មិនមែនគ្រាន់តែទិញគ្រឿងបរិក្ខារកឋិន មានស្បង់ចី
ហើយយកទៅប្រគេនព្រះសង្ឃដោយស្ងាត់ ៗ នោះឡើយ កឋិនទានបែ
នេះបានផលប្រយោជន៍ដែរ ប៉ុន្តែខ្វះការសប្បាយរីករាយ, ខ្វះភាតរភា
រវាងពុទ្ធបរិស័ទនិងសង្គមខ្មែរដូចគ្នា ដូច្នេះពុទ្ធបរិស័ទត្រូវឃោសនាផ្សា
ដំណឹងរៀងកឋិននេះដល់ទៅ ៣-៤ ខែមុន ហើយនាំគ្នាទិញត្រៃចីវរផ
ទិញបរិក្ខារជាបរិវារកឋិននោះ តាមសេចក្ដីត្រូវការរបស់ព្រះសង្ឃព្រ
ប្រាសក្នុងវត្តអារាមផង អង្គាសប្រមូលបច្ច័យឲ្យបានច្រើនពាន់-ម៉ឺន ទុ
សង្កត់ត្រៃ ដើម្បីជួយដល់ព្រះសង្ឃនិងពុទ្ធបរិស័ទចំណុះជើងវត្ត សម្រាប់
ទុកកសាងកុដិសាលា, វិហារ ឬសាលារៀន តាមចំណង់ចំណូលចិត្ត
របស់អ្នកស្រុកទេសផង ។ នៅពេលថ្ងៃហែរកឋិននេះសោតទៀត អ្នក
ហែរកឋិនទៅវត្តណាមួយ ត្រូវតែបានទទួលការជប់លៀងចំណីអាហារ
យ៉ាងថ្លៃថ្លា តាមដែលគេធ្វើកើត ។ គេសុខចិត្តចំណាយប្រាក់សារុប
គ្នា ដើម្បីចាត់ការទិញអ្វី ៗ សម្រាប់ទទួលអ្នកហែរកឋិនទៅ យ៉ាងពេញ
ដៃ ហើយជួនវិអ្នកទទួលកឋិនត្រូវខាតផងក៏មាន ប៉ុន្តែទោះយ៉ាងនេះក៏
ដោយ គេក៏ឥតថ្វេរត្អូចចិត្តឡើយ ធ្វើយ៉ាងណាឲ្យបានសប្បាយផង
បានបុណ្យកុសលតាមកាលផង ថែមទាំងដើម្បីគោរពប្រពៃណីខ្មែរផង ។

បុណ្យទានខ្មែរបែបនេះហើយ ដែលអាចបញ្ជាក់ឲ្យឃើញបាន ថា កឋិនទានខ្មែរដែលមានប្រភពពីឥណ្ឌា ជាទីកើតនៃពុទ្ធានុញ្ញាតនេះ ពុំដូចគ្នានឹងកឋិនទានឥណ្ឌាឡើយ ។

ភស្តុតាងជាច្រើនទៀតដែលអាចបញ្ជាក់ឲ្យឃើញថា មហា-វេស្សន្តរជាតក ត្រូវបានអ្នកនិពន្ធខ្មែរគាត់តែងឡើងឲ្យស្របទៅតាមមនោ-សាស្ត្រនិងសង្គមខ្មែរ គឺស្ថិតនៅត្រង់ជីវភាពព្រះវេស្សន្តរ ដែលបានធ្វើទានរួចហើយ ក៏បានទទួលផលទាននោះភ្លាម ហើយត្រូវរស់នៅទទួលផលទាននោះយ៉ាងយូរ រហូតទល់ទ្រង់មានវ័យចាស់ជរា មិនអាចធ្វើសកម្មភាពអ្វីបាន ទើបទ្រង់សោយទីវង្គតទៅកើតនៅស្ថានតុសិតសួគ៌ទាយ ។ ប្រជាជនខ្មែរកាលធ្វើអ្វីហើយ គេយល់ថាត្រូវតែទទួលផលនោះ ហើយទទួលនៅក្នុងសេចក្តីសប្បាយប្រកបដោយធម៌, ដោយភាគរភាព ដែលលេចចេញអំពីអំពើល្អនោះៗ ។ ត្រង់ចំណុចនេះហើយ ដែលខ្មែរចូលចិត្តធ្វើ ហើយចូលចិត្តនឹងជឿដល់សកម្មភាពនៃព្រះពោធិសត្វណាស់ ។

អាស្រ័យដោយមហាវេស្សន្តរជាតកបែបពុទ្ធនិយម ត្រូវបានអ្នកនិពន្ធខ្មែរគាត់តែងឡើង ឲ្យមានគោលដៅស្របទៅតាមសង្គម, តាមមនោសាស្ត្រខ្មែរបែបនេះហើយ ទើបរឿងនេះអាចក្លាយទៅជារឿងប្រ

ជាប្រិយមួយរបស់ខ្មែរ ហើយដែលខ្មែរតែងលើកតម្កើងទុកជារឿង ១ សក្តិសិទ្ធិក្នុងកាលសម័យខ្លះ ដែលសង្គមខ្មែរបានជួបប្រទះនឹងវិបត្តិទុរ្ភិក្ស ភ័យជាដើម ខ្មែរតែងរៀបចំពិធីទេសនាមហាជាតក៏នេះ ដើម្បីបួងសួងបន់ស្រន់សុំឲ្យមានភ្លៀងធ្លាក់ ដូចកាលព្រះវេស្សន្តរបានជួបនឹងញាតិវង្ស ហើយមានភ្លៀងបោក្ខរពស្សធ្លាក់ចុះមកលើ និងដូចកាលព្រះវេស្សន្តរយាងចូលមកក្នុងព្រះនគរវិញ ហើយមានភ្លៀងរត្ន ៧ ប្រការធ្លាក់ចុះ នាំឲ្យមានភាពសម្បូរសប្បាយដល់អ្នកនគរជេតុត្តរដូច្នោះឯង ។ ខ្មែរបានទុកមហាវេស្សន្តរជានិមិត្តរូបនៃភាពសម្បូណ៌ដោយទឹកភ្លៀង និងចំណីអាហារសម្រាប់សង្គមខ្មែរគ្រប់ពេលវេលា ។

# ប្រធាន

ចូរធ្វើការប្រៀបធៀបនូវសកម្មភាព និងបញ្ហាកំសត់ក្នុងមហាវេស្សន្តរជាតកនៅនឹងរឿងក្រុងសុភមិត្រ និងរឿងកាកី ។

## អត្ថាធិប្បាយ

តាមផ្ទៃនៃអត្ថរូប រឿងទាំង ៣ គឺមហាវេស្សន្តរជាតក, ក្រុងសុភមិត្រ និងរឿងកាកី សុទ្ធតែជារឿងក្នុងពុទ្ធនិយមទាំងអស់ ប៉ុន្តែបើយើងធ្វើការសិក្សាវែកញែកឲ្យច្បាស់លាស់ទៅ រឿងទាំង ៣ នេះពុំមែនសុទ្ធតែជារឿងពុទ្ធនិយមដូចគ្នាឡើយ ដែលយើងនឹងបានឃើញច្បាស់តាមការប្រៀបធៀបដូចតទៅ ៖

នៅក្នុងមហាវេស្សន្តរជាតក សកម្មភាពរបស់តួអង្គព្រះពោធិសត្វមានលក្ខណៈសំខាន់បំផុតគឺការកសាងបំពេញទានបារមីទាំងអស់។

យ៉ាងណាមិញ ក្នុងផ្នែកខាងដើម យើងបានឃើញសភាពអស្ចារ្យនិង លក្ខណៈល្អរបស់ព្រះវេស្សន្តរលេចផុសចេញមកពីគំនរទាន ថែមទាំង បានប្រព្រឹត្តធ្វើសកម្មភាពនៅក្នុងគំនរទាននេះថែមទៀត, ព្រះនាងសុ- បារសុប្បតីកំពុងយាងបំពេញទាននៅក្នុងចន្លោះនៃផ្ទះពួកឈ្មួញ ស្រាប់តែ ប្រសូតបានព្រះរាជបុត្រ ១ ព្រះអង្គ ហើយចេះនិយាយសួរព្រះមាតា ដើម្បីរកទ្រព្យសម្បត្តិសម្រាប់ធ្វើទាន ។ នៅក្នុងកុមារវ័យ ព្រះវេស្សន្តរ ជាតួអង្គដែលមានព្រះទ័យពោរពេញទៅដោយចំណង់ចង់តែធ្វើទាន បាន ប្រទានរបស់ផ្សេង ៗ យ៉ាងមានតម្លៃជាច្រើនឲ្យជនដទៃ ហើយដល់ ពេលព្រះអង្គមានព្រះជន្មត្រឹម ៨ ឆ្នាំប៉ុណ្ណោះ ក៏ចង់ធ្វើអជ្ឈត្តិកទាន ពោលគឺការឲ្យសាច់ឈាម, បេះដូង ភ្នែកសរសៃថែមទៀត ។ អំ ណោយទាននេះ បានផ្ទុះចេញជាផលអាក្រក់ដល់ព្រះវេស្សន្តរនៅពេល ដែលព្រះអង្គបានប្រទានដំរីបច្ច័យនាគេន្ទ្រឲ្យទៅព្រាហ្មណ៍ នៅស្រុក កលិង្គរាស្ត្រ ។ កំហឹងចិត្តនៃអ្នកស្រុកស្រីពិរាស្ត្រចំពោះទានរបស់ ព្រះវេស្សន្តរនេះ អាចធ្វើឲ្យព្រះអង្គព្រាត់ចេញពីព្រះនគរ ទៅគង់នៅក្នុង ព្រៃយ៉ាងត្រមោចត្រមង់ ហើយនៅទីបំផុត សកម្មភាពនៃទានបារមីនេះ ត្រូវទទួលជ័យជំនះគ្រប់ផ្លូវ គ្រប់ច្រកឡើងវិញ = បានព្រះឥន្ទថ្វាយពរ, បានព្រះបាទស្រីសញ្ជ័យអញ្ជើញមកឲ្យសោយរាជ្យ, បានភ្លៀងរត្ន ៧

ប្រការធ្លាក់មកក្នុងព្រះនគរញាំងជីវភាពប្រជាជនឲ្យបានសម្បូរសប្បាយ ។ ទាំងអស់សុទ្ធតែជាផលទានរបស់ព្រះវេស្សន្តរ ដែលទ្រង់ប្រឹងធ្វើប្រឹងបំពេញមក ។

ចំណែកខាងកំសត់វិញ ក៏លេចចេញមកពីទារុណកម្មយ៉ាងខ្លោចផ្សា មួយក្រោយពេលដែលព្រះវេស្សន្តរបានធ្វើបុត្តបរិច្ចាគដែរ មិនតែប៉ុណ្ណោះ នាងមទ្រីដែលទទួលរងទុក្ខខាងផ្លូវចិត្ត ដោយបាត់បុត្រាបុត្រី. ដោយត្រូវព្រះវេស្សន្តរប្រច័ណ្ឌ ក៏កើតចេញមកពីទានរបស់ព្រះពោធិសត្វនេះទៀត ។ រួមសេចក្តីមក ទារុណកម្មដែលអាចផ្តល់នូវសភាពកំ-សត់លន្លង់លន្លោចដល់អ្នកអាន គ្មានកើតមកពីប្រភពណា = កម្មផល ការព្រាត់ប្រាស ក្រៅពីសកម្មភាពនៃការធ្វើទានរបស់ព្រះវេស្សន្តរឡើយ បានសេចក្តីម្យ៉ាងទៀតថា ទានបារមីរបស់ព្រះវេស្សន្តរបានធ្វើឲ្យមានវិបត្តិចំនាស់ផង មានសភាពធូរស្រោស និងភាពសម្បូរសប្បាយង ។

ចំណែកខាងសកម្មភាព នៃតួអង្គក្នុងរឿងក្រុងសុភមិត្រ មានក្ខណៈត្រង់បញ្ហាផលកម្មទៅវិញ ។ យ៉ាងណាមិញ. ក្រុងសុភមិត្រលត្រូវអសុភមិត្រធ្វើរដ្ឋប្រហារដណ្តើមយករាជបល្ល័ង្ក ក៏ដោយសារនផលនៃកម្ម ជាពូជ-ពន្ធក ដើម មកទាញមកពង្រាត់ធ្វើឲ្យតួអង្គជួបប្រ-

ទះនឹងវិបត្តិធម្មជាតិដែលគ្របសង្កត់ ដូចជាទឹកស្ទឹងជាដើម ។ លុះពេលកម្លាំងធម្មជាតិរាំងរា បង្កើតជាឧបសគ្គពង្រាត់គូអង្គទាំងអស់នេះហើយ កម្មក្លាយដែលហៅថាពៀរនោះ ក៏ទាញយកគូអង្គទាំងអស់ទៅធ្វើបាប តាមជាន់តាមថ្នាក់គ្នារហូតទល់ផុតរលត់អស់ពៀរនោះ ទើបបានទទួលផលល្អវិញ ឧទាហរណ៍ :

- ព្រះបាទក្រុងសុភមិត្រដែលគ្រាន់តែមិនអើពើ ចំពោះកូនរបស់ខ្លួន ដែលយកកូនសត្វសារិកាមកលេងជាល្បែងពីជាតិមុនក៏ត្រូវពៀរមកទាញឲ្យព្រាត់និរាសពីរាជបុត្រទាំងពីរ បណ្តាលឲ្យព្រះអង្គក្រៀមក្រំព្រះទ័យយ៉ាងខ្លាំងក្លា ហើយទោះជាព្រះបាទក្រុងសុភមិត្របានសោយរាជ្យនៅនគរតក្កសិលាហើយក៏ដោយ ក៏ព្រះអង្គពុំបានសប្បាយព្រះទ័យទាល់តែសោះ ។

- ចៅជ័យសេន ជ័យទត្ត ដែលបានយកកូនសត្វសារិកាមកលេង ហើយធ្វើឲ្យរោចរោមតែ ៣ សរសៃពីជាតិមុននោះ ក៏ត្រូវពៀរតាមមកទាញប្រអូសឲ្យព្រាត់ពីព្រះមាតាបិតា ទៅនៅជាមួយព្រានព្រៃអស់ជាច្រើនឆ្នាំ ទាល់តែបានជួបព្រះបិតាហើយ ក៏បុត្រទាំងអស់មិនអាចស្គាល់គ្នាបានឡើយ ។ ការមិនស្គាល់គ្នានេះ គឺមកពីចំណាស់នៃវ័យនេះម្យ៉ាង ហើយម្យ៉ាងទៀតគឺមកពីកម្មពៀរបានបំភ័ន្ត បំបិទសតិ-

សម្បជញ្ញៈនេះឯង ។ រហូតទល់ជ័យសេន ជ័យទត្ត ត្រូវរងទទួលទុក្ខទល់ថ្នាក់បែកហូរឈាម ទើបកម្មពៀរបានរលត់ទៅវិញ ។

ដូច្នេះ រឿងនៃក្រុងសុភមិត្រ សកម្មភាពនៃតួអង្គស្ថិតនៅត្រង់ការទទួលសោយនូវកម្មផល ពៀរវេរាដែលខ្លួនបានធ្វើរួចហើយនោះឯង ។

រីឯបញ្ហាកំសត់វិញ ក៏មិនមែនលេចផុសចេញពីណា ក្រៅពីបញ្ហាកម្មផលនេះដែរ ។ តួអង្គទាំងអស់ដែលបានទទួលរងកម្មផល បានទទួលទុក្ខទារុណកម្មយ៉ាងខ្លាំង យើយដោយឪពុកម្តាយនិងកូន សុទ្ធតែមិនបានស្គាល់គ្នាទាំងអស់ ប៉ុន្តែស្ថិតនៅជិតគ្នាណាស់ ហើយដោយព្រះបាទសុភមិត្រ ក៏ឥតសួររកដើមចមជាមុន, សេនជ័យជ័យទត្ត ក៏មិនបានពោលពណ៌នាអំពីប្រវត្តិរបស់ខ្លួន ទូលព្រះបាទសុភមិត្រ ឬ រាជអាមាត្យណាមួយ ជាហេតុនាំឲ្យអ្នកអានមានចិត្តស្រងេះស្រងោចខ្លោចផ្សារឡើងមួយរំពេច ប៉ុន្តែក្រោយពេលដែលចលនាកំសត់នេះបានស្ងប់វិញ ដោយពៀរឈប់ប្ររួសប្រទាញហើយ តួអង្គក៏បានស្គាល់គ្នា ដោយមានសតិសម្បជញ្ញៈមកជួយគាំពារផង ។ ហេតុណាៈបែបនេះហើយ ដែលនាំឲ្យយើងយល់បានថា កំសត់ក្នុងរឿងក្រុងសុ-

ភមិត្រ  មិនមែនកើតចេញមកពីការបំពេញបារមីណាមួយរបស់ព្រះពោធិ-សត្វឡើយ  ប៉ុន្តែជាកំសត់ដែលកើតចេញពីបញ្ហាកម្មផលទៅវិញ កាលណាពៀរឡើងកំរិតខ្លាំង  បណ្ដាលឲ្យមានចលនាកំសត់ឡើង  ហើយកាលណាកម្មពៀរនេះថយឫទ្ធិអំណាចទៅ  ដោយតួអង្គបានទទួលផលអាក្រក់រួច  ចលនាកំសត់ក៏បានចុះកំរិត  នាំឲ្យអ្នកអានបានយល់ច្បាស់លែងកំសត់ទៅទៀត ។

ផ្ទុយពីរឿងទាំងពីរខាងលើ  រឿងកាកីដែលជាអក្សរសិល្ប៍ក្នុងពុទ្ធនិយមក្លែងក្លាយនោះ  សកម្មភាពពុំមែនស្ថិតនៅលើការសាងបារមីឡើយ  ហើយក៏ពុំស្ថិតនៅលើបញ្ហាកម្មពៀរដែរ  ប៉ុន្តែជាសកម្មភាពមួយដែលលេចចេញមកពីទំនាស់រវាងភេទខ្លាំងនិងភេទខ្សោយនេះឯង ។ យ៉ាងណាមិញ  ចាប់តាំងពីដើមរឿងទៅ  យើងឃើញថាតួអង្គមានភេទនិងកម្លាំងខ្លាំងក្លាជាងត្រូវមានអំណាច មានប្រៀបលើជាដរាប ។

តួអង្គជាតំណាងភេទខ្លាំង  មានព្រះបាទព្រហ្មទត្ត, គ្រុឌ និងគន្ធីន  **ឯតួអង្គ**ជាតំណាងភេទខ្សោយ  មានតែនាងកាកីមួយប៉ុណ្ណោះ ។ **កាលណាតួអង្គ**ជាតំណាងភេទទាំងពីរនេះ  ធ្វើសកម្មភាពជាមួយគ្នា  អ្នក**និពន្ធចេះតែដាក់ឲ្យតួអង្គភេទខ្សោយ**ចាញ់ដៃ**តួអង្គខ្លាំង**ជានិច្ច  ហើយទៅ

ទីបំផុត នាងកាកីក៏ចាញ់ស្រឡះ ដោយគេបានចង្អុលបង្ហាញថា នាងកាកីបានធ្វើអំពើអាក្រក់ = ក្បត់ស្វាមី, ម្ដងក្បត់ព្រះបាទព្រហ្មទត្ត ជាមហាក្សត្រដែលសម្បូណ៌ទៅដោយស្រីស្នំទៅហើយ ម្ដងនាងកាកីក្បត់គ្រុឌដែលជាសត្វបក្សីពុំអាចផ្ដល់សុភមង្គលឲ្យបរិបូណ៌ដល់នាងបាន។ ប៉ុន្តែអំពើអាក្រក់របស់តួអង្គខ្លាំងផង គេចេះតែឲ្យតម្លៃមានកិរិតខ្ពស់ខ្លាំងឡើងឥតមានខុសសោះ គេទុកស្ត្រីជាគ្រឿងល្បែង, ជាផ្កាប្ដូយចង បើកាលជ្រុះចាកទងហើយ មិនអាចមានសម្រស់មានលំអងវិញឡើយ ហើយគេទុកបុរសជាភេទខ្លាំង ឲ្យមានតម្លៃស្មើនឹងមាសទឹកដប់ សូម្បីធ្លាក់ទៅក្នុងភក់ជ្រាំជុំលាយកបែបណា ក៏មាសនោះមិនចេះក្លាយទៅជាអ្វីដែរ ។

ដូច្នេះ សកម្មភាពរបស់តួអង្គក្នុងរឿង កាកី ដែលអ្នកនិពន្ធបានឲ្យតម្លៃថាជារឿងពុទ្ធនិយមដែរនោះ ពុំមានការទាក់ទងអ្វីទៅនឹងការសាងបារមីរបស់ព្រះពោធិសត្វ ឬ បញ្ហាកម្មផលតាមបែបពុទ្ធនិយមឡើយ ប៉ុន្តែអ្នកនិពន្ធ បានលើកយកសកម្មភាពនៃវិបត្តិទំនាស់របស់គ្រួសារនៅក្នុងសង្គមមនុស្សនេះមកលាតត្រដាងទៅវិញ ។

រីកំសត់ក្នុងរឿងកាកីនេះសោតទៀត ក៏មានលក្ខណៈស្របទៅតាមដំណើររឿង និងសកម្មភាពរបស់តួអង្គដែរ ។ កំសត់ក្នុងរឿងកាកី បានផ្ដល់នូវភាពស្រងេះស្រងោចយ៉ាងស្អិតនៅត្រង់ការធ្វើ

ទារុណកម្មរបស់ព្រះបាទព្រហ្មទត្តចំពោះនាងកាកី ធ្វើឲ្យនាងកាកីវេ
សង្រេងស្រណោះស្រណោកគ្មានទីបំផុត ព្រោះគ្មានសេចក្ដីសង្ឃឹ
នឹងបានរស់រានបានជីវិតវិញបាន ។ សំណោកខ្ញួញស្រណេ
របស់នាងកាកី បានរំលឹកនូវអនុស្សាវរីយ៍ចាស់ ។ យ៉ាងច្រើនវែងឆ្ងាយ
លើពោងពាយ ដែលធ្វើឲ្យអ្នកផងជួយស្រណោះនាងយ៉ាងខ្លាំង
តួអង្គឯទៀត ។ ក៏បានធ្វើកំហុសដូចនាងដែរ ប៉ុន្តែមិនបានទទួល
អាក្រក់ដូចនាងឡើយ ។

សកម្មភាព និងកំសត់ក្នុងមហាវេស្សន្តរជាតកស្ថិតនៅ
កសាងទានបារមី ឯក្នុងរឿងក្រុងសុភមិត្រ ស្ថិតនៅលើការសោយ
ផលពីអតីតជាតិរបស់តួអង្គ គឺក្រុងសុភមិត្រឥតមានសាងបារមីណា
ចំណែកខាងសកម្មភាព និងកំសត់ក្នុងរឿងកាកីវិញ ពុំស្ថិតនៅ
សាងបារមី, លើបញ្ហាកម្មផលទេ តែស្ថិតនៅលើវិបត្តិទំនាស់
អង្គខ្លាំង-ខ្សោយ ដែលអ្នកនិពន្ធបានដកយកចេញពីវិបត្តិទំនាស់ដែ
មាននៅក្នុងសង្គមមនុស្សក្បាលខ្មៅ អាចអត្ថបទនេះ មកលោតត្រ
វែ្ធងឲ្យទៅជារឿងពុទ្ធនិយម បែបពុទ្ធនិយមក្លែងក្លាយនេះឯង ។
ទាំង ៣ បែបនេះ គ្មានកំសត់ប្រភេទណា មានតម្លៃជាងប្រវេ
ឡើយ ។

# ប្រធាន

គ្រប់កណ្ឌទី ៥ ក្នុងមហាវេ-
ស្សន្តរជាតក គឺកណ្ឌជូជក និងរឿង
រាមកេរ្តិ៍ខ្មែរ ៤ អ្នកនិពន្ធបានធ្វើការ
ពណ៌នាអំពីតាជូជក និងអំពីរឿងក្រ
បីយ៉ាងវែង ហាក់ដូចជាដាច់ចេញ
ស្រឡះ ពីសាច់រឿងទាំងពីរទៅ
វិញ ។

តើឧបករជាវិធីបែបនេះ មាន
សារៈសំខាន់យ៉ាងណាខ្លះ ក្នុងរឿង
ទាំងពីរ ?

# អត្ថាធិប្បាយ

ពិតមែនតែរឿងតាជូជក និងរឿងក្របីទូភិជាដើម នៅក្នុងមហាវេស្សន្តរជាតក និងរឿងរាមកេរ្តិ៍ មានលក្ខណៈជាឧបកថាពិតក៏ពិតដែលអ្នកនិពន្ធបានលើកយករឿងផ្សេង មកច្រៀតបញ្ចូលនៅក្នុងដំណើររឿងចាស់ក៏ដោយ ក៏ដំណើររឿងថ្មីនេះ មានការទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងរឿងចាស់ដែរ ហើយថែមទាំងជួយរចនារឿងដើមនោះឲ្យមានតម្លៃមួយផ្សេងទៀតផង ។

ក្នុងខណៈដែលព្រះវេស្សន្តរ ទ្រង់យាងចូលទៅគង់នៅក្នុងព្រៃភ្នំគិរីវង្កតជាមួយមហេសី និងបុត្រីបុត្រា អ្នកនិពន្ធបានបញ្ឈប់សកម្មភាពនៃព្រះវេស្សន្តរនេះទុក ១ ខណៈសិន ហើយបែរជាមកនិយាយពីរឿងតាជូជកទៅវិញ ។ រឿងតាជូជកនេះហាក់ដូចជាពុំមានការទាក់ទងទៅនឹងផ្លូវរឿងឡើយ ។ តើព្រោះហេតុអ្វីបានជាអ្នកនិពន្ធបែរមកនិយាយរឿងបែបនេះទៅវិញ ? ចុះហេតុម្តេចក៏ផ្អាកចោលនូវរឿងព្រះវេស្សន្តរចោលយ៉ាងនេះ ?

ចំពោះសំនួរខាងលើ យើងអាចឆ្លើយបានបែបនេះថា ការ

ដែលអ្នកនិពន្ធបានលើកយករឿងតាជូជកនេះ មកពណ៌នាធ្វើជាឧបកថាយ៉ាងវែងដូច្នេះ គឺដើម្បីនាំអ្នកអានឲ្យសំរាកចិត្តគំនិតបន្តិច ព្រោះប៉ុន្មានកណ្ឌរួចហើយ អ្នកអានបានឃើញតែតួអង្គព្រះវេស្សន្តរ និងតួអង្គឯទៃទៀត បំពេញទានយ៉ាងសកម្ម ហើយតមកព្រះវេស្សន្តរក៏បានទទួលផលអាក្រក់ពីទាននេះទៅវិញ ។ ក្នុងខណៈនេះអ្នកអានអ្នកស្តាប់ទាំងឡាយ មានចិត្តស្ទុះស្ទាប់ធុញទ្រាន់តានតឹងយ៉ាងខ្លាំង ស្ទើរនឹងចង់លែងអាន លែងស្តាប់តទៅទៀតហើយ ដូច្នេះ បានជាអ្នកនិពន្ធបានយកតួអង្គមួយថ្មីទៀតដែលប្លែក ប្រកបដោយលក្ខណៈកំប្លុកកំប្លែងតាមធម្មជាតិផងតាមសង្គមបរិយាកាសផង មកលាតត្រដាង ។ អ្នកអាន អ្នកស្តាប់ ដែលកំពុងតែតឹងចិត្តចំពោះតួអង្គមុន ៗ នោះ លុះបានជួបតួអង្គប្លែកមានលក្ខណៈគួរឲ្យចង់សើចបែបដូចតាជូជកនេះ ក៏បានធូរចិត្តមួយខណៈយ៉ាងធំ ហើយក៏ចង់ដឹងដំណើររឿងតទៅទៀត ។

ម្យ៉ាងទៀត ហេតុដែលអ្នកនិពន្ធបានលើកយកតាជូជកនេះមកនិយាយគឺដើម្បីធ្វើជាគ្រឿងប្រដាប់សម្រាប់មើលទីតាំងនៅ និងសកម្មភាពរបស់ព្រះវេស្សន្តរនៅក្នុងព្រៃភ្នំឯណោះ ។ បើគ្មានតាជូជកទេ អ្នកអាន អ្នកស្តាប់ មិនអាចបានដឹងពីជីវភាព–សកម្មភាពរបស់ព្រះវេស្សន្តរដែលស្ថិតនៅឆ្ងាយពីសង្គមមនុស្សនោះបានឡើយ ។

ដូច្នេះ រឿងតាផ្លូជកជាឧបកថាវិធីយ៉ាងរបស់អ្នកនិព
គោលបំណងនឹងចំឡងអារម្មណ៍អ្នកអាន – អ្នកស្ដាប់ឲ្យចង់ដឹងត
តណ្ហាខាងមុខ ៗ ទៀត ជាពិសេស គឺជាកត្តា ១ នៃការនាំឲ្យ
ព្រះវេស្សន្តរនេះឯង ។

ចំណែកខាងក្នុងរឿងរាមកេរ្តិ៍វិញ អ្នកនិពន្ធបានទុក
ភាពរបស់ព្រះរាម ដែលប្រឹងតាមរកនាងសីតា នៅក្នុងព្រៃមួយអ
ហើយចាប់យករឿងមួយផ្សេងទៀតដែលមាននៅក្នុងព្រៃនោះដែរ
និទានជាឧបកថាបន្តក្នុងដំណើររឿងរាមកេរ្តិ៍ដដែល ។ ចំពោះ
ថ្មីដែលអ្នកនិពន្ធលើកយកមកជ្រៀតជ្រែកបែបនេះ តើនឹងមានប្រយោ
អ្វីដែរ ? ហេតុដូចម្ដេចបានជាអ្នកនិពន្ធមិននិទានរៀបរាប់ពីដំណើ
រាមស្វែងរកនាងសីតាតទៅទៀត ?

ចំពោះសំនួរខាងលើ យើងអាចឆ្លើយបានថា បានជាអ្
ពន្ធមិនបាននិទានរៀបរាប់ពីសកម្មភាព ព្រះរាមព្រះលក្ស្មណ៍ក្នុងការ
រកនាងសីតាតទៅទៀត ហើយបែរជាមកយករឿងថ្មីផ្សេងមក
ឧបកថានេះ ព្រោះអ្នកស្ដាប់ អ្នកអានហាក់ដូចជាយន់ចិត្តធុញទ្រា
រឿងរបស់ព្រះរាមណាស់ទៅហើយ ជាពិសេស គេធុញទ្រាន់

ត្រង់ព្រះរាម ជាមនុស្សចាញ់កលគូសត្រូវធ្វើឲ្យគូសត្រូវបោកបញ្ឆោតយកប្រពន្ធបាន បើព្រះរាមជាមនុស្សមានប្រពន្ធច្រើនទៅក៏មិនជាអ្វីទេ ប៉ុន្តែព្រះរាមមានស្រីតែ១ គត់សម្រាប់ធ្វើប្រពន្ធ ដល់គេបោកបញ្ឆោតយកបានទាំងភ្នែកស្រស់បែបនេះទៅ អ្នកអាន អ្នកស្តាប់តឹងចិត្តណាស់ តឹងចិត្តព្រោះឃើញព្រះរាមចាញ់កលគេនេះម្យ៉ាង ហើយម្យ៉ាងទៀត តឹងចិត្តព្រោះស្អប់ខ្ពើមព្រះរាម– ឬស្អប់យក្សក្រុងរាពណ៍ ។ តំណឹងចិត្តដោយការតប់ប្រមល់នេះហើយដែលអាចធ្វើឲ្យអ្នកអាន–ស្តាប់ លែងចង់ដឹងរឿងរាមកេរ្តិ៍តទៅទៀត ហើយឯអ្នកនិពន្ធសោតក៏ហាក់ដូចជាគ្មានមធ្យោបាយណានឹងរកពាក្យសំដីមកពណ៌នា រឿងព្រះរាមឲ្យពីរោះជាងនេះទៅទៀតបាន ក៏ត្រូវលើកយកឧបកថាមកធ្វើជាពិធីសាស្ត្រសម្រាប់បន្តរឿងតទៅទៀត ។ ប៉ុន្តែ ឧបកថានេះមិនមែនដាច់ចេញស្រឡះរហូតចប់ចុងដើមពីរឿងរាមកេរ្តិ៍នោះឡើយ ។-

ម្យ៉ាងទៀត ឧបកថានេះ គឺជាមធ្យោបាយមួយ សម្រាប់បង្ហាញឥទ្ធិពលរបស់ព្រះរាមនេះឯង ព្រោះអីក្នុងពេលនេះ ព្រះរាមមានតែព្រះលក្ស្មណ៍ជាគ្នាប៉ុណ្ណោះ គ្មានគូអង្គណាមួយផ្សេងទៀតជាកងទ័ពឬជាបរិវារមកជួយសម្រាលទុក្ខព្រះរាមសោះ ។ ការលើកយករឿងក្របីមកពណ៌នាជាដំបូងនេះ គឺដើម្បីទាញអារម្មណ៍អ្នកអាន អ្នកស្តាប់

ឲ្យភ្ញាក់ព្រើតឡើង ពីសភាពងោកងុយ យក់ទង់អារម្មណ៍យូរហើយនោះ
ព្រោះរឿងក្របីនេះ ជារឿងប្លែក = ក្របីទូភី មិនមែនជាក្របីព្រៃធម្ម-
តា ឬក្របីតូចតាចនោះឡើយ ក៏ប៉ុន្តែជាក្របីមានសិល្បសាស្ត្រនៅក្នុ
ខ្លួន ផឹកទឹកមួយថ្ងៃ ៣ បឹង ស៊ីស្មៅមួយថ្ងៃ ៣ វាល ..... ជាក្របី
មានជ័យជំនះគ្រប់ផ្នែកលើតួអង្គឯទៀត ។ ប៉ុន្តែរំពេចនោះ អ្នកនិពន្ធ
បានបង្ហាញតួអង្គមួយទៀត ដ៏ខ្លាំងពូកែលើសក្របីទូភីនេះទៅទៀត គឺ
ស្តេចស្វា ឈ្មោះពាលី នៅខាស់ខិនបុរី ។ ចលនានៃឧបកថានេ
ចេះតែបង្ហាញច្បាស់ឡើង ។ នូវចម្បាំងរវាងពាលីនិងទូភី ព្រមទាំង
ជ័យជំនះដ៏អស្ចារ្យរបស់ពាលី លើក្របីទូភី នៅក្នុងរូងភ្នំមួយដែលអាច
បង្កើតជាទំនាស់ វិបត្តិយ៉ាងធ្ងន់រវាងពាលីជាបងរបស់សុគ្រីព ។

· គឺដោយឧបកថានេះហើយ ដែលយើងអាចឃើញតួអង្គព្រ
រាម នៅតាមរយៈតួអង្គសុគ្រីព ( មានទុក្ខនៅក្នុងមតង្គបពិត ) បានប្រើ
ហនុមានជាក្មួយ ឲ្យចេញទៅពិនិត្យមើលហេតុភេទដ៏ចំឡែកមួយនៅក្នុ
ព្រៃ ។ ក្នុងខណៈនេះហើយ ដែលយើងបានជួបនឹងតួព្រះរាមវិញ
ដដែល ហើយព្រះរាមក្នុងពេលនេះ មិនមែនជាព្រះរាមដូចមុនទេ គឺជា
ព្រះរាមចេះសន្ធនាភាសាស្វា មានស្វាជាបរិវារ, ជាកងទ័ពដ៏ច្រើនអនេក
មានធ្នូសរព្រហ្មាស្ត្រដ៏ខ្លាំងអស្ចារ្យ ។

ដូច្នេះឧបកថាក្នុងរឿងរាមកេរ្តិ៍ ក៏បិទផ្ទុយពីឧបកថាក្នុងមហាវេស្សន្តរជាតកដែរ ។ អ្នកនិពន្ធបានលើកយកឧបកថាបែបនេះ មកដាក់ក្នុងដំណើររឿង ជាវិធីម៉្យាងអាចធ្វើអារម្មណ៍អ្នកអាន អ្នកស្តាប់ឲ្យភ្ញាក់ឡើងនេះម៉្យាង ហើយម៉្យាងទៀត តួអង្គដែលអ្នកនិពន្ធបានលើកយកមកធ្វើជាឧបកថានេះ មានសារសំខាន់ក្នុងការចំឡងអារម្មណ៍-ចិត្តអ្នកអានអ្នកស្តាប់ ឲ្យចូយទៅកាន់រឿងចាស់នោះដដែល ប៉ុន្តែស្ថិតនៅក្នុងដំណាក់ការមួយថ្មីផ្សេងទៀត = តាជូជកទៅជួបព្រះវេស្សន្តរ ដើម្បីជួយបំពេញទានបារមីរបស់ព្រះវេស្សន្តរ ព្រមទាំងធ្វើដំណើររឿងឲ្យរឹតតែពីរោះ មានខ្លឹមសារឡើង, ទំនាស់វិបត្តិរវាងពាលីនិងសុគ្រីពក្នុងរឿងសម្លាប់ក្របីទូភី គឺដើម្បីឲ្យតួអង្គព្រះរាមដែលមានទុក្ខ នៅក្នុងព្រៃតែពីរនាក់បងប្អូននោះ មានស្វាជាបរិវារក្នុងដំណើរតាមរកព្រះនាងសីតានេះឯង ។ បើខ្វះឧបកថាបែបនេះ ដំណើររឿងក៏ខ្វះតម្លៃម៉្យាងដែរ ។

# ប្រធាន

ចូរធ្វើការប្រៀបធៀប នូវលក្ខណៈជាពោធិសត្វ នៃព្រះវេស្សន្តរនៅនឹងលក្ខណៈជា អាទិទេព នៃតួអង្គព្រះរាម ក្នុងរឿងរាមកេរ្តិ៍ ដោយមានគោលបញ្ជាក់ថាលក្ខណៈនៃតួអង្គទាំងពីរនេះមានស្ថិរភាពដូចគ្នា ឬ ផ្សេងគ្នា ។

## អត្ថាធិប្បាយ

ព្រះវេស្សន្តរជាតួអង្គពោធិសត្វ អ្នកសាងបារមីដើម្បីបានត្រាស
ជាព្រះពុទ្ធ ឯព្រះរាមជាអាទិទេពដែលអវតារចុះមកដើម្បីបង្ក្រាបពួកអសុរ
ដើម្បីនឹងស្គាល់ថា តើលក្ខណៈនៃតួអង្គទាំងពីរនេះមានស្ថិរភាពជាពោ-

ធិសត្វ ឬ ជាអាទិទេព តាំងពីដើមដល់ចប់នោះ យើងត្រូវលើកនូវលក្ខណៈនៃតួរង្គទាំងពីរនេះមកធ្វើការសិក្សាប្រៀបធៀបដូចតទៅ ៈ

លក្ខណៈដែលបញ្ជាក់ឲ្យដឹងថា ព្រះវេស្សន្តរជាតួអង្គពោធិ--សត្វអ្នកសាងបារមី គឺការធ្វើទានរបស់ព្រះអង្គដែលមានហេតុភេទបញ្ជាក់តាំងពីព្រះអង្គប្រសូតមក រហូតដល់ព្រះជន្មបាន ៨ វស្សា ទ្រង់ក៏ប្រា-រព្ធធ្វើទានខាងក្នុងដែលគ្មានអ្នកណាអាចធ្វើកើត គឺការឲ្យសាច់ឈាមរហូតទល់បេះដូង ថ្លើម ប្រមាត់ ទៀតទៅជនទាំងឡាយណាដែលចង់បាន ។ បន្ទាប់មក ព្រះវេស្សន្តរបានធ្វើទាននេះរហូត មិនតែប៉ុណ្ណោះ ទឹកព្រះទ័យព្រះអង្គគ្មានប្រែប្រួលចំពោះការឲ្យទាននេះទេ ។ បើនិយាយម្យ៉ាងទៀតថា គោលបំណងដែលលេចចេញពីដើមយ៉ាងណា ព្រះវេស្សន្តរបានធ្វើយ៉ាងនោះរហូតទល់ចប់មួយជីវិត ។ ពេលក្រោយត្រឡប់ពីភ្នំគិរីវង្កតមក ព្រះវេស្សន្តរនៅតែបំពេញទានក្នុងឋានៈជាពោធិសត្វដដែល ។

ដូច្នេះ យើងអាចធ្វើការកត់សំគាល់បានថា លក្ខណៈនៃព្រះវេស្សន្តរ មានស្ថិរភាពនឹងនរ ឥតប្រែប្រួលទៅជាមនុស្សសាមញ្ញវិញទេ បើទុកជាមានខ្លះក៏គ្រាន់តែជាគំនិតគិតឃើញប៉ុណ្ណោះ ដូចជាការចង់ប្រ-ហារតាជូជកជាដើម គ្រាន់តែជាគំនិតកើតឡើងមួយខណៈនោះឯង

ប៉ុន្តែព្រះអង្គពុំបានប្រហារតាផុផក ដូចព្រះទ័យគិតឃើញនោះឡើយ ។

ឲ្យរំពឹងនេះ ក្នុងរឿងរាមកេរ្តិ៍ផ្នែកខាងដើម យើងបានឃើញថា ព្រះរាមជាតួអង្គអាទិទេព អវតារចុះមកដើម្បីរកយុត្តិធម៌ឲ្យសត្វលោកមនុស្សនេះមែន = ជាមនុស្សមានសន្ដានចិត្តនិងសកម្មភាព ជាអាទិទេពយ៉ាងពិតប្រាកដ ឧទាហរណ៍ យើងបានឃើញព្រះរាមជួយដោះស្រាយវិបត្តិចំនាស់ រវាងពាលីពិស្វាមិត្រនិងពួកអសុរកាកនាសូរ, ទប់ព្រះទ័យដោយការគោរពពាក្យសច្ចៈចំពោះនាងកៃកេសី ដែលផណ្ដឹមរាជ-សម្បត្តិថ្វាយទៅព្រះភិរុត . . . . ធ្វើទោសចំពោះពាលី ដែលមានកំហុសដោយផណ្ដឹមនាងតារាទេពីពីសុគ្រីព យកមកធ្វើជាទេពី, ស្គាល់ដើមត្នោតដែលដុះតាំងពីពេលកំណើតនៃផែនដីកើតជាដើម ។

ទៅចំពោះមុខតួអង្គឯទៀត ។ ដូចជារាមបរមសូរ, ពាលី ជាដើម ព្រះរាមតែងបង្ហាញនូវលក្ខណៈរបស់ទ្រង់ថាជាវិស្ណុអវតារ ចុះមកបង្ក្រាបផាត់ទោសអ្នកធ្វើអាក្រក់ ធ្វើខុសទាំងអស់ ។ គឺដោយហេតុដូច្នេះហើយ បានជាក្នុងរឿងរាមកេរ្តិ៍ ចាប់តាំងពីខ្សែមួយដល់ខ្សែដប់ យើងឃើញថាព្រះរាមមានលក្ខណៈជាអាទិទេពមែន ព្រោះជាអ្នកដឹងខុសត្រូវផង ជាអ្នកបង្ក្រាបអ្វី ។ ដែលអាក្រក់ផង ។

ផ្ទុយទៅវិញ មកដល់ផ្នែកខាងចុង ពីខ្សែ ៧៥ ដល់ខ្សែ ៨០

ព្រះរាមបែរជាមានលក្ខណៈជាមនុស្សក្បាលខ្មៅ អាចប៉ះស្ពាយ ធុនអន់ថែមទៀត ព្រោះម្តងនេះព្រះរាមប្រែលក្ខណៈពីអាទិទេព មកជាមនុស្សមិនដឹង មិនស្គាល់អ្វីទាល់តែសោះ គ្រាន់តែនាងសីតាតួររូបរាពណ៍ឲ្យពួកស្នំបំរើមើលប៉ុណ្ណោះ ព្រះរាមក៏យកទោសព្រះទេពីនេះ រហូតដល់ចាត់ឲ្យព្រះលក្ស្មណ៍យកព្រះនាងសីតាទៅពិឃាតចោល ដោយគ្មានគិតពិចារណាសោះឡើយ ។ មិនតែប៉ុណ្ណោះ សូម្បីព្រះលក្ស្មណ៍យកថ្លើមក្តែមកថ្វាយ ក៏ព្រះរាមនៅតែមិនដឹងថា ថ្លើមនោះជាថ្លើមក្តែ ឬថ្លើមមនុស្សទៀតផង ។

នៅពេលដែលរាមលក្ស្មណ៍ជុបលក្ស្មណ៍បានបាញ់រំលំដើមឈើឮសន្ធឹកគគ្រឹកគគ្រេង ក៏ព្រះរាមមិនដឹងថាជាសំឡេងអ្វីដែរ, ព្រះរាមបានធ្វើសង្គ្រាមតតាំងជាមួយកូនរបស់ខ្លួន ដោយមិនបានដឹងថាជាកូនរបស់ខ្លួនសោះ ហើយនៅទីបំផុត ព្រះរាមជាមនុស្សមានលក្ខណៈអន់ណាស់ទៅទៀត ដោយរកបញ្ញាឆ្លាតយទីងសុំយាងព្រះនាងសីតាឲ្យចូលមកក្នុងព្រះនគរមិនបាន ក៏ទៅចូលកោដ្ឋ ធ្វើជាគ្រាំគ្រាទីវង្គត បញ្ឆោតបោកនាងសីតាមកវិញ ។

ព្រះរាម មានលក្ខណៈជាអាទិទេពមែននៅក្នុងផ្នែកខាងដើម ប៉ុន្តែ មកដល់ផ្នែកខាងចុង ព្រះរាមត្រូវប្រែក្លាយលក្ខណៈជាអាទិទេពមក

ជាមនុស្សធុនអន់គ្មានដឹងហេតុអីសោះឡើយ ។

ដូច្នេះ លក្ខណៈនៃតួរអង្គទាំងពីរ គឺព្រះវេស្សន្តរ និងព្រះរាម
ដូចគ្នាឡើយ. ព្រះវេស្សន្តរប្រកបដោយលក្ខណៈជាពោធិសត្វ ក៏
តែរក្សាលក្ខណៈនេះ តាំងពីដើមដល់ចប់ពុំប្រែប្រួលទៅជាអ្វីផ្សេងឡើយ
ផ្ទុយទៅវិញ ព្រះរាមពុំមានលក្ខណៈជាអាទិទេពនេះនៅស្ថិតស្ថេរជា
តាំងពីដើមដល់ចុងឡើយ ព្រោះនៅផ្នែកខាងចុង ព្រះរាមប្រែប្រួ
លក្ខណៈពីភាពជាអាទិទេពមកជាមនុស្សភាព ហើយធុនខ្សោយខ្វះស
សម្បជញ្ញៈ, គ្មានការពិចារណា ហើយសូម្បីបញ្ហាក្នុងគ្រួសារក៏មិនអា
ដោះស្រាយរួចឡើយ ។

### គួរចំណាំ

– ពោធិសត្វ ជាលក្ខណៈពុទ្ធនិយម

– អាទិទេព ជាលក្ខណៈព្រាហ្មណ៍និយម

# ប្រធាន

សភាពអស្ចារ្យក្នុង មហាវេ–ស្សន្តរជាតក និងក្នុងរឿងរាមកេរ្តិ៍គឺ ជាកលល្បិចមួយដ៏សំខាន់របស់អ្នក និពន្ធអក្សរសិល្ប៍ក្នុងបុរាណកាល ។ តើសភាពអស្ចារ្យនេះ មាន លក្ខណៈ និងតម្លៃយ៉ាងណាខ្លះនៅក្នុង រឿងទាំងពីរនេះ ។

## អត្ថាធិប្បាយ

លក្ខណៈ និងតម្លៃម៉្យាងដែលលេចផុសចេញឡើងយ៉ាងចម្លែក ខុសធម្មតាតាមរយៈតួអង្គ ដើម្បីបង្ហាញនូវចលនាណាមួយនៅក្នុងផ្ទៃរឿង គឺសភាពអស្ចារ្យ ( អច្ឆរិយភាព ) ។

សភាពអស្ចារ្យ មិនគ្រាន់តែមានលក្ខណៈប្លែកពីភាវៈធម្មតា, សកម្មភាពដែលធ្លាប់តែកើតមានឡើងនៅក្នុងធម្មជាតិ ឬ ក្នុងសង្គមមនុស្ស ធ្វើឲ្យអ្នកអាន អ្នកស្ដាប់ ចាប់ចិត្ត ចាប់អារម្មណ៍ដោយភ្ញាក់ស្មារតីតែប៉ុណ្ណោះទេ ក៏ប៉ុន្តែអាចជួយបញ្ជាក់នូវតម្លៃនៃសកម្មភាពរបស់តួអង្គអាក្រក់-ល្អឲ្យរឹតតែច្បាស់ឡើងថែមទៀត ។ យ៉ាងណាមិញ អច្ឆរិយភាពនៅក្នុងពុទ្ធនិយម ដូចជាព្រះធរណីស្រូបទេវទត្ត, សុប្បពុទ្ធ, នាងចិញ្ចា, នន្ទិយមាណព, និងកោកាលិកភិក្ខុ (១) គឺជាភេទបញ្ជាក់តម្លៃ ៧ របស់ព្រះសម្មាសម្ពុទ្ធ និងតម្លៃនៃផលអាក្រក់របស់តួអង្គទាំងនោះ ។

សភាពអស្ចារ្យនេះ បានលេចចេញឡើងយ៉ាងច្រើននៅក្នុងមហាវេស្សន្តរជាតក និងរាមកេរ្តិ៍ ។ ក្នុងមហាវេស្សន្តរជាតក ដូចជាដំរីចេះហោះនាំភ្លៀងមកថ្វាយព្រះវេស្សន្តរ, ព្រះឥន្ទនិមិត្តសាលាថ្វាយព្រះវេស្សន្តរនៅក្នុងព្រៃភ្នំ· ព្រះធរណី, ទឹកសមុទ្រ, ព្រៃព្រឹក្សារហូតទល់ភ្នំតូចធំនានា បានកំរើករំពើកញាប់ញ័រញ្ជួយ, លោកបក់ចុះឡើង ១ ខណៈ ហាក់ដូចជាជួយអបអរសាទរចំពោះការបំពេញទានរបស់ព្រះ

---

១ – មនុស្សដែលត្រូវព្រះធរណីស្រូបក្នុងសម័យពុទ្ធកាលមានតែ ៥ នេះ ។

វេស្សន្តរ ហើយថែមទាំងជួយថ្វាយពរសព្ទសាធុការចំពោះព្រះវេស្សន្តរ ដើម្បីឱយបានត្រាស់ជាព្រះពុទ្ធ ។ សភាពអស្ចារ្យមួយជាចុងក្រោយបំផុត គឺភ្លៀងរត្ន ៧ ប្រការធ្លាក់ចុះពាសពេញក្នុងនគរ ទោះក្នុងរាជវាំងក៏ដូចក្នុងរបងផ្ទះអ្នកស្រុកទាំងមូលដែរ ។ សភាពអស្ចារ្យទាំងនេះបានលេចចេញឡើងស្ទើរតែគ្រប់កណ្ឌក្នុងមហាវេស្សន្តរជាតក ។

ចំណែកខាងក្នុងរឿងរាមកេរ្តិ៍វិញ សភាពអស្ចារ្យបានលេចឡើងជាជំនួយដល់តួអង្គព្រះរាមជាច្រើនកន្លែង ( ភាគច្រើននៅក្នុងខ្សែ ១ ដល់ខ្សែ ៥ ) គឺអស្ចារ្យដែលកើតចេញពីតួព្រះរាមផ្ទាល់ ដូចជាការប្រហារកាកនាសូរ, ការលើកធ្នូសរមានជ័យជំនះលើពួកអសុរ និងទៃវៈផ្សេង ៗ ដើម្បីបាននាងសីតាធ្វើជាអគ្គទេពី និងសភាពអស្ចារ្យដែលលេចមកពីធម្មជាតិ ដូចជាពឫជាតិព្រៃព្រឹក្សានានាដែលក្រៀមស្ងួតសោះកក្រោះនៅរដូវក្ដៅរាំងរីង ក៏ប្រែជាមានស្លឹក—ផ្កា—ផ្លែស្រស់បំព្រងល្វតលាស់យ៉ាងល្អ នៅពេលដែលព្រះរាមយាងចេញពីព្រះរាជនគរចូលទៅគង់នៅក្នុងព្រៃជាមួយទេពី និងព្រះលក្ស្មណ៍, សរព្រហ្មាស្ត្ររបស់ព្រះរាមមានឥទ្ធិពលខ្លាំងក្លា អាចផ្ទេងបញ្ចោះសាកសពក្របីទូភី ហើយផ្ទេងសរពាយុវាសមួយទៀត បង្កើតជាខ្យល់ផាត់ឆ្អឹងទម្លាក់ទៅក្នុងមហាសមុទ្រផាដើម ។ ម្យ៉ាងវិញទៀត សភាពអស្ចារ្យផ្សេកដែលកើតឡើងពីការ

បាចសាចផ្ការរបស់ពួកទេវៈផ្សេង ៗ មកក្នុងរូងគុហា នៅពេលដែលពា
សម្លាប់ទូភីចាក ដើម្បីផាឌិបិត្តរូបនៃទឹកចិត្តត្រេកអររបស់ខ្លួន ដែលបា
ផុតរបួតពីការបៀតបៀនព្យាបាទរបស់ក្របីឈ្មោះទូភីនេះ ឬក៏ភាពអស្ចា
ដែលកើតឡើង នៅពេលដែលព្រះរាមផ្ដុំក្រោមដើមស្វាយ ជាមួយព្រ
លក្ស្មណ៍ រហូតទល់ថ្ងៃរសៀលហើយ តែស្រមោលនៅផះទៅក្រោ
គ្រប់ឫប់ឈើទាំងអស់ មិនព្រមផះទៅខាងតាមចំណាំងថ្ងៃនោះសោះ

សភាពទាំងអស់នេះ ទោះស្ថិតនៅក្នុងខ្លួនក្ដី, ក្រៅខ្លួនក្ដី
សុទ្ធតែមានលក្ខណៈអស្ចារ្យ តាមរយៈតួអង្គព្រះរាមនេះដែរ ។
សំភាពអស្ចារ្យទាំងអស់នេះ ជាសញ្ញាភាពនៃអ្វី ?

តាមពិត អ្នកនិពន្ធបានលើកយកសភាពអស្ចារ្យទាំងនេះម
ដាក់ក្នុងផ្ទៃរឿង ក៏ដើម្បីនឹងបង្កើតឥទ្ធិពល, សកម្មភាពរបស់តួអង្គនីមួយ
ឲ្យរឹតតែមានសម្រស់, មានបារមីខ្លាំងក្លាឡើងតែប៉ុណ្ណោះ ហើយផ
ក្រៅពីនេះ សភាពអស្ចារ្យក៏ជាតួអង្គមួយ ដែលចេះជួយធ្វើអន្តរាគម
លើកតំកើងតួអង្គសំខាន់ ៗ ក្នុងផ្ទៃរឿង ឲ្យរឹតតែមានតម្លៃ មានអនុភា
ច្រើនឡើងនេះឯង ។

សភាពអស្ចារ្យនៅក្នុងមហាវេស្សន្តរជាតក ពុំសូវមានស្ថិ
ក្នុងតួអង្គឡើយ គឺមានលក្ខណៈជាអស្ចារ្យក្រៅខ្លួន ហើយសភាពអស្ចា

នេះ ជាការបញ្ជាក់នូវតម្លៃនៃតួអង្គព្រះពោធិសត្វផង ចង្អុលបង្ហាញនូវតម្លៃនៃការសាងបារមីរបស់ព្រះពោធិសត្វនេះផង ។ ចំណែកខាងសភាពអស្ចារ្យក្នុងរឿងរាមកេរ្តិ៍វិញ មិនមែនជាការបញ្ជាក់នូវគុណធម៌របស់ពោធិសត្វ ក៏ប៉ុន្តែជាគ្រឿងលើកតម្កើងឥទ្ធានុភាពរបស់តួអង្គ ជាអវតារនៃអាទិទេព ព្រមទាំងបង្ហាញនូវតម្លៃនៃព្រះរាមជាអាទិទេព ដែលមានបុណ្យបារមីដ៏ប្លែកនៅក្នុងមនុស្សលោក ទាំងក្នុងសង្គមមនុស្ស សង្គមសត្វ និងសង្គមពួកទេវៈថែមទៀត ។ បារមីនៃតួអង្គមានសភាពប្លែកគ្នា ភាពអស្ចារ្យដែលចេញមកពីធម្មជាតិ ឬទេវៈ ដែលជាជំនួយៈក្រៅខ្លួនក៏ខុសគ្នា បើបារមីនេះមានសភាពប្រហែលគ្នា សភាពអស្ចារ្យក៏ប្រហែល ឬ ដូចគ្នាដែរ ។

# ប្រធាន

តួអង្គនៅក្នុងមហាវេស្សន្តរជាតក, ក្រៅពីមនុស្ស មានពួកទេវៈ, ធម្មជាតិ, និងសត្វធាតុ ព្រមទាំងទ្រព្យសម្បត្តិទៀតផង ។

ចូរធ្វើអត្ថាធិប្បាយបញ្ជាក់ នូវតម្លៃនៃតួអង្គទេវៈ ធម្មជាតិនិងសត្វធាតុ ព្រមទាំងទ្រព្យសម្បត្តិទាំងនោះឲ្យបានឃើញច្បាស់ថា តើមានលក្ខណៈសំខាន់យ៉ាងណា ចំពោះទានបារមីនៃព្រះវេស្សន្តរ ។

# អត្ថាធិប្បាយ

ក្រៅពីតួអង្គមនុស្ស, ពួកទេវៈ, ធម្មជាតិ, សត្វនិងទ្រព្យសម្បត្តិ គឺជាតួអង្គបន្ទាប់ដែលមានតម្លៃស្មើនឹងតួអង្គមនុស្ស ហើយតួអង្គទេវៈជាដើមនេះ ជាកត្តានៃការធ្វើអំពើរបស់ព្រះវេស្សន្តរដែរ ។

តួអង្គមនុស្សមានព្រះនាងមទ្រី, ជាលីក្រស្នា, តាជូជកជាដើម សុទ្ធតែមានសកម្មភាព, គុណសម្បត្តិ, គុណវិបត្តិយ៉ាងច្រើននៅក្នុងផ្ទៃរឿង ហើយលក្ខណៈសំខាន់ គឺតួអង្គទាំងនេះជួយរចនាដំណើររឿងឲ្យវិតវែល្អ មានសម្រស់នាំឲ្យពីរោះជាប់ចិត្តខ្លាំងឡើង ។ ឧទាហរណ៍ :

- ព្រះនាងមទ្រី, កាលព្រះវេស្សន្តរយាងទៅគង់នៅក្នុងព្រៃ, បានទៅនៅតាមលំពែ, ធ្វើកិច្ចការសព្វយ៉ាងជំនួសព្រះស្វាមីទាំងអស់, ព្រះនាងបានយកខ្លួនទៅពោធា បីបាច់ថែរក្សាព្រះរាជបុត្រាបុត្រីផង ធានារកបេះផលាផលនៅក្នុងព្រៃជិតឆ្ងាយ មកថ្វាយព្រះរាជបុត្រនិងព្រះស្វាមីផង, សោតឯកិច្ចការសព្វពំពួកនៅក្នុងអាស្រមបទ នាងធានាធ្វើថ្វាយព្រះស្វាមីគ្មានសល់កិច្ចការណាមួយឡើយ, ទឹកព្រះទ័យនាងសោតទៀតក៏ស្មោះត្រង់ចំពោះព្រះស្វាមីរកស្រីណាមកប្រៀបផ្ទឹមឲ្យស្មើគ្មានបាន ។

កាលព្រះនាងជ្រាបថាព្រះស្វាមីធ្វើបុត្តបរិច្ចាគហើយ ព្រះនាងបានជួយអនុមោទនាបុត្តទាននេះ ដោយព្រះហឫទ័យយ៉ាងសោមនស្ស លើសពីនេះទៅទៀត នាងសូមព្រមតាមព្រះទ័យព្រះស្វាមីទាំងស្រុង ក្នុងពេលដែលព្រះស្វាមីត្រូវការរូបព្រះនាង យកទៅធ្វើជាទានបរិច្ចាគចំពោះព្រះឥន្ទ្រព្រាហ្មណ៍ ។

-- តួអង្គជាលីក្រស្នា ក៏រិតតែមានតម្លៃចំពោះទានបារមីនៃព្រះវេស្សន្តរទៅទៀត បុត្រាបុត្រីទាំងពីរអង្គនេះសុខព្រះទ័យព្រមតាមព្រះបិតាដែលត្រូវការខ្លួនយកទៅធ្វើបុត្តបរិច្ចាគ ។ ជាលីក្រស្នា, ជាស្ពានចំឡងព្រះវេស្សន្តរឲ្យបានយាងចូលមកកាន់ព្រះនគរ សោយរាជសម្បត្តិថែមទៀត ។

- តាជូជក ពិតមែនតែក្នុងដំណើររឿងជាតួអង្គមានលក្ខណៈអាក្រក់ ធ្វើបាបរាជកុមារ - ស្លាប់ទៅកើតជាទេវបុត្ត ប៉ុន្តែតាជូជកនេះជាតួអង្គមួយសំខាន់ណាស់ ដែលជួយរចនារឿងព្រះវេស្សន្តរ ឲ្យមានសម្រស់ មានលក្ខណៈពីរោះពិសា បានសេចក្ដីម្យ៉ាងទៀតថា តាជូជកជាតួអង្គអាក្រក់សម្រាប់ធ្វើដំណើរនិងសាច់រឿងឲ្យល្អនេះឯង ។

ស្របជាមួយនឹងតួអង្គមនុស្សប៉ុណ្ណោះជាដើម តួអង្គទេវៈ, ធម្មជាតិ, សត្វឬទ្រព្យសម្បត្តិ ក៏មានគុណភាព, លក្ខណៈផ្ទាល់ខ្លួនសំខាន់

ស្មើ ឬ លើសតួអង្គមនុស្សទៅទៀតក៏មាន ឧទាហរណ៍ :

ពួកទេវៈមួយពួក បានមកបញ្ចុលចិត្តពួកអ្នកស្រីពិរាស្ត្រឲ្យខឹងនឹងព្រះវេស្សន្តរ ហើយសុំឲ្យព្រះបាទស្រីសញ្ជ័យបំបរបង់ព្រះវេស្សន្តរឲ្យទៅនៅក្នុងព្រៃ ។

ចំពោះទេវៈពួកនេះ បើយើងដឹង ៗ ភ្លាម ៗ ក៏ហាក់ដូចជាតួអង្គអាក្រក់មានចិត្តប្រទូស្តសារ៉ាយនឹងព្រះវេស្សន្តរ, ជាទេវៈដែលមានចិត្តមិច្ឆាទិដ្ឋិ ចំពោះទានបារមីនៃព្រះវេស្សន្តរ ប៉ុន្តែកាលណាយើងធ្វើការសិក្សាពិចារណាឲ្យជ្រៅតែបន្តិចទៅ យើងនឹងបានឃើញយ៉ាងច្បាស់ថា ពួកទេវៈទាំងនោះ ជាកត្តាមួយដែលនាំឲ្យព្រះវេស្សន្តរធ្វើសត្តសតកមហាទាននិងធ្វើបុត្តបរិច្ចាគ, ទារបរិច្ចាគថែមទៀត ។ មិនតែប៉ុណ្ណោះសោត ទេវៈពួកនេះអាចបានជាបុព្វហេតុមួយ នាំឲ្យព្រះវេស្សន្តរឃ្លាតចេញពីព្រះនគរទៅគង់នៅក្នុងព្រៃបាន ជាហេតុនាំឲ្យរឿងព្រះវេស្សន្តរប្រែសភាពពីរឿងទានទៅកាន់សភាពជារឿងកំសត់បាន ។ ប្រសិនបើកំហឹងនេះកើតចេញពីពួកអ្នកស្រីពិរាស្ត្រយ៉ាងសុទ្ធសាធវិញ ម្ល៉េះសមនឹងអាចក្លាយទៅជាកំហឹងដ៏យោរយៅយ៉ាងពិតប្រាកដ ព្រោះថា « **នៅក្នុងលោកនេះ គ្មានកំហឹងអ្វីឲ្យឃោរឃៅ ហើយ**

ខ្លាំងជាងកំហឹងនិងកម្លាំងប្រជាជនឡើយ »
ប៉ុន្តែចំពោះកំហឹងពួកអ្នកស្រីពិរាស្ត្រនៅពេលនេះ  បែរជាមានគ្រឿង
ទៅវិញ  ទំនប់នេះគឺជាទំនប់របស់ពួកទេវៈនោះឯង  បានសេចក្តីថា
ជាតួអង្គដែលបណ្តាលឲ្យតួអង្គមនុស្សជាអ្នកផ្ដេរលំ,  អានរូបរាង
ស្ថិតនៅក្នុងសង្គមមនុស្សនេះឯង  ឲ្យមានកំហឹងច្រួលច្របល់ឡើង
កំហឹងនេះពុំបានឡើងកំរិតហួសព្រំដែន  រហូតទល់វាយតប់បង្កើតស
ស្ទុះស្ទាប់ហួសប្រមាណ ឬបង្កើតការបង្ហូរឈាមជាបែបទារុណកម្មទៀ
កាលណាព្រះបាទស្រីសញ្ជ័យ ទ្រង់យល់ព្រមតាមមតិប្រជាជនភាគ
**ហើយ**  ពួកទេវៈក៏បន្ថយបន្ធូរនូវកំហឹង ដែលផុះឡើងនៅក្នុងទឹកចិត្តប្រ
ជនស្រីពិរាស្ត្រភ្លាម ។

ដូច្នេះតួអង្គទេវៈទាំងនោះ  មិនមែនជាទេវៈចិត្តអាក្រក់  មិ
ទិដ្ឋិ ប្រទូស្តរារាំងប្រឆាំងនឹងទានបារមីរបស់ព្រះវេស្សន្តរឡើយ
ជាតួអង្គដែលជួយធ្វើអន្តរាគមន៍  បំពេញទានបារមីរបស់ព្រះវេស្សន្ត
វិញ ។

ទេវៈមួយពួកទៀត បានបញ្ចេញសកម្មភាពរបស់ខ្លួន រាំង
ដោយការខ្ទះឲ្យឈប់មួយពេលមួយខណៈសិន ដូចជាពួកទេវៈដែលកា

និម្មិតខ្លួនជាសត្វខ្លាធំ រាជសីហ៍ និងខ្លាឃ្មុំបងស្កាត់ដំណើរនាងមទ្រី ដែលយាងមកពីបេះផ្លែឈើក្នុងព្រៃស្ងាត់ ក្នុងថ្ងៃដែលព្រះវេស្សន្តរធ្វើបុត្តបរិច្ចាគ ដើម្បីកុំឲ្យនាងមទ្រីមកទាន់ពេលដែលតាជូជក កំពុងធ្វើការទាក់ទងជាមួយព្រះវេស្សន្តរឯអាស្រមបទ ។

ពួកទេវៈមួយទៀត បានបណ្ដាលឲ្យឈើគ្មានផ្លែទុំ ហើយបណ្ដាលឲ្យនាងមទ្រីយាងទៅក្នុងព្រៃ ជ្រៅទៅៗ ដើម្បីឲ្យនាងខកពេលកុំឲ្យយាងមកទាន់ដំណើរតាជូជក ។

ពួកទេវៈទាំងពីរផ្នែកនេះ ក៏ដូចពួកទេវៈខាងដើមដែរ ពិតមែនតែបានធ្វើឲ្យឈើគ្មានផ្លែ, ធ្វើជាខ្លាចាំរាំងស្កាត់ផ្លូវ កុំឲ្យនាងមទ្រីមកទាន់ហើយនាំឲ្យមានវិបត្តិទំនាស់ស្ទើរនឹងក្លាយទៅជារឿងទារុណកម្មប៉ុន្តែបើកុំបានពួកទេវៈទាំងនេះមកជួយធ្វើអន្តរាគមន៍បំពេញកិច្ចទេ ទានបារមីរបស់ព្រះវេស្សន្តរ ពិតជានឹងជួបប្រទះនឹងវិបត្តិមួយយ៉ាងធំមិនខាន ។

ទេវៈមួយពួកទៀត បានធ្វើអន្តរាគមន៍បំពេញទានបារមីរបស់ព្រះវេស្សន្តរដោយត្រង់ ។ តែម្ដង ឧទាហរណ៍ ទេវៈខ្លះជួយរូសរទេះព្រះវេស្សន្តរ, ទេវៈខ្លះជួយបង្រួញផ្លូវពីជេតុត្តរទៅមាតុលនគរ, ពួកទេវៈខ្លះជួយនិម្មិតសាងសាលាថ្វាយព្រះវេស្សន្តរឲ្យបានគង់នៅជាមួយមហេសីនិងបុត្រដោយសុខស្រួល ។ ក្នុងចំណោមនេះ ព្រះឥន្ទ្រា

ធិរាជបានជួយបំពេញទានបរិច្ចាគព្រះវេស្សន្តរដោយផ្ទាល់តែម្តង ហើយទេវៈមួយផ្នែកទៀតបានក្លែងខ្លួនជាព្រះវេស្សន្តរ និងនាងមទ្រីទៅបីបមបំពេរបំបៅជេរ ជាលីក្រស្នា រហូតទល់ភ្លឺតពោះ ហើយថែមទាំងជួយបង្វែងផ្លូវតាជូជកឲ្យដឹកជាលីក្រស្នាចូលទៅនគរជេតុត្តរ ហើយបានជួបនឹងព្រះរាជអយ្យកោអយ្យិកាវិញ ។

ទេវៈពួកនេះ ជាអ្នកជួយឧបត្ថម្ភតម្រាយដំណើររឿងព្រះវេស្សន្តរឲ្យស្ថិតនៅជារឿងសាងទានបារមីដដែល ដោយកុំឲ្យក្លាយទៅជារឿងទារុណកម្មបានដូចរឿងឯទៀត ៗ បាន ។

ដូច្នេះតួអង្គទេវៈ គឺជាជំនួយមួយដ៏សំខាន់, ជាប្រជាប់នៃទានបារមីនៃព្រះវេស្សន្តរ ហើយជួយសាងនូវទានបារមីនៃព្រះវេស្សន្តរឲ្យបានពេញបរិបូណ៌ឡើង ។ តួអង្គទាំងនេះ មានតម្លៃស្មើនឹងតួអង្គមនុស្សឯទៀត ៗ មានតួអង្គតាជូជកជាដើមក៏មាន អាចមានតម្លៃលើសតួអង្គមនុស្សទៀតផងក៏មាន ។

ចំណែកខាងតួអង្គតិរច្ឆានវិញ ក៏មានសកម្មភាពដូចតួអង្គទេវៈ ឬ តួអង្គមនុស្សដែរ តួយ៉ាងដូចរុក្ខជាតិខ្លះ ភ្នំឬមហាសមុទ្រ បានបញ្ចេញកាយវិការរបស់ខ្លួន ហាក់ដូចជាមានវិញ្ញាណជួយត្រេកអរសាទរចំពោះទានបារមីព្រះបាទស្រីវេស្សន្តរណាស់ កាលព្រះវេស្សន្តរចូល

ទៅរស់រានជាមួយខ្លួន ធម្មជាតិទាំងនោះប្រឹងបញ្ចេញផ្លែផ្កាស្លឹកឲ្យស្រស់បំព្រង មានខ្លឹម មានចាស់-ទុំ ឬ ត្រួយផ្កាយ៉ាងច្រើនស្របទៅតាមសេចក្តីត្រូវការរបស់ព្រះវេស្សន្តរ និងមហេសី បុត្រីបុត្រា; កាលព្រះវេស្សន្តរបំពេញទានធំ ៗ រួចប្លង់ ព្រៃព្រឹក្សា ភ្នំ មហាសមុទ្រ ប្រឹងកម្រើករំពើកបោកបក់ជួយថ្វាយពរសព្ទសាធុការ ហាក់ដូចជាក្រាបទូលព្រះអង្គនិងប្រកាសប្រាប់រស់សភាវៈទាំងរស់ក្នុងលោក ដ៏ពោរពេញទៅដោយធម្មជាតិជាសម្មាទិដ្ឋិ និងមិច្ឆាទិដ្ឋិនេះថា ព្រះអង្គវេស្សន្តរធ្វើនេះត្រូវណាស់ល្អណាស់ ស្របទៅតាមគតិបណ្ឌិតយ៉ាងពិតប្រាកដ,ព្រះអង្គធ្វើនេះ ជាប្រភព ១ ដែលអាចនឹងបានត្រាស់ជាព្រះពុទ្ធអង្គទៅអនាគតកាលមិនខាន ។

ដូច្នេះ ធម្មជាតិទាំងប៉ុន្មានដែលនៅក្នុងមហាវេស្សន្តរជាតកសុទ្ធតែជាជំនួយដល់ទានបារមីព្រះវេស្សន្តរ ហើយមានតម្លៃស្មើនឹងតួអង្គមនុស្ស ឬ តួអង្គទេវៈដែរ ពិសេសលើសនេះ ភ្លៀងបោក្ខរពស៌ ជាធម្មជាតិ ១ ផ្នែកដែលអាចជួយបញ្ចប់វិបត្តិទំនាស់ក្នុងផ្ទៃរឿង ឲ្យបានចប់ទៅដោយស្រួល ហើយអាចជួយព្រះវេស្សន្តរឲ្យបានយាងវិលត្រឡប់ចូលមកក្នុងព្រះនគរដោយងាយថែមទៀត ។

រីឯតួអង្គសត្វធាតុ និងទ្រព្យសម្បត្តិវិញ ក៏មានតម្លៃមិនចាញ់តួអង្គមនុស្សដែរ ឧទាហរណ៍ ដំរីបច្ច័យនាគេន្ទ្រ គឺជាប្រដាប់នៃទាន

បារមីរបស់ព្រះវេស្សន្តរដ៏សំខាន់ណាស់ទៅទៀត ។ ដំរីនេះអា
ធ្វើឲ្យមានទឹកភ្លៀងបរិបូណ៌ដល់ប្រទេសជាតិ ហើយអាចជួយបង្កើ
ផលិតផលផ្សេង ៗ ដល់ព្រះអង្គសម្រាប់ធ្វើទានគ្រប់យ៉ាងចំពោះអ្នកក្រី
ហើយទោះបីដំរីបច្ច័យនាគេន្ទ្រនេះ ត្រូវបានព្រះវេស្សន្តរលើកប្រទាន
ទៅពួកអ្នកនគរកលិង្គរាស្ត្រទៅក្តី ផលិតផលនៅឯជេតុត្តរពេលនោះ
នៅតែមានហូរហៀរដដែល; ប្រជាជនធ្វើផលបាន ។ ប្រ
ទេសមានសន្តិភាពជានិច្ច ។ មិនតែប៉ុណ្ណោះ ដំរីនេះជាជំនួយដ
ទានបារមីផង ជាបុព្វហេតុដែលនាំឲ្យព្រះវេស្សន្តរធ្វើបុត្តបរិច្ចាគ
ទារបរិច្ចាគ នៅឯភ្នំគិរីវង្កតផង ។

ដទៃពីនេះ នៅមានទ្រព្យសម្បត្តិផ្សេង ៗ ទៀតដែលជាប្រ-
ជាប់នៃទានបារមីរបស់ព្រះវេស្សន្តរក្នុងការបំពេញពាហិរទាន ។ កវីនិ-
ពន្ធបានឲ្យតម្លៃមួយផ្នែកធំទៅលើទ្រព្យសម្បត្តិ ទាំងវិញ្ញាណវត្ថុ និ
អវិញ្ញាណវត្ថុ ។ នៅពេលដែលព្រះវេស្សន្តរត្រូវពួកស្រីពិរាស្ត្
សុំឲ្យបំបរបង់ហើយ ព្រះវេស្សន្តរបានយកទ្រព្យសម្បត្តិទាំងនោះទោ
ចែកចាយដល់ថ្នាក់ជាសត្តសតកមហាទាន ។

រួមតួអង្គទេវៈនិងធម្មជាតិ, សត្វធាតុ, ទ្រព្យសម្បត្តិ យើង
បានឃើញថា តួអង្គទាំងនេះមានសកម្មភាព និងគុណភាពស្មើនឹងតួអង្គ

មនុស្សក៏មាន លើសពីតួអង្គមនុស្សក៏មាន ព្រោះរឿងលក្ខណ៍ខ្លះ តួអង្គមនុស្សពុំអាចមានសមត្ថភាពធ្វើឲ្យបានកើតដូចទេវៈ ឬ ធម្មជាតិ,សត្វធាតុទាំងនោះបានឡើយ ។ មិនតែប៉ុណ្ណោះសោត ក្នុងគ្រាដែលព្រះវេស្សន្តរពោធិសត្វ យាងទៅគង់នៅក្នុងព្រៃដាច់ស្រយាលពីសង្គមមនុស្សទៅ មានតែតួអង្គទេវៈ និងធម្មជាតិ សត្វធាតុនេះឯងជួយបំពេញទានបារមីព្រះវេស្សន្តរឲ្យចប់ចុងដើម ហើយបានរួចផុតពីទារុណភាពទៀតផង ។

**មានចេញលក់ហើយ**

សូមរកទិញសៀវភៅ **តែងសេចក្តី** យកទៅសិក្សាកុំបីខាន ។ មានប្រធានទូទៅ សំរាប់ថ្នាក់ទី ១ ចំនើប

របស់អ្នកនិពន្ធ **ឱម-ណារុគ្រី**

# ប្រធាន

មហាវេស្សន្តរជាតក ជារឿងដែលស្ថិតនៅក្នុងឯកភាពមួយដ៏សំខាន់ជាងរឿងឯទៀតៗ ទាំងអស់ ។

ចូរធ្វើអត្ថាធិប្បាយបញ្ជាក់ ឲ្យបានឃើញច្បាស់ថា តើលក្ខណៈ និងបញ្ហាណាខ្លះ ដែលគួរឲ្យយើងស្គាល់ថាជារឿងមានឯកភាពមែន។

## អត្ថាធិប្បាយ

ខ្សែរឿងមួយ ដែលបាននិយាយពីការបំពេញទានបារមីរបស់ព្រះវេស្សន្តរ មានចលនាទាក់ទងគ្នាតែពីរឿងទាននេះទាំងអស់ ដោយគ្មានងាកចេញផុតពីព្រំដែននៃទានបារមីនេះឡើយ ។

ពិតមែនតែសេចក្ដីផ្ដើមរឿង អ្នកនិពន្ធបាននិយាយពីពុទ្ធសកម្ម-ភាពនៅក្នុងដែនមគធរដ្ឋ និងក្នុងក្រុងកបិលព័ស្ដុ ដែលជាកិច្ច ឬ ពិធីសាស្ដ្រមួយសម្រាប់ទាញយករឿង ក្លៀងយោគ្ជរពសិមកធ្វើជាឧបករណ៍ក្នុងការបំផុសផំណាលរឿងព្រះវេស្សន្ដរ ប៉ុន្ដែ ក្នុងផ្ទៃរឿងដែលចាប់និយាយពីបុញ្ញប្រវត្តិ និងសេចក្ដីប្រាថ្នាតាមរយៈពរ ១០ ប្រការរបស់នាងសុបារសុប្បតីអ្នកនិពន្ធបានចុកចំពោះតែបញ្ហាទាននេះតែប៉ុណ្ណោះ ។ ដំបូងអ្នកនិពន្ធបាននិយាយតែរឿងទានរបស់នាងសុបារសុប្បតី កាលពីអតីតជាតិដែលជាបុព្វហេតុ នាំឲ្យព្រះនាងបានទៅយកកំណើតក្នុងស្ថានសួគ៌ , លុះក្នុងពរ ១០ ប្រការដែលព្រះនាងបានកើត – សោយសុខនៅក្នុងស្ថានសួគ៌រួចហើយ ។ មានបំណងនឹងត្រឡប់មកយោនយកកំណើតកើតក្នុងមនុស្សលោកនេះវិញក៏ព្រះនាងបានប្រារព្ធបរិកទាននេះជាថ្មីទៀត ។

ពេលព្រះនាងបានមកកើតតាមសេចក្ដីប្រាថ្នាហើយ ៗបានជាបរមហេសីនៃព្រះបាទស្រីសញ្ជ័យផងទៀត អ្នកនិពន្ធបាននិយាយពីរឿងទាននេះផងដែរ – ព្រះវេស្សន្ដរចូលមកចាប់កំណើត នាំឲ្យព្រះនាងធ្វើទានដោយមិនធុញទ្រាន់ឡើយ រហូតទល់ព្រះរាជបុត្រានោះប្រសូតក៏ប្រសូតនៅពេលដែលព្រះនាងសុបារសុប្បតី កំពុងយាងទៅបំពេញទាននៅកណ្ដាលទីក្រុងថែមទៀត ។ ព្រះរាជបុត្រដែលទើបនឹងប្រសូតមក

ភ្ជាមនោះសោត ក៏ចេះនិយាយក្នុងក្របខ័ណ្ឌនៃទាននេះដែរថា « ទ្រព
ក្នុងផ្ទះមានដែរ ឬ ទេអើ ? ខ្ញុំនឹងឲ្យទាន .. ។

ព្រះកុមារវេស្សន្តរ ចាប់ពីពេលដឹងសេចក្ដីកាលណា ក៏មា
ព្រះម័យាល្អណាស់បានប្រទានទ្រព្យសម្បត្តិធម្មតាទៅអ្នកដទៃចាប់តាំងពីះ
ផែនោយធម្មតា រៀតសល់ទាន ហើយទីបំផុត គឺទានបារមីតែម្ដង
ក្នុងប្រវត្តិពិតព្រះវេស្សន្តរ អ្នកនិពន្ធពុំបាននិយាយពីរឿងអ្វីក្រៅពីការបំ
ពេញទានបារមីនេះឡើយ, ការប្រទានទ្រព្យសម្បត្តិធម្មតានៅក្នុងព្រ
រាជវាំង ក៏ព្រះអង្គបំពេញទានបារមី, ទ្រង់ធ្វើសត្តសតកមហាទាន
បុត្តបរិច្ចាគ, ទារបរិច្ចាគ ក៏ស្ថិតនៅក្នុងរង្វង់ទានបារមីនេះដែរ ។

ពេលដែលសកម្មភាពនេះទទួលនឹងគ្រោះថ្នាក់ ដោយត្រូវពួ
ស្រីពិរាស្ត្រសុំឲ្យបំបរបង់ព្រះអង្គចេញពីព្រះនគរ ក៏មិនមែនដោយហេ
ថា ព្រះវេស្សន្តរបានក្បត់ជាតិ, សាសនា, ព្រះរាជបល្ល័ង្ក ឬ ធ្វើកំ
ហុសណា ១ ប៉ះពាល់ប្រជារាស្ត្រក្រៅពីរឿងទានបារមីនេះដែរ
សេចក្ដីទុក្ខព្រាត់ប្រាសដែលកើតមួយខណៈនោះ ក៏កើតចេញមកពីចំ-
បាយនៃទានបារមីដូចមុនទៀត ។

សេចក្ដីទុក្ខទារុណកម្ម ដែលកើតឡើងចំពោះកុមារជាលីក្រស្នា

និងសេចក្តីភ័យតក់ស្លុតរបស់ព្រះនាងមទ្រី នៅក្នុងព្រៃហោត់ហោងដោយខ្លាធំ, រាជសីហ៍ និងខ្លាដំបងមកស្កាត់ដំណើរយាយីព្រះនាងកុំឲ្យយាងមកពីថ្ងៃ ឬ ទុក្ខសោកនាងមទ្រីព្រោះបាត់រាជបុត្រាបុត្រី រហូតទល់សន្លប់បាត់ស្មារតី ក៏គ្មានកើតមកបែមផ្លូវផ្កាន ឬ ហេតុភេទណា ១ ក្រៅពីទានបារមីនេះឡើយ ។

សេចក្តីស្នេហាក្នុងមហាវេស្សន្តរជាតក មិនមែនជាស្នេហាគូសង្សារ, ស្នេហារវាងមាតានិងបុត្រាដែលមានសភាពនិងទំហំធំលើសលុបនោះឡើយ ប៉ុន្តែស្នេហាទានបារមី ជាកំរិតមួយដ៏ធំហើយខ្ពស់លើសជីវិត ឬបុត្តភរិយាទៅទៀត ។ ពិតមែនតែជាលីក្រស្នា ជារាជបុត្រីបុត្រាដ៏ជាទីស្រឡាញ់, នាងមទ្រីជាអគ្គមហេសី ដែលមានព្រះទ័យស្មោះត្រង់រកស្ត្រីណាមកប្រៀបផ្ទឹមគ្មាន ប៉ុន្តែកាលដែលព្រះវេស្សន្តរត្រូវការបុត្រីបុត្រានិងមហេសីយកទៅបំពេញទានបារមី ព្រះអង្គទ្រង់សុខព្រះទ័យចំណាយបុត្រីបុត្រានិងមហេសីទាំងនោះឲ្យទៅជាទាន ដើម្បីសាងទាន-បារមីឲ្យពេញបរិបូណ៌ភ្លាម ដោយគ្មានស្តាយស្រណោះឡើយ ។

កំសត់ផ្សេងៗ ដែលលេចចេញឡើនៅក្នុងមហាវេស្សន្តរជាតក មានសុទ្ធតែកំសត់ដែលកើតចេញពីរឿងទានបារមីនេះដែរ ឧទាហរណ៍

ព្រះវេស្សន្តរ, នាងមទ្រី, ជាលីក្រស្នា ព្រាត់ប្រាសចេញពីព្រះនគរ
តុត្តរ, គាផ្ដកវាយធ្វើបាបជាលីក្រស្នានៅកណ្ដាលព្រៃតាមអំពើចិត្ត
មែនដោយមានហេតុណាមួយនោះទៀយ គឺពិតជាកើតចេញពីការបំពេ
មានរបស់ព្រះវេស្សន្តរនេះតែម្ដង ។

ភ្លៀងបោក្ខរពស្សធ្លាក់ចុះនៅឯគិរីវង្កត ក្នុងពេលដែលក្សត្រ
៦ អង្គបានជួបជុំគ្នាជាមួយពួកមន្ត្រីសេវកាមាត្យ គឺជាផលមួយដែលផ្ដ
បញ្ចប់វិបត្តិខ្លះក្នុងទានបារមី ហើយភ្លៀងនេះគឺជាផលល្អ ដែលលេ
ចេញពីការកសាងទានបារមីរបស់ព្រះវេស្សន្តរនោះឯង ។ រត្ន ៧ ប្រ
ការដែលធ្លាក់ចុះនៅក្នុងនគរជេតុត្តរក្ដី ព្រះវេស្សន្តដែលទ្រង់បានយា
ត្រឡប់ចូលមកក្នុងព្រះនគរវិញដោយសុខសាន្តក្ដី គឺជាផលនៃទានបារ
នេះឯង ។

ដោយរួបរួមមក យើងបានឃើញថា មហាវេស្សន្តរជាត
ជារឿងដែលមានឯកភាពតែមួយ ស្ថិតនៅក្នុងក្របខណ្ឌនៃទានបារមីនេ
តែម៉្យាង សូម្បីសកម្មភាពនៃពួកទេវៈ ឬរបស់ធម្មជាតិនានាក្ដី ក៏កើត
ឡើង ឬ ធ្វើចលនាឡើងនៅក្នុងវង្វង់នៃទានបារមីរបស់ព្រះវេស្សន្តរពោធិ-
សត្វទាំងអស់ ។ រឿងព្រះវេស្សន្តរ ជារឿងដែលផ្ដើមឡើងនៅក្នុង

តាលណាមួយគឺបញ្ញាទានបារមី ហើយនៅក្នុងផ្ទៃរឿងរហូតទល់ចប់ សុទ្ធ
តបានចោទនិងដោះស្រាយរឿងទានបារមី និងដោយទានបារមីដូចគ្នា
ានបញ្ហាណាដែលឃ្លាតចេញពីរឿងទាននេះសោះឡើយ ។ ត្រង់
នេះហើយដែលមហាវេស្សន្តរជាតកមានតម្លៃ ម្យ៉ាងទៀតគឺតម្លៃនៃជាតក-
ាតនេះឯង ។

## ទានបារមីមាន ៣ ថ្នាក់

១— ទានបារមី — ការឲ្យទ្រព្យសម្បត្តិធម្មតា

២— ទានឧបបារមី — ការឲ្យប្រពន្ធកូនទៅអ្នកដទៃ

៣— ទានបរមត្ថបារមី — ការឲ្យសាច់ឈាម, អវយវៈជាទាន

## ប្រធាន

មតិមួយពោលថា « ប្រសិនបើនៅក្នុងការសរជាតិរបស់តួអង្គ អ្នកនិពន្ធបានផ្តន្ទាទោសឲ្យតាជូជកចុះនរក នោះគេត្រូវតែផ្តន្ទាទោសទេវតា ដែលយាំងដំណើរវិលត្រឡប់របស់នាងមទ្រីក្តី ព្រះវេស្សន្តរក្តី ឲ្យចុះនរកដូចតាជូជកដែរ ។

ចូរពិនិត្យពិភាក្សាមតិខាងលើនេះ ។

## អត្ថាធិប្បាយ

តាមធម្មតារបស់រឿងពុទ្ធនិយមនានា កវីតែងធ្វើការសរជាតិ

បញ្ចប់ដោយការចាត់ឲ្យតួអង្គទាំងអស់នៅក្នុងផ្ទៃរឿង បានទទួលផលល្អ អាក្រក់មានកំណើតខ្ពស់ទាបទៅតាមគុណសម្បត្តិ គុណវិបត្តិរបស់ខ្លួន ។ ក្នុងមហាវេស្សន្តរជាតក អ្នកនិពន្ធបានធ្វើការសរជាតិនេះដែរ ដោយចាត់ឲ្យតួអង្គនានាបានទទួលនូវឋានៈខ្ពស់ទាប ល្អ-អាក្រក់ សមទៅតាមបាបកម្មរបស់ខ្លួន ប៉ុន្តែក្នុងចំណោមការសរជាតិនៃតួអង្គទាំងនោះ មានតែការសរជាតិនៃតួអង្គតាជូជកមួយប៉ុណ្ណោះ ដែលអាក្រក់ជាងគេ ។ ដូច្នេះបានជាមានមតិខ្លះយល់ថា បើឲ្យតាជូជកធ្លាក់នរក គួរតែឲ្យទេវតាខ្លះ ដែលធ្វើសកម្មភាពអាក្រក់ដែរនោះ ធ្លាក់នរកជាមួយតាជូជក ។ ចំពោះមតិខាងលើនេះ យើងនឹងលើកយកមកធ្វើការសិក្សា ពិភាក្សាដូចតទៅ ៖

តួអង្គទាំងអស់ក្នុងមហាវេស្សន្តរជាតក គ្មានតួអង្គណាម្នាក់ ឬតួអង្គមួយ ទោះមនុស្ស ទេវៈ ធម្មជាតិ ឬសត្វធាតុផ្សេងៗ ដែលគ្មានសកម្មភាពជួយបំពេញទានបារមី របស់ព្រះវេស្សន្តរពោធិសត្វនោះឡើយ ពោលគឺតួអង្គណាក៏ដោយ សុទ្ធតែមានបេទ្ធភាពចំពោះការស្វែងរកព្រាជ្ញាសម្មាសម្ពោធិញ្ញាណនៃព្រះពោធិសត្វនាមវេស្សន្តរទាំងអស់ ។ ក្នុងចំណោមនោះ យើងអាចលើកយកតួអង្គ ២ គឺតាជូជកនិងទេវតាអ្នកឃាំងដំណើរព្រះនាងមទ្រីកុំឲ្យវិលត្រឡប់មកទាន់ពេលតាជូជក ដែលគំ-

ពុងសុំផាលីក្រស្នាពីព្រះវេស្សន្តរនៅឯអាស្រមបទ ដែលបានធ្វើសកម្ម-ភាពបំពេញទានបារមីឲ្យបានសម្រេច ។ តួអង្គទាំងពីរផ្នែកនេះ ពិតមែនមានលក្ខណៈខុសគ្នា, មានចិត្តគំនិត**សកម្មភាពផ្សេង**គ្នា ហើយរស់នៅក្នុងសង្គមទីទៃពីគ្នាក៏ដោយ ក៏សុទ្ធតែជួយបំពេញទានបារមីព្រះវេស្សន្តរដូចគ្នា ។ ចុះបើតួអង្គទាំងពីរពួកជួយកិច្ចការជាកុសលរបស់ព្រះពោធិសត្វដូចគ្នាបែបនេះ ម្តេចក៏ការសរសេរជាតិជាក្រោយបង្អស់អ្នកនិពន្ធបានឲ្យតួអង្គតាជូជក ធ្លាក់ចុះទៅទទួលទុក្ខវេទនាលំបាកលំបិនអាប់យីនឯស្ថាននរកឯណោះ ហើយទុកឲ្យទេវតាដែលស្លាក់ផ្លូវព្រះនាងបម្រើ ឲ្យនៅតែបានឋានៈខ្ពស់ផ្ទូច្នោះទៅវិញ ? ចំពោះសំនួរទាំងប៉ុន្មាននេះ មានមតិជាច្រើនណាស់ដែលបានធ្វើការដោះស្រាយផ្សេង ៗ គ្នា ។

អ្នកខ្លះយល់ឃើញថា បុព្វហេតុដែលនាំឲ្យអ្នកនិពន្ធបានទម្លាក់តួអង្គតាជូជកឲ្យធ្លាក់ចុះទៅទទួលទុក្ខវេទនានៅក្នុងស្ថាននរកនោះ ព្រោះតាជូជកបានធ្វើកំហុសខុសឆ្គងជាច្រើនណាស់ចំពោះព្រះវេស្សន្តរ ។ ដំបូងអ្នកនិពន្ធគ្រាន់តែទុកតាជូជកជាតួអង្គតុកកំប្លែងប៉ុណ្ណោះ ប៉ុន្តែបន្ទាប់**មកទៀត** អ្នកនិពន្ធកាន់តែធ្វើឲ្យតួអង្គនេះជាមនុស្សឆ្វេងជម្ងៃយបន្តិចម្តង ៗ **ហើយ**ជាតួអង្គដែលគិតតែខ្លួនឯង ឬ ជាអ្នកអាត្មានិយមហួសប្រមាណ ។

កាលតាជូជកជួបនឹងព្រះវេស្សន្តរ គាត់បានសុំជាលីក្រស្នាតាមត្រង់ត្រឹមត្រូវមែន ប៉ុន្តែគ្រាន់តែព្រះអង្គសុំអង្វរថាឲ្យចាំនាងមទ្រីយាងមកពីព្រៃសិន ក៏តាជូជកមិនព្រម លុះគាត់សុំជាលីក្រស្នាបានហើយដឹកយកទៅ ក៏ចាប់ចងវាយបណ្ដើរសំដែងអាការៈកាចសាហាវយង់ឃ្នងអាក្រក់ក្រៃពេកនៅចំពោះព្រះភក្ត្រភ្លាមដោយគ្មានទុកពេលឲ្យ ឬគ្មានកោតញ-ញើតសោះឡើយ ។ លុះជាលីក្រស្នាបម្រះរបូតរត់រួចមកវិញ តាជូជកតាមមករកណរ៉ែង ៗ ព្រះវេស្សន្តរប្រាប់ដោយត្រង់ថា ទ្រង់ពុំបានឃើញផងទេ តាជូជកប្រមាថថែមទាំងត្មះតិះដៀលព្រះពោធិសត្វ ដោយគ្មានប្រណី ឬខ្លាចញញើតកោតព្រះទ័យសោះឡើយ ។ គេយល់ថាតាជូជកជាតួអង្គមានចិត្តអាក្រក់ជួរជង់ ប្រទូស្តសាហាវយនឹងព្រះវេស្សន្តរផង វាយធ្វើបាបបៀតបៀនទុក្ខទោសណាកម្មលើជាលីក្រស្នា រាជបុត្រាបុត្រីជាទីស្នេហារបស់ព្រះវេស្សន្តរពោធិសត្វស្មើប្រស្រីក្មេកផង ។ អំពើប៉ុណ្ណោះហើយដែលនាំឲ្យអ្នកនិពន្ធបានសម្រេចចិត្តធ្វើទោសតាជូជក ក្នុងការសរជាតិឲ្យទៅកើតនៅនរកអវចី លុះឡើងមកវិញមកកើតជាទេវទត្ត នៅតែបន្តការប្រទូស្តសាហាវព្រះពុទ្ធអង្គថែមទៀតដូច្នេះ ។

ចំណែកខាងទេវតាដែលស្ទាក់ផ្លូវព្រះនាងមទ្រីវិញ បានជាអ្នកនិពន្ធមិនបានធ្វើទោសឲ្យចុះទៅទទួលទោសទណ្ឌកម្ម នៅស្ថាននរកដូចតា

ផ្ទជកផង ព្រោះទេវតាទាំងនោះមិនបានធ្វើទុក្ខទារុណកម្មចំពោះព្រះនាងមទ្រីផ្ទួចតាផ្ទជកឡើយ ។ ពិតមែនតែទេវតាទាំងនោះបានចុះមកកាឡាខ្លួនជាខ្លា, រាជសីហ៍ ស្កាត់ផ្លូវព្រះនាងមទ្រីមែន ប៉ុន្តែពុំបានធ្វើទុក្ខទារុណកម្មព្រះនាង ឲ្យមានគ្រោះថ្នាក់ ឬឲ្យឈឺចាប់ឡើយ បានសេចក្តីថា ទេវតាទាំងនោះគ្រាន់តែមកស្កាត់ដំណើរ កុំឲ្យនាងមទ្រីយាងមកទាន់ដំណើរតាផ្ទជកតែប៉ុណ្ណោះ រួចក៏កៀសខ្លួនទៅបាត់អស់វិញទៅ នាងមទ្រីបានយាងមកដល់អាស្រមបទបានដោយស្រួល ។ ម៉្យាងទៀត បើតាមផ្នែអត្ថរូប បានបញ្ជាក់ថា ទេវតាទាំងនោះដែលធ្វើដូច្នេះ គឺធ្វើតាមបញ្ជាការរបស់ព្រះឥន្ទ្រាធិរាជឯណោះទេ ហើយខ្លួនដែលមានភារៈបំពេញកិច្ចនេះ គឺដើម្បីជួយចម្លងទាន់បារមីរបស់ព្រះវេស្សន្តរឲ្យបានដល់ត្រើយនៃសេចក្តីសម្រេចតែប៉ុណ្ណោះ តែពុំមានប្រាថ្នានឹងបំផ្លាញជីវិតនាងមទ្រី ឬចង់ឲ្យនាងបែកបាក់ព្រាត់ប្រាសពីរាជបុត្រាបុត្រីសោះឡើយ ។ ដូច្នេះបានជាអ្នកនិពន្ធពុំបានធ្វើទោសតួអង្គទេវៈទាំងនោះ ឲ្យធ្លាក់ទៅនរកដូចតាផ្ទជក ។

ផ្ទុយទៅវិញ អ្នកខ្លះយល់ឃើញថា អ្នកនិពន្ធដែលបានធ្វើទោសតាផ្ទជកឲ្យធ្លាក់នរកបែបនេះ ហើយបែរជាទុកតួអង្គទេវតាដែលបាន

ធ្វើទោសកំហុសដូចតាជូជកដែរនោះឲ្យរួចខ្លួន ជាការពុំសមហេតុផលឡើយ ព្រោះតាជូជកមិនមែនប្រទូស្តសារ៉ាយប្រឆាំងនឹងព្រះវេស្សន្តរសោះឡើយ គឺគាត់បានឮល្បីថាព្រះវេស្សន្តរមានព្រះទ័យល្អតាំងតែពីធគរជេតុត្តរមកម៉្លេះ បានជាគាត់ប្រឹងធ្វើដំណើរកាត់ព្រៃយ៉ាងឆ្ងាយដាច់សង្វេងដើម្បីទៅសុំរាជបុត្រាបុត្រី លុះបានជួបព្រះវេស្សន្តរហើយ តាជូជកបានសុំតាមច្បាប់ទម្លាប់ ។ ក្នុងរឿងនេះ ប្រសិនបើព្រះវេស្សន្តរព្រមប្រទានឲ្យ ក៏តាជូជកទទួលយក ប៉ុន្តែ បើព្រះវេស្សន្តរមិនព្រមប្រទានឲ្យទេ ក៏តាជូជកមិនអាចទៅប្លន់សំឡុតជណ្តើមយកកើតឡើយ ។ កាលព្រះវេស្សន្តរព្រមប្រទានហើយ ថែមទាំងបានប្រាថ្នាសុំឲ្យផលនៃបុត្តបរិច្ចាគនេះឲ្យបានទៅជាកុសលជួយទ្រទ្រង់ព្រះអង្គឲ្យបានត្រាស់ជាព្រះពុទ្ធទៅអនាគតកាលនេះថែមទៀត ។ មិនតែប៉ុណ្ណោះសោតព្រះវេស្សន្តរបានប្រទានជាលីក្រស្នាទៅតាជូជកនេះ គឺប្រទានដោយប្រាថ្នាប្តូរយកព្រាជ្ញាសម្មាសម្ពោធិញ្ញាណផង ដោយកាត់តម្លៃជាមាសរាប់សែនតម្លឹងទៀតផង ។ ដូច្នេះ ជាលីក្រស្នាជារបស់ដាច់មុខហើយជាកម្មសិទ្ធិរបស់តាជូជកទៅហើយ ទោះបីតាជូជកវាយដំស្តីដេរយ៉ាងណោ ក៏ព្រះវេស្សន្តរគ្មានសិទ្ធិនឹងទាមទារ ឬ ការពារជាបុត្រធីតាទៀតដែរ ។ តាជូជកដែលជាម្ចាស់លើជាលីក្រស្នា មានអំណាចនឹង

ស្តីប្រដៅប្រើប្រាសបានតាមចិត្ត ហើយកាលគាត់បាត់កុមារទាំងពីរនេះ គាត់មកសួររកឯកន្ទែងដើរដោយកំហឹងផង ឯព្រះវេស្សន្តរក៏ដូចជាលាក់លៀមផង ទើបគាត់ស្តីបន្ទោសក្នុងឋានៈនៃខ្លួនជាមនុស្សល្ងង់ខ្លៅពុំយល់ធុរឋានៈ និងទឹកព្រះទ័យនៃព្រះវេស្សន្តរតែប៉ុណ្ណោះ ។

តាជូជកជាតួរអង្គមនុស្សញាណទន់ទាប ហើយបានធ្វើអំពើប៉ុណ្ណោះ មិនគួរឡើយអ្នកនិពន្ធបានផ្តន្ទាទោស ទម្លាក់គាត់ឲ្យធ្លាក់ចុះនរកយ៉ាងនេះសោះ គួរតែផ្តន្ទាទោសទេវតាទៅវិញទើបសម ព្រោះអីទេវតាដែលជាទេវៈមានញាណខ្ពស់ប្រសើរជាងមនុស្ស, បើជាអ្នកជួយបំពេញទានបារមីរបស់ព្រះពោធិសត្វ គួរតែទៅបញ្ចុះចិត្តនាងមទ្រីឲ្យទន់ ព្រមលើកជាលីក្រស្នា ប្រទានទៅតាជូជកដោយរាប់អាល័យ ហើយដោយស្មោះជាមួយព្រះស្វាមីវិញប្រសើរជាង មិនគួរទៅស្កាត់ផ្លូវរាំងដំណើរនាំឲ្យព្រះនាងមទ្រីភ័យតក់ស្លុតផង ឲ្យព្រះនាងខានយាងទៅទាន់ដំណើរតាជូជកផងដូច្នេះឡើយ ។ ក្នុងរឿងនេះ បើគេចោទថា តាជូជកជាតួអង្គអាក្រក់ ប្រទូស្តសារាយព្រះវេស្សន្តរ ត្រូវតែចោទទេវតាអ្នកចាំស្កាត់ផ្លូវព្រះនាងមទ្រីផង ហើយបើផ្តន្ទាទោសតាជូជកឲ្យធ្លាក់នរក ក៏ត្រូវតែផ្តន្ទាទោសទេវតាទាំងនោះ ឲ្យធ្លាក់នរកជាមួយផងទើបសមរម្យត្រូវនឹងសកម្មភាពរបស់ខ្លួន ។

ការផ្ដន្ទាទោសតាជូជក ដែលមកបំពេញទានបារមីរបស់ព្រះវេស្សន្តរនេះ ពិតជាពុំសមហេតុផលទាល់តែសោះ ព្រោះមនុស្សពីរពួកបានធ្វើសកម្មភាពជាមួយគ្នា មិនគួរឲ្យពួកមួយខុស ពួកមួយត្រូវយ៉ាងនេះឡើយ ។

ប៉ុន្តែទោះយ៉ាងនេះ ក៏នៅមានអ្នកខ្លះយល់ថា តាជូជកត្រូវតែផ្ដន្ទាទោសយ៉ាងនេះដោយខានមិនបាន ព្រោះគាត់មកសុំជាលីក្រស្នានេះ មិនមែនមានបំណងនឹងបំពេញកិច្ចក្នុងការសាងបារមីរបស់ព្រះវេស្សន្តរដូចឥន្ទ្រព្រាហ្មណ៍មកសុំព្រះនាងមទ្រីនោះឡើយ គឺតាជូជកមកសុំដោយមានបំណងយកទៅឲ្យធ្វើខ្ញុំកំដរផ្ទាល់ខ្លួនគាត់ ជាមួយនាងអមិត្តតាបនាតែប៉ុណ្ណោះ កាលសុំបានដូចបំណងហើយ គាត់តាំងចិត្តអាងយ៉ាងថាជារបស់អញភ្លាម ។ ចំណែកខាងទេវតាវិញ កាលទទួលបញ្ជាពីព្រះឥន្ទ្រាធិរាជមក គឺដោយមានបំណងនឹងជួយបំពេញបំណងនៃការសាងទានបារមីព្រះវេស្សន្តរដោយផ្ទាល់តែម្ដង មិនមែនមកយាយីព្រះនាងមទ្រីដើម្បីនាំសម្លាប់មែនៗ នោះឡើយ ។ គឺត្រង់ចំណុចនេះហើយ ដែលជាលេសមួយយ៉ាងធំ ដែលអ្នកចិត្តត្រូវផ្ដន្ទាទោសតាជូជកតែម្នាក់ឯង ។

ចំពោះយោបល់បែបខាងលើនេះ ក៏នៅតែពុំសមហេតុផលដែរ ព្រោះថាពិតមែនតែតាជូជកកាលមកសុំនោះ ពុំដឹងថាព្រះវេស្សន្តរ

ប្រាថ្នានូវប្រាជ្ញាសម្មាសម្ពោធិញ្ញាណក៏ដោយ ក៏តាជូជកដឹងថាព្រះវេ– ស្សន្តរជាក្សត្រមានព្រះទ័យល្អ ដែលមានល័ក្សន្តិពុកុះសាយខ្វាំងណាស់ នៅហៅនៅឯព្រះនគរ បានជាគាត់មកសុំរាជបុត្រាបុត្រី ម្យ៉ាងទៀត ពេលគាត់សុំបានជាលីក្រស្ណានោះ ព្រះវេស្សន្តរក៏ប្រាថ្នាទៅចំពោះមុខគាត់ថា សុំឲ្យបានត្រាស់ជាព្រះពុទ្ធទៅអនាគតកាលទៀតផង ។ ដូច្នេះ តាជូជកពិតជាដឹងរឿងនេះមិនខាន ។ ម្យ៉ាងទៀត បើទោះជាតាជូជក មិនបានដឹងក៏ដោយ ក៏ទានបារមីរបស់ព្រះវេស្សន្តរក្នុងបុត្តបរិច្ចាគនេះ បានសម្រេចដោយសារតាជូជកនេះដែរ, តាជូជកពុំមែនមកប្រទូស្តសា- រ៉ាយប្ញន់ផ្ដើមឡើយ ហើយឯការបំពេញទានរបស់ព្រះវេស្សន្តរ ក៏ មិនមែនធ្វើលេងជាល្បែងដែរ ។ ការឲ្យមានសម្រេចផល ទោះឲ្យ ទៅតាជូជកក៏សម្រេច ឲ្យនាងមទ្រីទៅឥន្ទ្រព្រាហ្មណ៍ក៏សម្រេច ឲ្យដំរី បច្ច័យនាគេន្ទ្រទៅពួកកលិង្គរាស្ត្រក៏សម្រេចដូចគ្នា ហើយឯទេវតាដែល ចុះមកជួយ ក៏ជួយដើម្បីឲ្យបានសម្រេចផលដែរ ព្រោះបុត្តបរិច្ចាគមាន មេត្តាករុណាតែងតែជាងទានបរិច្ចាគដទៃទៀត ។ ។

ដូច្នេះ ចំពោះការផ្ដន្ទាទោសរបស់អ្នកនិពន្ធមហាវេស្សន្តរជា- តក ដែលឲ្យតាជូជកតែម្នាក់ឯងទទួលរងទុក្ខធ្លាក់នរក ដោយសារខ្លួន បានជួយបំពេញទានបារមីរបស់ព្រះវេស្សន្តរ ពួកទេវតាបែរជាឲ្យរួច

ខ្លួនទៅវិញនោះ ជាការមិនត្រឹមត្រូវឡើយ ។ ការធ្វើបែបនេះ
ព្រោះថាធ្វើដោយប្រកាន់ឋានៈខ្ពង់ពេក ដែលជាហេតុនាំឲ្យគេយល់
បានម្យ៉ាងទៀតថា អ្នកនិពន្ធជាមនុស្សឋានៈនិយមហួសហេតុ រហូត
ល់ធ្វើឲ្យតួអង្គដែលមានសកម្មភាពដូចគ្នាទទួលផលខុសគ្នាស្រឡះ ។
ការផ្តន្ទាទោសតាឃ្លុកបែបនេះ ដោយមិនបានផ្តន្ទាទោសតួអង្គទេវតាផង
នោះចាត់ជាកុណវិបត្តិ ១ បាន ហើយអាចនាំឲ្យសាច់រឿងបានទម្ងន់
ខុសគ្នា ថែមទាំងគ្មានតុល្យភាពទៀតផង ។


មានចេញលក់ហើយ

សូមរកទិញសៀវភៅ វិតថសេចក្តី យកទៅសិក្សា
កុំបីខាន ។ មានប្រធានឆ្លើយ សំរាប់ថ្នាក់ទី ១ ទំនើប
របស់អ្នកនិពន្ធ ឱម-ណារុត្រី

# ប្រធាន

មហាវេស្សន្តរជាតក ជារឿងមួយ ដែលមានទស្សនៈអប់រំសំខាន់ជាងរឿងឯទៀត ។

• ចំពោះមតិខាងលើ តើអ្នកយល់យ៉ាងណា? ចូរធ្វើការដោះស្រាយដោយមានហេតុផលមកបញ្ជាក់ ។

## អត្ថាធិប្បាយ

រឿងរ៉ាវផ្សេងៗ ក្នុងគម្ពីរទសជាតក៍ សុទ្ធតែបានលើកយកទស្សនៈនៃការអប់រំ មកពន្យល់បង្ហាញអ្នកអាន – ទស្សនា ឲ្យស្គាល់ និងយល់ច្បាស់នូវចលនាពុទ្ធនិយមដ៏ពិតប្រាកដ ។ មហាវេស្សន្តរជាតក ក៏ពោរពេញទៅដោយគតិទស្សនៈនៃការអប់រំនេះដែរ ហើយត្រង់

ចំណុចខ្វះ រឿងនេះបានលាតត្រដាងនូវទស្សនៈអប់រំនេះលើសរឿង ឯទៀត ៗ ផង ។

ព្រះវេស្សន្តរជាតក ជារឿងកសាង មិនមែនរឿងកម្មផល ឬព្រេងវាសនានិយមដូចរឿងក្រុងសុភមិត្រ ឬភោគកុលកុមារឡើយ ។ រឿងកសាងរបស់ព្រះវេស្សន្តរពោធិសត្វនេះសោតទៀត ក៏មិនមែនសាងអំពើអាក្រក់ ជាបាបកម្មនាំឲ្យជនឯទៀតទទួលទុក្ខវេទនានោះទេ ប៉ុន្តែទ្រង់សាងសេចក្តីល្អ គឺការធ្វើទាននេះឯង ។ ព្រះវេស្សន្តរជាតួអង្គតំរូយដ៏ល្អពិសេស ដែលមានព្រះទ័យទូលាយណាស់ ក្នុងការចែករំលែកទ្រព្យផ្តល់សេចក្តីសុខ ដល់អ្នកក្រីក្រលំបាកតោកយ៉ាក ដោយមិនរើសអើងឋានៈ វណ្ណៈ ត្រកូលឡើយ ទោះត្រកូលចណ្ឌាល ឬត្រកូលសូទ្រក៏ដោយ ក៏ព្រះអង្គប្រទានទ្រព្យផ្តល់សេចក្តីសុខឲ្យដែរ ។

សង្គមខ្មែរ ទោះសម័យណាក៏ដូចសម័យណា ការចេះចែករំលែកទ្រព្យផ្ទាល់ខ្លួន សាងសេចក្តីសុខឲ្យសង្គម ឲ្យសាធារណជន អ្នកក្រីក្រនេះតែងមានជាដរាប ចាប់តាំងពីព្រះមហាក្សត្រខ្មែររហូតទល់ប្រជារាស្ត្រសាមញ្ញ ឲ្យតែមានទ្រព្យសម្បត្តិល្មម ក៏តែងចែកចាយទ្រព្យនោះ សង្គ្រោះដល់គ្នានឹងគ្នាជានិច្ច បើខ្លួនឯងតែម្នាក់គ្មានសមត្ថភាពនឹងធ្វើកើត ក៏តែងប្រមូលទ្រព្យគ្នាជាសមាគមរួបរួមទ្រព្យនោះបន្តិចម្នាក់ ៗ បង្កើតជា

ទ្រព្យច្រើន ហើយជួយសង្គ្រោះជនណាម្នាក់ ឬធ្វើកិច្ចការជាកុសលណាមួយជាដរាប ។

រឿងព្រះវេស្សន្តរជារឿងពុទ្ធនិយម ដែលមានលក្ខណៈល្អមានគោលនៃការអប់រំយ៉ាងសមហេតុសមផល លើសពីរឿងឯទៀត ។ ត្រង់ដែលអ្នកនិពន្ធបានលើកយកទ្រឹស្តីពុទ្ធនិយម ក្នុងព្រះពុទ្ធសាសនាមកលាតពន្យល់បង្ហាញយ៉ាងច្បាស់លាស់ ហើយមិនតែប៉ុណ្ណោះ អ្នកនិពន្ធបានពោលរៀបរាប់ដំណើររឿង ដោយបដិយោគវិធី ពោលគឺនៅត្រង់ចំណុចណា ក៏បានការត្រិះរិះពិចារណារកហេតុផលឲ្យច្បាស់លាស់ជាដរាប មុននឹងជឿ ឬកាន់តាម ។ ផ្ទុយទៅវិញ រឿងឯទៀត ។ ក្នុងបញ្ញាសជាតក ឬក្នុងគម្ពីរ ៥០០ ជាតិ មានរឿងភាគីជាដើម បាននិយាយពីតួអង្គព្រះពោធិសត្វ, តួអង្គឯទៀត ។ ធ្វើសកម្មភាពល្អ - អាក្រក់ដែរ ប៉ុន្តែមិនបានពន្យល់ ឬបានលើកបដិយោគវិធី មកលាតត្រដាងបង្ហាញឲ្យអ្នកស្តាប់យល់ឡើយ បើកាលណាចង់ឲ្យមនុស្សជឿតាម គេច្រើនតែធ្វើការសរសើរផុតកុងផុតដើម ស្របទៅតាមជំនឿអវិចារណៈទៅវិញ ។

ចំណុចអប់រំទីមួយ គឺអ្នកនិពន្ធបានយកតួអង្គព្រះវេស្សន្តរនេះឯង ជាគោលធំដែលបានអនុវត្តនូវទាននិយមនេះ យ៉ាងខ្ជាប់ខ្ជួនតាំងពីដើមរហូតចប់ ។ ក្នុងសកម្មភាពនៃទាននេះសោតទៀត សូម្បីមាន

វិបត្តិទំនាស់ ឬ មានការបៀតបៀនចង្អៀតចង្អល់យ៉ាងណា ក៏ព្រះអង្គបានប្រឹងសាងឲ្យទាល់តែដល់ទីបំផុត ស្របតាមគោលបំណងព្រះអង្គជានិច្ច ។

គោលនៃការអប់រំទី ២ គឺបង្ហាញនូវផលល្អ-អាក្រក់ ។ ក្នុងមហាវេស្សន្តរជាតក គ្មានតួអង្គណាជាតួអង្គអាក្រក់ដូចក្នុងរឿងក្រុងសុភមិត្រ, រឿងមរណៈមាតា ឬរឿងរាមកេរ្តិ៍នោះឡើយ ប៉ុន្តែសូម្បីតែតួអង្គមានចិត្តអាក្រក់ គ្មានចិត្តសន្តោសខុសប្លែកពីគេបន្តិច ក៏អ្នកនិពន្ធបានផ្តន្ទាទោសឲ្យធ្លាក់នរកដែរ ដូចតួអង្គតាជូជកដែលជាអ្នកជួយសាងបារមីព្រះវេស្សន្តរដែរ ប៉ុន្តែគាត់មានចិត្តអាក្រក់កាចសាហាវ វាយធ្វើបាបជាលីក្រស្នាដោយគ្មានប្រណី ។ អ្នកនិពន្ធបានផ្តន្ទាតាជូជកនៅក្នុងរឿងនេះ គឺផ្តន្ទាទៅតាមចិត្តអាក្រក់ គ្មានធម៌សន្តោសចំពោះមនុស្សទូទៅនេះឯង មិនមែនផ្តន្ទាព្រោះគាត់ទៅសុំជាលីក្រស្នា យកមកធ្វើជាខ្ញុំបំរើ ឬព្រោះគាត់ប្រទូស្តសារ៉ាយនឹងព្រះវេស្សន្តរនោះឡើយ ប៉ុន្តែការធ្វើយ៉ាងនេះ គឺដើម្បីអប់រំមនុស្សឲ្យយល់នូវទោសកំហុសតែបន្តិចបន្តួចក៏អាចទទួលផលអាក្រក់ដែរ ។

មហាវេស្សន្តរជាតក មិនត្រឹមតែបានពន្យល់បង្ហាញកម្មវិធីនៃការធ្វើទានរបស់ព្រះពោធិសត្វប៉ុណ្ណោះទេ ប៉ុន្តែជារឿង ១ ដែល

អ្នកនិពន្ធបានធ្វើសំយោគរវាងបារមីទាំង ១០ ដែលព្រះពោធិសត្វបាន សាងឡើងក្នុងពេលជាប្អូននិងទានបារមីនោះដែរ ។

ទានបារមី ព្រះវេស្សន្តរទ្រង់សាងឡើងដោយលក្ខណៈ និងសកម្មភាពពីរស្ពាន្យ ដែលក្នុងផ្ទៃរឿងការវេស្សន្តរជាតកទាំងមូលមានឯកភាពយ៉ាងបរិបូណ៌ ។

សីលបារមី ព្រះអង្គទ្រង់មានសីល និងសីលធម៌នេះយ៉ាងបរិបូណ៌ មិនប្រព្រឹត្តបាបកម្មកាចសាហាវ ធ្វើទារុណកម្មទោសដល់ជនណាម្នាក់ឡើយ ទោះគាត់ផ្ដកវាយដំរាជបុត្រាបុត្រីនៅចំពោះព្រះភក្ត្រព្រះអង្គក្តី ។

នេក្ខម្មបារមី ការបំពេញផ្នួសជាតាបសឥសីនៅភ្នំគិរីវង្កតដោយការប្រព្រឹត្តធម៌យ៉ាងតឹងតែង ហើយគ្មានស្ដាយស្រណោះចំពោះកាមតណ្ហាណា ១ ដែលមាននៅក្នុងព្រះហឫទ័យឡើយ ។

បញ្ញាបារមី នៅចំពោះការឲ្យទានក្តី បំពេញទានបារមីក្តី ចំពោះហេតុការផ្សេងៗ ដែលកើតឡើងព្រោះអ្នកស្រីពិភាក្សាសុំឲ្យបំបរបង់ព្រះអង្គក្តី ចំពោះការស្ទូចយោធាឲ្យសោយរាជ្យនៅមាតុលនគរក្តី ក៏ព្រះអង្គតែងយកប្រាជ្ញាពិចារណាដោះស្រាយធ្វើជាធំជាងរាប ។

វីរិយបារមី នោះមានវិបត្តិចំនាស់កើតឡើងក្នុងការបំពេញ

ទាននេះក្តី ក៏ព្រះអង្គទ្រង់នៅតែព្យាយាមបំពេញទាននេះទាល់តែចប់កុងផើម ។

ខន្តិបារមី ព្រះវេស្សន្តរជាតួអង្គដ៏សំខាន់ ដែលបានយកព្រះទ័យអ៏ធ្ងន់ទៅចប់គល់ប៉ះពាល់នឹងវិបត្តិ ឬ ការប្រកាន់ផ្សេង ។ ជានិច្ចឧទាហរណ៍ ព្រះអង្គបានអត់ធ្មត់មិនតបតនឹងកំហឹងរបស់ពួកអ្នកស្រុកដែលបះបោរសុំឲ្យបំបរបង់ព្រះអង្គចេញពីព្រះនគរ, អត់ធ្មត់ចំពោះកាយវិការដ៏យង់ឃ្នងរបស់តាជូជកដែលប្រព្រឹត្តនៅចំពោះព្រះភក្ត្រព្រះអង្គ ។

សច្ចបារមី កាលបួយនឹងរឹកព្រះទ័យអំណត់អត់ធន់នេះ ព្រះវេស្សន្តរទ្រង់កាន់ពាក្យទៀងត្រង់ មិនព្រមទទួលពាក្យសុំរបស់ពួកក្សត្រទៅមាតុលនគរ, មិនលាក់លៀមនូវរាជបុត្រាបុត្រីដែលរត់គេចពីជូជក ហើយតាំងព្រះទ័យទៀងត្រង់គោរពតាមឆន្ទៈនៃអ្នកនគរស្រីពិរាស្រ្តដែលកំពុងមានកំហឹងចំពោះព្រះអង្គ ។

អធិដ្ឋានបារមី ទ្រង់តាំងយ៉ាងខ្ជាប់ខ្ជួននូវការប្រាថ្នាជាព្រះពុទ្ធទៅអនាគត ទោះបីមានឧបសគ្គខ្លះដល់ផ្លូវព្រះហឫទ័យក្តី ។

មេត្តាបារមី ក្នុងការធ្វើទានគ្រប់ពំពួកនោះសោត ព្រះវេស្សន្តរមិនមែនធ្វើដោយឡើងជោរ ឬ ដោយអគតិធម៌ ព្រោះហេតុស្រឡាញ់ផ្ទាល់ខ្លួនឡើយ ប៉ុន្តែព្រះវេស្សន្តរទ្រង់មានព្រះទ័យមេត្តាករុ

ណាភាអាណកិតអាសូរចំពោះមនុស្សទូទៅ ។ ប្រយោជន៍សាធារណៈផ
ផងរាប ព្រះរាជទ្រព្យដែលព្រះអង្គមានហើយ ទ្រង់មិនបានទុកសម្រា
តែព្រះអង្គ និងរាជវង្សប៉ុណ្ណោះទេ, គឺព្រះអង្គទ្រង់យកព្រះរាជទ្រព្យទៅ
ទៅចែកចាយឲ្យគាត់រស់នៅដោយសេចក្ដីសុខដូចគ្នា ។

ឧបេក្ខាបារមី — ទោះបីមានហេតុការណ៍ណាមករារាំងក្ដី ក៏ព្រ
អង្គនៅតែតាំងព្រះទ័យជាកណ្ដាលជានិរាប ។ ក្នុងសកម្មភាពបំពេញ
ទានបារមីនេះសោតទៀត ក៏ព្រះអង្គមានព្រះទ័យតាំងស្មើ ៗ ជានិច្ចមិ
មែនស្រឡាញ់អ្នកណាជាងអ្នកណាឡើយ ។

បារមីទាំង ១០ យ៉ាងនេះ ជាភារកិច្ចរបស់ព្រះវេស្សន្តរក្ស
បានៈជាពោធិសត្វផង ក្នុងឋានៈព្រះអង្គជាមហាក្សត្រផង ព្រោះអីទាន
សីល, បរិច្ចាគ, ខន្តី ។ ទាំងនេះជាទសពិធរាជធម៌នៃព្រះមហាក្សត្រ
គ្រប់ព្រះអង្គ ។

ក្នុងសកម្មភាពដែលព្រះវេស្សន្តរត្រូវទទួលរងទុក្ខលំបាកវេទន
ទាំងផ្លូវកាយ ផ្លូវព្រះហឫទ័យយ៉ាងណានៅក្នុងព្រៃ ក៏ព្រះវេស្សន្តរគ្មា
ចងគំនុំគុំគួនព្យាបាទជនណា មានពួកស្រីពិរាស្ត្រជាដើមឡើយ ប៉ុន្តែ
ព្រះអង្គនៅតែប្រាថ្នានឹងយាងត្រឡប់មកចូលព្រះនគរវិញ ហើយថែ
ទាំងប្រាថ្នាឲ្យបានជួយសង្គ្រោះ ដោយព្រះរាជទ្រព្យចំពោះមនុស្សទូទៅ

ថែមទៀត ពោលគឺព្រះអង្គទ្រង់បានធ្វើសំណូមពរចំនួន ៨ ប្រការអំពីព្រះឥន្ទ្រាធិរាជក្នុងសក្កបាពិផង ។ លក្ខណៈប៉ុណ្ណេះបង្ហាញឲ្យឃើញថា ព្រះវេស្សន្តរជាតួរអង្គដ៏សំខាន់ មានព្រះទ័យយល់ច្បាស់នូវបញ្ហាសង្គមមនុស្ស មានប្រាជ្ញាញាណភ្លឺស្វាងណាស់ ក្នុងការស្គាល់ទឹកចិត្តមនុស្ស ។

ការពន្យល់បង្ហាញប្រកបដោយទស្សនៈសំខាន់ ៗ ទាំងនេះ នាំឲ្យយើងឃើញថា ព្រះវេស្សន្តរជាតួអង្គស្អាតស្អំ ហើយរឿងព្រះវេស្សន្តរនេះឯង ជារឿងប្រកបដោយលក្ខណៈអប់រំល្អ ដោយការបញ្ជាក់ហេតុផលយ៉ាងច្បាស់លាស់, ជាបដិយោគវិធីរវាងតួអង្គផង ជាសំយោគវិធីរវាងបារមីទាំង ១០ ផង ។ ការអប់រំនេះហើយ ដែលនាំឲ្យសង្គមខ្មែរបានទទួលសុខសន្តិភាពជានិច្ច ពោលគឺមនុស្សបានស្គាល់និងយល់ច្បាស់នូវទ្រឹស្តីពុទ្ធនិយម តាមខ្សែរឿងព្រះវេស្សន្តរនេះឯង ។

## ប្រធាន

ជំនឿក្នុងព្រះពុទ្ធសាសនា ត្រូវប្រកបដោយវិចារណញ្ញាណ ជាដរាប ។

បើដូច្នោះ តើក្នុងមហាវេស្សន្តរជាតក អ្នកនិពន្ធបានពន្យល់យ៉ាងណា ដើម្បីឲ្យយើងជឿថាព្រះវេស្សន្តរ ជាតួអង្គព្រះពោធិសត្វមែន ។

## អត្ថាធិប្បាយ

ជំនឿនិងការពិចារណា ជាគំនិតគូគ្នានៅក្នុងព្រះពុទ្ធសាសនា ។ ដើម្បីនឹងជឿលើអ្វីមួយ មនុស្សម្នាក់ ៗ ត្រូវតែមានការត្រិះ

រិះពិចារណារកហេតុផលឲ្យជាក់ច្បាស់ជាមុនសិន សឹមប្រគល់ជំនឿផ្ដេកផ្ដួលចិត្តគំនិតទៅលើវត្ថុ ឬពាក្យប្រៀនប្រដៅ ឬបុគ្គលនោះ ៗ ។ បកោវាទសុត្តជាតក ដែលជារឿង ១ ស្ថិតនៅក្រោមឥទ្ធិពលពុទ្ធនិយម ហើយដែលអ្នកនិពន្ធបានយកទ្រឹស្ដីព្រះពុទ្ធមកចោទ និងដោះស្រាយជាបញ្ហាផ្សេង ៗ នោះ ក៏នាំឲ្យយើងឃើញច្បាស់ថា អ្នកនិពន្ធបានពន្យល់ប្រកបដោយបរិចារណកៈនេះទាំងអស់ ។

ព្រះពុទ្ធសាសនាជាពាក្យប្រៀនប្រដៅ និងពន្យល់ពីកនាំប្រកបដោយលក្ខណៈជាវិទ្យាសាស្ត្រ ។ យ៉ាងណាមិញ ក្នុងវិជ្ជាវិទ្យាសាស្ត្រទៅទាំងអស់ ទោះប្រទេសណា អ្នកប្រាជ្ញណា បានបង្កើតឡើងក៏ដោយ សុទ្ធតែមានការត្រិះរិះគិតពិចារណា រកហេតុផលនៃការទាក់ទងគ្នាជាជាប់ មិនតែប៉ុណ្ណោះសោត វិទ្យាសាស្ត្រដែលមនុស្សបង្កើតរួចចេញហើយនោះ អ្នកបង្កើតសុទ្ធតែបានទ្រឹស្ដីនិងការអនុវត្តន៍ យកមកពន្យល់បង្ហាញដល់អ្នករៀនសូត្រ ដែលត្រូវការចង់ចេះដឹងវិជ្ជានោះ ៗ អ្នកចេះដឹងពីមួយ ៗ សុទ្ធតែបានត្រិះរិះពិចារណារួចរាល់អស់ហើយជានិច្ច; អ្នកចង់ចេះដឹងយល់ ត្រូវតែសិក្សា និងមានការត្រិះរិះតាមរហូតទល់យល់ហេតុផលនៃការទាក់ទងគ្នានោះ ៗ ទើបអាចចេះដឹងបាន ។ ឯព្រះពុទ្ធសាសនាក៏ដូច្នោះដែរ ។ ជំនឿ ( សទ្ធា ) ជាកត្តាមួយដ៏ធំណាស់ ពេលគឺអ្នកកាន់ព្រះពុទ្ធសាសនាទូទៅ កាលណាបានដឹង ឮ

**ទៀតផង** ឬមុននឹងមានជំនឿ ( សទ្ធា ) លើព្រះពុទ្ធ ឬលើពាក្យប្រៀនប្រ-ដៅណាមួយ ក៏ត្រូវតែត្រិះរិះឲ្យល្អិតល្អន់ជាមុនសិន សឹមជឿជាខាងក្រោយ ។ អ្នកកាន់ពុទ្ធសាសនានេះ បានត្រិះរិះពិចារណាហើយ នឹងឃើញយល់ហេតុផលយ៉ាងជាក់ច្បាស់ ពិតប្រាកដមិនខាន ។ បើនិយាយឲ្យខ្លីមក ព្រះពុទ្ធសាសនាជាសាសនាប្រកបដោយវិទ្យាសាស្ត្រយ៉ាងល្អិតល្អន់ណាស់ ។

នៅក្នុងទ្រឹស្តីព្រះពុទ្ធសាសនា បានបញ្ជាក់ប្រាប់ថែមទៀតថា ទីពឹងធំបំផុតគឺខ្លួនហ្នឹងឯង ( អត្តា ហិ អត្តនោ នាថោ ) មុននឹងពឹងបុគ្គល ឬ ជនដទៃ មនុស្សម្នាក់ ។ ត្រូវពឹងខ្លួនឯងនេះមុនជាដរាប ។

សេចក្តីខាងលើនាំឲ្យយើងឃើញថា : ជំនឿក្នុងព្រះពុទ្ធសាសនាត្រូវមានការពិចារណានៅរែបជាមួយជានិច្ច ( យត្ថ សទ្ធា តត្ថ វិចក្ខណា ) ហើយព្រះពុទ្ធសាសនានេះជាសាសនាប្រកបដោយវិទ្យា-សាស្ត្រ ត្រូវពឹងខ្លួនឯង ( អត្តា ហិ អត្តនោ នាថោ ) មិនមែនពឹងលើតួអង្គព្រះពុទ្ធ ឬ ព្រះអាទិទេព, វត្ថុសក្តិសិទ្ធិ ព្រៃភ្នំ ដុំថ្ម ឬ អារក្សអ្នកតា ទេវតា ព្រះឥន្ទ ព្រះព្រហ្មឯណានោះឡើយ ។

ដោយហេតុយ៉ាងនេះហើយ ទើបក្នុងមហាវេស្សន្តរជាតកអ្នកនិពន្ធបានធ្វើឲ្យតួអង្គព្រះវេស្សន្តរ ដែលជាព្រះពោធិសត្វនោះ មានលក្ខណៈជាមនុស្សធ្វើសកម្មភាព ចាប់តាំងពីនៅក្នុងសង្គមមនុស្ស និង

ជាមួយមនុស្សផងគ្នាប្រកបដោយការប្រឆាំងជំទាស់ពីមជ្ឈដ្ឋានខ្លះ ហើយព្រះវេស្សន្តរក៏នៅតែប្រឹងតស៊ូដោយការអត់ធ្មត់តទៅទៀត ដើម្បីសម្រេចនូវគោលបំណងនេះ ។ អ្នកនិពន្ធបានលើកយកតួអង្គព្រះវេស្សន្តរមកលាតត្រដាងបង្ហាញ ដោយគ្មានលាក់លៀម ឬ បិទបាំងទាល់តែសោះ ។ ការលាបង្ហាញនេះ គឺធ្វើក្នុងលក្ខខ័ណ្ឌនៃទានបារមីនេះឯង ។

តាំងពីកណ្ដើមមក អ្នកនិពន្ធមិនបានតាំងខ្លួនជាអ្នកដឹកនាំអ្នកអាន - អ្នកស្ដាប់ឲ្យជឿលើសកម្មភាព ទឹកព្រះទ័យស្អាតស្អំរបស់ព្រះវេស្សន្តរ ដោយការបង្ខិតបង្ខំសោះឡើយ ប៉ុន្តែផ្ទុយទៅវិញ អ្នកនិពន្ធគ្រាន់តែមានភារៈជាអ្នកបង្ហាញនូវសកម្មភាព និងទឹកព្រះទ័យនៃព្រះពោធិសត្វតែប៉ុណ្ណោះ ឯលក្ខណៈល្អ - អាក្រក់នៃព្រះវេស្សន្តរយ៉ាងណា ។ ស្រេចនៅលើអ្នកអាននិងអ្នកស្ដាប់ យកទៅត្រិះរិះពិចារណាដោយខ្លួនឯងចុះ ។ ការពន្យល់បង្ហាញបែបនេះ ស្របទៅតាមទ្រឹស្ដីនៃព្រះពុទ្ធសាសនាមែន ពីព្រោះព្រះពុទ្ធជាមេសាសនា ក៏មិនអាចបង្ខំជនណាឲ្យជឿព្រះអង្គដែរ ព្រះពុទ្ធគ្រាន់តែជាអ្នកបង្ហាញផ្លូវល្អ - អាក្រក់ប៉ុណ្ណោះ ឯការប្រតិបត្តិនិងជំនឿ ស្រេចទៅលើបុគ្គលម្នាក់ ៗ គិតគូរពិចារណាដោយខ្លួនឯង ។

ការនិយាយថា អ្នកនិពន្ធរឿងព្រះវេស្សន្តរ មិនមែនជាអ្នក

ការពារ ឬ ជាអ្នកបួងសួរសើរព្រះវេស្សន្តរទល់ចប់ចុងដើមនោះ យើងបានឃើញថា អ្នកនិពន្ធចេះតែលើកយកសកម្មភាពព្រះពោធិសត្វអង្គនេះ មកចោទហើយចោទទៀត តាំងពីដើមដល់ចប់ ចំណែកឯការដោះ-ស្រាយ មានលេចឡើងតាមរយៈតួអង្គដទៃ ឬសកម្មភាពនៃទានបារមីនេះតែម្តង មិនមែនអ្នកនិពន្ធបានដោះស្រាយដោយខ្លួនឯងនោះឡើយ ។

កាលព្រះវេស្សន្តរប្រទានដំរីបច្ច័យនាគេន្ទ្រទៅពួកអ្នកកលិង្គ-រាស្ត្រ, ពួកអ្នកនគរស្រីពិរាស្ត្របះបោរឡើង សុំឲ្យបំបរបង់ព្រះអង្គចេញពីព្រះនគរ ។ ក្នុងពេលនេះ អ្នកនិពន្ធមិនបានវិនិច្ឆ័យ ឬ ពន្យល់យ៉ាងណាឡើយ ប៉ុន្តែការដោះស្រាយបានលេចចេញពីពួកជនអ្នកកំសត់ទុគ៌តស្មូមយាចក ដែលជាអ្នកស្គាល់តម្លៃនៃទ្រព្យសម្បត្តិ, ជីវិត, ក្រខ្សត់ឲ្យលាស់ជាងគេ ជួយការពារព្រះវេស្សន្តរ ។ រួមជាមួយនេះ យើងបានឃើញព្រះនាងផុសតីសុប្បពីរួយព្រះអង្គទៀត ជាអ្នកជួយការពារព្រះរាជបុត្រដោយព្រះទំនួញថា :

«... ឱរហាគុអ្វីអើយ អ្នកស្រីពិរាស្ត្រផងទាំងឡាយ គេបំបរបង់ព្រះវេស្សន្តរកូនអញ ជាអ្នកឥតទោសនេះឲ្យប្រាសលែងនៅស្រុក ។

ឱដូចអញគិតនេះហើយ ព្រះវេស្សន្តរកូនអញនេះជាអ្នកឥតទោស ជាអ្នកមានអធ្យាស្រ័យ អាល័យចង់តែឲ្យទាន ពុំចេះមានកំណាញ់ទ្រព្យអ្វីឡើយ...ឱបាវេស្សន្តរអើយបាជាអ្នកឥតទោស ហេតុអ្វីក៏អ្នកស្រីពិរាស្ត្រផងទាំងឡាយ មកបំបរបង់ចេញអំពីស្រុកនេះ មួយវិសោត បាវេស្សន្តរជាអ្នកឥតទោស នៅសព្វថ្ងៃនេះ តែងនឹងបំរើម្តាយឪពុក ទំនុកបំរុងចាស់ព្រឹទ្ធាចារ្យ មួយវិសោត បាវេស្សន្តរជាអ្នកឥតទោស នៅសព្វថ្ងៃនេះ ជាអ្នកអាល័យចង់ធ្វើប្រយោជន៍ដល់ទេពតានិងព្រះមហាក្សត្រ ទំនុកបំរុងញាតិមិត្រផងទាំងឡាយ ជាអ្នកធ្វើប្រយោជន៍ដល់ផែនដីទាំងមូល ចុះហេតុអ្វីក៏អស់អ្នកស្រីពិរាស្ត្រ មកបំបរបង់បាវេស្សន្តរចេញអំពីស្រុកនេះ ? (ទំព័រ១១៣ ១១៤) ។

ព្រះទំនួញខាងលើនេះ បានបញ្ជាក់ឲ្យឃើញថា ព្រះនាងសុបារសុបត្តិ, ក្នុងឋានៈជាព្រះមាតាផង ជាអ្នកមានសតិសម្បជញ្ញៈ (មកពីកំណើតទេពតា ដោយបានពរ ១០ ប្រការ) បរិបូណ៌ផង បានការពារព្រះវេស្សន្តរ មិនមែនក្នុងឋានៈព្រះអង្គជារាជបុត្រប៉ុណ្ណោះទេ ប៉ុន្តែការពារដោយយល់ថាព្រះវេស្សន្តរធ្វើនេះត្រូវ ព្រោះព្រះវេស្សន្តរ :

- ជាអ្នកមានព្រះច័យអធ្យាស្រ័យល្អ
- ជាអ្នកបំរើម្ដាយឪពុក
- ជាអ្នកធំនុកបំរុងចាស់ព្រឹទ្ធាចារ្យ
- ជាអ្នកពំនុកបំរុងញាតិមិត្រ
- ជាអ្នកធ្វើប្រយោជន៍ដល់ផែនដី

ដូច្នេះព្រះបាទស្រីវេស្សន្តរជាអ្នកឥតទោសកំហុសអ្វីទេ ការធ្វើទាននេះពិតជាត្រូវណាស់គឺ ត្រូវតាមមនុស្សធម៌ យ៉ាងពិតប្រាកដ ។ មិនតែប៉ុណ្ណោះសោត បើយើងបែរទៅស្ដាប់ពាក្យសំដីរបស់ប្រជាជនស្ត្រីប្រុសវិញ យើងនឹងបានឮយ៉ាងច្បាស់ទែងនឹងត្រចៀកថា :

« គោរព ម្ចាស់ក្សត្រយើងទាំងឡាយ »

ព្រះបាទស្រីវេសន្តរនេះ ជាពំនាក់អស់ស្ងមទាំងឡាយ ឧបមាបីដូចអ្វី? ជាឧបមាបីដូចដើមឈើណា ១ មានផ្លែផ្កា ដ៏ជាពំនាក់នៃសត្វផងទាំងឡាយ ទាំងហើរមកអំពីចម្ងាយ ឃ្លានបាយចំណីចង់បរិភោគឲ្យទាល់តែឆ្អែត ។

ឱព្រះបាទស្រីវេសន្តរអើយ ព្រះអង្គហោងជាអ្នកឥតទោស ហេតុអ្វីឡើយក៏អ្នកស្រីពិរាស្ត្រ មកបំបរបង់ព្រះអង្គ ឲ្យខ្ចាយចេញអំពីស្រុកដូច្នេះ !

ភោណ្ឌា ម្ចាលគ្នាយើងទាំងឡាយ រីអ្នកស្រីពិរាស្ត្រនេះ ឧបមាបីដូចអ្នកកន្ទ្រីសប្ស្បាមកកាប់ដើមឈើសឹងដ៏មានផ្លែផ្កា សឹងជាពំនាក់នៃសត្វផងទាំងឡាយនោះឲ្យអន្តរាយ ពុំឲ្យសត្វផងទាំងឡាយពឹងបានឡើយ ឱ! ព្រះវេសន្តរ

ជាអ្នកឥតទោស ជាពំនាក់នៃសត្វទាំងឡាយ នោះសត្វឯណានឹងប្រាថ្នាអ្វីៗ ឥតទើសទាល់សល់ក្រអ្វីឡើយ .... រីអ្នកស្រីពិរាស្ត្រផងទាំងឡាយនេះ ហៅថាជាអ្នកឥតធម៌ពិតហោង ម្តេចឡើយក៏មកបំបរបង់ព្រះបាទវេស្សន្តរ ជាអ្នកឥតទោស ឲ្យប្រាសនិរាស្ត្រចេញអំពីស្រុកដូច្នេះ... ( ទំព័រ ១២៦–១២៧–១២៨ ) ។

តាមពាក្យអ្នកនគរទាំងនេះ ក៏នាំឲ្យយើងដឹងថា ព្រះវេស្សន្តរជាអ្នកឥតទោសដែរ ហើយមិនតែប៉ុណ្ណោះ ព្រះវេស្សន្តរជាទីពឹងពំនាក់នៃអ្នកនគរដែលក្រីក្រជុនដាបទៀតផង ប្រៀបបាននឹងដើមឈើដែលមានផ្លែផ្កាជាទីពឹងពំនាក់នៃសត្វបក្សាបក្សីទាំងឡាយ ពិសេសលើសនេះ គឺដើមឈើនេះសូម្បីសត្វស៊ីផ្លែហើយជុះអាចម៍ដាក់ ចឹកមែកស្លឹកចោលក៏ដោយ ក៏ដើមឈើមិនដែលយកទោសពៃរ៍ ឬ ចងកំហឹងចំពោះសត្វទាំងនោះដែរ ។

នៅក្នុងពេលដែលព្រះវេស្សន្តរ គង់នៅក្នុងព្រៃផុតដាច់ពីសង្គម

មនុស្សហើយ ក៏ត្រូវពាក្យចោទយ៉ាងធ្ងន់លើសលប់ពីសំណាក់ព្រះបាទស្រីសញ្ជ័យជាបិតា និងពួកសេវកាមាត្យ មន្ត្រីតូចធំថែមទៀត ។ ម្តងនេះយើងរិតតែឃើញច្បាស់ថា ចំណោទពីមនុស្សជាទីទុកព្រះទ័យនិងជាទីគោរពស្រឡាញ់នោះ បានធ្លាក់សង្កត់មកលើព្រះអង្គយ៉ាងធ្ងន់លើសពេលណាទាំងអស់ ។ ឯអ្នកនិពន្ធវិញសោត ក៏គ្មានជួយដោះស្រាយការពារព្រះអង្គកើតដែរ ។ បើដូច្នោះ តើបាននរណាជួយដោះស្រាយ – ការពារព្រះអង្គ ព្រមទាំងបង្ហាញនូវទឹកព្រះទ័យ–គោលដៅរបស់ព្រះអង្គឲ្យបានជាក់ច្បាស់ ? ដើម្បីនឹងធ្វើឲ្យអ្នកអាន–អ្នកស្តាប់រិតតែបានយល់ច្បាស់ មានគំនិតពិចារណារិតតែវែងឆ្ងាយទៅទៀត អ្នកនិពន្ធបានធ្វើការដោះស្រាយតាមរយៈតួអង្គជាលីក្រស្ណាដែលបានបង្ហាញនូវគុណធម៌ និងទឹកព្រះទ័យព្រះបិតាថាជាតួអង្គពោធិសត្វអ្នកប្រាថ្នាកប្រាថ្នាសម្មាសម្ពោធិញ្ញាណ ហើយព្រះអង្គមិនមែនជាអត្តទត្ថបុគ្គល ដែលគិតតែប្រយោជន៍ផ្ទាល់ព្រះអង្គក្នុងការបានត្រាស់ជាព្រះពុទ្ធហើយបរិនិព្វានចោលយើងរាល់គ្នាឲ្យ នៅកំព្រាអាក្នុងជំនោរវាលវដ្តសង្សារនោះឡើយ ព្រះអង្គកាលបានប្រាថ្នាសម្ពោធិញ្ញាណហើយនឹងយក **ពុទ្ធិ** ជាចំណេះចេះដឹងថ្មីនេះមកពន្យល់ប្រាប់យើងទាំងឡាយទាំងអស់គ្នានេះឲ្យបានយល់ ហើយកសាងខ្លួនដោយខ្លួនឯង ដើម្បីឆ្លង ,

មហាសមុទ្រតណ្ហានេះផុតស្រឡះ ឡើងទៅកាន់ត្រើយអមតមហានិព្វាន ជាស្ថានក្សេមផុតចាកមុក្ខទាំងឡាយ ជាបរមសុខនោះឯង ។

សកម្មភាពព្រះវេស្សន្តរ ដែលកសាងព្រះអង្គតាមរយៈបុគ្គ–បរិច្ចាគនេះ ហើយដែលនាំឲ្យព្រះអង្គបានសម្រេចនូវអនុត្តរសម្មាសម្ពោធិ ខុសប្លែកពីយើងរាល់គ្នា ដែលចេះតែមានចិត្តកំណាញ់ ស្រឡាញ់ប្រពន្ធ កូនយ៉ាងជាប់ស្អិតបេះមិនចេញបែបនេះ ឬ នៅតែមានចិត្តប្រកាន់ថា « . . . គិតដ៏មានច្បាប់ឯណាដែរ ឬ ក្សត្រានៅជាខ្ញុំគេ ដូចអ្នកស្រដីនោះយល់ពុំសមសត្វហាឲ្យប្រចាំនឹងហ្វូងក្អែកយល់ប្លែកក្រៅវិស័យ ( ទំព័រ ៤៨៣ ) . . . » នោះឡើយ ។ អ្នកអានទស្សនា កាលណាឮការដោះស្រាយរបស់ជាលីក្រស្នាត្រង់ចំណុចនេះ នឹងមានចិត្តទ... អាណិតព្រះវេស្សន្តរព្រមទាំងបានយល់ច្បាស់ថា ព្រះវេស្សន្តរជាពោធិ... សត្វអ្នកស្វែងរកការត្រាសដឹង ដែលជាគុណប្រយោជន៍ដ៏ធំចំពោះមនុស្ស... សត្វទូទៅដោយគ្មានរើសមុខឡើយ ។

ដូច្នេះ អ្នកនិពន្ធរឿងព្រះវេស្សន្តរ ដែលបានលើកយកទ្រឹ... តាមបែបពុទ្ធនិយមមកលាតត្រដាងបង្ហាញដល់អ្នកអាន អ្នកស្តាប់...

ជាអ្នកប៉ិនប្រសប់យ៉ាងពិសេស ដោយចេះធ្វើឲ្យអ្នកអាន អ្នកស្តាប់មាន ការពិចារណាយ៉ាងជាក់ច្បាស់ ហើយបានយល់ចូលចិត្តដោយងាយជា ខាងក្រោយ ។ ពិធីសាស្ត្រនៃការរចនាបែបនេះ អាចនាំឲ្យមនុស្ស មានជំនឿជឿជាក់កាន់តែច្បាស់លាស់ឡើងប្រកបដោយលក្ខណៈវិទ្យា–សាស្ត្រយ៉ាងជាក់ស្តែងស្របតាមទ្រឹស្តីក្នុងពុទ្ធនិយមវែន ។


មានចេញលក់ហើយ

សូមរកទិញសៀវភៅ **វែកញែកសេចក្តី** យកទៅសិក្សា កុំបីខាន ។ មានប្រយោជន៍ទូទៅ សំរាប់ថ្នាក់ទី ១ ទំនើប

របស់អ្នកនិពន្ធ **ឌិម-ឈាវគ្រី**

# ប្រធាន

សិល្បវិធី នៃការតែងនិពន្ធមហាវេស្សន្តរជាតក ស្ថិតនៅលើគោលវិធីដ៏វិសេសដែលអាចចម្លងអារម្មណ៍អ្នកអាន អ្នកស្ដាប់ ឲ្យជាប់ចិត្តពីដើមដល់ចប់ ។

ចូរលើកនូវសិល្បវិធីនេះ មកធ្វើអត្ថាធិប្បាយបញ្ជាក់ តើស្ថិតនៅលើគោលអ្វីខ្លះ ?

## អត្ថាធិប្បាយ

ការចេះផ្សំសកម្មភាពជាក់ស្តែងរបស់មនុស្ស ទៅនឹងសកម្មភាពនៅក្នុងសង្គមទេវៈ បានកើតទៅជាសិល្បវិធីពិសេសម៉្យាងដ៏សំខាន់

អាចជួយរចនារឿងព្រះវេស្សន្តរ ដែលជាចលនានៃការសាងទានបារមីឲ្យក្លាយទៅជារឿងមានលក្ខណៈប្រកបដោយអត្ថន័យ, អត្ថរូប និងអត្ថ-រសដ៏ពីរោះពិសាបាន ថែមទាំងជាគ្រឿងលើកតម្លៃនៃតួអង្គព្រះពោធិសត្វឲ្យមានគុណភាពល្អ ផ្តល់ជំនឿប្រកបដោយវិចារណៈយ៉ាងមុតមាំចំពោះអ្នកអាន–អ្នកស្តាប់ផង ។

សិល្ប៍វិធី គឺការរចនារៀបចំតែង និពន្ធ និងធ្វើដំណើររឿងឲ្យមានចលនាទៅមុខប្លែក ៗ គ្នា ហើយថែមទាំងចេះនាំអ្នកអាន-ទស្សនា និងអ្នកស្តាប់ ឲ្យជក់ចិត្តជក់អារម្មណ៍ ចង់ដឹងតទៅទៀតផង ធ្វើដំ–ណើររឿងឲ្យសមរម្យទៅតាមទ្រឹស្តីណាមួយ ដើម្បីឲ្យមនុស្សមានជំនឿ ឬកើតចិត្តស្អប់–ស្រឡាញ់ចំពោះតួអង្គ និងទ្រឹស្តីនោះ ៗ ផង ។ សិល្ប៍វិធីនេះ ជាគ្រឿងប្រដាប់ម៉្យាងដ៏សំខាន់ក្នុងការតែងនិពន្ធទូទៅ ។ ក្នុងមហាវេស្សន្តរជាតក យើងបានជួបនឹងសិល្ប៍វិធីដ៏សំខាន់ ២ យ៉ាងផ្សេងគ្នា តែទាក់ទងគ្នាគឺ :

**១) សាមញ្ញវិធី** – ក្នុងការដែលព្រះវេស្សន្តរនៅមានសកម្មភាពទាក់ទងជាមួយសង្គមមនុស្ស អ្នកនិពន្ធបានលើកយកសិល្ប៍វិធីបែបធម្មតា ដែលគេតែងអនុវត្តក្នុងការតែងនិពន្ធរឿងផ្សេង ៗ ។ សាមញ្ញវិធីក្នុងមហាវេស្សន្តរនេះសោតទៀត មានចែកជា ២ បែបទៅ

ទៀតគឺ :

**ក)សាមញ្ញវិធីធម្មតា**—ពោលគឺអ្នកនិពន្ធបានពណ៌នាឬចោទនិងដោះស្រាយនូវបញ្ហាផ្សេងៗតាមសកម្មភាពនៃមនុស្សផងទាំងពួង ឧទាហរណ៍ ការពណ៌នាពីការធ្វើទានរបស់ព្រះវេស្សន្តរចំពោះអ្នកកំសត់ទុគ៌តទូទៅ ដោយមិនរើសមុខ, ព្រះវេស្សន្តរបានប្រទានដំរីបច្ច័យនាគេន្ទ្រទៅពួកកលិង្គរាស្ត្រ ដែលជាបុព្វហេតុនាំឲ្យពួកស្រីពិរាស្ត្រចងកំហឹង ហើយសុំឲ្យព្រះបាទស្រីសញ្ជ័យបំបរបង់ព្រះអង្គចេញពីព្រះនគរ ឯព្រះវេស្សន្តរទ្រង់យល់ព្រមទៅគង់នៅឯគិរីវង្កត ហើយនាងមទ្រីបានទទូចសុំយាងទៅតាម ដើម្បីបានគាល់បំរើព្រះស្វាមីនៅទីនោះ ។

ពុំនោះសោតទេ តាជូជកវាយបណ្ដើរជាលីគ្រស្នា ដើរកាត់ព្រៃអស់វេលា ១៥ ថ្ងៃ បានទៅដល់ជេតុត្តរនគរ ។ ជាលីជាអ្នកជួយការពារព្រះបិតា នៅចំពោះការចោទប្រកាន់របស់ព្រះរាជអយ្យកោអយ្យិកា និងមន្ត្រីសេវកាមាត្យជាដើម ។

ការពណ៌នា ឬចោទនិងដោះស្រាយបែបនេះ តែងមានស្ថិតនៅក្នុងរឿងរ៉ាវផ្សេង ៗ ទាំងផ្នែកពុទ្ធនិយមឬខេមរនិយម ។

**ខ) សាមញ្ញវិធីបែបអស្ចារ្យ**— នៅក្នុងវិធីដូចគ្នា

ដដែលនេះ អ្នកនិពន្ធបានលើកយកគោលវិធីមួយបែបទៀត ដែលមាន លក្ខណៈអស្ចារ្យប្លែកពីសភាពធម្មតាបន្តិចមកបង្ហាញ ឧទាហរណ៍ តួ អង្គព្រះវេស្សន្តរ ទ្រង់ប្រដាប់តាក់តែងគ្រឿងអលង្ការមានតម្លៃ ១ សែន តម្លឹងបើគិតជាមាស ហើយព្រះកុមារទ្រង់មានព្រះទ័យល្អណាស់ កាល យកគ្រឿងអលង្ការទាំងនេះមកប្រដាប់តាក់តែងព្រះកាយតែបន្តិច ក៏ដោះ ប្រទានទៅមេធំនេះ ឬ មេធំនោះ អស់វារៈ ៩ ដង ។

ឬ មួយជាលី ជាកុមារតូចទើបមានព្រះជន្ម ៤ វស្សាក៏ចេះយល់ នូវបញ្ហាផ្សេង ៗ សព្វជំពូក= ព្រះកុមារបាននិយាយអង្វរលួងលោមព្រ- ស្នាឲ្យព្រមតាមបិតា ដើម្បីជួយចម្លងទានបារមីព្រះអង្គឲ្យបានដល់ត្រើយ ឬ មួយជាលីបានចេញការពារព្រះបិតា ដោយសមហេតុផលនៅចំពោះ ការចោទប្រកាន់ព្រះរាជអបរៀកោអយ្យិកា មន្ត្រីអាមាត្យ ។ ក្នុង ពេលនេះ គឺមានតែជាលីក្រស្នាប៉ុណ្ណោះដែលយល់នូវទានបារមីរបស់ ព្រះបិតា ឯព្រះរាជអបរ្យកោ ឬ មន្ត្រីឯទៀត ៗ ដូចជាគ្មានអ្នកណា ម្នាក់បានយល់រឿងនេះទាល់តែសោះ ។

សិល្ប៍វិធីទាំង ២ បែបក្នុងសាមញ្ញវិធីនេះ មិនមែនស្ថិតដាច់ ស្រឡះចេញពីសិល្ប៍វិធីយ៉ាងទី ២ គឺវិសេសវិធីនោះដែរ បានសេចក្តី ថា សាមញ្ញវិធីស្ថិតជាប់ក្នុងកណ្តោ ឬ ចលនានៃវិសេសវិធីនេះដែរ មិន

មែនស្ថិតនៅក្នុងកណ្ឌដទៃដាច់ស្រឡះពីគ្នាឡើយ ។

**២) វិសេសវិធី** — ក្នុងផ្នែកទី ២ នេះ យើងបានជួបប្រទះនូវវិធីម៉្យាងទៀតដែលប្លែកអស្ចារ្យជាងពេលមុន ពោលគឺអ្នកនិពន្ធបានយកហេតុភេទអស្ចារ្យឬយដែលស្ថិតនៅ ក្រៅសង្គមមនុស្សឲ្យធ្វើសកម្មភាពជាមួយតួអង្គមនុស្ស ជាពិសេស គឺតួអង្គព្រះវេស្សន្តរនេះឯង ឧទាហរណ៍ ក្នុងថ្ងៃដែលព្រះវេស្សន្តរប្រសូត មានមេដំរីមួយនាំយកកូនឈ្មោលមួយហោះតាមអាកាសមកថ្វាយព្រះវេស្សន្តរ សម្រាប់ធ្វើជាព្រះទីនាំងរបស់ព្រះអង្គ ហើយតទៅ ដំរីបច្ច័យនាគេន្ទ្រនេះបានទៅជារបស់មង្គល និងជាប្រដាប់នៃទានបារមីរបស់ព្រះវេស្សន្តរផង ។

នៅក្នុងកណ្ឌតទៅ យើងបានឃើញពួកទេវៈចុះមកជួយធ្វើអន្តរាគមន៍ក្នុងដំណើរសាងទានបារមីរបស់ព្រះវេស្សន្តរស្ទើរតែគ្រប់កន្លែង ឧទាហរណ៍ ទេវៈមួយពួកមកបណ្ដាលចិត្តពួកស្រីពិរាស្ត្រឲ្យខឹងនឹងព្រះវេស្សន្តរ, ទេវៈមួយពួកបានបង្រួញផ្លូវពីជេតុត្តរនគរទៅមាតុលនគរហើយទេវៈមួយពួកទៀត បានចុះមកនិម្មិតសាលាថ្វាយព្រះវេស្សន្តរ, ចាំស្អាក់ផ្លូវនាងមទ្រីនៅកណ្ដាលព្រៃ ដើម្បីទុកឱកាសថ្វាយព្រះវេស្សន្តរសាងបុត្តទាន, ជួយដោះចំណងដៃជាលីក្រស្នា ហើយបំបោរដោះ ព្រមទាំងជួយបង្ហុំតាជូជកឲ្យចូលទៅនគរជេតុត្តរជាដើម ។ នៅក្នុងចំ

ពេណាមនៃទេវន្តរាគបន្ធ័ទាំងនោះ យើងបានឃើញព្រះឥន្ទ្រាធិរាជដោយផ្ទាល់តែម្តង ដែលបានមកជួយបំពេញទានបរិច្ចាគនៃព្រះវេស្សន្តរ ។

សិល្បវិធីទាំង ២ គោលនេះហើយដែលអាចនាំឲ្យអ្នកអាន–អ្នកស្តាប់រឿងព្រះវេស្សន្តរ ចេះតែមានការចាប់អារម្មណ៍ជានិច្ច ហើយជាមួយនេះ គេតែងនាំប្រឹងផ្ទៀងស្តាប់ និងអានដោយយកចិត្តទុកដាក់ទៀតផង ។ មិនតែប៉ុណ្ណោះ សិល្បវិធីទាំងនេះ ក៏បានជួយរចនាតម្លៃនៃទានបារមី, ពោធិសត្វភាពព្រះវេស្សន្តរឲ្យរឹតតែមានកំរិតខ្ពស់ឡើងជានិច្ច ។

ភ្នំពេញ, ថ្ងៃទី ១៧ ធ្នូ ១៩៦៨

រឹសម–ស្វូរ

និស្សិតមហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រ

លេខដំកល់ទុក ១៣៥៦ ចុះថ្ងៃទី ១ ខែ ១១ ១៩៦៨

បោះពុម្ពលើកទី ១ ចំនួន ១.០០០ ក្បាល